ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត




- ការកែប្រែតួនាទីជនរងគ្រោះនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម
- កសាងឱ្យបានយូរអង្វែង ៖ ការផ្សះផ្សាសម្រាប់ប្រជាជនខ្មែរកម្ពុជាក្រោម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១១៩ ខែវិច្ឆិកា ឆ្នាំ២០០៩

# ស្វែងរកការពិត

លេខ១១៩ ខែវិច្ឆិកា ឆ្នាំ២០០៩


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ការកែប្រែតួនាទីជនរងគ្រោះនៅក្នុងតុលាការកាត់ទោស ........................១

**ផ្នែកឯកសារ**

◆កម្ពុជា ........................................................................................៣

◆ការផ្សះផ្សាតាមរយៈល្ខោននិយាយរឿង ..........................................៤

◆ទស្សនៈរបស់ប្រជាជនទៅលើគុកទួលស្លែង.........................................៦

◆ការយល់ឃើញនិងការចែករំលែកព័ត៌មានអំពីតុលាការខ្មែរ .................៨

◆អ្នកភូមិនៅក្នុងសវនាការកាត់ទោស ឌុច .........................................១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆រឿងទាក់ទិននឹងទណ្ឌកម្មមានជាបន្ត .................................................១២

◆តាមរយៈកែវភ្នែកជនរងគ្រោះនៃមន្ទីរស-២១ ...............................១៥

◆មជ្ឈមណ្ឌលឯកសារកម្ពុជាចេញផ្សាយ .......................................១៨

◆ការតស៊ូបញ្ចាំងរបស់ខ្ញុំ : សហគមន៍ចាមមូស្លីម.........................................២១

**ផ្នែកច្បាប់**

◆ការស្វែងរកយុត្តិធម៌ដ៏យូរសម្រាប់ប្រជាជនកម្ពុជា ............................២៤

◆ការពិនិត្យទៅលើគំរូយុត្តិធម៌នៅប្រទេសកម្ពុជា ................................៣១

◆សម្លឹងមើលទៅអនាគតកាល .........................................................៣៨

**វេទិកាពិភាក្សាសាធារណៈ**

◆កសាងឲ្យបានយូរអង្វែង : ......................................................៤៣

◆ឌុច មិនមានការស្មោះត្រង់.......................................................៤៦

◆ស្ថានភាពផ្លូវចិត្តរបស់ ឌុច.......................................................៤៨

◆ថ្ងៃមុនខ្ញុំបានឃើញបិសាច.......................................................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ទណ្ឌកម្មដួងចិត្ត ....................................................................៥៤




កុមារជនជាតិចាម កំពុងអានសៀវភៅ
“ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ”


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នាលេខនេះ :** ដឺ ទេវិទ្ធ, ម៉ែន ពិចិត្រ, គ្រី ស៊ុយហៀង, ឡូរិន ដូសុន, សារ៉ាន់ណាស វីសមែន, គៀល ស្រ្តូប, អេឡេន សៅ, អេង កុកថាយ, ដូឌី ឡេដើរ៉ូដ, ហេង ថាល់សារ៉ុង **អ្នកនិពន្ធនិងស្រាវជ្រាវ :** តាត លក្ខិណា, សោម ប៊ុនថន, ស៊ិន សុធីតា, ទេស ម៉ារ៉ែម **អ្នកបកប្រែៈ** ជា ផល្លា **និពន្ធនាយកទូទៅៈ** ឆាំង យុ **ជំនួយការនិពន្ធនាយកៈ** ទេព ម៉េងឃាន, ញាណ សុជាតិ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** ម៉ម សុផាត Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ:*

# ការកែប្រែតួនាទីជនរងគ្រោះនៅក្នុងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

ខ្ញុំសរសេរលិខិតនេះដើម្បីរួមចំណែកនូវគំនិតខ្លះៗជុំវិញការវាយតម្លៃសាជាថ្មីដោយអង្គជំនុំជម្រះសាលាដំបូងស្តីអំពីការចូលរួមរបស់ជនរងគ្រោះនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងជុំវិញការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាការព្យាយាមដើម្បីបញ្ចូលជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ ដូចដែលបានដឹងគ្រប់គ្នាតាំងពី ដំបូងហើយលោកស្រីចៅក្រម ហ្វែនហ្ស៍ ក៏បានលើកឡើងនៅក្នុងកិច្ចប្រជុំជាមួយអង្គការក្រៅរដ្ឋាភិបាលកាលពីថ្ងៃទី២១ ខែសីហា ដែលថាជនសង្ស័យស្ថិតនៅក្រោមការឃុំឃាំងខ្លួនបណ្តោះអាសន្ន បច្ចុប្បន្ននេះមានអាយុច្រើន ព្រមទាំងមានសុខភាពមិនល្អទៀត ហើយអង្គជំនុំជម្រះវិសាមញ្ញមានពេលវេលានិងថវិកាកំណត់ថែមទៀត ។ ដូច្នេះ វាតម្រូវឲ្យអង្គជំនុំជម្រះវិសាមញ្ញសម្រេចឲ្យបានសាលក្រមឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន ។ ជាងនេះទៅទៀត ការលំបាកនៅក្នុងការបញ្ជាក់អត្តសញ្ញាណរបស់អ្នកដាក់ពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីនិងពេលវេលាដែលត្រូវចំណាយលើការពិនិត្យមើលពាក្យបណ្តឹងនិងការជំទាស់របស់ចុងចោទមិនមែនមិនបានដឹងជាមុនទាំងស្រុងនោះទេ ។ តុលាការព្រហ្មទណ្ឌអន្តរជាតិដែលបានផ្តល់សិទ្ធិឲ្យជនរងគ្រោះចូលរួមដែរ ប៉ុន្តែមិនផ្តល់សិទ្ធិច្រើនដូចនៅអង្គជំនុំជម្រះវិសាមញ្ញបានព្យាយាមដោះស្រាយការជំទាស់ដូចគ្នានេះចាប់តាំងពីពេលដែលវិធានផ្ទៃក្នុងមិនទាន់ត្រូវអនុម័តរួចម្លេះ ។

របៀបចូលរួមជាដើមបណ្តឹងរដ្ឋប្បវេណីចែងនៅក្នុងវិធានផ្ទៃក្នុង ជានិច្ចកាលតែងតែត្រូវគិតថា ជាការលោភលន់ ។ ជាងនេះទៅទៀត អង្គភាពជនរងគ្រោះត្រូវបានបង្កើតឡើងមានការយឺតយ៉ាវ គ្មានហិរញ្ញវត្ថុ និងបុគ្គលិកគ្រប់គ្រាន់ក្នុងការពិនិត្យមើលពាក្យបណ្តឹងជាច្រើនដែលទទួលបានឲ្យទាន់ពេលវេលា ។ បើពិនិត្យមើលអំពីចំនួនជនរងគ្រោះដែលនៅមានជីវិតប្រមាណជា៥លាននាក់នោះ ការព្យាយាមច្បាស់លាស់ណាមួយក្នុងការបញ្ចូលជនរងគ្រោះទៅក្នុងដំណើរការនេះនឹងបណ្តាលឲ្យមានការដាក់ពាក្យបណ្តឹងទៅអង្គភាពជនរងគ្រោះយ៉ាងហោចណាស់ក៏មួយលានដែរ ហើយចំនួនពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងប្រាកដជាច្រើនជាង២ពាន់ដូចដែលទទួលបានរហូតមកដល់ពេលនេះ ។ បើតាមគំនិតខ្ញុំ លើសពីការបារម្ភសមហេតុសមផលដែលលើកឡើងដោយអង្គជំនុំជម្រះសាលាដំបូង ការចូលរួមរបស់ជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញទំនងជាបរាជ័យរួចហើយ ដោយសារកង្វះខាតការផ្សព្វផ្សាយអប់រំប្រាប់អ្នករួចរស់ជីវិតអំពីសិទ្ធិចូលរួមរបស់ជនរងគ្រោះ ។

សំខាន់ជាងគេ ដូចដែលបានលើកឡើងដោយលោកស្រីចៅក្រម ហ្វែនហ្ស៍ សហចៅក្រមស៊ើបអង្កេតមិនធ្លាប់បានព្យាយាមកំណត់ចំនួនដើមបណ្តឹងរដ្ឋវេណីតាមរយៈការកំណត់លក្ខខណ្ឌទទួលយកឬត្រួតពិនិត្យមើលលើពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ជាលទ្ធផល ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដែលបាននិយាយនៅក្នុងសវនាការរបស់ ឌុច ត្រូវបានបដិសេធដោយខាងចុងចោទ និងត្រូវទទួលការសង្ស័យជាសាធារណៈ ។ បើទោះបីជារឿងរបស់ជនរងគ្រោះពិតទាំងស្រុង ឬយ៉ាងណាក៏ដោយ អ្នកនៅរស់ជីវិតទាំងនេះត្រូវទទួលរងនូវការប៉ះពាល់ផ្លូវចិត្តខ្លះមិនខានក្នុងការសម្រេចចិត្តចូលនិយាយនៅក្នុងសវនាការ ។ ប្រសិនបើការទទួលស្គាល់ពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានពិនិត្យមើលតាំងពីដំបូង បញ្ហានេះប្រហែលជាអាចចៀសវាងបាន និងអាចរកឃើញបញ្ហាដែលអង្គជំនុំជម្រះសាលាដំបូងបច្ចុប្បន្ននេះ

កំពុងព្យាយាមដោះស្រាយទាំងយឺតពេលនេះទៀត ។

ឥឡូវនេះ អង្គជំនុំជម្រះវិសាមញ្ញទំនងជារួចរាល់ក្នុងការលុបបំបាត់តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមុនពេលចាប់ផ្តើមសំនុំរឿង០០២ ។ លទ្ធផលអាក្រក់ចេញពីនេះគឺការយល់ឃើញដែលថា អង្គជំនុំជម្រះវិសាមញ្ញបានធ្វើការពិសោធន៍ផ្លូវច្បាប់ដែលប៉ះពាល់ដល់ជនរងគ្រោះ ។ ការព្រួយបារម្ភបំផុតរបស់ខ្ញុំគឺរបៀបដោះស្រាយផលប៉ះពាល់ជនរងគ្រោះជិត២លាននាក់ដែលបានដាក់ពាក្យសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំនុំរឿង០០២រួច ។ ខ្ញុំជឿជាក់ថាមានវិធានការណ៍ចាំបាច់ ដែលអង្គជំនុំជម្រះសាលាដំបូងអាចចាត់វិធានការដើម្បីការពារកុំឲ្យជនរងគ្រោះទាំងនោះបាត់បង់ទំនុកចិត្តពីដំណើរការជំនុំជម្រះក្តី ។

វាជាការពិតណាស់ដែលថា ជនរងគ្រោះជាច្រើនរួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផង មិនយល់បានទូលំទូលាយអំពីនិយមន័យរបស់ពាក្យថា «ដើមបណ្តឹងរដ្ឋប្បវេណី» និងទំហំនៃតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះនៅក្នុងសវនការ ។ ទោះបីជាយ៉ាងណាក៏ដោយ វាមិនសមរម្យទេ ដែលតុលាការត្រូវលាក់ខ្លួននៅពីក្រោយការបរាជ័យក្នុងកិច្ចការផ្សព្វផ្សាយនេះ ។ ប្រសិនបើតុលាការជំនួសការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីដោយ «មេធាវីតំណាងជនរងគ្រោះ» តុលាការត្រូវមានកាតព្វកិច្ចពន្យល់ពីផ្នែកច្បាប់ ដែលពាក់ព័ន្ធទៅកាន់សាធារណៈជន និងអ្នកដាក់ពាក្យធ្វើបណ្តឹងរដ្ឋប្បវេណី នៅមុនពេលសម្រេចអនុវត្តផែនការកែប្រែនេះ ។

ទាក់ទងអ្នកដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង សរសេរទៅកាន់គាត់ម្នាក់ៗទទួលស្គាល់ពាក្យសុំរបស់ជនរងគ្រោះ ជូនដំណឹងអំពីការកែប្រែនីតិវិធី និងបញ្ជាក់ប្រាប់ជនរងគ្រោះថា តួនាទីចូលរួមរបស់ជនរងគ្រោះនៅតែសារៈសំខាន់ជាលក្ខណៈប្រវត្តិសាស្រ្ត ។ បន្ថែមជាងនេះទៅទៀត ខ្ញុំជឿជាក់ថា អង្គជំនុំជម្រះនៅតែសាលាដំបូង គួរអញ្ជើញអ្នកទាំងនោះជាក្រុមតូចៗមិន គួរច្រើនជាង២០០នាក់ ក្នុងមួយក្រុមទេ ។ ឲ្យមកកាន់ទីក្រុងភ្នំពេញដើម្បីទទួលដំណឹង អំពីការស្នើកែប្រែនេះពីមន្រ្តីតុលាការ និងទទួលបានកាសបញ្ចេញយោគបល់ស្របនិងមិនយល់ស្របតាមរយៈផ្ទាល់មាត់ក្តី ឬតាមរយៈការបំពេញកម្រងសំណួរក្តី ។ កិច្ចប្រជុំនេះគួរតែធ្វើឲ្យបានហ្មត់ចត់ និងចំណាយពីរ ឬបីថ្ងៃសម្រាប់មួយក្រុម ។ ជាចុងបញ្ចប់ ខ្ញុំគាំទ្រគំនិតរបស់លោកស្រីចៅក្រម ហ្វែនហ្ស៍ ដែលថាអ្នកតំណាងជនរងគ្រោះមួយក្រុមនិងត្រូវអញ្ជើញឲ្យផ្តល់សក្ខីកម្ម នៅក្នុងសំនុំរឿង០០២ ។ ប៉ុន្តែខ្ញុំគិតថា អ្នកដែលត្រូវផ្តល់សក្ខីកម្មនេះឬអ្នកខ្លះក្នុងចំណោមនេះ គួរត្រូវបានបោះឆ្នោតជ្រើសរើសពីក្នុងចំនោមអ្នកដាក់ពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូច ដែលត្រូវបានជ្រើសរើសរួចហើយ ដោយមេធាវី «មេធាវីតំណាងជនរងគ្រោះ» ។

ខ្ញុំយល់ច្បាស់ណាស់ថា ការរៀបចំកិច្ចប្រជុំបែបនេះ គឺត្រូវចំណាយពេលវេលា និងថវិកាច្រើន ។ យើងប៉ាន់ស្មានថាថវិកាត្រូវចំណាយគឺប្រមាណជា១សែន៥ម៉ឺនដុល្លា ។ ប៉ុន្តែ ខ្ញុំគិតថាមានអ្នកពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនធំ ដែលមិនចាប់អារម្មណ៍ចង់ចូលរួមប្រជុំនេះទេ ។ សំខាន់ជាងនេះ អ្នកដាក់ពាក្យធ្វើជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន២ពាន់នាក់ បច្ចុប្បន្ននេះគ្រាន់តែជាចំណែកមួយតូចប៉ុណ្ណោះនៃអ្នករួចរស់ជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យចំនួន៥លាននាក់ ដែលអាចមានសិទ្ធិចូលរួមនៅក្នុងដំណើការតុលាការនេះ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញមិនអាចប្រឈមមុខ និងស្តាប់យោបល់របស់ជនរងគ្រោះក្រុមតូចៗនេះទេ ការអនុញ្ញាតឲ្យជនរងគ្រោះ ចូលរួមរបស់អង្គជំនុំជម្រះវិសាមញ្ញរហូតមកដល់ពេលនេះនឹងបង្កផលប៉ះពាល់ដល់ភាពស្របច្បាប់របស់តុលាការនេះ និងដល់ការរំពឹងរបស់អ្នករួចរស់ជីវិត ជាជាងមិនមានការចូលរួមបែបនេះទាល់តែសោះទៅទៀត ។

បើទោះបីជាការសម្រេចរបស់តុលាការចុងក្រោយបំផុតយ៉ាងណាក៏ដោយ ក្នុងការបញ្ចូលជនរងគ្រោះក្នុងដំណើរការនេះ តុលាការមានកាតព្វកិច្ចពន្យល់អំពីការកែប្រែទាំងឡាយដែលធ្វើឲ្យប៉ះពាល់ដោយផ្ទាល់ទៅលើជនរងគ្រោះ និងក្នុងការស្តាប់យោបល់របស់ជនរងគ្រោះ ។ ប្រសិនបើមានការស្នើសុំមជ្ឈមណ្ឌលឯកសារកម្ពុជា នឹងមានការសប្បាយរីករាយក្នុងចូលរួមចំណែក ជាងការគាំទ្រផ្នែកសម្ភារៈសម្រាប់ការរៀបចំកិច្ចប្រជុំបែបនោះ ដែលរួមមានការរកកន្លែងសម្រាប់ធ្វើកិច្ចប្រជុំរៀបចំការ សម្តែងបែបសិល្បៈផ្សេងៗ និងជួយរៀបចំកម្រងសំណួរ ។

**ឆាំង យុ**

# កម្ពុជា: ការខុសត្រូវរបស់កម្មាភិបាលដើម្បីប្រជាជន និងបក្ស

## (ឯកសារកម្ពុជាប្រជាធិបតេយ្យ)

ដកស្រង់ពីសេចក្តីអធិប្បាយ «ស្មារតីទំនួលខុសត្រូវខ្ពស់របស់កម្មាភិបាលបដិវត្តន៍យើងចំពោះការងារដែលកំណត់ដោយបក្សកុម្មុយនីស្តកម្ពុជា»:

ចាប់តាំងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ សង្គមកម្ពុជាថ្មីរបស់យើងបានបែងនូវវណ្ណៈធម្មតាពីរ គឺ វណ្ណៈកម្មករ និង វណ្ណៈកសិករ ។ សម្រាប់វណ្ណៈជិះជាន់ដទៃទៀតដូចជា ពួកសក្តិភូមិ ពួកមូលធន ដែលបានកកើតឡើង និងបានចាក់ឫសគល់ក្នុងសង្គមខ្មែរជាច្រើនទសវត្សរ៍មកហើយ វណ្ណៈជិះជាន់ទាំងអស់នេះត្រូវបានដកឫសចេញទាំងស្រុង ។ កម្មាភិបាលរបស់យើង កងទ័ពទាំងប្រុសស្រីដែលបម្រើការក្នុងជួរបដិវត្តន៍របស់យើង និងកងទ័ពបដិវត្តន៍ប្រជាជនកម្ពុជាដែលចាត់ទុកជាឧបករណ៍នៃអំណាចផ្តាច់ការដ៏ស្មោះត្រង់បំផុតរបស់បក្សកុម្មុយនីស្តកម្ពុជារបស់យើងឥឡូវនេះបានក្លាយជាសមាជិកក្នុងវណ្ណៈកសិករនិងកម្មករ ។ នេះមានន័យថា កម្មាភិបាល និង កងទ័ពទាំងប្រុសស្រីនៃកងបដិវត្តន៍របស់យើងដែលធ្វើការនៅក្នុងទីក្រុងគឺស្ថិតក្នុងវណ្ណៈកម្មករ ហើយចំណែកអ្នកដែលធ្វើការនៅជនបទគឺស្ថិតក្នុងវណ្ណៈកសិករ ដោយសារពួកគេទាំងអស់នេះក៏មានកាតព្វកិច្ចការពារនិងកសាងប្រទេសដូចកម្មករនិងកសិករសហមូហភាពរបស់យើងដែរ ។ នៅក្នុងដំណើរការបច្ចុប្បន្ន និង ពេលអនាគតរបស់កងបដិវត្តន៍របស់យើងកម្មាភិបាលបដិវត្តន៍យើងគ្រប់លំដាប់ថ្នាក់កំពុងតែបង្កើន ហើយនិងបន្តបង្កើនគោលការណ៍តស៊ូឲ្យកាន់តែខ្ពស់នៅក្នុងសង្គ្រាមវាយលុកដើម្បីរំដោះប្រទេសជាតិឲ្យមានសេរីភាពពីពួកអាណានិគមសក្តិភូមិរបស់សង្គមជិះជាន់ដែលនៅសេសសល់ និងដើម្បីចូលរួមយ៉ាងសកម្មក្នុងស្មារតីទទួលខុសត្រូវខ្ពស់ជាមួយនឹងមហាជនកម្មករនិងកសិកររបស់យើង ក្នុងវិស័យផលិតកម្ម ការការពារជាតិ និងឆន្ទៈកសាងស្ថាបនាជាតិ ។

ក្នុងសមាសភាពជាអ្នកដឹកនាំមហាជនក្នុងជួរបដិវត្តន៍ និងក្នុងចលនាការពារ និងកសាងប្រទេស និងក្នុងសមាសភាពជាអ្នកកសាងកម្លាំងបដិវត្តន៍សម្រាប់ដំណើរការបន្តរបស់បដិវត្តន៍នេះកម្មាភិបាលបដិវត្តន៍របស់យើងបានបង្ហាញថាពួកគេគឺជាឧទាហរណ៍ល្អមួយក្នុងការបំពេញកិច្ចការគ្រប់វិស័យទាំងអស់ដល់ប្រជាជនទាំងអស់ ។ កម្មាភិបាលរបស់យើងបានរក្សានូវការតស៊ូក្នុងជួរបដិវត្តន៍ជាប្រពៃណី និងមាគ៌ាជីវិតក្នុងជួរបដិវត្តន៍របស់ពួកគេដែលចាប់ផ្តើមឡើងតាំងពីសង្គ្រាមបដិវត្តន៍ឲ្យនៅស្ថិតថេរ ។ លើសពីនេះទៅទៀត ដោយនៅក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឆ្លាតវៃរបស់បក្សកុម្មុយនីស្តកម្ពុជា កងទ័ពបដិវត្តន៍យើងកំពុងតែបន្តពង្រឹងគោលជំហរនៃការធ្វើពលិកម្ម សមូហភាពនិយម ឯករាជ្យភាព អធិបតេយ្យភាព និង ភាពពឹងពាក់លើខ្លួនឯង ។ តាមពិតបន្ទាប់ពីប្រទេសជាតិរបស់យើងបានរំដោះខ្លួនចេញពីសង្គ្រាមមហន្តរាយពីការឈ្លានពានរបស់ពួកសក្តិភូមិអាមេរិក កម្មាភិបាលបដិវត្តន៍របស់យើងបានលះបង់នូវអត្តប្រយោជន៍ផ្ទាល់ខ្លួន ហើយបានទទួលយកនូវដំណើរជីវិតថ្មីដោយធ្វើការរួមជាមួយនឹងកម្មករនិងកសិករយើង ។ ក្នុងអំឡុងពេលរស់នៅជាមួយប្រជាជនរួមជាតិរបស់យើង កម្មាភិបាលទាំងអស់បានព្យាយាមផ្តល់នូវការដឹកនាំសម្រាប់ប្រជាជនចាស់ និងប្រជាជនរំដោះថ្មីក្នុងឆន្ទៈតស៊ូដើម្បីបង្កើនផលិតផលរបស់វិស័យផលិតកម្មដោយធ្វើការគោរពតាមគោលជំហរឯករាជ្យភាព និងការពឹងពាក់លើខ្លួនឯងយ៉ាងម៉ឺងម៉ាត់ក្នុងអំឡុងពេលលំបាក និង កង្វះខាតរយៈពេលនេះ ។

កាលពីរដូវប្រាំងមុនរហូតមកដល់បច្ចុប្បន្ន កម្មាភិបាលបដិវត្តន៍របស់យើងតែងតែឃើញអវត្តមានក្នុងការចូលរួមសកម្មភាពជាមួយនឹងប្រជាកសិករ និងកម្មកររបស់យើងតាមជួរសំខាន់ៗដូចជា ការដ្ឋានសាងសង់ប្រព័ន្ធធារាសាស្ត្រ ការដ្ឋានធ្វើស្រែកំពង់ផែ និង ឃ្លាំងអីវ៉ាន់របស់រដ្ឋជាដើម ។

ដោយសារហេតុផលនេះ កម្មាភិបាលបដិវត្តន៍របស់យើងតែងតែត្រូវបានប្រជាជនគោរពនិងស្រឡាញ់ដោយចាត់ទុកកម្មាភិបាលទាំងអស់នេះជាកូនជាចៅ ។ **D២៩៨១១**

# ការផ្សះផ្សាតាមរយៈល្ខោននិយាយរឿង "ទម្លាយភាពស្ងប់ស្ងាត់"

នៅថ្ងៃទី១៦-១៨ ខែសីហា ឆ្នាំ២០០៩ ក្រុមបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំគម្រោងធ្វើទស្សនកិច្ចដោយបានអញ្ជើញប្រជាជនមកពីបណ្តាខេត្តផ្សេងៗ ដែលមានចំនួនសរុបប្រហែល៥០០នាក់ ដូចជា ខេត្តពោធិ៍សាត់ កំពត ស្ទឹងត្រែង កំពង់ចាម កណ្តាល តាកែវ ក្រចេះ។ គោលបំណងរបស់ទស្សនកិច្ចនេះគឺដើម្បីផ្សព្វផ្សាយព័ត៌មានអំពីតុលាការខ្មែរក្រហម អប់រំពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងធ្វើការចែករំលែកអំពីតុលាការទៅកាន់សហគមន៍របស់ខ្លួន។ នៅក្នុងដំណើរទស្សនកិច្ចនៅថ្ងៃទីនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានយកល្ខោននិយាយដែលមានចំណងជើងថា «ទម្លាយភាពស្ងប់ស្ងាត់» ដែលសម្តែងដោយក្រុមល្ខោន នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈមកសម្តែងជូនអ្នកភូមិទស្សនាផងដែរ។

ល្ខោននិយាយ «ទម្លាយភាពស្ងប់ស្ងាត់» នេះត្រូវបានរៀបចំនិងនិពន្ធដោយអ្នកស្រី អាណាម៉ារី ព្រីន និងរួមជាមួយការសហការការស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារដោយមានការជួយឧបត្ថម្ភពីស្ថានទូតរបស់ព្រះរាជាណាចក្រហូឡង់។ គម្រោងនេះ ត្រូវបានរៀបចំដើម្បីផ្សព្វផ្សាយនិងអប់រំដល់ប្រជាជនកម្ពុជានិងអតីតកម្មាភិបាលខ្មែរក្រហមដែលបានប្រព្រឹត្តនូវអំពើឧក្រិដ្ឋកម្មយ៉ាងធ្ងន់ធ្ងរមកលើជនរងគ្រោះស្លូតត្រង់ឲ្យហ៊ាននិយាយការពិតជាពិសេសលើកទឹកចិត្តឲ្យជនដៃដល់ធ្វើការសុំទោស ហើយសារភាពនូវកំហុសរបស់ខ្លួនដែលធ្លាប់បានប្រព្រឹត្តទៅលើជនរងគ្រោះកាលពីរបបខ្មែរក្រហម។ អត្ថន័យនៃសាច់រឿងល្ខោននេះផ្តោតសំខាន់ទៅលើការផ្សះផ្សានូវផ្នត់គំនិតនៃការគុំកួន ស្អប់ខ្ពើមដើម្បីប្រែក្លាយទៅជាការបង្រួបបង្រួម ការចេះរស់នៅជាមួយគ្នារវាងជនដៃដល់ និងជនរងគ្រោះ។



តួអង្គសម្តែងក្នុងល្ខោននិយាយរឿង «ទម្លាយភាពស្ងប់ស្ងាត់»

អ្នកភូមិមានការចាប់អារម្មណ៍ចំពោះការសម្តែងនេះ ដោយគាត់បានយកចិត្តទុកដាក់ និងសង្កេតពីខ្លឹមសារល្ខោននេះ ព្រោះវាបង្ហាញពីជីវិតពិតរបស់ប្រជាជននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែលគាត់ធ្លាប់បានជួបប្រទះនិងទទួលរងទណ្ឌកម្ម ព្រមទាំងការធ្វើបាបពីកម្មាភិបាលខ្មែរក្រហមផង ។

ក្រោយពីការសម្តែងបានបញ្ចប់ សះ ម៉ាត់ អាយុ៤៨ឆ្នាំ មានស្រុកកំណើតនៅភូមិទី៦ ឃុំពាមជីលាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម បានបញ្ជាក់ថា «សាច់រឿងនេះពិតជាដូចជាជីវិតពិតរបស់ប្រជាជនម្នាក់ៗដែលបានឆ្លងកាត់នៅក្នុងរបបខ្មែរក្រហម ដោយមានការសម្លាប់ ការបង្អត់អាហារ និងការធ្វើទារុណកម្ម ។ គាត់បានបន្ថែមថា ទោះបីជារឿងនេះបានបង្ហាញពីភាពព្រៃផ្សៃរបស់ខ្មែរក្រហមក៏ដោយ ក៏ការសម្តែងនេះបានអប់រំប្រជាជនឲ្យចេះអត់ឱនទោស និងហ៊ានសារភាពពីទោសកំហុសដែលខ្លួនបានប្រព្រឹត្តដែរ ទោះបីជាពេលវេលាបានកន្លងផុតទៅជាច្រើនឆ្នាំក៏ដោយ ។ «បើកាលណាមនុស្សគ្រប់ៗគ្នានៅតែមានគំនិតសងសឹកនឹងគ្នានោះ មិនដឹងថាថ្ងៃណាប្រទេសជាតិមានការរីកចម្រើនឡើយ ។ ដូច្នេះ មានតែការបង្រួមបង្រួមទេ ទើបធ្វើឲ្យប្រទេសជាតិមានការរីកលូតលាស់ទៅមុខ» ។ ចុងក្រោយ សះ ម៉ាត់ បានប្រាប់ថា សិស្សានុសិស្ស និស្សិត និងប្រជាជនមិនត្រូវយកតម្រាប់តាមទេ និងសំណូមពរឲ្យមានការសម្តែងល្ខោននេះម្តងទៀត ដើម្បីឲ្យអ្នកដែលអវត្តមានមានឱកាសបានមកទស្សនាដោយផ្ទាល់ភ្នែក ព្រោះល្ខោននេះមានសារសំខាន់ណាស់ដើម្បីផ្សះផ្សានូវរបួសផ្លូវចិត្តដែលកើតឡើងនៅក្នុងរបបនោះ ។

ជក់ ធឿង អាយុ ៥៥ឆ្នាំ ប្រជាជនមកពីភូមិជើងព្រៃ ឃុំអំពៅព្រៃ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បានរៀបរាប់ថា «ល្ខោននេះចង់បង្ហាញពីកម្មាភិបាលខ្មែរក្រហមដែលបានសារភាពពីកំហុសរបស់ខ្លួនដែលធ្វើកន្លងមក» ។ គាត់បន្តថា ទោះបីជារឿងនេះបង្ហាញពីការផ្សះផ្សាក៏ដោយប៉ុន្តែចំពោះគាត់វិញនៅតែមានអារម្មណ៍ឈឺចាប់ និងនៅតែនឹកឃើញជានិច្ច ។

ទោះបីជារឿងរ៉ាវនៃរបបខ្មែរក្រហមបានកន្លងផុតរយៈពេលជាង៣០មកហើយក៏ដោយ ក៏រឿងនៃការឈឺចាប់ ការបាត់បង់បងប្អូន ទារុណកម្ម ការបង្ខំឲ្យធ្វើការហួសកម្លាំងនៅតែជិតដាមជាប់នៅក្នុងអារម្មណ៍របស់គាត់រហូតដល់បច្ចុប្បន្ននេះ ។ ប៉ុន្តែតាមរយៈការសម្តែងល្ខោននិយាយរឿង «ទម្លាយភាពស្ងប់ស្ងាត់» ធ្វើឲ្យប្រជាជនហ៊ាននិយាយការពិត សារភាពពីកំហុស និងការអត់ឱនទៅវិញទៅមករវាងជនរងគ្រោះ និងជនដៃដល់ ។ **ស៊ិន សុធីតា**



ល្ខោននិយាយរឿង «ទម្លាយភាពស្ងប់ស្ងាត់»

# ទស្សនៈរបស់ប្រជាជនទៅលើគុកទួលស្លែង

អំពើប្រល័យពូជសាសន៍ជាអំពើសាហាវយង់ឃ្នងដែលធ្លាប់កើតមាននៅក្នុងប្រទេសជាច្រើននៅលើពិភពលោកដែលការសម្លាប់បែបអំពើប្រល័យពូជសាសន៍នេះមានលក្ខណៈខុសប្លែកពីគ្នាដូចជា នៅប្រទេសអាល្លឺម៉ង់ អាដុល ហ៊ីត្លែ ដែលជាមេដឹកនាំដ៏ឃោរឃៅបានសម្លាប់ជនជាតិជ្វីហ្វប្រហែល៦លាននាក់ ដោយការចាប់បញ្ជូនអ្នកទាំងនោះទៅសម្លាប់នៅជំរំប្រមូលផ្តុំ និងនៅតាមផ្លូវ ។ ចំណែកឯនៅប្រទេស រ្វាន់ដា ជនជាតិហ៊ូទូបានយកកាំបិតម្នាក់មួយៗទៅសម្លាប់ជនជាតិ ទុតស៊ី ប្រមាណ៨សែននាក់ក្នុងរយៈពេល១០០ថ្ងៃ ។ យ៉ាងណាមិញ ប្រទេសកម្ពុជាក៏ធ្លាប់ជួបប្រទះអំពើប្រល័យពូជសាសន៍ដ៏គួរឲ្យភ័យខ្លាចស្រដៀងគ្នានេះដែរ ដោយស្ថិតនៅក្រោមការដឹកនាំរបស់ខ្មែរក្រហម ប្រជាជនស្លូតត្រង់ប្រមាណជិត២លាននាក់ត្រូវបានសម្លាប់ដោយការធ្វើទារុណកម្ម ការបង្អត់អាហារ និងបង្ខំឲ្យធ្វើពលកម្មជាទម្ងន់ ។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅឆ្នាំ២០០៦ សាលាក្តីខ្មែរក្រហមដែលមានឈ្មោះជាផ្លូវការថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដោយមានការចូលរួមពីរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅអំឡុងពេលនោះ ។ ដោយសារតែមានឯកសារនិងភ័ស្តុតាងជាច្រើនបញ្ជាក់ពីបទឧក្រិដ្ឋនៅមន្ទីរស-២១ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៩ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏ចាប់ផ្តើមសវនាការជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាប្រធានមន្ទីរ ស-២១ ដែលជាជនត្រូវចោទម្នាក់ក្នុងចំណោមជនត្រូវចោទទាំង៥រូបដែលត្រូវបានឃុំឃាំងនៅអង្គជំនុំជម្រះ ។

គុកទួលស្លែង ឬមន្ទីរសន្តិសុខស-២១ គឺជាគុកថ្នាក់ខ្ពស់បំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យក្នុងចំណោមគុកដទៃទៀតចំនួន១៩៦ ។ ក្រោយពីគុកនេះត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៥ មានប្រជាជនប្រមាណ១៤.០០០នាក់ បានស្លាប់ដោយសារការធ្វើទារុណកម្ម ការសួរចម្លើយ និងការយកទៅកម្ទេចនៅបឹងជើងឯកមន្ទីរស-២១នេះ អ្នកទោសទាំងអស់សុទ្ធតែត្រូវបានសម្លាប់ដោយមិនបានទទួលការជំនុំជម្រះត្រឹមត្រូវតាមផ្លូវច្បាប់ឡើយ ។

ដោយសារការសម្លាប់នៅគុកទួលស្លែងនេះមានលក្ខណៈ


អ្នកភូមិជនជាតិចាមកំពុងមើលរូបថតនៅទួលស្លែង

សាហាវព្រៃផ្សៃ ប្រជាជនដែលបានមកទស្សនាកន្លែងនេះតែងតែគិតនិងចង់ដឹងពីមូលហេតុថា ហេតុអ្វីបានជាអ្នកគ្រប់គ្រងមន្ទីរនេះសម្លាប់មនុស្សដោយគ្មានការវិនិច្ឆ័យទោសនិងហេតុអ្វី ឌុច ធ្វើអំពើអមនុស្សធម៌បែបនេះទៅលើប្រជាពលរដ្ឋខ្មែរដូចគ្នាបាន ។ ចក់ ភឿង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល បាននិយាយថា

«ពេលមកដល់ទួលស្លែង ខ្ញុំមានអារម្មណ៍តក់ស្លុត និងព្រឺព្រួចក្នុងចិត្តជាខ្លាំង ជាពិសេសធ្វើឲ្យខ្ញុំនឹកឃើញទៅដល់ការស្លាប់របស់បងប្អូនខ្ញុំប្រហែល៣០នាក់នៅគុកសង់ទន្ទេបាទី» ។ ឥឡូវពេលដែលគាត់ឃើញ ឌុច ត្រូវបានតុលាការកាត់ទោសបែបនេះ គាត់សប្បាយចិត្តជាខ្លាំង ព្រោះអ្វីដែល ឌុច បានធ្វើទៅលើជនរងគ្រោះវាពិតជាសាហាវនិងអាក្រក់ជាទីបំផុត ។

បុរសជនជាតិអ៊ីស្លាមម្នាក់មក ពីស្រុកបារាយណ៍ ខេត្តកំពង់ធំ បានរៀបរាប់មិនខុសគ្នាប៉ុន្មានពី ចក់ ភឿង ដែរ គឺថា «ខ្ញុំមិនចង់ជឿថាគុកទួលស្លែងនេះជាកន្លែងសម្លាប់មនុស្សប្រកបដោយប្រដាប់ប្រដាធ្វើទារុណកម្មដ៏គួរឲ្យភ័យខ្លាចនិងតក់ស្លុតបែបនេះទេ ។ ឥឡូវនេះពេលដែលឃើញ ឌុច និយាយនៅក្នុងសវនាការថា គាត់សុំទោសចំពោះក្រុមគ្រួសារជាដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្លាប់នៅក្នុងមន្ទីរស-២១ ស្ថិតក្រោមការគ្រប់គ្រងរបស់គាត់គឺពិតជាមិនអាចអត់ឱនទោសឲ្យបានទេ ដោយគ្រាន់តែនិយាយពាក្យសុំទោសតែមួយម៉ាត់ពីរម៉ាត់ប៉ុណ្ណោះ នោះពីព្រោះកំហឹងរបស់គាត់ក៏ដូចជាជនរងគ្រោះដទៃទៀតដែលមានទៅលើ ឌុច នៅតែមានដដែល» ។



ចំណែក ឡុក គ្រី រស់នៅស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បានរៀបរាប់ថា «ទោះបីជាគាត់មិនមានបងប្អូនស្លាប់នៅក្នុងគុកទួលស្លែងក៏ដោយ ប៉ុន្តែបទឧក្រិដ្ឋដែល ឌុច បានប្រព្រឹត្តនៅពេលនោះមិនគួរឲ្យអត់ឱនទោសឲ្យបានទេ គួរតែយកទៅសម្លាប់ ឬទៅព្យួរកទើបសម ។ ការយកមេដឹកនាំមកកាត់ទោសនេះពិតជាត្រឹមត្រូវល្អណាស់ ព្រោះអាចរកយុត្តិធម៌ឲ្យប្រជាជនដែលបានទទួលរងគ្រោះនៅក្នុងអំឡុងពេល៣ឆ្នាំ ៨ខែ ២០ថ្ងៃ» ។

ផ្ទុញពីទស្សនៈរបស់អ្នកទាំងបីខាងលើ យាយជី គឹម ឡេង ហៅយាយពោធិ៍សាត់ នៅវត្តថ្មាយដង្គុំ ដែលកូនទាំង១២នាក់ ប្តីនិងបងប្អូនជាច្រើននាក់ទៀតដែលស្លាប់នាក្នុងរបបខ្មែរក្រហម បានអភ័យទោសដល់ ឌុច ព្រោះគិតថាគាត់ដឹងកំហុសហើយ ទោះបីជាពេលមកដល់ទួលស្លែងគាត់ឃើញកន្លែងនេះគួរឲ្យតក់ស្លុតនិងគួរឲ្យខ្លាចក៏ដោយ ដូចជាសកម្មភាពធ្វើទារុណកម្មនិងសួរចម្លើយជាដើម ។ «បើតាមផ្លូវធម៌ ការសុំទោសនេះគឺគាត់មានការស្តាយក្រោយហើយ ។ ពីជំនាន់មួយទៅជំនាន់មួយសុទ្ធតែមានការកាប់សម្លាប់ តែការសម្លាប់នេះមិនមែនចិត្តរបស់គាត់ចង់ធ្វើទេ គឺសុទ្ធតែធ្វើតាមការបញ្ជារបស់ថ្នាក់លើ ព្រោះគ្មានអ្នកណាម្នាក់ចង់សម្លាប់មនុស្សទេ ទាល់តែមានគេចង្អុលបង្ហាញ ។ អ្នកណាក៏ដោយឲ្យតែទទួលស្គាល់ទោសកំហុសរបស់ខ្លួន សុទ្ធតែអាចទទួលការអភ័យទោស ពីព្រោះគេដឹងខ្លួនធ្វើខុស» ។

ទោះបីជារបបខ្មែរក្រហមបានកន្លងផុតទៅអស់រយៈពេល៣០ឆ្នាំហើយក៏ដោយ ប៉ុន្តែប្រជាជនភាគច្រើននៅតែមិនអាចបំភ្លេចបានអំពីបទពិសោធន៍ពីអតីតកាលរបស់ខ្លួន និងនៅតែចងកំហឹងទៅលើមេដឹកនាំខ្មែរក្រហមទាំងអស់រួមទាំង ឌុច ដែលជាប្រធានមន្ទីរស-២១ផង ដែលបានដឹកនាំប្រទេសជាតិឈានទៅរកភាពវិនាសអន្តរាយ ។ តាមរយៈបទសម្ភាសន៍ខាងលើ ទោះបីជាគាត់មិនមានបងប្អូនស្លាប់នៅគុកទួលស្លែងក៏ដោយ ក៏គាត់នៅតែខឹងសម្បា និងមិនអាចរំសាយកំហឹងរបស់ខ្លួនបានឡើយ ។ **ជា ផល្លា**

# ការយល់ឃើញនិងការចែករំលែកព័ត៌មានអំពីតុលាការខ្មែរក្រហមទៅកាន់សហគមន៍ចាម

ក្រោមការដឹកនាំរបស់មេដឹកនាំខ្មែរក្រហមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មានប្រជាជនប្រមាណជិតពីរលាននាក់ត្រូវបានស្លាប់នៅក្រោមរបបនេះ ដោយសារការសម្លាប់ ការធ្វើទារុណកម្ម ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការ និងការចោទប្រកាន់ថាក្បត់ៗ ដោយសារតែអំពើទាំងនេះជាអំពើសាហាវឃោរឃៅនិងសម្លាប់មនុស្សដោយគ្មានការវិនិច្ឆ័យទោស ក្រោយពីមានកិច្ចព្រមព្រៀងគ្នារវាងរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិនៅឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬហៅកាត់ថា តុលាការខ្មែរក្រហមត្រូវបានបង្កើតឡើង ដើម្បីនាំយកមេដឹកនាំយកមេដឹកនាំដែលទទួលខុសត្រូវខ្ពស់បំផុតទៅកាត់ទោសតាមច្បាប់ ដែលសព្វថ្ងៃនេះមានចំនួនប្រាំរូបគឺ ខៀវ សំផន, អៀង សារី, អៀង ធីរិទ្ធ, នួន ជា និង ឌុច ។

ក្រោយពីតុលាការនេះត្រូវបានបង្កើតឡើង មានអង្គការក្រៅរដ្ឋាភិបាលជាច្រើន រួមបញ្ចូលទាំងមជ្ឈមណ្ឌលឯកសារកម្ពុជាផងដែរ បានចុះទៅផ្សព្វផ្សាយនៅតាមទីជនបទអំពីដំណើរការរបស់តុលាការនេះតាមរយៈគម្រោងចុះទៅផ្សព្វផ្សាយតាមមូលដ្ឋាន និងគម្រោងឯកសាររស់ដើម្បីឲ្យប្រជាជនបានជ្រាបនិងបានចូលរួមតាមដានវាយតម្លៃទៅលើតុលាការនេះថា អាចរកយុត្តិធម៌ជូនប្រជាពលរដ្ឋបានដែរឬទេ ។ ដូច្នេះ តាមរយៈការផ្សព្វផ្សាយនេះបានធ្វើឲ្យប្រជាជនមួយចំនួនបានឆ្លៀតឱកាសដ៏មានតម្លៃពីការងារដើម្បីមកចូលរួមតាមដានសវនាការដោយផ្ទាល់ ដែលក្នុងចំណោមប្រជាជនទាំងនោះក៏មានជនជាតិចាមផងដែរ ដោយសារប្រជាជនចាមបានទទួលរងការឈឺចាប់ និងការបាត់បង់អ្នកជាទីស្រឡាញ់របស់ខ្លួនអស់ប្រហែលពី៤សែនទៅ៥សែននាក់ នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។

យ៉ាងណាមិញ មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើកិច្ចការជាមួយសហគមន៍ចាមចាប់តាំងពីឆ្នាំ២០០៨មកម្ល៉េះ គឺក្នុងគោលបំណងដើម្បីកត់ត្រាបទពិសោធន៍របស់សហគមន៍ចាមនិងផ្សព្វផ្សាយឲ្យសហគមន៍របស់គាត់បានដឹងៗ ។ ដោយហេតុនេះ នៅថ្ងៃទី១៦-១៨ ខែសីហា មជ្ឈមណ្ឌលបានអញ្ជើញជនជាតិចាមមកចំនួន៣៥០ ដូចជាតួន ហាគិម ក្រៅពីនេះរួមមាន ដូនជី៣០នាក់ ដើមបណ្តឹងរដ្ឋប្បវេណី៣០នាក់ និងអ្នកភូមិ៥០នាក់មកចូលរួមដើម្បីតាមដាននិងវាយតម្លៃតុលាការ អប់រំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងចែករំលែកនូវអ្វីដែលបានដឹងអំពីតុលាការនេះទៅកាន់សហគមន៍របស់គាត់ ។ តាមរយៈការចូលរួមនេះ ជនជាតិចាមមានចិត្តត្រេកអរជាខ្លាំងនៅពេលដែលបានឃើញ ឌុច ជាប្រធានគុកទួលស្លែងត្រូវបានតុលាការកាត់ទោស ដើម្បីរកយុត្តិធម៌ជូនជនជាតិរបស់គាត់ដែលបានស្លាប់នៅក្នុងរបបនោះ ។


ជនជាតិចាមឡើងសួរសំណួរអំពីតុលាការខ្មែរក្រហម

លើសពីនេះទៅទៀត អាចពាំនាំនូវអ្វីដែលគាត់ឃើញនៅពេលនេះដើម្បីប្រាប់ទៅដល់អ្នកដែលមិនបានចូលរួមឲ្យបានដឹងផងដែរ ។

ឌី ម៉ាឌុត មានតួនាទីជាអនុអ៊ីមាំខេត្តកែប បានរៀបរាប់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យឪពុកម្ដាយរបស់គាត់បានស្លាប់ដោយសារការអត់បាយនិងការបង្ខំឲ្យធ្វើពលកម្ម ។ ឥឡូវនេះគាត់សប្បាយចិត្តជាខ្លាំងដែលបានឃើញមេដឹកនាំខ្មែរក្រហមត្រូវបានយកមកកាត់ទោស ។ គាត់បានបន្ថែមថា អ្វីដែល ឌុច បាននិយាយសុំទោសទៅកាន់សាក្សីថ្ងៃនេះគឺមិនមែនចេញពីចិត្តស្មោះត្រង់របស់គាត់នោះទេ ។ ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ ចំពោះគាត់គឺអស់ចិត្តហើយក្រោយពីឮ ឌុច និយាយបែបនេះ ។ ចុងក្រោយ គាត់និយាយថា «ពេលទៅដល់សហគមន៍វិញគាត់នឹងផ្សព្វផ្សាយ ប្រាប់ប្រជាជនរបស់គាត់នូវអ្វីដែលគាត់បានកត់នៅក្នុងកូនសៀវភៅរបស់គាត់ ដូចជាទីតាំងអគារក្នុងសាលសវនាការមានចៅក្រម សហព្រះរាជអាជ្ញា មេធាវី និងជនជាប់ចោទ ។ អំពើដែលមេដឹកនាំខ្មែរក្រហមបានធ្វើមកលើប្រជាជននៅក្នុងរបបនោះ នៅថ្ងៃនេះត្រូវបានតុលាការយកអ្នកទាំងនោះមកធ្វើការកាត់ទោស ហើយដែលនេះពិតជាមានប្រយោជន៍ណាស់ ព្រោះធ្វើឲ្យប្រជាជនបានអស់ចិត្ត ។ ឌុច ទទួលបាបចំពោះអំពើរបស់ខ្លួនឯងហើយ» ។

ណុះ សើ សមាជិកអ៊ីមាំខេត្តនៅខេត្តកំពត បានរៀបរាប់ថា នៅជំនាន់នោះជាទូទៅប្រជាពលរដ្ឋដែលរស់នៅកម្ពុជានរណាក៏មិនអាចគេចផុតពីការរងគ្រោះដែរ ដោយឡែកគ្រួសាររបស់គាត់ក៏មានការបាត់បង់ដូចគ្រួសារដទៃទៀតដែរ គឺមានបងជីដូនមួយ មា ឪពុកមានិងជីដូនមួយ ។ ណុះ សើ បានបន្តថា «តុលាការនេះអាចរកយុត្តិធម៌ជូនប្រជាពលរដ្ឋកម្ពុជាពិតប្រាកដមែន ។ ដូច្នេះ ខ្ញុំនឹងនិយាយប្រាប់ដល់បងប្អូនរបស់ខ្ញុំដែលមិនបានមកទៅតាមអ្វីដែលបានឃើញដូចជាពេលចូលបន្ទប់សវនាការមានការត្រួតពិនិត្យពីសន្តិសុខនិងត្រូវរក្សាភាពស្ងប់ស្ងាត់ពេលស្ដាប់ចៅក្រម និងមេធាវីនិយាយ ។ ចំណែកក្នុងបន្ទប់សវនាការមានចៅក្រមធ្វើការកាត់សេចក្ដី ដោយធ្វើការចោទប្រកាន់ទៅលើជនជាប់ចោទ ឌុច ជាប្រធានគុកទួលស្លែង ហើយមានដើមបណ្ដឹងរដ្ឋប្បវេណីនិយាយតាមទារសំណងចំពោះគ្រួសារដែលបានស្លាប់» ។

អះម៉ាត់ ពន្យុះសុះ អាយុ៦៩ ជាអ៊ីមាំម៉ាស្ជិទ ឃុំប្រេស ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង បាននិយាយមិនខុសពីអ្នកទាំងពីរខាងលើដែរ ព្រោះបងប្អូនរបស់គាត់ស្លាប់អស់៧នាក់ដោយសារអត់បាយនៅក្នុងជំនាន់នោះ ។ គាត់បន្តថា ការស្លាប់របស់បងប្អូនរបស់គាត់ ក៏ដូចជាប្រជាជនដទៃទៀត ឥឡូវត្រូវបានរកយុត្តិធម៌ហើយតាមរយៈតុលាការខ្មែរក្រហមនេះ ។ ដូច្នេះ គាត់នឹងនិយាយអំពីរឿងតុលាការនេះនៅរៀងរាល់ថ្ងៃសុក្រ អំពីអ្វីគាត់បានឃើញជាពិសេសជនជាប់ចោទ ឌុច បានសារភាពពីទោសកំហុសទៅកាន់សាក្សីអំពីអ្វីដែលគាត់បានធ្វើនៅក្នុងរបបនោះ ដោយ ឌុច ប្រាប់ថាគាត់សុខចិត្តទទួលខុសត្រូវទាំងអស់ចំពោះមុខច្បាប់និងផ្លូវចិត្ត» ។

ដូច្នេះ ការចុះទៅផ្សាយដល់សហគមន៍របស់គាត់ និងការអញ្ជើញគាត់មកចូលរួមដោយផ្ទាល់ គឺជាវិធីសាស្ត្រដ៏ល្អនៅក្នុងដំណើរការស្វែងរកយុត្តិធម៌មួយដែលជួយផ្សះផ្សារបួសផ្លូវចិត្តដែលបង្កឡើងដោយរបបនេះ ។ លើសពីនេះទៅទៀតក៏អាចជួយអប់រំទៅដល់ក្មេងជំនាន់ក្រោយឲ្យបានដឹងពីអំពើប្រល័យពូជសាសន៍នៅក្នុងរបបនេះផងដែរ ។ **គាត លក្ខិណា**



ជនជាតិចាម នៅភូមិស្វាយឃ្លាំង

# អ្នកភូមិនៅក្នុងសវនាការកាត់ទោស ឌុច : ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង

តាំងពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចាប់ផ្តើមធ្វើការងារដំបូងរបស់ខ្លួននៅឆ្នាំ២០០៦ បានធ្វើឲ្យប្រជាជនកម្ពុជាចាប់អារម្មណ៍លើរឿងរ៉ាវនៅសម័យខ្មែរក្រហមកាន់តែខ្លាំង ។ នៅពេលថ្មីៗនេះ ពេលដែលតុលាការកំពុងដំណើរការនីតិវិធីកាត់ទោស ឌុច អតីតមេគុកទួលស្លែង មជ្ឈមណ្ឌលឯកសារកម្ពុជាដែលជាកន្លែងសិក្សាស្រាវជ្រាវនិងចងក្រងឯកសារសម័យខ្មែរក្រហម ក៏បានធ្វើការអញ្ជើញអ្នកភូមិ ដូនជី ថ្នាក់ដឹកនាំសាសនាអ៊ីស្លាម សិស្សានុសិស្ស និងដើមបណ្តឹងរដ្ឋប្បវេណីដែលមានបងប្អូនស្លាប់ក្នុងរបបខ្មែរក្រហមមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ព្រមទាំងទីតាំងអគាររបស់តុលាការខ្មែរក្រហមផង ។

គោលបំណងសំខាន់ក្នុងការរៀបចំកម្មវិធីនេះឡើង ដើម្បីឲ្យអ្នកចូលរួមទាំងអស់តាមដាន និងវាយតម្លៃចំពោះដំណើរការសវនាការរបស់តុលាការ ជាពិសេសផ្តល់ឱកាសដល់អ្នកភូមិដែលមិនបានមកចូលរួមឲ្យបានមកទស្សនានិងស្វែងយល់ដោយផ្ទាល់ដែរ ។ បន្ទាប់មក យកចំណេះដឹងទាំងនេះទៅផ្សព្វផ្សាយដល់ប្រជាជនក្នុងសហគមន៍របស់គាត់បន្តទៀត ។

អ្នកភូមិជាច្រើនសុទ្ធសឹងជាជនរងគ្រោះ ដែលយ៉ាងហោចណាស់មានសមាជិកគ្រួសារម្នាក់ស្លាប់ ដោយសាររបបខ្មែរក្រហម តែងតែរៀបរាប់ពីអំពើឃោរឃៅ ការកាប់សម្លាប់ ការធ្វើទារុណកម្ម ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការជាទម្ងន់ និងប្រាប់គ្នាទៅវិញមក ។ អ្នកភូមិដែលត្រូវជាឪពុកប្អូនម្តាយ យាយប្អូនតា តែងតែរៀបរាប់រឿងរ៉ាវជីវិតផ្ទាល់របស់គាត់ដែលធ្លាប់ឆ្លងកាត់របបនេះប្រាប់ដល់កូនចៅក្នុងគោលបំណងអប់រំឲ្យគេគិតខំរៀនសូត្រ និងចៀសវាងនូវការប្រព្រឹត្តខុសឆ្គង ។ ទោះបីជាបាននិយាយរឿងពិតយ៉ាងណាក៏ដោយ ក៏អ្នកភូមិនៅតែមានការលំបាកក្នុងការធ្វើឲ្យកូនៗបានជឿដែរ ដោយសារគ្មានភ័ស្តុតាងដើម្បីបង្ហាញឲ្យឃើញជាក់ស្តែង ។

នៅព្រឹកថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ គឺជាថ្ងៃដំបូងដែលអង្គជំនុំជម្រះបានអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីជនជាតិបរទេសឡើងផ្តល់សក្ខីកម្ម ។ នៅក្នុងសេចក្តីថ្លែងការណ៍ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ពីទំនាក់ទំនងគ្រួសាររបស់ខ្លួនជាមួយជនជាប់ចោទរហូតទទួលដំណឹងពីការចាប់ខ្លួនយកមកធ្វើទារុណកម្មនិងសួរចម្លើយនៅគុកទួលស្លែង ។ ដើមរដ្ឋប្បវេណីបានសម្តែងអារម្មណ៍សោកស្តាយ និងឈឺចាប់ បន្ទាប់មកបានយំខ្សឹកខ្សួលនៅពេលនិយាយពីវិធីធ្វើទារុណកម្មទៅលើអ្នកទោសនៅមន្ទីរស-២១ ។

## ការស្វែងយល់ពីឧក្រិដ្ឋកម្មដែលបានកើតឡើងនៅស-២១

នៅក្រោមការគ្រប់គ្រងរបស់ ឌុច នៅមន្ទីរស-២១ ឧក្រិដ្ឋកម្មជាច្រើនត្រូវបានប្រព្រឹត្តឡើងដោយកងសួរចម្លើយចំពោះអ្នកទោស ។ សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងជាអតីតបុគ្គលិកនៅមន្ទីរស-២១ បានរៀបរាប់ពីវិធីមួយចំនួនដើម្បីទាញយកចម្លើយពីអ្នកទោសដូចជា ការដកក្រចកជើង ការឆក់ខ្សែភ្លើង ការវាយនឹងរំពាត់ ការដាក់ឲ្យអ្នកទោសនៅកន្លែងត្រជាក់ ការបង្ខំឲ្យអ្នកទោសស៊ីលាមកខ្លួនឯង ការឲ្យគោរពតុ គោរពជញ្ជាំង ការដាក់អ្នកទោសឲ្យសត្វក្អែបទិច និងជាពិសេសបានបង្ខំឲ្យអ្នកទោស គោរពរូបសត្វឆ្កែដែលជាការប្រមាថនៅក្នុងសាសនាអ៊ីស្លាម ។ អំពើដ៏សាហាវឃោរឃៅដែលមន្ទីរស-២១បានប្រព្រឹត្តមកលើអ្នកទោសនៅតែដិតដាមជាប់ក្នុងអារម្មណ៍របស់អ្នករួចរស់ជីវិតពីមន្ទីរស-២១ និងជនរងគ្រោះទូទៅ ។

នៅក្នុងការឆ្លើយរបស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីជាច្រើនបានបញ្ជាក់ពីការសួរចម្លើយនិងធ្វើទារុណតាមវិធីជាច្រើននៅមន្ទីរស-២១ ។ ជុំ ម៉ី អតីតអ្នកទោសទួលស្លែងបានរៀបរាប់ថា «គាត់ត្រូវបានកងសួរចម្លើយវាយបាក់ដៃ និង យកដង្កាប់មកកៀបបំបែកក្រចកជើង រួចទាញកន្ត្រាក់ចេញមក» ។

វ៉ាន ណាត ដែលជាអតីតជាងគំនូរនៅខេត្តបាត់ដំបង ក្រោយមកត្រូវខ្មែរក្រហមចាប់បញ្ជូនមកឃុំឃាំងនៅមន្ទីរស-២១ បានរៀបរាប់ថា «គាត់ត្រូវបានដាក់ខ្នោះជើងរហូតមិនអាចងើបដើរបាន ហើយគាត់ត្រូវឆ្មាំគុកវាយនិងឆក់ខ្សែភ្លើងរហូតដល់សន្លប់ ទោះបីគាត់ប្រាប់គេថាមិនបានជាប់ពាក់ព័ន្ធជាមួយខ្មាំងក៏ដោយ» ។

ស្វាន អ៊ូម៉ើត រៀនថ្នាក់ទី១២ នៅខេត្តកែប ដែលធ្លាប់បានមកចូលរួមទស្សនាតុលាការខ្មែរក្រហម សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងនិងជើងឯក បានរៀបរាប់ថា ទោះបីគាត់បានមកទស្សនាម្តងរួចមកហើយក៏ដោយ ក៏គាត់នៅតែចង់មកចូលរួមដើម្បីស្វែងយល់ពីតុលាការខ្មែរក្រហមថែមទៀត ។ ពីមុន អ៊ូ ម៉ើត បានដឹងឮពីអំពើឃោរឃៅរបស់ខ្មែរក្រហមតាមរយៈឪពុកម្តាយនិយាយប្រាប់ និងការអានឯកសារប៉ុណ្ណោះ ដែលធ្វើឲ្យគាត់មានការស្ទាក់ស្ទើរក្នុងការជឿជាក់ទៅលើអំពើឃោរឃៅរបស់ខ្មែរក្រហមដែលបានប្រព្រឹត្តទៅលើអ្នកទោសនិងប្រជាជនកម្ពុជាស្លូតត្រង់ ។ ក្រោយពី អ៊ូ ម៉ើត បានឃើញខ្នោះ ខ្សែចំណង រណ្តៅសាកសព ឆ្អឹង និងឧបករណ៍ធ្វើទារុណកម្មដែលនៅសេសសល់ ទើបធ្វើឲ្យគាត់ជឿថា ពិតជាមានរឿងដូច្នេះកើតឡើងពិតប្រាកដមែន ។

យយ នីតា និស្សិតឆ្នាំទី២ នៅខេត្តកំពត បាននិយាយថា នេះជាលើកទីមួយដែលខ្ញុំបានមកមើលការកាត់ទោស ឌុច នៅតុលាការខ្មែរក្រហម ។ ខ្ញុំបានឃើញដើមបណ្តឹងរដ្ឋប្បវេណីនិយាយលាយឡំជាមួយសំឡេងយំខ្សឹបខ្សួលស្ទើរតែធ្វើខ្ញុំស្តាប់មិនបាន ។ ដើមបណ្តឹងរដ្ឋប្បវេណីរៀបរាប់ពីការស្លាប់ប្តី ឪពុក និងបងប្រុស ដោយសារការធ្វើទារុណកម្មដើម្បីទាញយកចម្លើយនិងសម្លាប់យ៉ាងឃោរឃៅនៅមន្ទីរស-២១ ។ ខ្ញុំក៏បានឃើញរូបថតរបស់អ្នកទោសដែលជាប់ខ្នោះ ដេកផ្កាប់មុខលើឥដ្ឋការ៉ូ និងមានថ្កុកឈាមពីក្រោមដែលគួរឲ្យភ័យខ្លាច ។

## ការលើកលែង

បើនិយាយពីផ្នែកសីលធម៌នៅក្នុងសង្គមខ្មែរ អ្នកប្រព្រឹត្តខុសបានសារភាពពីកំហុសឆ្គងរបស់ខ្លួន និងបានសូមទោសចំពោះជនរងគ្រោះ ប៉ុន្តែអ្វីដែលត្រូវគិតនោះគឺទំហំទោសដែលជនដៃដល់បានប្រព្រឹត្តមកលើប្រជាជនស្លូតត្រង់ ។ នៅក្នុងសវនាការ ឌុច បានទទួលស្គាល់នូវឧក្រិដ្ឋកម្មទាំងឡាយដែលបានប្រព្រឹត្តទៅលើអ្នកទោសនិងទទួលស្គាល់ការឈឺចាប់របស់ប្រជាជនដែលមានសមាជិកគ្រួសារស្លាប់នៅក្រោមការគ្រប់របស់គាត់ ។ ទោះបី ឌុច បានសារភាពនិងសុំទោសម្តងហើយម្តងទៀតក៏ដោយ ក៏ការបែកបាក់ក្នុងផ្លូវអារម្មណ៍របស់ជនរងគ្រោះមិនអាចជួលជុលវិញបានឡើយ ។

សុះ សុហ្វយើនី ដែលឈប់រៀនត្រឹមថ្នាក់ទី៦ បាននិយាយថា «មានចាស់ទុំនៅក្នុងភូមិនិយាយប្រាប់ខ្ញុំថា គាត់ត្រូវខ្មែរក្រហមបង្ខំឲ្យធ្វើការហួសកម្លាំង បង្អត់អាហារ និងធ្វើទារុណកម្មយ៉ាងខ្លាំង ប៉ុន្តែក៏មានអ្នកភូមិមួយចំនួនបាននិយាយថា គាត់រស់នៅស្រួល និងមានហូបគ្រប់គ្រាន់ក្នុងសម័យខ្មែរក្រហមដែរ ។ នៅពេលនេះខ្ញុំបានមកមើលការកាត់ទោសផ្ទាល់ ខ្ញុំបានឃើញ ឌុច និងដើមបណ្តឹងរដ្ឋប្បវេណីយំសោកស្តាយចំពោះឪពុកនិងបងដែលត្រូវបានសម្លាប់ ធ្វើឲ្យ «ខ្ញុំមានអារម្មណ៍អាណិតអាសូរចំពោះដើមបណ្តឹងរដ្ឋប្បវេណី និង ឌុច ដែលបានយំ ហើយសុំទោសរាល់កំហុសឆ្គងដែលគាត់បានប្រព្រឹត្តទៅលើអ្នកទោស ។ ប៉ុន្តែខ្ញុំគិតថា ឌុច នៅតែមានការលាក់លៀមចំពោះឧក្រិដ្ឋកម្មរបស់គាត់ដដែល ។ កំហុសដ៏ធំធេងរបស់ ឌុច មិនអាចអត់ឱនបានទេសម្រាប់ប្រជាជនកម្ពុជានិងចាស់ទុំនៅក្នុងភូមិខ្ញុំ ហើយត្រូវតែកាត់ទោសទៅតាមច្បាប់ដោយយុត្តិធម៌» ។

## ការសន្និដ្ឋាន

ទោះបីក្មេងជំនាន់ក្រោយដូចជា អ៊ូម៉ើត, នីតា និង សុហ្វយើនី មិនបានឆ្លងកាត់របបខ្មែរក្រហមក៏ដោយ ក៏ភ័ស្តុតាងជាក់ស្តែងដែលនៅសេសសល់នៅតែបញ្ជាក់ប្រាប់ថា ពិតជាមានការកាប់សម្លាប់ប្រាកដមែន ។ អារម្មណ៍ដែលដក់ជាប់នៅក្នុងចិត្តរបស់អ្នកទាំងនោះបានក្លាយទៅជាគំនិតនៃការស្អប់ខ្ពើម និងការសងសឹកទៅលើមេដឹកនាំខ្មែរក្រហមទាំងអស់ ។ ទាំងនេះគឺជាបញ្ហាដ៏សំខាន់ដែលយើងត្រូវដោះស្រាយ ដើម្បីកុំឲ្យមានការសងសឹក ការរើសអើង និងត្រូវចេះរស់នៅជាមួយគ្នាដោយសុខសន្តិភាព ។ ដូច្នេះការសិក្សារៀនសូត្រពីប្រវត្តិសាស្ត្រខ្មែរក្រហមឲ្យបានច្បាស់លាស់គឺជាផ្នែកមួយដ៏សំខាន់ដើម្បីអប់រំផ្នត់គំនិតក្មេងជំនាន់ក្រោយកុំឲ្យមានការភ័ន្តច្រឡំនិងរួបរួមគ្នាស្តារប្រទេសជាតិឡើងវិញ ។

**សោម ប៊ុនថន**

# រឿងទាក់ទិននឹងទណ្ឌកម្មមានជាបន្ត

ព្រឹកនេះ សំ ម៉ែត ដែលជាអតីតកងសន្តិសុខយាម «អ្នកទោសសំខាន់» ក្នុងគុកទួលស្លែង (ស-២១) បន្តការផ្តល់សក្ខីកម្មលម្អិតអំពីដំណើរការនៃគុកដែលគ្រប់គ្រងដោយជនជាប់ចោទឈ្មោះ កាំង ហ្គេចអ៊ាវ (ហៅ ឌុច) ។ គាត់ផ្តល់សក្ខីកម្មជាបន្តចំពោះមុខចៅក្រមនិងគ្រូបង្រៀនមកពីតំបន់តាខ្មៅ ប្រមាណជា៤០០នាក់ដែលបានមកទស្សនាអង្គសវនាការ ។

ឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាជាតិ សំ ម៉ែត បាននិយាយថាគាត់បានឃើញផ្ទាល់នឹងភ្នែកនូវការធ្វើទារុណកម្មក្នុងអំឡុងពេលបដែលគាត់បម្រើការងារនៅមន្ទីរស-២១ ។ ឧទាហរណ៍ គាត់បានឃើញគេចាក់ទឹកកកទៅលើខ្លួនអ្នកទោសម្នាក់ក្រោយពេលត្រូវសម្រាតខោអាវចេញរហូតសល់តែខោអាវក្នុង ។ បន្ទាប់មក គេបានសួរអំពីការយល់ឃើញរបស់គាត់ទៅលើគំនូរពណ៌នាពីការដកក្រចកដៃអ្នកទោសម្នាក់ដែលគូរដោយ លោក វ៉ាន់ ណាត ជាអ្នកទោសនិងជាងគំនូរម្នាក់នៅមន្ទីរស-២១ដែរ ។ សំ ម៉ែត ឆ្លើយតបថា គាត់មិនដែលបានឃើញហេតុការណ៍បែបនេះផ្ទាល់នឹងភ្នែកទេ តែគាត់បានឃើញស្នាមរបួសខ្លះដែលបង្ហាញថាពិតជាត្រូវគេដកក្រចកមែន ។ មេធាវីភាគីដើមបណ្តឹងរដ្ឋប្បវេណីបានបន្តសំណួរនេះដោយសួរបញ្ជាក់ សំ ម៉ែត អំពីវិធីធ្វើទារុណកម្មផ្សេងៗដូចជាការឆក់ប្រដាប់ភេទដោយចរន្តអគ្គិសនីជាដើម ។ ប៉ុន្តែ សំ ម៉ែត បដិសេធមិនចង់និយាយច្រើន ដោយគ្រាន់តែឆ្លើយថាគាត់បានប្រាប់អ្វីដែលគាត់បានដឹងនិងឃើញដល់អង្គសវនាការរួចអស់ហើយ ។

សំ ម៉ែត ថែមទាំងនិយាយថា ឌុច ធ្លូនកាលចូលទៅមើលក្នុងបន្ទប់សួរចម្លើយដែរ ក្នុងករណី «អ្នកទោសសំខាន់» ខ្លះ ហើយ ឌុច ក៏គាំទ្រពាក្យសម្តីនេះដោយបញ្ជាក់ថាគាត់ធ្លាប់ចូលទៅមើលមែន ពេលដែលអ្នកទោសកំពុងត្រូវធ្វើទារុណកម្ម ។ ចំពោះសំណួរទាក់ទងទៅនឹងចរិតលក្ខណៈរបស់អ្នកសួរចម្លើយក្នុងមន្ទីរស-២១ សំ ម៉ែត បានឆ្លើយយ៉ាងខ្លីថា «អ្នកសួរចម្លើយទាំងអស់សុទ្ធតែកាចសាហាវ» ។

**រស់នៅក្នុងការភ័យខ្លាច**

សំ ម៉ែត បន្តសក្ខីកម្មដោយបង្ហាញពីភាពភ័យខ្លាចចំពោះ ឌុច ។ គាត់និយាយថា ថ្វីត្បិត ឌុច មិនដូចជាមនុស្សឃោរឃៅម្នាក់ក៏ដោយ តែ សំ ម៉ែត «តែងតែខ្លាចគាត់ជានិច្ច» ។ លើសពីនេះ គាត់អះអាងថា គាត់មិនដែលសប្បាយចិត្តនឹងការងារនៅក្នុងមន្ទីរស-២១ទេ តែគាត់ត្រូវតែបិទបាំងអារម្មណ៍ពិត ព្រោះភ័យខ្លាចនឹងត្រូវគេចាប់ខ្លួន ។ ជាក់ស្តែង ក្នុងចំណោមសមាជិកកងហរបស់គាត់ មានតែគាត់និងគ្នាគាត់បីបួននាក់ទៀតប៉ុណ្ណោះ ដែលគេចផុតពីសេចក្តីស្លាប់ ។

សំ ម៉ែត បានក្លាយទៅជាមុខសញ្ញាជាប់សង្ស័យម្នាក់ពេលដែលបងប្រុសគាត់ឈ្មោះ ម៉េង និង ប្រពន្ធគាត់ឈ្មោះ ធឿង ត្រូវបានចាប់ខ្លួនរួចបញ្ជូនទៅមន្ទីរស-២១ ។ ទីបំផុត គាត់ទាំងពីរនាក់សុទ្ធតែត្រូវបានសម្លាប់ ។ តាមសម្តីរបស់ សំ ម៉ែត ថា អ្នកដែលជួយឲ្យគាត់អាចនៅរស់គឺ ហ៊ុម ហ៊ុយ ។ ហ៊ុម ហ៊ុយ គឺជាអ្នកប្រាប់ សំ ម៉ែត ថាបងប្រុសរបស់គាត់ត្រូវគេចាប់ខ្លួន ។ សំ ម៉ែត អះអាងថា គាត់ពិបាកនឹងប្រមូលអារម្មណ៍បន្តការងារណាស់ក្រោយពីទទួលបានដំណឹងនេះ ប៉ុន្តែគាត់អាចរស់រានមានជីវិតដោយសារតែការណែនាំរបស់ ហ៊ុម ហ៊ុយ ដែលនិយាយថា បើចង់នៅរស់មានតែបន្តធ្វើការហាក់ដូចជាគ្មានរឿងអ្វីកើតឡើងទាល់តែសោះ ។

បន្ទាប់មក មេធាវីការពារក្តីបានចោទសួរ សំ ម៉ែត ពីមូលហេតុដែលគាត់មិនរត់គេចខ្លួន នៅពេលមានឱកាស ។ ចម្លើយរបស់គាត់ដូចគ្នាទៅនឹងកងសន្តិសុខដទៃទៀតដែរ គឺគាត់និយាយថា មិនអាចរត់គេចខ្លួនបានទេ ។ ការចាកចេញពីបរិវេណគុកមានការពិបាកជាខ្លាំង ហើយប្រសិនបើគេដឹងថា គាត់រត់គេចខ្លួន នោះគ្រួសាររបស់គាត់នឹងស្ថិតក្នុងគ្រោះថ្នាក់ដ៏ធំភ្លាម ។ មេធាវីការពារក្តីហាក់ដូចជាបន្តវិធីសាស្ត្រដើម្បីពណ៌នាថា ឌុច ក៏ស្ថិតក្នុងកាលៈទេសៈដូចគ្នា គឺស្តាប់តាមបញ្ជាថ្នាក់លើ ឬប្រឈមមុខនឹងគ្រោះថ្នាក់ដ៏ធំធេងដែលអាចនឹងបណ្តាលឲ្យបាត់បង់ជីវិត ។

**ការឆ្លើយតបរបស់ ឌុច**

ឌុច មិនបានបដិសេធនឹងការពិតដែល សំ ម៉េត ធ្លាប់ជាកងសន្តិសុខនៅមន្ទីរស-២១នោះទេ ។ ផ្ទុយទៅវិញ គាត់បានបង្ហាញនូវការសោកស្តាយរបស់គាត់ ។ គាត់អះអាងថា គាត់មានវិប្បដិសារីចំពោះការដែលគាត់បានបញ្ចុះបញ្ចូលមនុស្សជាច្រើនឲ្យជឿតាមមនោគមន៍វិជ្ជា និងគោលនយោបាយរបស់បដិវត្តន៍ ។ គាត់ថែមទាំងបង្ហាញនូវការសោកស្តាយជាខ្លាំង ព្រោះថាគាត់មានទំនួលខុសត្រូវលើរបាយការណ៍ដែលបានប្រគល់ទៅកាន់ថ្នាក់លើដើម្បីចង្អុលបង្ហាញជនសង្ស័យជាច្រើន ក្រោយមកអ្នកទាំងនោះត្រូវបានចាប់ខ្លួននិងសម្លាប់ ។

## ការអានសេចក្តីថ្លែងការណ៍របស់សាក្សី

អង្គជំនុំបានអនុញ្ញាតឲ្យសាក្សីមួយចំនួនអានសេចក្តីថ្លែងការណ៍របស់សាក្សីជំនួសឲ្យការផ្តល់សក្ខីកម្មដោយផ្ទាល់ ។

## សាក្សី ម៉ុក ស៊ីធីម

ម៉ុក ស៊ីធីម ជាអតីតពេទ្យនៅមន្ទីរស-២១ ។ គាត់បានព្យាបាលរបួសឲ្យអ្នកទោសជាច្រើន របួសទាំងនោះសុទ្ធតែបណ្តាលមកពីការវាយដំនិងការធ្វើទារុណកម្មផ្លូវកាយផ្សេងៗដូចជាដកក្រចកជាដើម ។ លើសពីនេះទៅទៀត មានអ្នកទោសមួយចំនួនប្រាប់គាត់ថា ធ្លាប់ត្រូវឆក់ដោយចរន្តអគ្គិសនី ។ យោងតាមសេចក្តីបំភ្លឺរបស់គាត់ អ្នកសួរចម្លើយបានបញ្ជាឲ្យគាត់ព្យាបាលអ្នកទោសដើម្បីឲ្យពួកគេអាចបន្តការសួរចម្លើយតទៅទៀត ។

គាត់ថែមទាំងធ្លាប់ព្យាបាលអ្នកទោសប្រមាណ៣០ទៅ៤០នាក់ដែលមានទឹកមុខស្លេកស្លាំងនិងទន់ខ្សោយដោយសារត្រូវគេបូមឈាម ហើយនេះជាទម្លាប់មួយនៅក្នុងគុកទួលស្លែង ។ ប្រាក់ ខន ដែលធ្លាប់ជាអ្នកសួរចម្លើយម្នាក់នៅមន្ទីរស-២១ បានឆ្លើយបំភ្លឺពីមុនមកហើយថា ឈាមដែលបូមចេញពីខ្លួនអ្នកទោសត្រូវបញ្ជូនទៅកាន់មន្ទីរពេទ្យភ-១៧ និងមុនីវង្ស ។

ឌុច បដិសេធនឹងសក្ខីកម្មរបស់ មុក ស៊ីធីម ដោយនិយាយថាគាត់មិនជឿថា មុក ស៊ីធីម ធ្លាប់ជាពេទ្យនៅក្នុងមន្ទីរស-២១ទេ ។ ទាក់ទិនទៅនឹងបញ្ហាបូមឈាម ឌុច អះអាងថាថ្នាក់លើរបស់គាត់ សុន សេន បានអនុញ្ញាតឲ្យធ្វើដូច្នេះតាំងពីមុនពេលដែលគាត់ក្លាយជាប្រធានគុកមន្ទីរស-២១ម្លេះ ។ លើសពីនេះ គាត់អះអាងថា មានតែអ្នកទោសប្រហែល១០០នាក់ប៉ុណ្ណោះដែលត្រូវបូមឈាម ដើម្បីបដិសេធនឹងពាក្យចោទប្រកាន់ដែល ប្រាក់ ខន ថាមានដល់ទៅ១០០០នាក់ ។

## សាក្សី តាយ តេង ហៅ ឌី តេង

តាយ តេង ជាកងសន្តិសុខនៅមន្ទីរស-២១និងជើងឯក ។ គាត់មានតួនាទីដឹករណ្តៅនៅជើងឯក ។ គាត់បំភ្លឺថា ហ៊ឹម ហ៊ុយ និងកងសន្តិសុខម្នាក់ទៀតបានដឹកអ្នកទោសប្រហែល២០នាក់តាមរថយន្តទៅកាន់វាលពិឃាត ។ ការបំភ្លឺរបស់គាត់ស៊ីសង្វាក់គ្នានឹងសក្ខីកម្មរបស់ ហ៊ឹម ហ៊ុយ ដែលបានផ្តល់ពីមុនមកដែរ ។

តាយ តេង បានបំភ្លឺយ៉ាងលម្អិតទៅលើបែបបទនៃការសម្លាប់អ្នកទោស ។ មុនពេលត្រូវគេដឹកចេញពីមន្ទីរស-២១ អ្នកទោសត្រូវចាប់ចងហើយឃ្លុំមុខ ។ ពេលដែលពួកគេទៅដល់ជើងឯក អ្នកទោសទាំងអស់នឹងត្រូវនាំយកទៅឃុំក្នុងផ្ទះមួយចម្ងាយប្រហែល១០០ម៉ែត្រពីរណ្តៅកប់ខ្មោច ដែលក្នុងខណៈពេលនោះមានអ្នកទោសពីរឬបីនាក់នឹងត្រូវគេហៅឲ្យចេញមក ។ អ្នកទោសត្រូវដាក់ឲ្យលុតជង្គង់ចម្ងាយ១ម៉ែត្រពីរណ្តៅ រួចវាយនឹងចប ។ អ្នកពិឃាតថែមទាំងយកកាំបិតមកវះពោះឬបំពង់កអ្នកទោសថែមទៀតដើម្បីធានាថាអ្នកទោសពិតជាស្លាប់ប្រាកដមែន ។ ក្នុងរណ្តៅមួយប្រហែលជាមានសាកសព១០នាក់ ហើយនៅទីនោះមានប្រមាណជា២០ទៅ៣០រណ្តៅ ។ តាយ តេង អះអាងថា គាត់មិនដែលឃើញកុមារនៅវាលពិឃាតទេ ។ ឌុច ទទួលស្គាល់ថា តាយ តេង ពិតជាធ្លាប់ធ្វើការនៅមន្ទីរស-២១មែន ហើយចម្លើយរបស់គាត់សុទ្ធតែត្រឹមត្រូវ ។

## សាក្សី សម សំអុល

សម សំអុល អះអាងថាគាត់ធ្លាប់ធ្វើជាអ្នកនាំសាររបស់ក្រសួងការបរទេស ។ គាត់និយាយថា មានពេលខ្លះគាត់ត្រូវបានចាត់ឲ្យបញ្ជូនសំបុត្រទៅផ្ទះ ឌុច ។ ទោះបីជាគាត់មិនដែលជួប ឌុច ដោយផ្ទាល់ក៏ដោយ ក៏គាត់បានទុកសំបុត្រនៅ ឆេន ដែលជាអ្នកនាំសាររបស់ ឌុច ដែរ ។ សម សំអុល ថែមទាំងបង្ហាញថា ឌុច បានចាត់ឲ្យ ឆេន យកឯកសារសំណេរមួយកញ្ចប់ទៅក្រសួងដែលគាត់ប៉ាន់ស្មានថាទាំងនោះសុទ្ធតែជាចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរស-២១ ។ ឌុច ជំទាស់នឹងសក្ខីកម្មរបស់ សម សំអុល ដោយអះអាងថាគាត់មិនមែនជាអ្នកនាំសាររបស់ក្រសួងការបរទេស

ទេ តែគ្រាន់តែជាកងសន្តិសុខធម្មតាម្នាក់នៅមន្ទីរស-២១ប៉ុណ្ណោះ ។

សម សំអុល ថែមទាំងនិយាយថា មានមេដឹកនាំខ្មែរក្រហមមួយចំនួនមានមុខនៅក្នុងពិធីរៀបការរបស់ ឌុច ។ ជាថ្មីម្តងទៀត ឌុច ជំទាស់នឹងសម្តីរបស់ សម សំអុល ដោយអះអាងថាខ្លួនគាត់មិនមានទំនាក់ទំនងជិតស្និទជាមួយមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ណាទៀតក្រៅពី សុន សេន និង នួន ជា នោះទេ ។ តាមសម្តីរបស់គាត់ ពិធីរៀបការរបស់គាត់មិនមែនធ្វើឡើងនៅក្នុងផ្ទះគាត់ឯស្រះស្រង់នោះទេ តែគឺធ្វើឡើងនៅការិយាល័យយោធានៅភូមិភាគបស្ចិម ។ គាត់ប្រកែកនឹងអំណះអំណាងថាមានវត្តមានរបស់ អៀង សារី, ខៀវ សំផន, នួន ជា, សុន សេន, និង ក្រុមខ្សែភាពយន្តចិនមួយក្រុម ។ គាត់បន្តដោយរៀបរាប់ឈ្មោះភ្ញៀវដែលបានចូលរួមពិធីរៀបការរបស់គាត់ ក្នុងនោះភាគច្រើនជាបុគ្គលិកចាស់នៅមន្ទីរស-២១ជាមួយនឹងមន្ត្រីថ្នាក់ខ្ពស់មួយចំនួននៅតំបន់បស្ចិម ។

## សាក្សី អ៊ុក ប៊ុនសេង

អ៊ុក ប៊ុនសេង និយាយថាគាត់ធ្លាប់ជាទាហានខ្មែរក្រហមមួយរូប ។ ដំបូងឡើយគាត់នៅភ្នំពេញ តែក្រោយមកត្រូវបញ្ជូនទៅជើងឯកនិងកន្លែងកសាងខ្លួនព្រៃស (ស-២៤) ។ គាត់រៀបរាប់ថាគាត់ធ្លាប់ត្រូវបញ្ជូនទៅមន្ទីរស-២១ដើម្បី «រៀនសូត្រ» នយោបាយជាមួយ ឌុច ។ គាត់ថែមទាំងអះអាងថាបានជួប ឌុច ម្តងទៀតនៅលើភ្នំក្រវាញនៅឆ្នាំ១៩៧៩ក្រោយពេលទ័ពវៀតណាមចូលមកដល់ ។ គាត់អះអាងថា ឌុច បញ្ជាឲ្យគាត់ចាប់ខ្លួនមនុស្ស៦នាក់ (បុរស៣នាក់និងស្ត្រី៣នាក់) ដោយសារតែធ្វើតាមសម្រែកបក្សីដែលមានសំឡេងដូច «ប៉ុល ពត» ។

ឌុច បដិសេធនឹងសក្ខីកម្មរបស់ អ៊ុក ប៊ុនសេង ។ ជាដំបូងគាត់និយាយថាការ «រៀនសូត្រ» ដែល អ៊ុក ប៊ុនសេង និយាយគឺធ្វើឡើងដោយ សុន សេន ផ្ទាល់ ហើយធ្វើចំពោះតែកម្មាភិបាលមន្ទីរស-២១ប៉ុណ្ណោះ ។ គាត់បន្តចោទប្រកាន់ថា អ៊ុក ប៊ុនសេង កុហកអំពីការចាប់ខ្លួនមនុស្ស៦នាក់ក្រោយពេលទ័ពវៀតណាមចូលមកដល់ ។ គាត់បញ្ជាក់ថា ក្រោយពីរត់ចេញពីមន្ទីរស-២១ គាត់មិនមានអំណាចដើម្បីដាក់បញ្ជាអ្វីទៀតឡើយ ។

## សាក្សី មាស ប៉េងគ្រី និង តាយ តេង

មាស ប៉េងគ្រី ធ្វើការនៅមន្ទីរស-២១ ហើយទទួលបន្ទុកក្នុងការដឹកអ្នកទោសទៅកាន់វាលពិឃាតជើងឯក ។ តាយ តេង ជាអ្នកទទួលអ្នកទោសពេលពួកគេមកដល់ ។ គាត់ថែមទាំងចូលរួមក្នុងការដឹកនិងកប់រណ្តៅដាក់សាកសពដែរ ។ គាត់ទទួលស្គាល់ថាធ្លាប់ប្រហារជីវិតអ្នកទោសម្នាក់ឬពីរនាក់ដោយផ្ទាល់ដៃ តែគាត់បន្តថាការសម្លាប់អ្នកទោសមិនមែនជាការងារជាប្រចាំរបស់គាត់នោះទេ ។ សក្ខីកម្មអំពីដំណើរការនៃការប្រហារជីវិតអ្នកទោសនៅជើងឯកទាំងពីរនេះស៊ីសង្វាក់គ្នានឹងសក្ខីកម្មធ្លាប់មានពីមុនមកហើយ ឌុច មិនបានប្រកែកចំពោះសេចក្តីថ្លែងការណ៍នេះ ដូចសាក្សីផ្សេងទៀតឡើយ ។

## សាក្សី ហ៊ិន អេម ហៅ មឿង

ហ៊ិន អេម ហៅ មឿង អាយុ៥៦ឆ្នាំ ធ្លាប់ជាកងសន្តិសុខមួយរូបនៅមន្ទីរស-២១ ។ គាត់ធ្លាប់បម្រើការងារនៅកន្លែងផ្សេងជាច្រើនមុនពេលត្រូវប្តូរមកមន្ទីរស-២១ក្នុងឆ្នាំ១៩៧៦ ។ គាត់ពន្យល់ប្រាប់ថា គាត់ធ្វើការពោរពេញដោយការភ័យខ្លាចនៅក្នុងមន្ទីរស-២១ ។ មានថ្ងៃមួយ ពេលដែលឃើញគាត់មិនយកចិត្តទុកដាក់ការងារដោយសារតែអស់កម្លាំងពេក មេក៏បានព្រមានគាត់ថា បើមិនយកចិត្តទុកដាក់ក្នុងការងារនឹងត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរ ។ ក្រោយពេលមិនយូរប៉ុន្មាន គាត់ត្រូវបានចាប់ខ្លួនចងបិទភ្នែក វាយធ្វើបាប ហើយឃុំក្នុងបន្ទប់មួយ ។ ក្រោយមកគាត់ត្រូវបានដោះលែង តែមិនត្រូវបានអនុញ្ញាតឲ្យត្រឡប់ទៅយាមនៅអគារឃុំឃាំងបន្តទៀតទេ ដោយប្តូរមកយាមនៅបរិវេណក្រៅគុកវិញ ។

ហ៊ិន អេម អះអាងថា គាត់បានចូលរួមក្នុងការរៀនសូត្រនយោបាយរបស់ ឌុច ដែលជាវិធីសាស្ត្រអប់រំយ៉ាងមានប្រសិទ្ធភាពមួយ ។ ការរៀននេះតម្រូវឲ្យអ្នករៀន «សម្គាល់ខ្មាំងគ្រប់រូប» ដោយមិនគិតពីទំនាក់ទំនងរវាងពួកគេឡើយ ។ តាមការបង្រៀនសូម្បីតែឪពុកម្តាយខ្លួនក៏ត្រូវជាប់សង្ស័យថាជាខ្មាំងដែរ ។ ជាក់ស្តែងមានតែមនុស្សស្អាតស្អំទេដែលអាចចាត់ទុកថាជាឪពុកម្តាយ ។

ឌុច ជំទាស់នឹងសេចក្តីបំភ្លឺទាំងមូលរបស ហ៊ិន អេម ដោយអះអាងថាជននេះមិនមែនជាកងសន្តិសុខនៅមន្ទីរស-២១ឡើយ ។

**ឌី ធេរិទ្ធ**

# តាមរយៈកែវភ្នែកជនរងគ្រោះនៃមន្ទីរស-២១

ភ្នែកគឺជាផ្នែកដ៏សំខាន់មួយនៃរាងកាយមនុស្ស ហើយដែលមនុស្សគ្រប់រូបអាចមើលឃើញនិងទទួលបានព័ត៌មានពីពិភពលោកទាំងមូលតាមរយៈកែវភ្នែកនេះ ។ ភ្នែកត្រូវបានប្រដូចទៅនឹងបង្អួចនៃព្រលឹងដែលមនុស្សអាចប្រើជំនួសពាក្យសម្តីបាន ។ តាមរយៈកែវភ្នែករបស់មនុស្សម្នាក់ យើងអាចដឹងពីអារម្មណ៍របស់គាត់ថា តើគាត់កំពុងសប្បាយរីករាយ អបអរសាទរ ភ្ញាក់ផ្អើល កើតទុក្ខ ភ័យខ្លាច ព្រួយបារម្ភ ឆ្ងើងឆ្ងល់ និងតក់ស្លុត ។ ប្រសិនបើយើងសម្លឹងទៅក្នុងកែវភ្នែកជនរងគ្រោះនៃមន្ទីរស-២១វិញ តើពួកគាត់ចង់បង្ហាញពីអ្វីខ្លះ?

វិទ្យាល័យពញាយ៉ាតដែលស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃនាប៉ែកខាងត្បូងទីក្រុងភ្នំពេញ ត្រូវបានខ្មែរក្រហមប្រើប្រាស់ជាកន្លែងមួយសម្រាប់សួរចម្លើយ និងធ្វើទារុណកម្ម ហើយដែលត្រូវបានគេស្គាល់ថាជាមន្ទីរស-២១ ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អ្នកទោសនៅក្នុងមន្ទីរនេះភាគច្រើនត្រូវបានខ្មែរក្រហមចោទប្រកាន់ថាជាជនក្បត់ ឬជាបក្ខពួករបស់ខ្មែរក្បត់ ។ អ្នកទោសដែលបានបញ្ជូនមកដល់គុកទួលស្លែងត្រូវតែត្រូវឲ្យថតរូបនិងប្រាប់ពីប្រវត្តិរូបលម្អិតផ្ទាល់ខ្លួន ។ បន្ទាប់មក អ្នកទោសទាំងនោះត្រូវបានខ្មែរក្រហមនាំយកទៅសួរចម្លើយ ។ ខណៈពេលដែលកំពុងសួរចម្លើយ អំពើទារុណកម្មយ៉ាងព្រៃផ្សៃជាច្រើនរូបភាពត្រូវបានខ្មែរក្រហមប្រើប្រាស់ដើម្បីបង្ខំឲ្យអ្នកទោសសារភាពពីសកម្មភាពក្បត់របស់ខ្លួន ដែលអំពើទាំងនោះមានដូចជាការវាយធ្វើបាប ការឆក់នឹងចរន្តអគ្គិសនី ការយកកន្ទុយបារីអុជលើខ្លួន ការចាប់ជ្រមុជក្បាលចូលក្នុងទឹកជាដើម ។ ចុងក្រោយអ្នកទោសទាំងនោះនឹងត្រូវបានយកទៅកម្ទេចចោល ពោលគឺយកទៅសម្លាប់ ។



អ្នកទោសនៅមន្ទីរ ស-២១

នៅឆ្នាំ១៩៧៩ បន្ទាប់ពីរបប ប៉ុល ពត ត្រូវបានផ្តួលរំលំ មានអ្នកទោសប្រមាណ១៤,០០០នាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនចូលទៅក្នុងគុកទួលស្លែង ហើយមានតែអ្នកទោសតែប្រមាណ១២នាក់ប៉ុណ្ណោះដែលរួចរស់ជីវិត ។ សព្វថ្ងៃនេះ មន្ទីរសន្តិសុខស-២១ ត្រូវបានប្រែក្លាយទៅជាសារមន្ទីរប្រល័យពូជសាសន៍មួយ ដោយនៅក្នុងសាលពិព័រណ៍នៃសារមន្ទីរនេះមានការដាក់តាំងបង្ហាញនូវរូបថតសខ្មៅរាប់ពាន់សន្លឹកដែលត្រូវបានថតនៅក្នុងរបបខ្មែរក្រហម រួមទាំងឧបករណ៍ធ្វើទារុណកម្ម និងឆ្អឹងរបស់ជនរងគ្រោះជាច្រើនទៀតផង ។

នៅថ្ងៃ១៨ ខែកញ្ញា ឆ្នាំ២០០៩ នៅពេលខ្ញុំកំពុងឈរនៅក្នុងបន្ទប់សាលពិព័រណ៍រូបថតនៃគុកទួលស្លែង ពេលនោះកែវភ្នែកជាច្រើននៃជនរងគ្រោះហាក់ដូចជាកំពុងសម្លឹងមករកខ្ញុំដូចជាមានអ្វីជាច្រើនចង់ប្រាប់ដល់ខ្ញុំ ។ បន្ទាប់មក ខ្ញុំក៏ចាប់ផ្តើមពិនិត្យមើលកែវភ្នែកនៅលើរូបថតទាំងនោះ ។ តាមរយៈក្រសែភ្នែកទាំងនោះ ពួកគាត់បានបង្ហាញប្រាប់ខ្ញុំអំពីភាពភ័យខ្លាច ភាពឆ្ងើងឆ្ងល់ និងភាពគ្មានកំហុសដែលពួកគាត់បានកប់ទុកយ៉ាងជ្រៅនៅក្នុងកែវភ្នែករបស់ពួកគាត់ ។ ភស្តុតាងទាំងនេះរំលេចនូវរូបភាពយ៉ាងច្បាស់នៃភាពសាហាវយង់ឃ្នងនៅក្នុងរបបនោះ ព្រមទាំងបង្ហាញថាប្រទេសជាតិទាំងមូលបានធ្លាក់ក្រោមការគ្រប់គ្រងយ៉ាងសាហាវ

ឃោរឃៅពីសំណាក់ខ្មែរក្រហម ដែលបណ្តាលឲ្យជនស្លូតត្រង់ជាច្រើននាក់ត្រូវបានបាត់បង់ជីវិត ។

មីង ស៊ីណែត មានអាយុ៤៧ឆ្នាំ ជាកសិករមួយរូប រស់នៅក្នុងខេត្តកំពង់ធំ បានរៀបរាប់ថា ពេលដែលគាត់សម្លឹងមើលរូបថតនៅក្នុងគុកទួលស្លែង រូបថតទាំងនោះបានដាស់គាត់ឲ្យនឹកឃើញឡើងវិញនូវរឿងរ៉ាវជាច្រើនដែលគាត់ធ្លាប់ជួបប្រទះនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ខណៈពេលដែលគាត់បានរកឃើញរូបថតជីតាជាទីស្រឡាញ់របស់គាត់ត្រូវបានសម្លាប់នៅគុកទួលស្លែងនេះ ទឹកភ្នែករបស់គាត់បានស្រក់ចុះមកដោយមិនដឹងខ្លួន ។ ពេលគាត់សម្លឹងចំភ្នែករបស់ជីតាគាត់ គាត់បានឃើញពីភាពភ័យខ្លាចរបស់ជីតាគាត់ដែលបានលាក់ទុកក្នុងចិត្ត ។ គាត់ហាក់ដូចជាសុំឲ្យគេជួយសង្គ្រោះ ប៉ុន្តែពុំមាននរណាម្នាក់អាចផ្តល់ជំនួយដល់គាត់បានឡើយ ។ មីង ស៊ីណែត បានបន្តថា គាត់រស់នៅជាមួយជីតារបស់គាត់តាំងពីគាត់នៅក្មេងម្ល៉េះ ។ ក្នុងចំណោមសមាជិកគ្រួសាររបស់គាត់ទាំងអស់ ជីតារបស់គាត់គឺជាមនុស្សតែម្នាក់ដែលមីងស្និទ្ធស្នាលនិងជិតដិតជាងគេ ។ មីង ស៊ីណែត មានវិប្បដិសារីជាខ្លាំងដែលគាត់មិនមានលទ្ធភាពអាចជួយសង្គ្រោះជីតារបស់គាត់បាន ។ ជាទីបញ្ចប់ មីង ស៊ីណែត សង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចស្វែងរកយុត្តិធម៌ជូនជីតារបស់គាត់ក៏ដូចជាជនរងគ្រោះជាច្រើននាក់ទៀត ដើម្បីឲ្យវិញ្ញាណក្ខន្ធរបស់ពួកគាត់នៅបានស្ងប់ចុះ ។

រ៉ស៊ីណះ ជាស្ត្រីខ្មែរអ៊ីស្លាមមួយរូប មានអាយុ៤៤ឆ្នាំ រស់នៅក្នុងខេត្តកំពង់ចាម ។ មីង រ៉ស៊ីណះ បាននិយាយរៀបរាប់ថា គាត់មានភាពតក់ស្លុតជាខ្លាំងនៅពេលដែលគាត់ដើរកាត់សាលពិព័រណ៍រូបថតនៅសារមន្ទីរទួលស្លែង ។ បងប្រុសរបស់គាត់ត្រូវបានខ្មែរក្រហមបញ្ជូនមកកាន់មន្ទីរស-២១ ហើយក៏ត្រូវបានសម្លាប់នៅទីនេះ ។ គាត់បានដើរចុះឡើងនៅក្នុងបន្ទប់នោះ ដោយសង្ឃឹមថានឹងបានឃើញរូបថតបងប្រុសរបស់គាត់ ។ តែជាអកុសល គាត់មិនបានរកឃើញរូបថតរបស់បងប្រុសគាត់នោះទេ ។ អ្វីដែលបងប្រុសគាត់បន្សល់ទុកឲ្យគាត់ គឺមានតែប្រវត្តិរូបអ្នកទោសនៅមន្ទីរស-២១មួយសន្លឹកគត់ប៉ុណ្ណោះ ។ បន្ទាប់មកគាត់ក៏បានឈរនៅស្ងៀមមួយកន្លែងនៅមុខរូបថតរបស់អ្នកទោសបុរសម្នាក់ ។ បុរសម្នាក់នោះ មានទឹកមុខស្គមស្លេកស្លាំង ដែលទឹកមុខរបស់គាត់បញ្ជាក់ប្រាប់ពីភាពភ័យខ្លាច ។ រូបថតរបស់បុរសម្នាក់នោះ មិនមែនជារូបថតបងប្រុសរបស់ មីង រ៉ស៊ីណះ ទេ តែមីងអាចយល់បានពីទុក្ខវេទនាដែលបុរសនោះបានជួបប្រទះ ។ តាមរយៈរូបថតនេះ មីង រ៉ស៊ីណះ បានស្រមៃថា វាជារូបភាពបងប្រុសគាត់ ដែលសុំឲ្យគាត់ជួយដើម្បីរំដោះជីវិតគាត់ឲ្យរួចផុតពីពិភពដ៏ខ្មៅងងឹតនេះ ។ គាត់បានរំឭកថា នៅសម័យខ្មែរក្រហមគាត់មិនអាចធ្វើអ្វីទាំងអស់ក្រៅពីនៅស្ងៀម ។ មីង រ៉ស៊ីណះ មិនបានដឹងផងដែរថា បងប្រុសរបស់គាត់ត្រូវមកជាប់ឃុំឃាំងនៅក្នុងគុកទួលស្លែងនោះឡើយ ពីព្រោះនៅសម័យ ប៉ុល ពត បងប្រុសរបស់គាត់កំពុងតែបន្តការសិក្សានៅឯអារ៉ាប់នៅឡើយ ។ រៀងរាល់ពេលដែលគាត់នឹកឃើញបងប្រុសគាត់ម្តងៗ គាត់តែងតែងឿង



អ្នកទោសនៅមន្ទីរស-២១

ឆ្ងល់ថា «តើហេតុអ្វីបានជាខ្មែរក្រហមយកគាត់មកសម្លាប់នៅទីនេះ? តើបងប្រុសរបស់គាត់បានប្រព្រឹត្តអ្វីខុស?» ។

អ៊ឹ ស្រី ស៊ីនួន មានអាយុ៦៨ឆ្នាំ ជាដូនជីមួយរូប សព្វថ្ងៃរស់នៅក្នុងក្រុងភ្នំពេញបានរៀបរាប់ថា ពេលចូលមកដល់សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង គាត់មិនអាចទប់អារម្មណ៍ក្តុកក្តួលរបស់គាត់បានឡើយ ។ គាត់អាចយល់បានពីការឈឺចាប់ និងអារម្មណ៍របស់អ្នកទោសនៅមន្ទីរស-២១ តាមរយៈកែវភ្នែករបស់ពួកគេ ។ អ្នកទោសទាំងនោះហាក់ដូចជាមិនបានដឹងថាជីវិតរបស់ពួកគាត់នឹងត្រូវប្រឈមមុខបែបណាទេនៅពេលដែលពួកគាត់ត្រូវបានខ្មែរក្រហមចាប់មកដល់ទីនេះ ។ ពួកគាត់ពិតជាគួរឲ្យអាណិតណាស់ ព្រោះត្រូវបានបាត់បង់ជីវិតដោយមិនបានដឹងថាមានកំហុសអ្វី ហើយគ្មានតុលាការជំនុំជម្រះទោសទៀត ។ គាត់បានរំពុកថា ជីវិតគាត់មានភាពងាយស្រួលជាងអ្នកទោសនៅទីនេះឆ្ងាយណាស់ ព្រោះគាត់មិនត្រូវបានខ្មែរក្រហមដាក់ខ្នោះច្រវាក់ ឬត្រូវវាយស្ទូរចម្លើយយ៉ាងព្រៃផ្សៃដូចអ្នកទោសទាំងនេះឡើយ ។

ចាន់កង ជានិស្សិតមហាវិទ្យាល័យម្នាក់ អាយុ១៨ឆ្នាំ សព្វថ្ងៃរស់នៅក្នុងខេត្តសៀមរាប បាននិយាយថា គាត់មានភាពរន្ធត់ជាខ្លាំងព្រោះនេះជាលើកទីមួយហើយដែលគាត់បានមកដល់គុកទួលស្លែង ។ គាត់បានឃើញឧបករណ៍ទារុណកម្ម រូបថតជនរងគ្រោះ ឆ្អឹងលលាដ៏ក្បាល និងវត្ថុតាងជាច្រើននៅទីនោះ ។ គាត់ស្ទើរតែមិនជឿថា របបនោះមានភាពសាហាវយង់ឃ្នងបែបនេះឡើយ ដោយវាត្រូវបានឆ្លុះបញ្ចាំងយ៉ាងច្បាស់តាមរយៈកែវភ្នែកជនរងគ្រោះទាំងនេះ ។ គាត់អាចយល់បានពីភាពភ័យខ្លាចយ៉ាងណាពេលដែលពួកគាត់បានទទួលរងនៅក្នុងសម័យខ្មែរក្រហម ។ ទាំងអស់នេះបានបង្ហាញ ចាន់កង យ៉ាងច្បាស់នូវរយៈកាលមួយដែលប្រជាពលរដ្ឋកម្ពុជាស្លូតត្រង់ជាច្រើនលាននាក់ត្រូវបានខ្មែរក្រហមធ្វើទុក្ខបុកម្នេញដូចជាទាសករ ហើយប្រជាជនខ្លះទៀតត្រូវខ្មែរក្រហមចាប់ឃុំឃាំងនិងយកទៅសម្លាប់យ៉ាងព្រៃផ្សៃ ។ ចាន់កងមានការងឿងឆ្ងល់យ៉ាងខ្លាំងថា ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនខ្លួនឯងបែបនេះ?

តាមរយៈកែវភ្នែករបស់មនុស្ស អាចប្រាប់យើងឲ្យដឹងពីរឿងរ៉ាវនិងអារម្មណ៍របស់ពួកគេ ។ តាមរយៈកែវភ្នែករបស់ជនរងគ្រោះ គុកទួលស្លែងបានបង្ហាញឲ្យពួកយើងដែលជាកូនចៅជំនាន់ក្រោយបានយល់ដឹងអំពីរឿងរ៉ាវសាហាវឃោរឃៅជាច្រើនដែលបានកើតឡើងនៅក្នុងជីវិតពួកគាត់ ។ ទាំងនេះជាភ័ស្តុតាងមួយចង្អុលបង្ហាញយ៉ាងច្បាស់អំពីភាពព្រៃផ្សៃរបស់របបខ្មែរក្រហម ។ ប្រជាជនស្លូតត្រង់រាប់ពាន់នាក់ ត្រូវបានសម្លាប់ដោយរបបនេះបណ្តាលឲ្យកុមារជាច្រើនក្លាយទៅជាក្មេងកំព្រាដែលបាត់បង់សេចក្តីស្រឡាញ់ពីឪពុកម្តាយ ។ កុមារទាំងនោះត្រូវតស៊ូរស់នៅក្រោមលក្ខខណ្ឌដ៏លំបាកដោយខ្លួនឯង ហើយការភ័យខ្លាចនៅតែដក់ជាប់ក្នុងចិត្តរបស់ពួកគេជានិច្ច ។ ពួកគេហាក់ដូចជានៅមិនទាន់រួចផុតពីសម័យកាលដ៏ខ្មៅងងឹងនោះនៅឡើយ ។ ប្រសិនបើសោកនាដកម្មនេះមិនបានកើតឡើងទេនោះ តើគ្រួសារពួកគេអាចនឹងមានសុភមង្គលបែបណាទៅ ។ **ម៉ែន ពិចិត្រ**




អ្នកទោសនៅមន្ទីរស-២១

# មជ្ឈមណ្ឌលឯកសារកម្ពុជាចេញផ្សាយសៀវភៅអំពីតុលាការខ្មែរក្រហម

ដើម្បីឆ្លើយតបទៅនឹងការចង់ដឹងបន្ថែមអំពីដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលកំពុងតែដំណើរការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះ មជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែបានចេញផ្សាយសៀវភៅមួយទៀតដែលមានចំណងជើងថា *«ដំណើរការកាត់ក្តីៈ ដំណាក់កាលនៃការដាក់ទោសខ្មែរក្រហម»* ដែលកែសម្រួលនិងត្រួតពិនិត្យដោយបណ្ឌិត ចន ឆរឆីអារី និង បណ្ឌិត អាន ហាញឌុល ។ កថាមុខនៃសៀវភៅនេះត្រូវបានរៀបរាប់ដោយលោក ឆាំង យុ ។

នេះជាសៀវភៅទី១៨ហើយដែលបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អត្ថបទនៅក្នុងសៀវភៅនេះត្រូវបានសរសេរឡើងដោយសាស្ត្រាចារ្យនិងអ្នកសិក្សាផ្នែកច្បាប់ជាតិ-អន្តរជាតិដើម្បីឆ្លើយតបទៅនឹងការចង់ដឹងចង់ឮអំពីការកាត់ទោសខ្មែរក្រហមក្នុងការរកយុត្តិធម៌ជូនជនរងគ្រោះនៃរបបកម្ពុជាប្រជាធិតេយ្យ ។ សៀវភៅនេះត្រូវបានទទួលការអបអរសាទរពីសំណាក់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ ដោយសិក្សាពីរបបដែលបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់បាត់បង់ជីវិតអស់ជិតពីរលាននាក់តាមរយៈការធ្វើការងារហួសកម្លាំង ការអត់ឃ្លាន ជំងឺ និងការសម្លាប់ ។ សៀវភៅនេះសរសេរឡើងដើម្បីឧទ្ទិសដល់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិតេយ្យ និងដើម្បីលើកកម្ពស់ដល់ដំណើរការនៃការទទួលខុសត្រូវតាមផ្លូវច្បាប់ ដែលនឹងនាំទៅរកការចងចាំនិងយុត្តិធម៌សម្រាប់គ្រួសារជនរងគ្រោះទាំងនោះ ។




ខាងក្រោមនេះគឺជាការរៀបរាប់របស់អ្នកស្រាវជ្រាវទាក់ទងទៅនឹងរបបខ្មែរក្រហម និងអំពីចំណាប់អារម្មណ៍ទៅនឹងសៀវភៅនេះ និងប្រវត្តិរបស់អ្នកនិពន្ធ ៖

***ដេវីដ ឆេនល័រ សាស្ត្រាចារ្យជាន់ខ្ពស់នៃសាកលវិទ្យាល័យម៉ូណាស់ ប្រទេសអូស្ត្រាលី និងជាអ្នកប្រវត្តិសាស្ត្រអំពីប្រទេសកម្ពុជាដ៏ឆ្នើមម្នាក់បានរៀបរាប់ថាៈ***

«អត្ថបទដែលមានសារសំខាន់នៅក្នុងសៀវភៅនេះបានស្រាវជ្រាវដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយដែលបានធ្វើការស្រាវជ្រាវអំពីរបបខ្មែរក្រហមបានផ្តល់មកនូវព័ត៌មានដ៏មានតម្លៃជាច្រើនឥតគណនាទាក់ទងនឹងតុលាការកាត់ទោសខ្មែរក្រហម ។ សៀវភៅនេះអាចរកបានដោយងាយសរសេរឡើងដោយហ្មត់ចត់ ល្អិតល្អន់ ហើយរៀបរាប់យ៉ាងពិស្តារអំពីសោកនាដកម្មនៃរបបខ្មែរក្រហម ។ អ្នកនិពន្ធនៅក្នុងសៀវភៅនេះអះអាងថា តុលាការដែលកំពុងតែដំណើរការនេះនឹងធ្វើដំណើរទៅមុខទៅរកការបង្រួបបង្រួម ព្រមទាំងផ្តល់ចំណេះដឹងយ៉ាងអនេកអំពីហេតុការណ៍ ដែលបានកើតឡើងទូទាំងប្រទេសកាលពីយុគសម័យដ៏ឃោរឃៅមួយនេះ ។

***បណ្ឌិត អៀ សុផល សាស្ត្រាចារ្យជំនួយផ្នែកកិច្ចការសន្តិសុខជាតិនៅថ្នាក់ក្រោយឧត្តមសិក្សានៃកងនាវាចរណ៍សហរដ្ឋអាមេរិក ហើយជាជនរងគ្រោះម្នាក់នៃរបបខ្មែរក្រហមមានចំណាប់អារម្មណ៍ថា៖***

«តុលាការខ្មែរក្រហមគឺមានសារសំខាន់ជាទីបំផុតសម្រាប់ប្រជាជនកម្ពុជា និងជាតិសាសន៍ដទៃទៀតនៅលើពិភពលោកយើងនេះ ។ តុលាការនេះបង្កើតឲ្យមនុស្សមានសេចក្តីប៉ងប្រាថ្នាមួយដែលបណ្តុំឲ្យមានការពិភាក្សាវែកញែកកាន់តែច្រើន ហើយក៏ផ្តល់ឲ្យជនរងគ្រោះនូវក្តីសង្ឃឹមក្នុងការរង់ចាំនូវភាពយុត្តិធម៌ដែលមិនទាន់បានទទួលជាយូរមកហើយ ។ សៀវភៅដ៏មានសារសំខាន់នេះក៏រៀបរាប់អំពីទិដ្ឋភាពទូទៅនៃតុលាការខ្មែរក្រហមអំពីដំណើរការយ៉ាងលម្អិតតាំងពីដើមរៀងមករហូតដល់បច្ចុប្បន្ន ហើយក៏បានផ្តល់នូវសំណើដ៏សមស្របមួយចំនួនក្នុងន័យធ្វើឲ្យដំណើរការតុលាការនេះសមស្របតាមគោលបំណងនិងតាមការទន្ទឹងរង់ចាំរបស់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ។

***ចៅក្រម ស៊ីលវៀ ខាតវ៉្រាយ នៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបកស្រាយថា៖***

«សៀវភៅនេះនឹងផ្តល់នូវទីកន្លែងដ៏មានសារសំខាន់មួយក្នុងចំណោមសៀវភៅ និងអត្ថបទជាច្រើនផ្សេងទៀតដែលបានសរសេរអំពីប្រវត្តិសាស្ត្រថ្មីៗនៃប្រទេសកម្ពុជា ជាពិសេសអំពីរបបខ្មែរក្រហម ។ សៀវភៅនេះក៏បានផ្តល់ផងដែរនូវបុព្វបទប្រវត្តិសាស្ត្រនិងបញ្ញវន្តដ៏មានប្រយោជន៍មួយសម្រាប់តុលាការដែលកំពុងតែដំណើរការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ សម្រាប់អ្នកឃ្លាំមើលដំណើរការនិងអ្នកសិក្សាស្រាវជ្រាវចំណុចសំខាន់បំផុតក្នុងសៀវភៅនេះទាក់ទងទៅនឹងការវិភាគផ្នែកច្បាប់ និងទម្រង់បែបបទដែលតុលាការកំពុងប្រតិបត្តិនៅក្នុងអង្គជំនុំជម្រះ ហើយក៏នៅមានបញ្ហាជាច្រើនទៀតដែលតុលាការពិសេសនេះត្រូវបំពេញ ប៉ុន្តែមិនទាន់បានធ្វើនៅឡើយ ។ ជាថ្មីម្តងទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់ជាជំនួយនៅក្នុងកិច្ចការដ៏ចាំបាច់ក្នុងការផ្តល់ជូនសាធារណជននូវព័ត៌មានដែលអាចជួយក្នុងការយល់ដឹងអំពីភាពអាថ៌កំបាំងនិងភាពខ្វាចផ្សានៃរបបខ្មែរក្រហម ហើយនិងផ្តល់វិធីក្នុងការដោះស្រាយបញ្ហាទាំងឡាយដែលកើតក្រោយរបបកម្ពុជាប្រជាធិតេយ្យ ។

***អំពីរូបថតៈ រូបភាពរបស់ សោ ភឹម***

សៀវភៅនេះរួមបញ្ចូលទាំងរូបថតជាច្រើនសន្លឹកដែលមាននៅក្នុងបណ្ណសារដ្ឋានរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងក្នុងទីភ្នាក់ងារសារព័ត៌មានវៀតណាម ។ រូបថតជាច្រើនត្រូវបានថតនៅក្នុងរបបខ្មែរក្រហម ព្រមទាំងមុននិងក្រោយរបបនេះ ហើយរូបថតទាំងអស់នេះមិនដែលបានផ្សព្វផ្សាយជាសាធារណៈពីមុនមកទេ ។ រូបថតមួយចំនួនមានដូចជា រូបថតរបស់ សោ ភឹម ដែលជាមិត្តរួមការងារដ៏ជិតស្និទ្ធម្នាក់របស់ ប៉ុល ពត ក្នុងអំឡុងសង្គ្រាមតស៊ូបដិវត្តន៍របស់បក្សកុម្មុយនីសកម្ពុជា ដែលក្រោយមកបានក្លាយជាលេខាភូមិភាគបូព៌ានៃរបបកម្ពុជាប្រជាធិបតេយ្យ មុននឹងគាត់បានបាត់បង់ជំនឿទុកចិត្តពីសំណាក់មេដឹកនាំរបបនេះ ហើយទីបំផុតគាត់បានសម្លាប់ខ្លួននៅឆ្នាំ១៩៧៨ ដើម្បីគេចពីគោលនយោបាយបោសសម្អាតរបស់បក្សកុម្មុយនីសកម្ពុជា ។

***អំពីអ្នកនិពន្ធ***

***ឆាំង យុ*** ជានាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានដឹកនាំមជ្ឈមណ្ឌលនេះតាំងពីទទួលបានឯករាជ្យភាពក្នុងនាមជាអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុកមួយក្នុងខែមករា ឆ្នាំ១៩៩៧ ។ លោក ឆាំង យុ គឺជាជនរងគ្រោះម្នាក់ដែលបានរស់ជីវិតពីរបបខ្មែរក្រហម ហើយលោកទទួលបានពានរង្វាន់សេរីភាព ទ្រូម៉ាន់-រីហ្គេន ពីមូលនិធិរំឭកដល់ជនរងគ្រោះនៃរបបកុម្មុយនីស្តនៅទីក្រុងវ៉ាស៊ីនតុនឌីស៊ី ក្នុងឆ្នាំ២០០០ ។ លោកក៏ជាវីរជនដ៏ឆ្នើមម្នាក់ដែលត្រូវបានទទួលស្គាល់ថាជា «វីរបុរស៦០នាក់របស់អាស៊ី» របស់ទស្សនាវដ្តីថៃម ក្នុងឆ្នាំ២០០៦ និងជាវីរជនម្នាក់នៅក្នុង «ទស្សនាវដ្តីថៃម១០០» ក្នុងនាមជាបុគ្គលដ៏មានឥទ្ធិពលម្នាក់នៅក្នុងពិភពលោកក្នុងឆ្នាំ២០០៧ ក្នុងជីវិតរបស់លោកប្រឆាំងទៅនឹងនិទណ្ឌភាពនៅក្នុងប្រទេសកម្ពុជា និងកន្លែងផ្សេងទៀតនៅលើពិភពលោក ។

***ឌី ខេមិ្ធ*** បានដឹកនាំគម្រោងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមួយឈ្មោះ «គម្រោងចូលរួមរបស់ជនរងគ្រោះ» ដែលធ្វើការផ្តោតទៅលើការផ្តល់សិទ្ធិដល់ជនរងគ្រោះនៃរបបខ្មែរក្រហមក្នុងការចូលរួមជាមួយដំណើរការកាត់ទោសខ្មែរក្រហម និងដើម្បី

ផ្សព្វផ្សាយដល់សាធារណជនអំពីដំណើរការតុលាការនេះ ។ នៅក្នុងឆ្នាំ២០០៧ដល់ឆ្នាំ២០០៨ លោកបានចូលបម្រើការងារនៅការិយាល័យឧត្តមស្នងការជាន់ខ្ពស់របស់អង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សក្នុងតំបន់អាស៊ីអាគ្នេយ៍ ប្រចាំនៅទីក្រុងបាងកក ។ លោកទទួលបានសញ្ញាប័ត្រអនុបណ្ឌិតច្បាប់សិទ្ធិមនុស្សពីសកលវិទ្យាល័យហុងកុង និងសញ្ញាបត្រសិទ្ធិមនុស្សនិងយុត្តិធម៌អន្តរជាតិពីមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យអាមេរិកខេនសហរដ្ឋអាមេរិក ។

**ចន ឆរណីអារី** គឺជាសាស្ត្រាចារ្យនៅសាលានយោបាយសាធារណៈ ជើរ៉ល ហ្វដ នៃសាកលវិទ្យាល័យមីឈីហ្គេន និងជាទីប្រឹក្សាជាន់ខ្ពស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាចាប់តាំងពីឆ្នាំ១៩៩៩មក ។ លោកគឺជាអ្នកស្រាវជ្រាវម្នាក់របស់កម្មវិធីសូវ៉េនស្តេន នៅមជ្ឈមមណ្ឌលស្រាវជ្រាវអាស៊ី-ប៉ាស៊ីហ្វិកពីឆ្នាំ២០០៧ដល់ឆ្នាំ២០០៨ ហើយលោកក៏ជាអ្នកសិក្សាស្រាវជ្រាវជាតិនៅវិទ្យាស្ថាន ហារើដ នៃសាកលវិទ្យាល័យស្តេនហ្វដដែរ ។ លោកទទួលបានសញ្ញាប័ត្របរិញ្ញាច្បាប់ពីសាកលវិទ្យាល័យហារើដ និងសញ្ញាបត្រថ្នាក់បណ្ឌិតខាងទំនាក់ទំនងអន្តរជាតិពីសាកលវិទ្យាល័យអុកស្ហ៊ើដ ចក្រភពអង់គ្លេស ។

**ចន ហាល** គឺជាសាស្ត្រាចារ្យផ្នែកច្បាប់នៅសាលាច្បាប់នៃសាកលវិទ្យាល័យឈេបមេន ។ លោកផ្តោតការស្រាវជ្រាវរបស់លោកទៅលើច្បាប់អន្តរជាតិនិងសិទ្ធិមនុស្ស ជាពិសេសទាក់ទងទៅនឹងតំបន់អាស៊ីអាគ្នេយ៍ ។ មុននឹងក្លាយជាមេធាវីខាងសិទ្ធិមនុស្ស លោកបានបង្រៀនអស់រយៈពេល១០ឆ្នាំនៅសាកលវិទ្យាល័យអាល់ប៊ឺយ៉ុង ។ លោកទទួលសញ្ញាប័ត្របរិញ្ញាផ្នែកសិក្សាពីអាមេរិកពីសាកលវិទ្យាល័យស្ទុសុិច សញ្ញាប័ត្រថ្នាក់បណ្ឌិតផ្នែកប្រវត្តិសាស្ត្រសម័យទំនើបពីសាកលវិទ្យល័យអុកស្ហ៊ើដ និងបរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យស្តេនហ្វដ ។ នៅសាកលវិទ្យាល័យស្តេនហ្វដលោកគឺជានិស្សិតតែម្នាក់គត់ដែលទទួលបានរង្វាន់ ខាល ហ្វ្រេងឃ្លីន ផ្នែកច្បាប់អន្តរជាតិចំនួនពីរលើក ។

**អាន ហាញខុល** គឺជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ មុននឹងមកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០០៧ អ្នកស្រីធ្លាប់បម្រើការជាជំនួយការនាយករបស់ការិយាល័យស្រាវជ្រាវឧក្រិដ្ឋកម្មសង្គ្រាមនៅសាលាច្បាប់នៃសាកលវិទ្យាល័យអាមេរិក ក្នុងទីក្រុងវ៉ាស៊ីនតុន ។ អ្នកស្រីក៏ធ្លាប់ធ្វើការជាពិធីការរងនៃអង្គការក្រៅរដ្ឋាភិបាលអាមេរិកទាំងអស់ដែលធ្វើការជាមួយតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ អ្នកស្រីទទួលបានបរិញ្ញាបត្រច្បាប់ពីមហាវិទ្យាល័យហាស្ទីងនៃសាកលវិទ្យាល័យកាលីហ្វ័រញ៉ា-សាន់ហ្វ្រែនស៊ីស្កូ និងទទួលបានអនុបណ្ឌិតច្បាប់អន្តរជាតិពីសាលាច្បាប់នៃសាកលវិទ្យាល័យញូវយ៉ក ។

**លី សុខឃាង** គឺជាសហប្រធានគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដើម្បីជួយជនរងគ្រោះនៃរបបកម្ពុជាប្រជាធិតេយ្យ និងពលរដ្ឋកម្ពុជាទូទៅឲ្យតាមដានពីដំណើរការតុលាការ និងស្វែងយល់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ លោកក៏ជាប្រធានគម្រោងការិយាល័យព័ត៌មានសាធារណៈទទួលបន្ទុកផ្តល់ជំនួយដល់សិស្ស និស្សិត អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងសាធារណៈជនទូទៅដែលធ្វើការស្រាវជ្រាវពីប្រវត្តិសាស្ត្រខ្មែរក្រហម ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកសន្តិភាពនិងការបង្រួមបង្រួមពីសាកលវិទ្យាល័យខូវេនទ្រី ចក្រភពអង់គ្លេស ហើយបច្ចុប្បន្នជាបេក្ខជនថ្នាក់បណ្ឌិតនៅក្នុងសាលកវិទ្យាល័យដដែលនេះ ។ លោកធ្លាប់បានទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានស៊ើបអង្កេតព្រហ្មទណ្ឌអន្តរជាតិ ។

**សាក៉ា ថូម៉ាស់** គឺជាសមាជិកនៃការិយាល័យមេធាវីនៃទីក្រុងញូវយ៉ក ។ កញ្ញាគឺជាអ្នកស្រាវជ្រាវរបស់វិទ្យាស្ថានសិទ្ធិមនុស្សអន្តរជាតិ ដេវីដ លីប្រុន ដែលបានមកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាពីឆ្នាំ២០០៧ ដល់ឆ្នាំ២០០៨ ។ នៅមជ្ឈមណ្ឌលឯកសារកម្ពុជា កញ្ញាទទួលបន្ទុកជាទីប្រឹក្សាច្បាប់ក្នុងគម្រោង «ការចូលរួមរបស់ជនរងគ្រោះ» ។ រហូតមកដល់បច្ចុប្បន្ននេះ កញ្ញានៅតែបន្តរជួយគម្រោងនេះដដែល ។ កញ្ញាធ្លាប់ធ្វើការនៅការិយាល័យប្រឹក្សាច្បាប់របស់អង្គការសហប្រជាជាតិ ក្នុងកម្មវិធីយុត្តិធម៌អន្តរជាតិ នៅអង្គការឃ្លាំមើលសិទ្ធិមនុស្ស និងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៃអតីតប្រទេសយូហ្គោស្លាវី ។ កញ្ញាទទួលបានបរិញ្ញាប័ត្រច្បាប់ពីសាកលវិទ្យាល័យកូឡុំបៀនិងសញ្ញាប័ត្រអនុបណ្ឌិតច្បាប់ពីសាលាសេដ្ឋកិច្ច ទីក្រុងឡុនដុន ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ការឆ្លុះបញ្ចាំងរបស់ខ្ញុំ៖ សហគមន៍ចាមមូស្លីម



គ្រី ស៊ុយហៀង

នាពេលថ្មីៗនេះ ខ្ញុំបានធ្វើដំណើរទៅកាន់ឃុំស្វាយឃ្លាំង ដែលជាភូមិអ៊ីស្លាមនៅក្នុងខេត្តកំពង់ចាម ។ អ្វីដែលសំខាន់នោះគឺថាភូមិនេះជាភូមិមួយដែលមានប្រវត្តិតស៊ូល្បីល្បាញក្នុងការទាមទារសេរីភាពប្រឆាំងនឹងរបបខ្មែរក្រហម ។ ដំណើរទស្សនកិច្ចនេះបានផ្តល់នូវព័ត៌មានថ្មីៗជាច្រើនសម្រាប់ខ្ញុំ ជាពិសេសទាំងផ្នែកបញ្ញា និងសតិអារម្មណ៍ ។

មុនពេលទៅដល់ឃុំស្វាយឃ្លាំង ខ្ញុំបានអានសៀវភៅមួយក្បាលមានចំណងជើងថា «ការបះបោររបស់ជនជាតិចាម» សរសេរដោយលោក អ៊ីសា ឧស្មាន ដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតនូវរូបភាពមួយនៅក្នុងខួរក្បាលរបស់ខ្ញុំស្តីពីសហគមន៍ចាមនោះ គឺពាក្យថា «សាមគ្គីភាព» ។ ក្នុងការការពារសាសនាពីការបំផ្លិចបំផ្លាញតាមរយៈការធ្វើទុក្ខបុកម្នេញជាលក្ខណៈប្រព័ន្ធសហគមន៍ចាមបានឯកច្ឆន្ទគ្នាក្រោកឈរឡើងយ៉ាងក្លាហានប្រឆាំងនឹងការធ្វើបាបយ៉ាងសាហាវឃោរឃៅរបស់ខ្មែរក្រហម ។ ទោះបីជាជនជាតិចាមទាំងនោះដឹងហើយថាការធ្វើបែបនេះនឹងអាចនាំមកនូវគ្រោះមហន្តរាយដល់ខ្លួនក៏ដោយ ក៏ជនជាតិចាមទាំងនោះមិនមានការភ័យខ្លាចក្នុងការក្រោកឈរប្រឆាំងនឹងខ្មែរក្រហមដែរ ។ ជាចុងក្រោយ ជនជាតិចាមតែ៦០០នាក់ប៉ុណ្ណោះក្នុងចំណោមជនជាតិចាម៦២០០នាក់ (អត្រាប្រជាជនជនជាតិឥស្លាមឆ្នាំ១៩៧០) ដែលអាចរួចរស់រានមានជីវិតពីរបបដ៏ឃោរឃៅនេះ ។

បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាប្រហែលជា៣០នាក់បានធ្វើដំណើរមកដល់ភូមិនេះ នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៩ ដើម្បីចំណាយពេលស្នាក់នៅក្នុងសហគមន៍នេះរយៈពេលពី៦ ទៅ១០ថ្ងៃ។ គោលបំណងសំខាន់នោះ គឺដើម្បីផ្សារភ្ជាប់សហគមន៍នេះទៅនឹងការស្វែងយល់ពីដំណើរការសាលាក្តីខ្មែរក្រហមតាមរយៈការអប់រំតាមសហគមន៍ និងជាពិសេសគឺតួនាទីជាដើមបណ្តឹងរដ្ឋប្បវេណី ។ ដោយសារតែភាពរាក់ទាក់គួបផ្សំនឹងជីវភាពរស់នៅដ៏សាមញ្ញតាមប្រពៃណីរបស់អ្នកភូមិនេះ ធ្វើឲ្យខ្ញុំមានអារម្មណ៍កក់ក្តៅនៅពេលដែលមកកាន់ភូមិនេះភ្លាម ។ អ្វីដែលខ្ញុំបានគិតទុកជាមុនទាក់ទងនឹងសហគមន៍ អ៊ីស្លាមនេះគឺចាប់ផ្តើមលេចឡើងជារូបភាពយ៉ាងច្បាស់ថែមទៀត ក្រោយពេលដែលមានអភូតហេតុមួយបានកើតឡើងនោះគឺក្រុមក្មេងៗមួយហ្វូងដណ្តើមគ្នាយកនំនៅពេលចាប់ផ្តើមកម្មវិធីវេទិកាអ្នកភូមិ ។ ប្រសិនបើយើងមើលតែពីសំបកក្រៅ ស្ថានភាពនេះប្រាកដជាធ្វើឲ្យយើងយល់ឃើញថា ក្មេងៗទាំងនេះពិតជាសាហាវខ្លាំងណាស់ មិនចេះគិតពីសុវត្ថិភាពរបស់ខ្លួនឯងសោះ ។



សឹងនៅភូមិស្វាយឃ្លាំង ខេត្តកំពង់ចាម

ប៉ុន្តែនៅក្នុងខណៈពេលនេះដែរ ប្រសិនបើយើងពិចារណាឲ្យបានល្អិតល្អន់ពីស្ថានភាពនេះ យើងអាចយល់បានថា ក្មេងៗទាំងនេះគឺមានបំពាក់នូវស្មារតីសាមគ្គីភាពដូចគ្នាទៅនឹងអ៊ីស្លាមជំនាន់មុនរបស់ក្មេងទាំងនោះអ៊ីចឹងដែរ ។ ក្មេងៗទាំងនេះប្រហែលជាយល់ថា ប្រសិនបើចង់បាននូវអ្វីដែលខ្លួនឯងត្រូវការ គឺចាំបាច់ត្រូវតែសហការគ្នាជាធ្លុងមួយ ។ ដូច្នេះហើយ ទើបធ្វើឲ្យក្មេងៗទាំងនោះយល់ថាពួកគេត្រូវតែសាកល្បងមើល ទោះបីជាដឹងថាពេលខ្លះលទ្ធផលចុងក្រោយមិនបានទទួលរង្វាន់អ្វីក៏ដោយ ។ តាមរយៈហេតុការណ៍មួយនេះ អាចឲ្យយើងយល់បានថា សូម្បីតែដើម្បីនំបន្តិចបន្តួចបែបនេះក៏ក្មេងៗជនជាតិចាមទាំងនោះនៅតែសហការគ្នាបានយ៉ាងខ្លាំងក្លាបែបនេះ ចុះទម្រាំតែការតស៊ូដើម្បីតម្លៃនិងសេរីភាពរបស់ខ្លួនឯងវិញនោះ? ពិតប្រាកដណាស់ពួកគេនឹងរួបរួមគ្នាយ៉ាងសកម្មអង់អាចដើម្បីតស៊ូទាមទារឲ្យខានតែបាន ។ ជាពិសេស ប្រសិនបើយើងឆ្លុះបញ្ចាំងទៅក្នុងករណីនៃការបះបោររបស់ ជនជាតិចាម (កាលពីចុងឆ្នាំ១៩៧៥) ។

ខ្ញុំជឿជាក់ថា ចំណងដ៏រឹងមាំមួយត្រូវបានចងភ្ជាប់រវាងអ្នកភូមិនេះ ហើយដោយសារវប្បធម៌និងសាសនានេះឯង ដែលធ្វើឲ្យចំណងនេះត្រូវបានរឹតបន្តឹងកាន់តែខ្លាំងឡើងថែមទៀត ។ គួយ៉ាងដូចជា នៅថ្ងៃទី២៥ ខែតុលា អ្នកភូមិយ៉ាងច្រើនកុះករដែលពោរពេញទៅដោយភាពរីករាយបានមកចូលរួមក្នុងកម្មវិធីវេទិកាអ្នកភូមិដែលក្នុងកម្មវិធីនោះមានការចូលរួមពីសំណាក់ប្រធានសហគមន៍ និងបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ក្នុងកម្មវិធីវេទិកាអ្នកភូមិនេះគឺមានការនិយាយពីសម័យខ្មែរក្រហម ការបះបោររបស់ជនជាតិចាមប្រឆាំងនឹងខ្មែរក្រហម និងការស្វែងរកយុត្តិធម៌ និងការទទួលខុសត្រូវ ជាពិសេសក៏មានការបញ្ចាំងកុនខ្លីៗចំនួន (២ : ទី១) គឺបទសម្ភាសន៍របស់អ្នករួចរស់មានជីវិតពីគុកទួលស្លែង និងអតីតអ្នកយាមគុកទួលស្លែងម្នាក់ ។ ទី២) គឺវីដេអូនៃការសុំទោសរបស់ ឌុច នៅក្នុងសវនាការ ។ អ្នកភូមិបានបង្ហាញពីការចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការបញ្ចាំងកុនទាំងនេះ ។ ក្នុងការឆ្លើយតបទៅនឹងការសុំទោសរបស់ ឌុច នេះមានអ៊ំប្រុសវ័យចំណាស់ម្នាក់បានក្រោកឈរឡើង ហើយនិយាយថា «ការសុំទោសនេះគឺមិនអាចទទួលយកបានទេ ព្រោះ ឌុច បានសម្លាប់មនុស្សច្រើនណាស់ ។ ដូចនេះថាតើការសុំទោសនេះអាចសងគ្រប់ដែរឬទេចំពោះអ្វីៗទាំងអស់ដែលពួកយើងបានបាត់បង់នោះ ជាពិសេសគឺអាយុជីវិតរបស់ក្រុមគ្រួសារពួកយើង?»

ឆ្លងកាត់ពាក្យសម្តីមួយម៉ាត់នេះ យើងអាចដឹងបានថា ភ្លើងកំហឹងនិងតម្រូវការចង់បានយុត្តិធម៌នៅតែដុតឆេះរោលរាលក្នុងផ្លូវអារម្មណ៍របស់ពួកគាត់ជានិច្ច ហើយភ្លើងនេះនឹងមិនអាចរលត់បានឡើយ ប្រសិនបើយុត្តិធម៌ពិតប្រាកដមិនត្រូវបានផ្តល់ឲ្យ ។

យ៉ាងណាមិញ ចំពោះអ៊ំស្រីជនជាតិចាមដែលខ្ញុំបានជួបវិញ គឺមើលទៅដូចជាមិនមានអារម្មណ៍ខ្លាំងដូច្នេះទេ ។ ទោះបីជាក្រុមគ្រួសាររបស់គាត់ជាច្រើននាក់ត្រូវបានសម្លាប់នៅក្នុងសម័យខ្មែរក្រហម ហើយសូម្បីតែខ្លួនគាត់ផ្ទាល់ត្រូវបៀមទុក្ខវេទនាអស់រយៈពេលយ៉ាងយូរបែបនេះក៏ដោយ ឥឡូវនេះពួកគាត់បែរជាមានអារម្មណ៍ស្កប់ស្កល់នឹងជីវភាពរស់នៅរបស់គាត់ទៅវិញ ជាពិសេសគឺគិតថា ទុកឲ្យអ្វីដែលកន្លងផុត ឲ្យវាកន្លងផុតទៅចុះ ។ ករណីជាក់ស្តែងគឺលោកយាយ ទី ដែលបានអះអាងថាសាច់ញាតិរបស់គាត់ជិត៣០នាក់ ត្រូវបានសម្លាប់រង្គាល ហើយខុសពីអ្វីដែលខ្ញុំបានគិតទុកជាមុន អ៊ំស្រីម្នាក់នេះបែរជាមិនមានបំណងបំពេញពាក្យបណ្តឹងទៅវិញ ។

ខ្ញុំពិតជាមានការភ្ញាក់ផ្អើលទៅនឹងការសម្រេចចិត្តរបស់គាត់ខ្លាំងណាស់ ។ ប៉ុន្តែ ក្រោយពីបានសំណេះសំណាលជាមួយគាត់រួចមក ទើបខ្ញុំជ្រាបច្បាស់ពីមូលហេតុសំខាន់ខ្លះៗដែលធ្វើឲ្យគាត់ជ្រើសរើសបែបនេះ ។ ជាបឋមគឺថា ការទាមទារយកយុត្តិធម៌សម្រាប់គាត់គឺពិតជាយូរខ្លាំងណាស់ រហូតទាល់តែធ្វើឲ្យគាត់បានសម្រេចចិត្តរួចទៅហើយ ដើម្បីផ្សះផ្សាខ្លួនគាត់ឲ្យរស់នៅក្នុងសង្គមដែលប្រះស្រាំបែបនេះ ។ អារម្មណ៍របស់គាត់ត្រូវបានសប់ទៅហើយ ដោយប្រើធម៌អារ្យនៃសាសនាមកដឹកនាំជីវិតរបស់គាត់បន្តិចម្តងៗ ។ គាត់យល់ថា ពេលវេលាគឺជាឱសថព្យាបាលរបួសដ៏ស័ក្តិសិទ្ធ ដោយលើកឧទាហរណ៍ ប្រាប់ខ្ញុំថាពីមុនប្រសិនបើគាត់បានដឹងថានរណាជាឃាតករសម្លាប់សាច់ញាតិគាត់ គាត់នឹងសម្លាប់អ្នកនោះឲ្យអ្នកភូមិទាំងអស់បានឃើញតែម្តង ហើយមិនប្រើកាំបិតនោះទេ គឺប្រើធាងត្នោតដូចគ្នាទៅ

នឹងអ្វីដែលពួកខ្មែរក្រហមធ្វើអ៊ីចឹង ។ ប៉ុន្តែគាត់បាននិយាយទៀតថា ឥឡូវនេះអ្វីៗបានកន្លងផុតទៅយូរណាស់មកហើយ យូររហូតទាល់តែអារម្មណ៍ចង់សងសឹក «ឈាមសងដោយឈាម» នោះត្រូវបានរលប់បាត់ទៅតាមពេលវេលា ។ ផ្ទុយមកវិញ គាត់បានប្រៀបធៀបពាក្យ «សងសឹក» ទៅជាដើមវល្លិ៍ដែលកំពុងតែលូតលាស់ ។ ហើយដើមវល្លិ៍នៃការសងសឹកនេះនឹងមិនអាចឈប់លូតលាស់បានឡើយ ប្រសិនបើយើងនៅតែខំស្រោចទឹកលើវាទៀត ។ អាស្រ័យហេតុនេះហើយ «ហេតុអ្វីមិននាំគ្នាដកដើមវល្លិ៍ហ្នឹងចេញតែម្តងទៅ ហើយបោះវាចោលឲ្យឆ្ងាយ ដូចនេះយើងទាំងអស់គ្នានឹងអាចរស់នៅដោយមានសេរីភាពក្នុងចិត្ត» ។ ម្យ៉ាងទៀត គាត់ក៏បានបន្ថែមទៀតថា គាត់មិនបានស្គាល់មុខជនដែលពិតប្រាកដថាជានរណានោះទេ ជាពិសេស គាត់ខ្លួនឯងផ្ទាល់គឺមានវ័យចាស់ជរាទៅហើយ គាត់មិនចង់គិតគូរពីរឿងសងសឹកអ្វីនោះទេ ឲ្យតែរស់នៅបានសុខសាន្តទៅបានហើយ ។ ទាំងនេះហើយធ្វើឲ្យគាត់មិនមានបំណងបំពេញទម្រង់បែបបទជនរងគ្រោះអ្វីនោះទេ ។

ខ្ញុំពិតជាជ្រួតជ្រាបពីអារម្មណ៍របស់អ៊ំស្រី ទី ខ្លាំងណាស់ ។ ក្រៅពីអ្វីដែលគាត់បានរៀបរាប់ខាងលើនេះ គឺនៅមានមូលហេតុដែលងាយយល់មួយទៀតដែលធ្វើឲ្យគាត់ប្រកាន់ខ្ជាប់នូវគោលជំហរនេះ ។ ដូចដែលយើងបានដឹងហើយថា ក្រោយពីឆ្នាំ១៩៧៩ អ្នកដែលរស់រានមានជីវិតនៅក្នុងសហគមន៍ចាមនេះ គឺភាគច្រើនសុទ្ធតែជាស្ត្រីនិងកុមារ ។ ដូចច្នេះហើយ ពួកគាត់ទាំងអស់នោះទោះជាតិចក្តីឬច្រើនក្តី គឺនៅតែទទួលរងការឈឺចាប់ មិនត្រឹមតែផ្លូវកាយនោះទេថែមទាំងផ្លូវចិត្តផងដែរ ។ ផ្លូវចិត្តនោះគឺទាក់ទងនឹងទុក្ខសោកនៃការបាត់បង់សាច់ញាតិ ចំណែកឯផ្លូវកាយវិញគឺជាសម្ពាធខាងក្រៅដែលបង្ខំឲ្យគាត់ផ្សាំទៅនឹងការរស់នៅក្នុងសង្គមដែលបាក់បែកនេះ ដោយចាប់ផ្តើមពីដៃទទេទាំងពីររបស់គាត់ ។ ដូចនេះអ៊ំស្រីទាំងនោះ ទោះបីជាយ៉ាងណាក៏ដោយ ក៏នៅតែមានអារម្មណ៍ភ័យខ្លាចចំពោះអ្វីៗដែលតាមទស្សនៈរបស់គាត់យល់ថា នឹងអាចនាំមកនូវបញ្ហាទៅថ្ងៃក្រោយដល់គាត់ ។

មិនខុលពីលទ្ធផលដ៏អាក្រក់នៃរបបខ្មែរក្រហមដែលបានបន្សល់ទុកនូវស្នាមរបួសដ៏ឈឺចាប់ដល់ ជនជាតិចាមយ៉ាងនេះក្តី ក៏អ្នកភូមិអ៊ីស្លាមទាំងនេះនៅតែពុះពារការលំបាកដើម្បីរស់នៅក្នុងសង្គមនេះដដែល ដោយរក្សាបាននូវតម្លៃនិងភាពថ្លៃថ្នូររបស់ខ្លួនជានិច្ច ។ ខណៈពេលដែលមានអ្នកភូមិខ្លះជ្រើសរើសយកការបំភ្លេចចោល ក៏នៅមានអ្នកភូមិជាច្រើនទៀតនៅតែបន្តស្វែងរកយុត្តិធម៌សម្រាប់អ្វីដែលពួកគាត់បានបាត់បង់ ។ ខ្ញុំពិតជាកោតសរសើរខ្លាំងណាស់ចំពោះការខ្នះខ្នែងរបស់គាត់ក្នុងការស្វែងរកការពិត នោះគឺយុត្តិធម៌ដែលជាឫសគល់នៃដើមវល្លិ៍នៃការសងសឹក ។ ល្គឹកណាដែលយើងមិនអាចរកឃើញនូវឫសគល់មួយនោះ ល្គឹកនោះយើងនឹងមិនអាចដករឹសនោះចេញទាំងស្រុងបានឡើយដែលជាហេតុធ្វើឲ្យឫសគល់នោះនឹងបន្តលូតលាស់ឡើងវិញ ។


អ្នកភូមិជនជាតិចាម នៅភូមិស្វាយឃ្លាំង ទស្សនាខ្សែភាពយន្តអំពីការសុំខមាទោសរបស់ ឌុច

ដូចគ្នាទៅនឹងរបួសនៃការឈឺចាប់ដ៏ខ្លាំងក្លានេះដែរ ដែលថារបួសនេះនឹងមិនអាចព្យាបាលបានជាសះស្បើយឡើងវិញនោះទេ ប្រសិនបើយើងទុកវាចោលមិនរវល់ ។ ថ្ងៃក្រោយរបួសនោះនឹងរើឡើងវិញ ហើយធ្វើឲ្យយើងឈឺចាប់ម្តងទៀតនៅពេលដែលយើងប៉ះវា ។ ដូចនេះដើម្បីព្យាបាលឲ្យជាសះស្បើយទាំងស្រុងទាំងផ្លូវកាយនិងផ្លូវចិត្តគឺមានតែស្វែងរកឱសថដ៏ស័ក្តិសិទ្ធិមួយប៉ុណ្ណោះ នោះគឺយុត្តិធម៌ដែលជាវិធីតែមួយគត់ដែលអាចទប់ទល់នឹងរបួសដែលមិនអាចបំភ្លេចចោលនេះបាន ។ **ត្រី ស៊ុយហៀង**

# ការស្វែងរកយុត្តិធម៌ដ៏យូរសម្រាប់ប្រជាជនកម្ពុជា

រយៈពេលសាមសិបឆ្នាំបន្ទាប់ពីបញ្ចប់របបខ្មែរក្រហម ដែលមានការសម្លាប់រង្គាល កិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ត្រូវបានគេធ្វើចុងក្រោយដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនិងអ្នករស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ ។ ប៉ុន្តែនៅតែមានសំណួរចោទសួរថាតើត្រូវធ្វើយ៉ាងណាដើម្បីបម្រើជនរងគ្រោះឲ្យបានស័ក្តិសមនិងថាតើត្រូវធ្វើយ៉ាងដូចម្តេចដើម្បីផ្តល់ការផ្សះផ្សាប្រកបដោយសន្តិភាព និងយុត្តិធម៌សម្រាប់គ្រប់ភាគីដែលពាក់ព័ន្ធទាំងអស់ ។ វាបង្ហាញផងដែរពីការរួមផ្សំនៃវិធីសាស្ត្រដោះស្រាយតាមរយៈតុលាការនិងក្រៅតុលាការ ទាំងផ្លូវការនិងមិនផ្លូវការដែលបម្រើផលប្រយោជន៍ផ្សេងគ្នា និងតម្រូវការចាំបាច់ដល់អ្នករស់រានជីវិតពីរបបខ្មែរក្រហម ។

វាមានសារសំខាន់ណាស់ដើម្បីធ្វើការកត់សម្គាល់ជាដំបូងទៅលើស្ថានភាពសេដ្ឋកិច្ចសង្គម និងស្ថានភាពនយោបាយក្នុងប្រទេសដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ពីយុត្តិធម៌និងការផ្សះផ្សាជាតិដែលប្រជាជនកម្ពុជាបានជួបប្រទះ ។ ក្រោយរបបប្រល័យពូជសាសន៍ ប្រទេសកម្ពុជាទទួលរងនូវអស្ថិរភាពនយោបាយ សេដ្ឋកិច្ចដ៏លំបាក ជីវភាពរស់នៅក្រីក្រ ការរីករាលដាលនៃបញ្ហាសុខភាព ប្រព័ន្ធអប់រំទន់ខ្សោយ រចនាសម្ព័ន្ធសង្គមប្រេះស្រាំអស់ជាងបីទសវត្សរ៍ ។ ចំណែកប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាក៏ត្រូវបានមើលឃើញថាមានភាពទន់ខ្សោយនិងមានអំពើពុករលួយដែរ ។ ប្រជាជន មួយចំនួនធំកំពុងត្រូវការការងារ ការអប់រំ សុខភាពសាធារណៈនិងសេវាសង្គមផ្សេងៗទៀត ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានក្នុងពេលបច្ចុប្បន្ន ។

ខ្មែរក្រហម ឬ បក្សកុម្មុយនីស្តកម្ពុជាដឹកនាំដោយ សាឡុត ស ដែលគេស្គាល់ថា ប៉ុល ពត ។ នៅពេលឡើងកាន់អំណាចភ្លាម ប៉ុល ពត បានអនុវត្តនូវគោលនយោបាយកុម្មុយនីស្តដ៏តឹងរ៉ឹង ដើម្បីកែប្រែប្រទេសកម្ពុជាឲ្យទៅជាសង្គមកសិកម្មជឿនលឿន ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានបញ្ជាឲ្យជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញដើម្បីគេចចេញពីការទម្លាក់គ្រាប់បែករបស់អាមេរិក ។ ប្រជាជនរាប់សែននាក់ត្រូវបានបង្ខំឲ្យចាកចេញទៅកាន់ទីជនបទ ។ ព្រឹត្តិការណ៍នេះគឺជាការចាប់ផ្តើមនូវអ្វីដែល ប៉ុល ពត ហៅថា ឆ្នាំសូន្យ ។ ប្រទេសកម្ពុជាបានបញ្ចប់ហើយបានក្លាយទៅសង្គមកម្ពុជាថ្មី និង បរិសុទ្ធ ។

ក្នុងអំឡុងសម័យកាលដ៏យោយៅ មេដឹកនាំខ្មែរក្រហមបានសម្គាល់ពីខ្មាំងសំខាន់ៗមួយចំនួនរបស់បក្ស រួមទាំងប្រជាជនវៀតណាម ចិន ចាមមូស្លីម បញ្ញវន្ត អភិជន អ្នកទីក្រុង និង អតីតទាហាន លន់ នល់ ឬអ្នកគាំទ្រទាហាន លន់ នល់ ។ ប្រជាជនចាស់ ឬប្រជាជនមូលដ្ឋានត្រូវបានចាត់ទុកថាជាប្រជាជនល្អនៅក្នុងសង្គម អ្នកទាំងនេះគឺជាអតីតកសិករដែលរស់នៅទីជនបទធ្វើស្រែចម្ការមិនបានទទួលការអប់រំហើយក្រីក្រ ។ «ប្រជាជនថ្មី» ដែលត្រូវបានសម្គាល់ជាអតីតអ្នករស់នៅទីក្រុងត្រូវបានបង្ខិតបង្ខំឲ្យផ្លាស់ទីលំនៅគឺជាសត្រូវ ។ ប្រសិនបើប្រជាជនថ្មីមិនអាចសម្របខ្លួនទៅនឹងជីវិតកសិករបានទេ អ្នកទាំងនេះអាចត្រូវបានសម្លាប់ ឬស្លាប់ដោយសារជំងឺនិងការអត់ឃ្លាន ។ សម្រាប់ខ្មែរក្រហម ប្រជាជនគ្មានតម្លៃ ដោយសុខចិត្តសម្លាប់មនុស្សច្រឡំជាជាងទុកឲ្យខ្មាំងរួចខ្លួន ។ ប្រជាជនគ្រប់រូបត្រូវធ្វើការដកស្ទូង ដាំដំណាំ និងដាំស្លសម្រាប់សហគមន៍ដែលជាកន្លែងត្រូវបង្ខំឲ្យរស់នៅ ។ កុមារត្រូវបានបំបែកចេញពីឪពុកម្តាយ ហើយដាក់ឲ្យរស់នៅឃុំផ្សេងៗពីគ្នា ។ អាហារខ្វះខាតព្រោះតែអង្ករដែលប្រមូលបានត្រូវបញ្ជូនទៅក្នុងឃ្លាំងដើម្បីបំពេញគោលដៅសេដ្ឋកិច្ចរបស់ខ្មែរក្រហមសម្រាប់ប្រទេសកម្ពុជា ។ អ្នកធ្វើការត្រូវបានហាមប្រាមមិនឲ្យហូបអាហារដែលបានប្រូតកាត់ ឬផ្លែឈើនៅលើដើមឈើ ពីព្រោះរបស់ទាំងអស់នេះជាកម្មសិទ្ធរបស់អង្គការ ។ ប្រជាជនរស់នៅក្នុងស្ថានភាពភ័យខ្លាចជាប្រចាំ ។ ប្រជាជនជាច្រើនចាប់ផ្តើមស្លាប់ដោយជំងឺ អត់អាហារនិងការសម្លាប់ ។ ដើម្បីសម្រេចនូវគោលដៅបន្សុទ្ធកម្ម ប៉ុល ពត បានចាប់ផ្តើមបញ្ជាឲ្យមានការធ្វើបន្សុទ្ធកម្មនៅទូទាំងប្រទេស ។ ជនណាដែលត្រូវបានសង្ស័យថាមានសកម្មភាពប្រឆាំងអង្គការនឹងត្រូវបានចាប់ខ្លួន ឬ សម្លាប់មួយរំពេច ។

គុកទួលស្លែងគឺជាទីតាំងដ៏សំខាន់សម្រាប់ឃុំឃាំង សួរចម្លើយ និងធ្វើទារុណកម្មមនុស្សដែលត្រូវបានចោទប្រកាន់ជាខ្មាំងនយោបាយ ។ បុរស ស្ត្រី និងក្មេងៗប្រមាណ១៨០០០នាក់ត្រូវបានបញ្ជូនមកទួលស្លែង ហើយក្រោយមកត្រូវបានកម្ទេចដោយពួកខ្មែរក្រហម ។ អ្នកទោសត្រូវបានណែនាំឲ្យសារភាពអំពើក្បត់របស់ខ្លួន និងបង្ហាញឈ្មោះអ្នកផ្សេងដែលអាចជាជនក្បត់និងជាខ្មាំង ។ ជនរងគ្រោះតែងតែរៀបរាប់ឈ្មោះរបស់អ្នកផ្សេងដែលគេនឹកឃើញដើម្បីបញ្ឈប់អំពើទារុណកម្ម ។ ចម្លើយសារភាពខ្លះមានរហូតដល់ទៅ៤០ទំព័រ អ្នកផ្សេងមានត្រឹមតែពីរទៅបីទំព័រប៉ុណ្ណោះ ។ បន្ទាប់ពីសារភាព អ្នកទោសទាំងអស់ត្រូវបានបញ្ជូនទៅវាលពិឃាតជើងឯកនិងទៅកន្លែងសម្លាប់ ។ អ្នកទាំងនេះត្រូវបានបណ្តើរជាជួរទៅមាត់រណ្តៅ ហើយត្រូវបានវាយចំក្បាលឬកដោយត្បូងចបដែលមានប្រវែងប្រហែលជិតមួយម៉ែត្រ ។ សាកសពរបស់អ្នកទាំងនេះត្រូវបានបោះចូលទៅក្នុងរណ្តៅ ហើយសាកសពរាប់រយទៀតត្រូវបានកប់ជាមួយគ្នា ។ ក្មេងៗដែលត្រូវបាននាំយកទៅគុកជាមួយឪពុកម្តាយក៏ត្រូវបានគេសម្លាប់នៅវាលពិឃាតជើងឯកដែរ ។ អ្នកយាមនឹងចាប់កជើងរបស់ក្មេងៗនោះ ហើយបោកផ្ទប់នឹងដើមឈើទាល់តែស្លាប់ បន្ទាប់មកកប់ពួកគេក្នុងរណ្តៅរួមមួយ ។ រណ្តៅសាកសពរួមទាំងអស់នេះត្រូវបានរកឃើញនៅទូទាំងប្រទេស ។

ប្រជាជនប្រមាណ១,៧លាននាក់ ជាង២០ភាគរយនៃប្រជាជនទាំងអស់ បានស្លាប់ដោយសារកណ្តាប់ដៃខ្មែរក្រហមនៅចន្លោះឆ្នាំ១៩៧៥ដល់១៩៧៩ ។ តាមការប៉ាន់ស្មាន ១០០ ភាគរយនៃប្រជាជនវៀតណាមត្រូវបានសម្លាប់ ឬបង្ខំឲ្យចេញពីប្រទេស ៤០ភាគរយនៃជនជាតិអ៊ីស្លាម និង៥០ភាគរយនៃជនជាតិចិនត្រូវបានសម្លាប់ ។

## យុត្តិធម៌តាមរយៈការផ្សះផ្សា

យុត្តិធម៌តាមរយៈការផ្សះផ្សាមានសារសំខាន់សម្រាប់ផ្សះផ្សាប្រជាជនកម្ពុជា ។ យុត្តិធម៌តាមរយៈការផ្សះផ្សាមានគោលបំណងបង្កើតសន្តិភាពបន្ទាប់ពីជម្លោះនិងការដោះស្រាយបញ្ហាតាមរយៈការចូលរួមដ៏សកម្មភាពរបស់ជនរងគ្រោះ ជនដៃដល់និងសហគមន៍ទាំងមូលនៅក្នុងដំណើរការផ្សះផ្សាជាតិ ។ វាអាស្រ័យទៅលើការជាប់ពាក់ព័ន្ធរបស់បុគ្គលម្នាក់ៗ និងការចូលរួមរបស់ក្រុមទាំងអស់នេះ ហើយវាតម្រូវថាជម្លោះត្រូវបានបង្ហាញនៅក្នុងបរិបទសង្គម ។ យុត្តិធម៌តាមរយៈការផ្សះផ្សាពាក់ព័ន្ធយ៉ាងខ្លាំងក្នុងការជួយជនរងគ្រោះ (ផ្នែកហិរញ្ញវត្ថុ ផ្លូវចិត្ត និងសង្គម) សហគមន៍ និងជាមួយការនាំជនប្រព្រឹត្តបទល្មើសឲ្យទៅរស់នៅក្រោមច្បាប់ទម្លាប់ ។ ដំណើរការទាំងអស់នេះគួរតែកើតឡើងដំណាលនឹងដំណើរការនីតិវិធីនៃភ្នាក់ងារយុត្តិធម៌ដែលត្រូវបានគេទទួលស្គាល់ ។

## យុត្តិធម៌តាមរយៈការកាត់ទោស

យុត្តិធម៌តាមរយៈការកាត់ទោសមានគោលបំណងដោះស្រាយជម្លោះដោយធ្វើការដាក់ទោសទៅលើបទល្មើសជាក់លាក់ ។ យុត្តិធ៌មតាមរយៈការកាត់ទោសផ្អែកទៅលើគោលការណ៍ដែលថាភាពខុសឆ្គងនៃការប្រព្រឹត្តខុសនាំទៅរកការដាក់ទោសលើជនប្រព្រឹត្តបទល្មើស ។ ទោះបីជាយ៉ាងណាក៏ដោយ យុត្តិធម៌តាមរយៈការកាត់ទោសមិនមែនជាការស្វែងរកសន្តិភាពសម្រាប់ជនរងគ្រោះឬជនដៃដល់ទេ ។ ការបង្កើតការដាក់ទោសគឺដើម្បីជំរុញកុំឲ្យមានការរំលោភច្បាប់ ឬប៉ះពាល់ដល់ឥរិយាបថ ប៉ុន្តែវាមិនអាចជួយដល់ជនដៃដល់ឬផ្សះផ្សាជនរងគ្រោះបានច្រើនឡើយ ។ ជាជាងជំរុញការផ្សះផ្សានិងការនាំយកជនដៃដល់ទៅកាន់សង្គមស្របច្បាប់ ការដាក់ទោសអាចបង្កើនកំហឹងការអាក់អន់ចិត្ត និងការបាក់បែកចេញពីសង្គម ដែលអាចជំរុញឲ្យជនដៃដល់ប្រព្រឹត្តបទល្មើសផ្សេងទៀត ។ ហេតុដូច្នេះ យុត្តិធម៌តាមផ្លូវតុលាការតែមួយមិនអាចផ្តល់ផលប្រយោជន៍ដល់ការផ្សះផ្សាជាតិដែលប្រកបដោយសន្តិភាពបានទេ ។

## យុត្តិធម៌ដែលអ្នកនៅរស់ចង់បាន

*ញឹមសុវត្ថិ អតីតទាហាន លន់ នល់ និង ជាជនរងគ្រោះខ្មែរក្រហម*

ញឹម សុវត្ថិ គឺជាបុរសដែលមានអាយុ៦៩ឆ្នាំ រស់នៅក្នុងភូមិកគ្រួស ឃុំព្រៃធំ ស្រុកកំពង់រោទិ៍ ។ គាត់ជានិស្សិត ហើយបានចូលបម្រើជាទាហាន លន់ នល់ ចាប់ពីឆ្នាំ១៩៧២ ដល់ឆ្នាំ១៩៧៥ ។ សុវត្ថិ ត្រូវបានខ្មែរក្រហមជម្លៀសក្នុងនាមជាអ្នកទោសសង្គ្រាម បន្ទាប់មកបានបញ្ជូនទៅកាន់ខេត្តផ្សេងអស់រយៈពេល៣ខែ ក្រោយមកត្រូវបានគេបញ្ជូនឲ្យទៅលើកទំនប់ ។ គាត់បាន

ជួបជុំជាមួយប្រពន្ធរបស់គាត់វិញនៅឯជំរំពលកម្ម ។

បន្ទាប់ពីបាត់បង់សាច់ញាតិយ៉ាងច្រើន ញឹម សុវត្ថិ មិនសូវមានទុកព្រួយខ្លាំងពេកទេ ព្រោះដឹងថា គាត់មិនមែនជាមនុស្សតែម្នាក់ដែលទទួលការឈឺចាប់នោះទេ ។ ដោយគិតទៅដល់អ្នកដ៏ទៃដែលបានបាត់បង់កូនដែរ ក្រុមគ្រួសារនិងមិត្តភក្តិបានជួយដល់គាត់ឲ្យធ្វើដំណើរឆ្ពោះទៅមុខ និងផ្សះផ្សារបួសផ្លូវចិត្តបាន ។ ទាក់ទងនឹងការផ្សះផ្សាផ្លូវចិត្ត សុវត្ថិ បានបង្ហាញនូវការយល់ដឹងដូចខាងក្រោម ៖

«ការបង្រួបបង្រួមគ្នារបស់ប្រជាជនពិតជាមានសារសំខាន់សម្រាប់ជួយប្រទេសឲ្យបន្តដំណើរទៅមុខ ។ វាជាការរួបរួមគ្នាមួយដែលនឹងជួយប្រជាជនបាន ។ ឧទាហរណ៍ខ្ញុំបានចូលរួមជាមួយគណៈកម្មការក្នុងស្រុកដើម្បីកសាងវត្តនៅក្នុងតំបន់នោះ ។ ការមានទិសដៅមួយសម្រាប់ផ្តោតទៅលើដែលជាការរួបរួមគ្នាមានសារសំខាន់ណាស់ ។ សាសនាក៏មានសារសំខាន់ផងដែរក្នុងការផ្សះផ្សារបួសផ្លូវចិត្ត ។ សាសនាជាឈ្មោះមួយក្នុងចំណោមឈ្មោះទាំងបីនៅក្នុងបាវចនាប្រទេស «ជាតិ សាសនា ព្រះមហាក្សត្រ» ។ ប្រជាជនគួរតែចែករំលែកនូវគំនិតដូចគ្នា ដូចជាការរួបរួមជាមួយនឹងគោលដៅរបស់រដ្ឋាភិបាលដើម្បីបង្កើតការរួបរួមមួយជាចាំបាច់ក្នុងការផ្សះផ្សា ។ យើងគ្រាន់តែត្រូវការការរួបរួមគ្នាមួយ» ។

សុវត្ថិ បានដឹងពីសាលាក្តីខ្មែរក្រហម (អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) នៅមុនឆ្នាំ២០០៩ តាមរយៈគម្រោងឯកសាររស់របស់មជ្ឈមណ្ឌលកម្ពុជានៅក្នុងភូមិរបស់គាត់ ។ គាត់ជឿជាក់ថា សាលាក្តីនេះអាចធ្វើការសម្រេចថានឹងធ្វើអ្វីចំពោះ ឌុច, អៀង សារី, នួន ជា និង មេដឹកនាំដទៃទៀត ហើយគាត់សង្ឃឹមថា ចៅក្រមមានភាពយុត្តធម៌ និងសមត្ថភាពដែលអាចផ្តល់យុត្តធម៌ឲ្យកម្ពុជាបាន ។ នៅពេលសាកសួរថាគាត់នឹងធ្វើអ្វីប្រសិនបើគាត់ជាចៅក្រម សុវត្ថិ បានបញ្ជាក់ថា «គាត់នឹងសម្លាប់អ្នកទាំងនោះ ដោយកាត់ទោសប្រហារជីវិត» ។ ទោះបីជាយ៉ាងនេះក្តី គាត់ជឿជាក់ថា មានតែមេដឹកនាំខ្មែរក្រហមថ្នាក់ខ្ពស់ប៉ុណ្ណោះដែលគួរតែត្រូវបាននាំយកមកកាត់ទោសនិងផ្តន្ទាទោស ។ កម្មាភិបាលថ្នាក់ទាប «គ្រាន់តែទទួលបញ្ជាពីថ្នាក់លើ» ទេ ។ គាត់យល់ស្របថាការកាត់ទោសវាជាវិធីមួយសម្រាប់ឲ្យប្រជាជនកម្ពុជាឆ្ពោះទៅរកការរួបរួមមួយនិងការផ្សះផ្សាពីព្រោះច្បាប់ផ្តល់ការរួបរួមមួយ ប៉ុន្តែគាត់ជឿជាក់ផងដែរថាវារឹតតែសំខាន់ក្នុងការបង្ហាត់បង្រៀនក្មេងៗជំនាន់ក្រោយអំពីអ្វីដែលបានកើតឡើងក្រោមរបបខ្មែរក្រហម ។ គាត់ចង់ឃើញក្មេងៗទទួលបាននូវការអប់រំអំពីប្រវត្តិសាស្រ្តខ្មែរក្រហម «ដើម្បីការពារកុំឲ្យរបបនោះកើតឡើងម្តងទៀត» ។

## ***ជា ម៉ៅ អតីតទាហានវ័យក្មេងខ្មែរក្រហមនិងអ្នកយាមនៅមន្ទីរស-២១***

ជា ម៉ៅ ភេទប្រុសអាយុ ៥៩ឆ្នាំ រស់នៅខេត្តកំពង់ឆ្នាំង ។ គាត់ត្រូវបានបង្ខំឲ្យចូលបម្រើកងទ័ពរំដោះខ្មែរក្រហមនៅពេលដែលគាត់មានអាយុ១២ឆ្នាំ ហើយគាត់ត្រូវបានគេនាំចេញពីផ្ទះក្នុងឆ្នាំ១៩៧៣ ។ ក្រោយមក គាត់ត្រូវបានគេចាត់តាំងឲ្យធ្វើជាអ្នកយាមនៅខាងក្រៅមន្ទីរគុកទួលស្លែងដើម្បីការពារសន្តិសុខ ។

ជា ម៉ៅ ជឿជាក់ថាជនរងគ្រោះនៃរបបខ្មែរក្រហមគួរតែទទួលបានយុត្តិធម៌ ។ គាត់ចាត់ទុកខ្លួនគាត់ជាជនរងគ្រោះជាជាងជនដៃដល់ ហើយអះអាងថាគាត់គ្រាន់តែស្តាប់តាមបញ្ជាគេប៉ុណ្ណោះ ។ ជា ម៉ៅ មិនចង់ធ្វើការសងសឹកទេពីព្រោះ «ការចងពៀរគឺជារឿងមិនល្អ» ។ បើទោះបីជាគាត់មានកាសសងសឹកក៏ដោយ ក៏គាត់បាននិយាយថាគាត់មិនជ្រើសរើសធ្វើវាដែរ ។ នៅពេលសួរសំណួរថាតើយុត្តិធម៌គួរមានលក្ខណៈបែបណាសម្រាប់ប្រទេសកម្ពុជា ជា ម៉ៅ បានធ្វើការពន្យល់ ៖

«ប្រជាជនដែលបានស្លាប់គឺស្លាប់ក្នុងសេចក្តីថ្លៃថ្នូរ ប៉ុន្តែចំពោះអ្នកដែលរស់រានមានជីវិត មិនមានសេចក្តីថ្លៃថ្នូរទេពីព្រោះអ្នកទាំងនេះនៅតែគិតទៅដល់អ្នកដែលបានស្លាប់ ។ ការដែលរស់នៅមិនមានអ្វីល្អទេ ។ ខ្ញុំនៅតែគិតទៅដល់អ្នកគ្រប់គ្នាដែលបានស្លាប់ក្នុងរបប ប៉ុល ពត ខ្ញុំនៅតែយកម្ហូបទៅវត្តដើម្បីឧទ្ទិសដល់ឪពុកម្តាយរបស់ខ្ញុំ ។ ខ្ញុំគិតអំពីរឿងនេះជារៀងរាល់ថ្ងៃ ។ ចំពោះការកាត់ទោសខ្មែរក្រហមតាមទស្សនៈច្បាប់ ខ្ញុំមិនខ្វល់ទេគឺទុកឲ្យ ឌុច ប្រឈមមុខនឹងការកាត់ទោសពីព្រោះគាត់បានធ្វើអាក្រក់ ប៉ុន្តែបើគិតតាមផ្លូវព្រះពុទ្ធសាសនាទុកឲ្យគាត់ប្រឈមមុខនឹងកម្មពៀរ មនុស្សដែលបានធ្វើអាក្រក់នឹងប្រឈមមុខផលវិបាកដូចគ្នានៅជាតិក្រោយ» ។

ជា ម៉ៅ បានទទួលព័ត៌មានតិចតួចអំពីការកាត់ទោស

មេដឹកនាំខ្មែរក្រហម ហើយប្រជាជនភាគច្រើនមិនសូវមានការចាប់អារម្មណ៍នៅក្នុងដំណើរការកាត់ទោសនោះទេ ។ អ្វីដែលគាត់បារម្ភបំផុតគឺជីវភាពបច្ចុប្បន្ន ។ គាត់និយាយថា គាត់មិនមានសន្តិភាពនៅក្នុងចិត្តរបស់គាត់ឡើយ ពីព្រោះគាត់នៅក្រីក្រ គាត់មិនអាចមានសន្តិភាពរហូតទាល់តែគាត់ឈប់រស់នៅក្រោមបន្ទាត់ក្រីក្រទៀត ។ ហេតុដូច្នេះ សម្រាប់គាត់ យុត្តិធម៌ ដំណើរការការកាត់ទោស កិច្ចខិតខំប្រឹងប្រែងផ្សះផ្សាជាតិ ហើយនិងសហគមន៍អន្តរជាតិគឺមិនមានការទាក់ទងគ្នាទេ ។

*ម៉ៃយ៉ានេ ៖ អតីតមេដឹកនាំសហគមន៍ និង ជាជនរងគ្រោះនៃរបបខ្មែរក្រហម*

ម៉ៃយ៉ានេ ភេទស្រី អាយុ ៦៥ឆ្នាំ រស់នៅភ្នំពេញ ។ គាត់និងប្តីរបស់គាត់ត្រូវបានគេជម្លៀសពីភ្នំពេញនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ អ្នកទាំងពីរត្រូវបានគេហាមមិនឲ្យយករបស់របរទៅតាមខ្លួនឡើយពីព្រោះខ្មែរក្រហមប្រាប់ថាអ្នកទាំងពីរនឹងត្រឡប់មកវិញក្នុងរយៈពេលបីថ្ងៃ ។

ម៉ៃយ៉ានេ បានតាមដានដំណើរការតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមរយៈទូរទស្សន៍ ប៉ុន្តែគាត់មិនដឹងថាតើដំណើរការកាត់ទោសនោះផ្តល់ផលវិជ្ជមានឬអវិជ្ជមានទេ ។ មុនពេលការកាត់ទោស ប្រជាជនមិនបានផ្តោតសំខាន់ទៅលើខ្មែរក្រហមទេ ប៉ុន្តែឥឡូវការកាត់ទោសបានកើតឡើងហើយ ។ គាត់យល់ថាប្រជាជនកំពុងគិតកាន់តែខ្លាំងទៅលើអំពើប្រល័យពូជសាសន៍ និងអតីតកាល ។ គាត់មិនសូវពេញចិត្តចំពោះដំណើរការយឺតយ៉ាវរបស់តុលាការឡើយ ហើយមានអារម្មណ៍ថា តុលាការមានភាពខុសប្លែកពីអំពើប្រល័យពូជសាសន៍ ដូច្នេះវាមានការលំបាកនឹងយល់ថា យុត្តិធម៌ត្រូវបានគេរកឃើញ ។ ម៉ៃយ៉ានេនិយាយថាការកាត់ទោសកាន់តែមានសារសំខាន់ ប្រសិនបើការកាត់ទោសនោះកើតឡើងភ្លាមៗបន្ទាប់ពីរបបខ្មែរបានដួលរលំ ។ សម្រាប់បច្ចុប្បន្ន គាត់ចង់ឃើញក្មេងជំនាន់ក្រោយទទួលបាននូវការអប់រំពីអំពើប្រល័យពូជសាសន៍ ។ គាត់ចង់ឲ្យឪពុកម្តាយប្រាប់កូនៗអំពីអតីតកាល ៖ «បទពិសោធន៍របស់អ្នកគ្រប់គ្នាគឺមានលក្ខណៈខុសគ្នា» ។ គ្រួសារនីមួយៗគួរតែសរសេរនូវរឿងរ៉ាវរបស់ខ្លួនដើម្បីបង្ហាញចេញមក ។

## *ហ៊ឹម ហ៊ុយ ៖ អតីតប្រធានអង្គភាពពិសេសនៅមន្ទីរស-២១*



ហ៊ឹម ហ៊ុយ ចែកសៀវភៅ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ» ដល់សិស្សវិទ្យាល័យហ៊ុនសែនបាល្ល័ង្ក ក្នុងខេត្តកំពង់ធំ

ហ៊ឹម ហ៊ុយ ភេទប្រុសអាយុ៥៤ ឆ្នាំមកពីភូមិក្បាលជ្រោយ ។ រហូតដល់ឆ្នាំ១៩៧២ គាត់គឺជាសិស្សម្នាក់នៅសាលាក្នុងស្រុកនិងជួយឪពុកម្តាយធ្វើស្រែចម្ការ ។ ក្នុងឆ្នាំ១៩៧២ គាត់ត្រូវបានជ្រើសរើសចូលក្នុងកងទ័ពបដិវត្តន៍ ។ ឆ្នាំ១៩៧៦ គេប្រាប់គាត់ថាគាត់ត្រូវបានគេបញ្ជូនទៅកាន់កងទ័ពជើងទឹក ប៉ុន្តែការពិតគាត់ត្រូវបាននាំយកទៅកាន់មន្ទីរស-២១ជាមួយក្រុមកម្មាភិបាលខ្មែរក្រហមផ្សេងទៀតសោះ ។ គាត់បានស្ថិតនៅមន្ទីរស-២១ អស់រយៈពេលជាច្រើនថ្ងៃ ដោយពេលនោះកងអ្នកទោសត្រូវបានគេបង្កើតឡើង «បន្ទាប់មកទៀតកងជាច្រើនត្រូវបានបង្កើតឡើងដែរ» អ្នកទោសជាច្រើនមកពីកងពល៧០៣ ដែលជាកន្លែងរបស់ខ្ញុំ ហើយសូម្បីតែបុគ្គលិកទួលស្លែងក៏ត្រូវបានចាប់ខ្លួននិងសួរចម្លើយដែរ ។

កងរបស់ ហ៊ឹម ហ៊ុយ ទទួលបន្ទុកបញ្ជូនមនុស្សពីមន្ទីរស-២១ ទៅកាន់វាលពិឃាតជើងឯក ដែលជាកន្លែងអ្នកទាំងនោះត្រូវបានសម្លាប់និងកប់នៅក្នុងរណ្តៅរួម ។ មុនពេលទៅដល់វាលពិឃាតជើងឯក គាត់ទទួលខុសត្រូវកត់ត្រាឈ្មោះ បន្ទាប់មកនាំយកបញ្ជីឈ្មោះទៅឲ្យ សួស ធី នៅឯមន្ទីរស-២១ ។ នៅពេលសួរសំណួរថាតើគាត់ត្រូវទទួលខុសត្រូវអំពីការងាររបស់គាត់ក្រោមរបបខ្មែរក្រហមមានការសោកស្តាយឬអត់ គាត់បានឆ្លើយថា ៖

«ទេខ្ញុំមិនទទួលខុសត្រូវទេ ខ្ញុំមានគម្រោងបះបោរដែរ ។ ខ្ញុំបានធ្វើអ្វីល្អបំផុតដែលខ្ញុំអាចធ្វើបាន ។ នៅពេលដែលគម្រោងបរាជ័យ ក្តីសង្ឃឹមរបស់ខ្ញុំក៏អស់ដែរ ។ អ្នកអាចសួរខ្ញុំបាន «តើខ្ញុំ

មានជម្រើសទេ?» ទេ ខ្ញុំគ្មានជម្រើសទេ នៅក្នុងពេលនោះ ខ្ញុំមានការសោកស្តាយនូវរឿងទាំងអស់ដែលបានកើតឡើង ។ វាតែងតែស្ថិតនៅក្នុងចិត្តនិងគំនិតរបស់ខ្ញុំជានិច្ច វាពិតជាអាក្រក់ណាស់ ។ ខ្ញុំមិនដែលគិតថាខ្ញុំអាចរួចរស់ជីវិតពីរបបនេះទេ» ។

គាត់បញ្ជាក់ដដែលៗថា គាត់និងកម្មាភិបាលខ្មែរក្រហមដទៃទៀតគ្មានជម្រើសទេ គេគ្រាន់តែធ្វើតាមបញ្ជាថ្នាក់លើប៉ុណ្ណោះ ដូច្នេះ អ្នកទាំងនេះមិនគួរទទួលខុសត្រូវនូវអ្វីដែលបានកើតឡើងទេ ។ យោងទៅសម្តីរបស់ ហ៊ីម ហ៊ុយ មានតែ ឌុច ម្នាក់គត់ដែលគួរតែទទួលខុសត្រូវ ហើយមានតែ ឌុច ដែលមានកំហុសចំពោះការប្រព្រឹត្តឧក្រិដ្ឋកម្ម ។ គាត់យល់ស្របថា ក្មេងជំនាន់ក្រោយគួរតែទទួលបានការអប់រំអំពីរបបខ្មែរក្រហម ។ «ខ្ញុំគិតថាវាមានសារសំខាន់ណាស់ ការអប់រំគឺជាវិធីតែមួយ ។ ការមិនទទួលបានការអប់រំនាំទៅដល់ភាពងងឹត ។ ខ្ញុំចង់ឲ្យកូនរបស់ខ្ញុំដឹង ។ នៅពេលសួរថាគាត់ត្រូវការអ្វីចាំបាច់ខ្លះដើម្បីស្វែងរកសន្តិភាពសម្រាប់គាត់ ហ៊ីម ហ៊ុយ ឆ្លើយថា ៖

«វាគឺជាការចងចាំដ៏ឈឺចាប់ចំពោះអ្វីដែលកើតឡើងនៅទួលស្លែង ។ ខ្ញុំចង់ធ្វើអត្តឃាតជាច្រើនដង ប៉ុន្តែខ្ញុំដឹងថាប្រសិនបើខ្ញុំកេះកៃកាំភ្លើងបាញ់ខ្លួនឯង អ្នកទាំងនោះនឹងតាមទៅរកក្រុមគ្រួសាររបស់ខ្ញុំ ហើយសម្លាប់គ្រួសាររបស់ខ្ញុំដែរ ។ ខ្ញុំមិនអាចមានអារម្មណ៍សន្តិភាពទេ រហូតទាល់តែប្រជាជនឈប់សួរសំណួរខ្ញុំ ។ គ្រាន់តែឈប់សួរខ្ញុំ ខ្ញុំនឹងមានអារម្មណ៍សន្តិភាពហើយ» ។

## អំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ដោយត្រូវបានបង្កើតនៅក្នុងឆ្នាំ២០០៣ បន្ទាប់ពីសភាជាតិកម្ពុជាបានអនុម័តច្បាប់សម្រាប់ការបង្កើតអង្គជំនុំជម្រះ (ឆ្នាំ២០០១) អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដើម្បីកាត់ទោសបទឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមពីឆ្នាំ១៩៧៥-១៩៧៩ ។ អង្គជំនុំជម្រះនេះគឺជាតុលាការកូនកាត់ដែលបង្កើតឡើងរួមគ្នាដោយរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ បើទោះបីជាភាគីទាំងពីរសុទ្ធតែមានមានភាពឯករាជ្យរៀងខ្លួនក៏ដោយ ។ តុលាការនេះគឺជាតុលាការចម្រុះដែលចូលរួមដោយរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិដែលនឹងបង្កើតស្តង់ដារអន្តរជាតិ ។ វាមានភាពចម្រូងចម្រាសដ៏រ៉ាំរ៉ៃនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាក់ទងនឹងការបែងចែកថវិកាមិនត្រឹមត្រូវ ហើយអំពើពុករលួយក៏លេចឮឡើង ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានរួមទិដ្ឋភាពយុត្តិធម៌តាមរយៈការកាត់ទោសបែបប្រពៃណីដោយធ្វើការការកាត់និងការដាក់ទោសទៅលើអ្វីដែលបានប្រព្រឹត្តខុស ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក៏កំពុងព្យាយាមបញ្ចូលទិដ្ឋភាពយុត្តិធម៌តាមរយៈផ្សះផ្សាទៅដល់មូលដ្ឋានរបស់ប្រជាជន និងការចូលរួមរបស់ប្រជាជន ។ តាមរយៈកម្មវិធីទាំងអស់នេះ អ្នករស់រានមានជីវិតមកពីទូទាំងប្រទេសត្រូវបានអញ្ជើញមកទស្សនាដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ ។ ឯកសារផ្សព្វផ្សាយរាប់បញ្ចូលទាំងសៀវភៅផ្សព្វផ្សាយព័ត៌មាន ក្រដាសផ្សព្វផ្សាយ ប័ណ្ណប្រកាស អាវយឺត ក្រដាសបិទ ។ល ។ ត្រូវបានចែកចាយទៅតាមខេត្ត ។ ឯកសារទាំងនេះផ្តល់នូវព័ត៌មានអំពីតុលាការនិងដំណើរការកាត់ទោស ហើយវាមានគោលបំណងលើកកម្ពស់ការយល់ដឹងអំពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងជំរុញឲ្យមានការចូលរួមពីសំណាក់ជនរងគ្រោះ ។ អ្នករស់រានមានជីវិតក៏មានអ្នកជួយបំពេញពាក្យបណ្តឹងទៅតុលាការដែរប្រសិនបើគេចង់ ។ បន្ថែមពីលើនេះទៀត ការជជែកគ្នាអំពីព្រឹត្តិការណ៍ ការប្រជុំពិភាក្សាក្នុងភូមិនិងការសម្ភាសជាមួយកម្មវិធីវិទ្យុ ដូចជាសំឡេងវិទ្យុសហរដ្ឋអាមេរិកត្រូវបានបង្កើតឡើងដើម្បីបង្កើនការយល់ដឹងនិងការយកចិត្តទុកដាក់ ។

## តម្រូវការយុត្តិធម៌តាមផ្លូវតុលាការនិងការផ្សះផ្សាសម្រាប់ប្រទេសកម្ពុជា

ខ្លឹមសារទូរទៅមួយបង្ហាញនៅក្នុងបទសម្ភាសបានលើកឡើងខាងលើគឺជាខ្លឹមសារនៃការចែករំលែកបទពិសោធន៍ ។ អ្នកត្រូវបានសម្ភាសស្ទើរតែទាំងអស់ដែលរៀបរាប់នៅខាងលើនិងអ្នកដែលបានរៀបរាប់នៅខាងលើបាននិយាយថា រឿងរ៉ាវស្មុគ្រស្មាញអំពីបទពិសោធន៍របស់ខ្លួនដើម្បីស្វែងរកភាពស្ងប់ចិត្តដោយចងចាំថាខ្លួនមិនមែនជាមនុស្សតែម្នាក់ឯងដែលទទួលនូវការឈឺចាប់បែបនេះទេ អ្នកដទៃជុំវិញពួកគាត់ក៏ទទួលបាននូវការឈឺចាប់ដូចគ្នា ឬផលវិបាកដូចគ្នាដែរ ។ សរុបមក ដូចបានបញ្ជាក់ដោយ ម៉ៃយានេ នៅក្នុងបទសម្ភាសរបស់គាត់ ការចែករំលែកបទ

ពិសោធន៍របស់ខ្លួនជាមួយនឹងអ្នកដទៃគឺជារឿងមួយដ៏សំខាន់ដើម្បីបង្កើតនូវបរិយាកាសមួយដែលនាំមកនៅការកសាងសន្តិភាព ។ មជ្ឈមណ្ឌលឯកសារកម្ពុជាជួយផ្តួចផ្តើមគំនិតក្នុងការបង្កើតកម្មវិធីមួយតាមរយៈការសម្តែងសិល្បៈដែលមានឈ្មោះថា «ទម្លាយភាពស្ងប់ស្ងាត់» ។ ការសម្តែងបង្ហាញពីរឿងរ៉ាវជីវិតខុសគ្នាៗរបស់អ្នករួចរស់រានមានជីវិតពីរបបខ្មែរក្រហមចាប់ពីក្មេងស្រីម្នាក់ត្រូវបានរំលោភដោយកម្មាភិបាលខ្មែរក្រហមរហូតដល់ទាហានវ័យក្មេងបានជ្រើសរើសឲ្យចូលខ្មែរក្រហម រហូតដល់ក្មេងប្រុសម្នាក់ព្យាយាមស្វែងរកកន្លែងកប់សាកសពឪពុករបស់ខ្លួន ។ ការសម្តែងបានបញ្ចូលបទចម្រៀងប្រពៃណីខ្មែរដែលបានបង្ហាញពីរឿងរ៉ាវខុសៗគ្នាជាមួយនឹងសកម្មភាពរបស់តួអង្គ ។ ការសម្តែងត្រូវបានបង្កើតនិងបង្ហាញនៅក្នុងសហគមន៍ក្នុងស្រុក ។ ការសម្តែងគឺជាវិធីមួយជំរុញឲ្យមានការពិភាក្សាអំពីអំពើប្រល័យពូជសាសន៍និងបទពិសោធន៍របស់បុគ្គលម្នាក់ៗ ។ ការសម្តែងនេះធ្វើឲ្យអ្នកទស្សនាក្រឡេកទៅមើលរឿងអតីតកាលរបស់ខ្លួនតាមរយៈរឿងរ៉ាវ តួនាទី និងប្រតិកម្មខុសៗគ្នាចំពោះអតីតកាល ។ ការសម្តែងក៏បានជំរុញដល់អ្នកទស្សនាឲ្យគិតទៅដល់បទពិសោធន៍ផ្ទាល់ខ្លួននិងបទពិសោធន៍ក្រុមគ្រួសារដែរ ។ ការសម្តែងគួរតែត្រូវបានពង្រីកបន្ថែមដោយយកទៅសម្តែងនៅកន្លែងច្រើនជាងនេះ ហើយអាចកែសម្រួលដើម្បីបញ្ចូលតួសម្តែង និងខ្លឹមសារបន្ថែម ។ ការជួយសហគន៍ក្នុងការបង្កើតវេទិកាពិភាក្សាចំហបន្ទាប់ពីការសម្តែងអាចផ្តល់ឱកាសដល់ប្រជាជនឲ្យពិភាក្សាអំពីប្រតិកម្មរបស់ខ្លួន ឬចែករំលែករឿងរ៉ាវផ្ទាល់ខ្លួនជាមួយអ្នកដទៃដែលអាចមានផលល្អជាច្រើន ។

យោងទៅលើសេចក្តីសន្និដ្ឋានរបស់ ស៊ូសាណា លីនតុន ទៅលើការសិក្សាស្រាវជ្រាវដែលដឹកនាំដោយមជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងឆ្នាំ២០០២បានឲ្យដឹងថា «ប្រជាជនកម្ពុជាមានបំណងចង់ធ្វើការផ្សះផ្សាជាមួយខ្មែរក្រហមឬហៅថាបក្សកុម្មុយ-នីស្តកម្ពុជា និងធ្វើដំណើរឆ្ពោះទៅរកអនាគតកាន់តែប្រសើរជាមួយគ្នា ។ ការអត់ឱនទោសគឺពិតជាសំខាន់ណាស់ ហើយវាគឺជាចំណុចដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ» ។ ប៉ុន្តែដូចដែលបានបង្ហាញដោយអ្នកស្រាវជ្រាវឃើញថា ការអត់ឱនទោសមិនមែនជាការបំភ្លេចនូវអ្វីដែលបានកើតឡើងទេ ។ ការអត់ឱនទោសមានន័យថាគឺជាការស្វែងរកដំណោះស្រាយសម្រាប់បទពិសោធន៍ផ្ទាល់ខ្លួនរបស់មនុស្សម្នាក់ «ដោយទុកចោលម្ខាងនូវភាពអវិជ្ជមាននិងអារម្មណ៍បាក់បែក ហើយបន្ទាប់មកធ្វើដំណើរឆ្ពោះទៅរកការរស់នៅប្រកបដោយសុភមង្គល ។ ទស្សនៈនេះហាក់បីដូចជាទទួលការគាំទ្រយ៉ាងទូលំទូលាយពីប្រជាជនកម្ពុជាពីព្រោះវាផ្អែកទៅលើការអប់រំរបស់ព្រះពុទ្ធសាសនា ។ វាពិតជាមានសារសំខាន់ក្នុងការកត់សម្គាល់ថា ខ្លឹមសារនៃការសម្តែងនេះមិនប៉ះពាល់ដល់អារម្មណ៍ខឹងសម្បា ឬភាពស្អប់ខ្ពើមចំពោះខ្មែរក្រហមទេ ។ ទោះបីជាប្រជាជនបានទទួលស្គាល់ការអត់ឱនទោសចំពោះខ្មែរក្រហមក៏ដោយ ក៏បុគ្គលម្នាក់ៗប្រហែលនៅតែមានអារម្មណ៍ខឹងសម្បានឹងខ្មែរក្រហមដដែល ។ ជាងនេះទៅទៀត អ្នករស់រានមានជីវិតអាចអត់ទោសឲ្យខ្មែរក្រហមដែលបានធ្វើបាបខ្លួន ប៉ុន្តែនៅតែមានអាម្មណ៍ខឹងមេដឹកនាំ ឬអំពើហិង្សារបស់ខ្មែរក្រហមដដែល ។ អ្នកដែលទទួលការស្ទាបស្ទង់មតិក៏បានទទួលស្គាល់ថា ការផ្សះផ្សាជាដំណើរការដែលមានច្រើនប្រភេទ ហើយដែលពាក់ព័ន្ធនឹងការផ្សះផ្សាជាបុគ្គល និងកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីរស់នៅក្នុងសុខសន្តិភាព និងដើម្បីធ្វើដំណើរឆ្ពោះទៅរកអនាគត ។ មតិយោបល់និងជំនឿបានបង្ហាញយ៉ាងច្បាស់ដោយអ្នកទទួលការស្ទាបស្ទង់មតិគាំទ្រនិងយុត្តិធម៌តាមការផ្សះផ្សាក្រៅតុលាការ ។ ទោះបីជាយ៉ាងណាក៏ដោយ អ្នកទទួលការស្ទាបស្ទង់មតិភាគច្រើនយល់ស្របថា មនុស្សត្រូវតែទទួលខុសត្រូវចំពោះការប្រព្រឹត្តខុស ហើយមតិភាគច្រើនមានជាប់ពាក់ព័ន្ធនឹងការទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មជាបុគ្គលនៅក្នុងតុលាការ ។

នៅក្នុងការសិក្សាស្រាវជ្រាវដោយសាកលវិទ្យាល័យកាលីហ្វញ៉ាប៊ើកឃ្លី អ្នកឆ្លើយតបត្រូវបានគេសួរថាអ្វីដែលគេត្រូវការចាំបាច់មុនពេលអត់អោនទោសឲ្យមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ក្នុងចំណោមអ្នកបានរស់នៅក្រោមរបបខ្មែរក្រហម ៤១,៨ ភាគរយបាននិយាយថា មេដឹកនាំត្រូវតែដាក់ទោស ចំណែកឯ ២៣,៩ ភាគរយបាននិយាយថា គេមិនអាចអត់ទោសឲ្យមេដឹកនាំខ្មែរក្រហមទេ ។ ១២,៣ភាគរយបាននិយាយថាមេដឹកនាំត្រូវតែសារភាព និងនិយាយការពិត ហើយ៥,៤ភាគរយបាននិយាយថាមេដឹកនាំត្រូវតែនិយាយសុំទោស ។ ក្នុងចំណោម

អ្នកដែលមិនបានរស់នៅក្រោមរបបខ្មែរក្រហម ៣៣,១ ភាគរយ បាននិយាយថាមេដឹកនាំខ្មែរក្រហមត្រូវតែដាក់ទោស ១៩,៩ ភាគរយបាននិយាយថា មេដឹកនាំខ្មែរក្រហមមិនគួរត្រូវបានអត់ឱនទោសឲ្យទេ ១០,៩ភាគរយបាននិយាយថា មេដឹកនាំខ្មែរក្រហមត្រូវតែនិយាយសុំទោស ហើយ១០ភាគរយបាននិយាយថា អ្នកទាំងនោះត្រូវតែសងជំងឺចិត្តដល់អ្នករស់រានមានជីវិត ។ ផ្អែកទៅលើការសិក្សា ប្រជាជនកម្ពុជាទំនងជាចង់ឃើញអតីតមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវនូវអំពីឧក្រិដ្ឋកម្មរបស់ខ្លួនដែលបានប្រព្រឹត្ត ហើយសម្រាប់អ្នកឆ្លើយតបជាច្រើន ការដាក់ទោសត្រូវតែកើតមុនការអត់ឱនទោស ។ មតិឆ្លើយតបភាគច្រើនចង់ឃើញការទទួលខុសត្រូវដែលធ្វើឡើងដោយអ្នកដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ជាពិសេសគឺការសម្លាប់ ការបង្អត់អាហារ ការបង្ខំឲ្យ ធ្វើការហួសកម្លាំង និងការធ្វើទារុណកម្ម ។ អ្នកឆ្លើយតបជាច្រើន (៤៨,៩ ភាគរយ) បាននិយាយថា គេចង់ឃើញអ្នកទាំងអស់នោះទទួលខុសត្រូវនៅពេលកាត់ទោស ២២,៨ភាគរយបាននិយាយថា ចង់ឃើញខ្មែរក្រហមត្រូវបានគេដាក់ទោស ១២,៤ភាគរយចង់ឲ្យមេដឹកនាំខ្មែរក្រហមមិនត្រូវបានដាក់ទោស ហើយ១២ភាគរយចង់ឃើញខ្មែរក្រហមត្រូវបានដាក់ទោសប្រហារជីវិត ។

ផ្អែកទៅលើលទ្ធផលបង្ហាញឲ្យឃើញថាយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពបំផុតក្នុងការស្វែងរកយុត្តិធម៌ និងការផ្សះផ្សាជាតិគឺទាក់ទងទៅនឹងការរួមផ្សំនូវការអនុវត្តយុត្តិធម៌តាមរយៈការផ្សះផ្សាក្រៅតុលាការនិងយុត្តិធម៌តាមរយៈការកាត់ទោសស្របទៅនឹងដំណើរការខិតខំប្រឹងប្រែងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាសព្វថ្ងៃ ។ ទោះបីជាយ៉ាងណាក៏ដោយ វាវិតតែមានផលប្រយោជន៍ក្នុងការពង្រីកកិច្ចខិតខំប្រឹងប្រែងបច្ចុប្បន្នដើម្បីបញ្ចូលការចូលរួមដ៏ច្រើនរបស់ប្រជាជនកម្ពុជា ជាពិសេសអ្នកដែលមិនបានឆ្លងកាត់របបខ្មែរក្រហមចង់ឃើញការដាក់ទោសដែលជាយុត្តិធម៌ ។ ការបង្កើនកម្មវិធីយុត្តិធម៌តាមរយៈការផ្សះផ្សានៅក្រៅតុលាការគឺពិតជាសំខាន់ក្នុងការផ្តល់ដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់ប្រជាជន ។ វាគឺជាការសំខាន់ក្នុងការបង់ចាំថាគ្មានយុទ្ធវិធីណាមួយនឹងធ្វើឲ្យពេញចិត្តសម្រាប់ជនរងគ្រោះទាំងអស់ទេ ។ ហេតុដូច្នេះ ការរួមបញ្ចូលយុទ្ធសាស្ត្រជាច្រើនចូលគ្នាអាចជួយបម្រើនូវតម្រូវការរបស់ជនរងគ្រោះ ។

ហេតុដូច្នេះ បន្ថែមទៅលើតុលាការកូនកាត់ ការជួយសម្របសម្រួលដល់ការពិភាក្សារវាងជនរងគ្រោះ និងជនដៃដល់អាចជំរុញឲ្យមានការផ្សះផ្សាជាតិ និងសន្តិភាព ជាពិសេសសម្រាប់បុគ្គលដែលបង្ហាញពីគោលបំណងចង់ឃើញការសាភាពរបស់ជនដៃដល់ ឬការសុំទោសអំពីតួនាទីរបស់គេ ។ បន្ថែមពីលើនោះទៀត ប្រតិកម្មបែបនេះប្រហែលជាបង្ហាញនូវការយល់ដឹងកាន់តែប្រសើររវាងជនរងគ្រោះនិងជនដៃដល់ ហើយអនុញ្ញាតឲ្យផ្នែកនីមួយៗមានអារម្មណ៍អាណិតអាសូរពីបទពិសោធន៍របស់អ្នកដទៃ ក្នុងករណីដូចគ្នាដែលបុគ្គលម្នាក់គឺជាជនរងគ្រោះផង និងជាជនដៃដល់ផង ។

ទាំង ម៉ៃយ៉ានេ និង ញឹម សុវត្ថិ បានធ្វើការកត់សម្គាល់ការផ្តោតទៅលើអនាគតថាអាចជួយបុគ្គលម្នាក់ និងសហគមន៍ទាំងមូលដើម្បីបង្កើតនូវសន្តិភាពថ្មីមួយ ។ ទិសដៅជារួមមួយអាចបង្រួបបង្រួមអតីតខ្មាំង និងធ្វើឲ្យមនុស្សដែលគិតផ្ទុយគ្នាអាចរួបរួមគ្នា ។ ការរៀបចំកម្មវិធីសហគមន៍ ដូចជាហេដ្ឋារចនាសម្ព័ន្ធរស់ឡើងវិញ ឬការបង្កើតកម្មវិធីសុខមាលភាពឃុំ ឬកសាងវត្តអារាមគឺជាវិធីមួយក្នុងការបង្កើតទិសដៅនោះ ។

ប្រជាជនកម្ពុជាអាចចាប់យកគំនិតនេះដើម្បីបង្កើនការយល់ដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដោយការកត់ត្រាអំពីប្រវត្តិផ្ទាល់ខ្លួន «ដូចជាការលើកឡើងដោយម៉ៃយ៉ានេ» ចូលរួមក្នុងកម្មវិធីឯកសាររស់ជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬ ការរៀបចំបុណ្យហេតុចងចាំសម្រាប់សហគមន៍ ។

នៅក្នុងតំបន់ទេសចរណ៍ដ៏មហិមា ដូចជាខេត្តសៀមរាប ព័ត៌មានអំពីខ្មែរក្រហមត្រូវបានគេដាក់បញ្ចូលក្នុងការដឹកនាំទេសចរណ៍ ។ ឧទាហរណ៍ ដំណើរទេសចរណ៍អាចធ្វើការអប់រំអ្នកទេសចរណ៍អំពីការការពារប្រាសាទអង្គរវត្តក្នុងរបបខ្មែរក្រហម និងការប៉ះទង្គិចអំពើហិង្សានៅជុំវិញតំបន់នោះ ។ ខ្មែរក្រហមបានបង្រៀនគ្រប់ជ្រុងអំពីប្រទេសកម្ពុជា និងអ្នកទេសចរណ៍ ដូច្នេះប្រជាជនកម្ពុជាគួរតែសិក្សាអំពីប្រវត្តិសាស្ត្រដ៏ច្របូកច្របល់នេះដើម្បីផ្តល់សំឡេងទៅដល់អ្នករស់រានមានជីវិត និងបង្កើនការយល់ដឹងដែលជាហេតុធ្វើឲ្យប្រវត្តិសាស្ត្រដ៏គួរឲ្យខ្លើមរអើមនេះនឹងមិនកើតឡើងខ្លួនឯងម្តងទៀត ។ **ឡូរិន ជូសុន**

# ការពិនិត្យនៅលើគំរូយុត្តិធម៌នៅប្រទេសកម្ពុជា ដែលជាប្រទេសក្រោយអំពើប្រល័យពូជសាសន៍

ខ្ញុំបានទៅប្រទេសកម្ពុជាដើម្បីធ្វើការស្រាវជ្រាវអំពីបញ្ហាយុត្តិធម៌នៅប្រទេសនេះដែលជាប្រទេសក្រោយអំពើប្រល័យពូជសាសន៍ ។ ខ្ញុំបានសម្លឹងមើលគំរូយុត្តិធម៌អន្តរកាលនិងរបៀបដែលគំរូនោះអាចនឹងយកមកប្រើប្រាស់នៅក្នុងស្ថានភាពប្រទេសកម្ពុជាបច្ចុប្បន្ន ។ ជាក់ស្តែង ខ្ញុំបាននិយាយជាមួយអតីតសមាជិកខ្មែរក្រហមនិងជនរងគ្រោះនៃរបបនោះ និងចូលរួមក្នុងសវនាការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដែលមានទីតាំងនៅជាយក្រុងភ្នំពេញ ។ បន្ទាប់ពីបានស្តាប់រឿងរ៉ាវរបស់ជនរងគ្រោះនិងជនដៃដល់នៃរបបដ៏ឃោរឃៅ ខ្ញុំយល់ឃើញថាការកាត់ទោសតាមផ្លូវច្បាប់ ការដាក់ទោស ការអភ័យទោស និងការប្រាប់ពីការពិតដែលមិនអាចសងនិងអំពើនៃការធ្វើទារុណកម្ម ការបង្អត់អាហារ ភាពភ័យខ្លាច និងការសម្លាប់ដែលបានត្រូវបានបង្ហាញនៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។


រូបព្រះនារាយណ៍នៅប្រាសាទបន្ទាយឆ្មារ

យោងទៅតាមទស្សនៈ «យុត្តិធម៌» គឺជាភាពមិនលម្អៀង ដូច្នេះវាគឺជាគោលដៅដែលមិនអាចសម្រេចបានបន្ទាប់ពីមានអំពើប្រល័យពូជសាសន៍ ។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាបាននិយាយថា «អ្នកអាចគិតទៅដល់ការដាក់ទោសដ៏ធ្ងន់បំផុតនៅក្នុងពិភពលោក ប៉ុន្តែវាអាចមិនអាចស្មើគ្នាបានទេ» ។ វានឹងមិនមែនជា «យុត្តិធម៌» ទេ ។ «យុត្តិធម៌» តាមទម្រង់មនោគមន៍វិជ្ជាខ្ពស់នឹងមិនអាចសម្រេចទៅបានទេ ។ ទោះបីជាយ៉ាងនេះក្តី «គំរូយុត្តិធម៌» អាចត្រូវបានយកមកស្រដៀងនឹង «យុត្តិធម៌» ហើយអាចជួយសម្រួលដល់ការផ្សះផ្សា ។ ខ្ញុំស្នើថាការរួមបញ្ចូលគ្នានៃគំរូយុត្តិធម៌តាមរយៈការផ្សះផ្សានិងការយកមកដាក់ទោស និងកម្មវិធីសង្គមដែលមានការរៀបចំល្អអាចត្រូវបានយកមកប្រើដើម្បីសម្រេចឲ្យបាននូវការផ្សះផ្សានៅកម្ពុជាតាមកម្រិតថ្នាក់ឃុំ អន្តរជាតិ ជាតិ និង ជាបុគ្គល ។ ខ្ញុំនឹងវិភាគទៅលើភាពខ្លាំងនិងខ្សោយនៃគំរូទាំងពីរ និងកម្មវិធីសង្គម ព្រមទាំងវិភាគថា វិធីសាស្ត្រនីមួយៗនេះនឹងត្រូវយកមកអនុវត្តនៅកម្ពុជាដោយរបៀបណា ហើយថាតើវិធីសាស្ត្រនីមួយៗនេះអាចជួយជំរុញឲ្យមានការផ្សះផ្សានិងត្រឡប់ទៅរកភាពដូចដើមដោយរបៀបណា ។

**យុត្តិធម៌តាមរយៈការកាត់ទោស ៖ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

គំរូយុត្តិធម៌តាមរយៈការកាត់ទោសត្រូវបានគាំទ្រថាមានប្រសិទ្ធភាព ហើយតម្រូវឲ្យមានគំរូសម្រាប់កាត់ទោសឧក្រិដ្ឋកម្មនិងសម្រាប់ផ្តល់យុត្តិធម៌ ។ គំរូយុត្តិធម៌តាមរយៈការកាត់ទោសតម្រូវឲ្យមានការទទួលខុសត្រូវទៅលើឧក្រិដ្ឋកម្មតាមផ្លូវច្បាប់ ហើយរដ្ឋាភិបាលគួរតែទទួលខុសត្រូវនិងដាក់ទោសអ្នកប្រព្រឹត្តខុស ។ អង្គការសហប្រជាជាតិតម្រូវមានការប្រើប្រាស់គំរូយុត្តិធម៌តាមរយៈការកាត់ទោសនៅក្នុងករណីដែលមានច្បាប់អន្តរជាតិ ប៉ុន្តែនៅតែមានការរំលោភបំពានទៅលើច្បាប់សិទ្ធិមនុស្ស ។ ប្រទេសកម្ពុជាក៏បានរំលោភបំពានទៅលើច្បាប់សិទ្ធិមនុស្សដែរ ។ អង្គការសហប្រជាជាតិបានធ្វើការជាមួយរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចនាយករដ្ឋមន្ត្រី (ហ៊ុន សែន) ដើម្បីបង្កើត «តុលាការចម្រុះ» មួយដែលមានឈ្មោះថាអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោស

ឧក្រិដ្ឋកម្មខ្មែរក្រហម ។ អង្គជំនុំជម្រះត្រូវបានតាក់តែងឡើង ដើម្បី «ដាក់ឲ្យមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋកម្មសង្គ្រាម និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាក្រុងហ្សឺណែវ» និងដើម្បីដាក់ទោសអ្នកដែលត្រូវបានសម្រេចថាឲ្យជាប់ពន្ធនាគារអស់មួយជីវិតដែលជាទោសធ្ងន់បំផុត និងជាប់ពន្ធនាគារ៥ឆ្នាំដែលជាទោសស្រាលបំផុត ។ ដើម្បីសម្រេចគោលបំណងនេះ អង្គជំនុំជម្រះបានបង្កើតគណៈកម្មការស៊ើបអង្កេត ក្រុមធ្វើការចោទប្រកាន់និងក្រុមការពារក្តីដែលនឹងធ្វើការតទល់គ្នានៅមុខក្រុមមួយដែលមានចៅក្រមកម្ពុជាកម្ពុជា៣រូបនិងចៅក្រមអន្តរជាតិ២រូប ។ សវនាការបានចាប់ផ្តើមនៅខែមីនា ឆ្នាំ២០០៩ ។

ភាពខ្លាំងរបស់អង្គជំនុំជម្រះកើតឡើងដោយសារមានការសហប្រតិបត្តិការនិងការចូលរួមដោយអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជា ។ ប្រទេសកម្ពុជាខ្វះខាតវិធានច្បាប់ ដូច្នេះតួនាទីរបស់អង្គការសហប្រជាជាតិត្រូវធានាថា អង្គជំនុំជម្រះអនុវត្តទៅតាមបទដ្ឋានច្បាប់អន្តរជាតិទាក់ទងនឹងដំណើរការសិទ្ធិមនុស្សប្តូព្រហ្មទណ្ឌ ។ វាមានសារសំខាន់ថា អង្គជំនុំជម្រះអាចអនុវត្តទៅតាមបទដ្ឋាននេះ ទើបសហគមន៍អន្តរជាតិអាចទទួលស្គាល់ថាសាលក្រមរបស់អង្គជំនុំជម្រះមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។ សហគមន៍អន្តរជាតិជាបង្គោលដែលអាចនាំមកនូវដំណើរការដ៏ជោគជ័យ ពីព្រោះអង្គជំនុំជម្រះដែលជឿថាមានតម្លាភាព និងយុត្តិធម៌នឹងបង្កើតជាគំរូដល់អន្តរជាតិសម្រាប់បង្កើតតុលាការអន្តរជាតិនាំយកជនត្រូវចោទមកកាត់ទោស ស្វែងរកការពិតតាមរយៈដំណើរការជំនុំជម្រះ អនុវត្តតាមច្បាប់អន្តរជាតិ និងដាក់ទោសអ្នកដែលរំលោភបំពានច្បាប់ ។ នៅពេលជាមួយគ្នា ការចូលរួមរបស់រដ្ឋាភិបាលកម្ពុជាមានសារសំខាន់ក្នុងការផ្តល់សិទ្ធិដល់កម្ពុជាគ្រប់គ្រងទៅលើដំណើរការអង្គជំនុំជម្រះ ។ ប្រទេសកម្ពុជាធ្លាប់មានប្រវត្តិសាស្ត្រដែលស្ថិតនៅក្រោមអំណាចរបស់បរទេស ហើយការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិទៅលើដំណើរការអង្គជំនុំជម្រះអាចត្រូវបានចាត់ទុកថាជាការប៉ុនប៉ងរំលោភទៅលើអធិបតេយ្យភាពរបស់កម្ពុជា ។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះនឹងបម្រើគោលបំណងផ្តល់យុត្តិធម៌ដល់ប្រជាជនកម្ពុជាប្រសិនបើវាត្រូវបានបង្កើតឡើងនៅកម្ពុជាមានការចូលរួមដោយរដ្ឋាភិបាលកម្ពុជានិងប្រជាជន មិនមែនបង្កើតនៅប្រទេសផ្សេងដូចជាតុលាការអន្តរជាតិផ្សេងទៀតដែលសម្រាប់កាត់ទោសអំពើប្រល័យពូជសាសន៍ឡើយ ។

កត្តាផ្សេងទៀតដែលអាចនឹងកើតមាន ប៉ុន្តែមានផលប្រយោជន៍ពីកិច្ចសហប្រតិបត្តិការចូលរួមរវាងអង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាគឺជាការពង្រឹងវិធានច្បាប់នៅកម្ពុជា និងបន្ថយ «វប្បធម៌នៃការមិនដាក់ទោស» របស់កម្ពុជា ។ រដ្ឋាភិ-បាលកម្ពុជាអាចសិក្សាពីដំណើរការកាត់ក្តីរបស់អង្គជំនុំជម្រះដែលផ្តល់សវនាការដ៏យុត្តិធម៌ដល់ជនត្រូវចោទ ចៅក្រម មេធាវី សាក្សី អ្នកជំនាញ និងភ័ស្តុតាងបន្ទាប់ពីចេញសាលក្រម ។ បទពិសោធន៍ដ៏មានតម្លៃនេះអាចអភិវឌ្ឍប្រព័ន្ធតុលាការក្នុងស្រុកដែលតែងតែកើតមានអំពើពុករលួយ ការមិនគោរពច្បាប់ ភាពមិនស៊ីសង្វាក់គ្នា និងអ្វីដែលមិនអាចស្មានទុកមុននៅកម្ពុជា ។ អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិ លោក កូហ្វី អាណាន់ អះអាងថា «អង្គជំនុំជម្រះនឹងបន្សល់ទុកនូវកេរដំណែលដ៏វិជ្ជមានសម្រាប់កិច្ចខំប្រឹងប្រែងបន្តបន្ទាប់គ្នាដើម្បីពង្រឹងវិធានច្បាប់ ។ ជាសង្ខេប អង្គជំនុំជម្រះគឺជាការអភិវឌ្ឍជាវិជ្ជមានមួយសម្រាប់សហគមន៍អន្តរជាតិ និងកម្ពុជា ពីព្រោះនៅពេលជាមួយគ្នានឹងបង្កើតប្រព័ន្ធគំរូមួយសម្រាប់ស្វែងរកយុត្តិធម៌និងអភិវឌ្ឍន៍វិធានច្បាប់នៅកម្ពុជា ។ តុលាការដែលមាននីតិវិធីស៊ីសង្វាក់គ្នានិងយុត្តិធម៌គឺជាជំហានដំបូងសម្រាប់សម្រេចនូវការផ្សះផ្សាជាតិនិងអន្តរជាតិ ។

ទោះបីជាអង្គជំនុំជម្រះអាចសម្រេចបាននូវការផ្សះផ្សាជាបុគ្គលនិងថ្នាក់ឃុំក៏ដោយ ក៏វាហាក់ដូចជាមិនទាន់ល្អគ្រប់គ្រាន់ដែរ ។ សារព័ត៌មានក្នុងស្រុកនិងអន្តរជាតិមិនបានផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងអង្គសវនាការទៅដល់គ្រប់តំបន់នៃប្រទេសកម្ពុជាឡើយ ជាពិសេសនៅតំបន់ដាច់ស្រយាល ។ នៅពេលដែលខ្ញុំនិយាយជាមួយប្រជាជននៅខេត្តផ្សេងគ្នា ភាគច្រើននៃអ្នកទាំងនោះមិនបានដឹងពីការកាត់ទោសដែលការពិតអង្គជំនុំជម្រះត្រូវបានបង្កើតឡើងរួចទៅហើយនោះទេ ។ ការសិក្សាមួយដែលដឹកនាំដោយសាកលវិទ្យាល័យកាលីហ្វញ៉ាប៊ែឃ្លី បានឆ្លុះបញ្ចាំងពីបទពិសោធន៍របស់ខ្ញុំ ដោយផ្តល់របាយការណ៍ថា ៨៥ភាគរយនៃ

ប្រជាជនកម្ពុជាដែលត្រូវបានសម្ភាសន៍មិនដឹង ឬដឹងពីអង្គជំនុំជម្រះបន្តិចបន្តួច ។ ជាងនេះទៅទៀត ប្រជាជនកម្ពុជាជាច្រើន ជាពិសេសអ្នកដែលរស់នៅតំបន់ដាច់ស្រយាលមិនដឹងពីការអនុវត្តនិងច្បាប់ប្រពៃណីរបស់ប្រទេសលោកខាងលិចទេ ។ ជាឧទាហរណ៍ អ្នកដែលត្រូវបានខ្ញុំសម្ភាសន៍ម្នាក់ឈ្មោះ កុង សួ អតីតព្រះសង្ឃនៅខេត្តដែលមានទីតាំងនៅភូមិភាគបូព៌ា មិនយល់ស្របនឹងគោលការណ៍របស់មេធាវីការពារក្តីឲ្យមេដឹកនាំខ្មែរក្រហមទេពីព្រោះលោកបានដឹងហើយថា អ្នកទាំងនោះមានទោស ។ គោលការណ៍សិទ្ធិរបស់ជនត្រូវចោទដែលត្រូវចាត់ទុកថា ជនត្រូវចោទគ្មានទោសដរាបណាពិរុទ្ធភាពរបស់គេមិនទាន់ត្រូវបានរកឃើញ មិនមែនជាផ្នែកណាមួយដែលធ្លាប់មាននៅក្នុងប្រព័ន្ធតុលាការកម្ពុជាឡើយ ។ ប្រជាជនកម្ពុជាភាគច្រើនមិនមានការជឿទុកចិត្តទៅលើប្រព័ន្ធតុលាការនៅកម្ពុជា ដោយសារតែការគ្រប់គ្រងដែលមិនមានសមត្ថភាព ច្បាប់មានភាពច្របូកច្របល់ ធនធានមិនគ្រប់គ្រាន់ និងអំពើពុករលួយ ។ ការសិក្សារបស់ ប៉ែឃ្លី បង្ហាញឲ្យឃើញថា ៦២ភាគរយនៃប្រជាជនកម្ពុជាដែលត្រូវបានសម្ភាសន៍ជឿទៅតុលាការថាជាការបង់សំណូកទៅឲ្យចៅក្រម ។ នៅក្នុងបទសម្ភាសន៍ជាមួយ នូ ឆាយ អ្នកនៅរស់ពីរបបខ្មែរក្រហមមកពីខេត្តកណ្តាលយល់ឃើញថា អំពើពុករលួយគឺជាបញ្ហាធំបំផុតដែលកើតឡើងនៅប្រទេសកម្ពុជា ។ ដោយសារប្រជាជនកម្ពុជាភាគច្រើនដឹងពីអង្គជំនុំជម្រះតែបន្តិចបន្តួច នោះជាធម្មតាការយល់ដឹងមានកំណត់ចំពោះដំណើរការអង្គជំនុំជម្រះនិងមិនសូវជឿទៅលើប្រព័ន្ធតុលាការ ។ អង្គជំនុំជម្រះនិងយុត្តិធម៌តាមរយៈការកាត់ទោសមិនទំនងជាអាចផ្សះផ្សាបុគ្គលនិងសហគមន៍បានទេ ។

ការពន្យារពេលកាត់ក្តី៣០ឆ្នាំ នៅអង្គជំនុំជម្រះបានប៉ះពាល់ដល់ដំណើរការផ្សះផ្សានិងយុត្តិធម៌ ។ ការពន្យារពេលសវនាការអាចបង្កឲ្យមានចលាចលក្នុងស្រុកដែលកើតឡើងបន្ទាប់ពីការដួលរលំនៃរបបខ្មែរក្រហមនិងបង្កឲ្យមានសង្គ្រាមត្រជាក់ ។ ទោះបីជារបបខ្មែរក្រហមបានបញ្ចប់នៅឆ្នាំ១៩៧៩ ដោយសារតែការចូលមកដល់របស់វៀតណាមក៏ដោយ ក៏ចលាចលក្នុងស្រុកដែលមានជាបន្តបន្ទាប់រហូតដល់ឆ្នាំ១៩៩៨ បានរាំងស្ទះដល់ដំណើរការកាត់ទោសដ៏យុត្តិធម៌និងសេរីត្រឹមត្រូវដែរ ។ ប្រហែលជាសង្គ្រាមត្រជាក់ (សហរដ្ឋអាមេរិកនិងចិនដែលជាសត្រូវរបស់វៀតណាមគាំទ្រខ្មែរក្រហមជារដ្ឋាភិបាលស្របច្បាប់នៃប្រទេសកម្ពុជា) ដែលធ្វើឲ្យអន្តរជាតិខកខានមិនបានកាត់ទោសខ្មែរក្រហម ។ នៅពេលពន្យារពេល៣០ឆ្នាំ ពេលវេលាបានជះឥទ្ធិពលដល់ការចងចាំ ទីតាំង សុខភាព និងទស្សនៈចំពោះរបបខ្មែរក្រហម ។ មេដឹកនាំសំខាន់ៗជាច្រើនបានស្លាប់រួមទាំង ប៉ុល ពត ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះអំពើសាហាវឃោរឃៅរបស់ខ្មែរក្រហមផង ។ ហ្វូស្រ្តប និង ចាវីស បានអះអាងថា «ដំណើរឆ្ពោះទៅមុខយឺតៗនិងការមិនឆ្ពោះទៅមុខបានធ្វើឲ្យមានភាពចុះខ្សោយ.... ការជំរុញឲ្យមានការផ្សព្វផ្សាយព័ត៌មានអាស្រូវបង្កឲ្យមានការបាត់បង់ការជឿទុកចិត្តទៅលើដំណើរការអង្គជំនុំជម្រះ» ។

ការពន្យារពេល៣០ឆ្នាំមានន័យថា ប្រជាជនកម្ពុជាភាគច្រើននៅពេលបច្ចុប្បន្នមិនបានកើតនៅក្នុងអំឡុងពេលដែលមានអំពើសាហាវឃោរឃៅកើតមាននៅក្នុងប្រទេសឡើយ ។ ទោះបីជា៨៥ភាគរយនៃប្រជាជនកម្ពុជា ក្មេងៗដែលបានផ្តល់ការស្ទង់មតិនៅក្នុងការសិក្សារបស់ ប៉ែឃ្លី បាននិយាយថា គេចង់រៀនសូត្របន្ថែមអំពីប្រវត្តិសាស្រ្តរបស់ប្រទេស ប៉ុន្តែភាគច្រើននៃអ្នកទាំងនោះបែរជាយកចិត្តទុកដាក់ទៅលើការធ្វើឲ្យជីវិតរបស់គេប្រសើរឡើង (ការថែទាំសុខភាព និង ចំណីអាហារ) ការពង្រឹងសេដ្ឋកិច្ចនិងការកសាងហេដ្ឋារចនាសម្ព័ន្ធទៅវិញ ។ មានតែ២ភាគរយនៃអ្នកទាំងនោះឆ្លើយថា ការនាំយកខ្មែរក្រហមទៅប្រឈមមុខនឹងយុត្តិធម៌គឺជាអត្ថិភាពចម្បង ។ ប្រជាជនចាស់ៗដែលនៅរស់ពីរបបខ្មែរក្រហមប្រហែលជាមិនដែលគិតទៅដល់ការស្វែងរកយុត្តិធម៌តាមផ្លូវច្បាប់ទេ អ្នកទាំងនេះសឹងតែមិនដែលរំពឹងថាចង់បានតុលាការដែលមានលក្ខណៈផ្លូវការបែបនេះឡើយ ។ ការពន្យារពេលកាត់ក្តីដ៏យូរធ្វើឲ្យប្រជាជនមានអារម្មណ៍ថាមិនមានយុត្តិធម៌នៅកម្ពុជាទៅហើយ ។ គួង សួ បាននិយាយថា បើការកាត់ក្តីកាន់តែពន្យារពេលការកាត់ក្តីនោះកាន់តែមិនសូវមានអត្ថន័យទេ ពីព្រោះថាជនរងគ្រោះកាន់តែមានវ័យចំណាស់ ឬស្លាប់ ដូច្នេះគេប្រហែលជាមិនអាចមានជីវិតនៅចាំមើលការផ្តល់យុត្តិធម៌ដោយអង្គជំនុំជម្រះឡើយ ។ ឥរិយាបថខុសគ្នារវាងមនុស្សចាស់និងក្មេងបង្ហាញឲ្យឃើញថា ប្រជាជនកម្ពុជាភាគច្រើន

មិនសូវមានការចាប់អារម្មណ៍ឬមិនសូវសង្ឃឹមថា សវនាការជំនុំជម្រះនឹងផ្តល់យុត្តិធម៌ដល់ជនរងគ្រោះ ។ លោក លីន ថុន បាន អះអាងថា «ប្រជាជនកម្ពុជាចង់ធ្វើដំណើរឆ្ពោះទៅមុខជាមួយគ្នា ដើម្បីអនាគត ។ រឿងនេះហាក់ដូចជាមិនមែនជារឿងផ្ទាល់ខ្លួនរវាងជនរងគ្រោះនិងជនដៃដល់ទៀតឡើយ ប៉ុន្តែការធ្វើនេះគឺដើម្បីអនាគតអ្នកទាំងអស់គ្នា» ។ ទោះបីជាកិច្ចការរបស់អង្គជំនុំជម្រះមានដែនកំណត់ក៏ដោយ ក៏អង្គជំនុំជម្រះគួរតែបង្កើតគំរូយុត្តិធម៌តាមរយៈការកាត់ទោសដែរដូចជា : ◆ ទទួលស្គាល់ទុក្ខវេទនាការឈឺចាប់ និងការបាត់បង់របស់ជនរងគ្រោះនៅក្នុងស្រុកនិងអន្តរជាតិ ◆ ទទួលស្គាល់ភាពស្មុគ្រស្មាញនៃតួនាទីរបស់ជនដៃដល់ ◆ បង្កើត និងជំរុញឲ្យមានការពិភាក្សាជាលក្ខណៈជាតិនិងអន្តរជាតិទៅលើបញ្ហារំលោភសិទ្ធិមនុស្ស និងអំពើប្រល័យពូជសាសន៍ ◆ បញ្ជូនការព្រមានដល់អ្នកដែលបានរំលោភទៅលើសិទ្ធិមនុស្សឬអ្នកដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ◆ បង្កើតការកត់ត្រាប្រវត្តិសាស្ត្រពិតទាក់ទងនឹងរបបខ្មែរក្រហម ◆ បង្រៀនក្មេងៗបច្ចុប្បន្ន និងជំនាន់ក្រោយអំពីការគោរពនីតិវិធី និងច្បាប់អន្តរជាតិ ជាពិសេសទាក់ទងនឹងមូលដ្ឋានគ្រឹះនៃមនុស្សធម៌និងសីលធម៌ ។

សហគមន៍អន្តរជាតិនិងភាគច្រើននៃសហគមន៍កម្ពុជាគាំទ្រជាខ្លាំងនឹងការងារអង្គជំនុំជម្រះក្នុងការស្វែងរកការពិត និងការដាក់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ ការស្ទង់មតិមួយចំនួននៅពេលថ្មីៗនេះបង្ហាញឲ្យឃើញថា ៧៥ ទៅ៨៥ ភាគរយនៃអ្នកដែលបានចូលរួមក្នុងការស្ទង់មតិគាំទ្រការកាត់ទោសមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមរបស់អង្គជំនុំជម្រះ ។ អ្វីគួរឲ្យភ្ញាក់ផ្អើលគឺអ្នកភូមិដែលខ្ញុំបានសម្ភាសន៍ជាទូទៅតែងតែមិនគាំទ្រឲ្យកាត់ទោសជនដៃដល់ ដែលជាកម្មាភិបាលថ្នាក់ទាបនិងកណ្តាលដែលជាអ្នកជិតខាងរបស់ខ្លួន ។ ប្រជាជនដែលកាន់ព្រះពុទ្ធសាសនាជឿទៅលើកម្មពៀរជាជាងអង្គជំនុំជម្រះ ជាងនេះទៅទៀត គេជឿថាអង្គជំនុំជម្រះមិនសូវជាមានការជាប់ពាក់ព័ន្ធនឹងប្រជាជនតាមតំបន់ទេ ។

ថ្មីៗនេះ មានការចោទប្រកាន់ពីអំពើពុករលួយនៅអង្គជំនុំជម្រះ ។ ការចោទប្រកាន់ទាំងនេះ (ប្រសិនបើវាជាការពិត) អាចប៉ះពាល់ដល់ការសម្រេចបាននូវយុត្តិធម៌និងការផ្សះផ្សានៅគ្រប់កម្រិត ជាពិសេសកម្រិតជាតិនិងអន្តរជាតិ ។ ប្រសិនបើអង្គជំនុំជម្រះត្រូវបានគេរកឃើញថា មានអំពើពុករលួយ សហគមន៍កម្ពុជានិងអន្តរជាតិនឹងមិនទទួលស្គាល់សវនាការជំនុំជម្រះនិងសាលក្រមដោយស្របច្បាប់ឡើយ ។ ការបាត់បង់ភាពជឿជាក់ទៅលើអង្គជំនុំជម្រះអាចបញ្ជាក់ថា យុត្តិធម៌នៅកម្រិតអន្តរជាតិនឹងមិនអាចសម្រេចបានទេ ពីព្រោះមិនមាន «ប៉ូលិសពិភពលោក» ឬ «មេដឹកនាំជាន់ខ្ពស់» ដើម្បីធានាថាអ្នកចូលរួមទាំងអស់ (ឬនៅក្នុងករណីខ្លះនៅលើពិភពលោក) ធ្វើការជាមួយអ្នកដែលមានជំនាញខ្ពស់ ។ ការខកខានមិនបានសម្រេចបាននូវតុលាការដែលមិនរងឥទ្ធិពលអាចបង្អាក់ដល់ការអនុវត្តរបស់តុលាការចម្រុះនៅថ្ងៃអនាគត ។ ជាងនេះទៅទៀត អំពើពុករលួយរបស់អង្គជំនុំជម្រះនឹងប៉ះពាល់ដល់លទ្ធភាពនៃការបង្កើតវិធានច្បាប់របស់កម្ពុជា ។ អង្គជំនុំជម្រះនឹងមិនអាចបន្សល់ទុកនូវកេរដំណែលដូចដែលលោក កូហ្វី អាណាន់ បានសង្ឃឹមទេ ។ ការចោទប្រកាន់អំពើពុករលួយទាំងនេះទំនងជាអាចក្លាយជាការពិត ហើយវាហួសពីទំហំនៃការស្រាវជ្រាវរបស់ខ្ញុំ (ការចោទប្រកាន់ហាក់ដូចជាថ្មីៗ ហើយមិនទាន់មានការស៊ើបអង្កេតច្បាស់លាស់ទៅលើការចោទប្រកាន់នៅឡើយទេ) ។ ទោះបីជាយ៉ាងណាក៏ដោយ ការចោទប្រកាន់អំពើពុករលួយគឺជាហេតុផលសំខាន់ផ្សេងទៀត ដែលថាការផ្សះផ្សារបស់កម្ពុជាមិនគួរពឹងផ្អែកទាំងស្រុងទៅលើអង្គជំនុំជម្រះនិងគំរូយុត្តិធម៌តាមរយៈការកាត់ទោសឡើយ ។

## យុត្តិធម៌តាមរយៈការផ្សះផ្សា ៖ ការទទួលស្គាល់និងការអភ័យទោសដល់ឧក្រិដ្ឋកម្ម

គំរូយុត្តិធម៌តាមរយៈការផ្សះផ្សាអាចត្រូវបានយកមកប្រើដើម្បីបន្ថែមទៅលើគំរូយុត្តិធម៌តាមរយៈការកាត់ទោសដើម្បីពង្រឹងភាពខ្សោយនៃគំរូយុត្តិធម៌តាមរយៈការកាត់ទោសនៅកម្រិតថ្នាក់ឃុំ និង ជាបុគ្គល ។ គំរូយុត្តិធម៌តាមរយៈការផ្សះផ្សាតែងតែមានការរួមបញ្ចូលដោយការទទួលស្គាល់ឧក្រិដ្ឋកម្មនិងការអភ័យទោសដល់ឧក្រិដ្ឋកម្មដែលអាចជួយសម្របសម្រួលការផ្សះផ្សាក្នុងស្រុក ។ អេមស្ទូត្យ បានអះអាងពាក្យថា «ការផ្សះផ្សា» គឺជា «ការតំណាងឲ្យការចាប់ផ្តើមនៃមិត្តភាព និងការបង្កើតសហគមន៍សាជាថ្មី» ។ ខ្មែរក្រហមបានបំផ្លាញចំណងគ្រួសារមិត្តភាពនិងសហគមន៍ដោយផ្លាស់ប្តូរចំណងនេះទៅជាការស្តាប់

បន្ទាប់និងការស្មោះត្រង់ «អង្គការ» ។ សក្ខីកម្មរបស់អ្នកនៅរស់បង្ហាញថា ការមិនគោរពបញ្ជារបស់ខ្មែរក្រហមបន្តឲ្យមានការធ្វើទារុណកម្ម ការបង្អត់អាហារ និងការសម្លាប់ ។ ដោយហេតុផលនេះ ការកាត់ទោសតាមផ្លូវច្បាប់និងការដាក់ទណ្ឌកម្មអ្នកដែលធ្វើតាមបញ្ជាខ្មែរក្រហមអាចប៉ះពាល់ដល់ដំណើរការផ្សះផ្សាពីព្រោះវាអាចប៉ះពាល់ដល់គ្រួសារនិងសង្គម ។ ការចាប់ខ្លួន «ជនដៃដល់» ទាំងអស់គឺជាការបំបែកគ្រួសារដោយទុកឲ្យប្រពន្ធរស់នៅមិនមានប្ដី កូនរស់នៅមិនមានឪពុកម្ដាយជាដើម ។ ដោយសារតែគំរូយុត្តិធម៌តាមរយៈការកាត់ទោសមានសារសំខាន់ក្នុងការសម្រេចនូវការផ្សះផ្សាជាបុគ្គលគ្រួសារ និងសហគមន៍ ។

រដ្ឋាភិបាលកម្ពុជាបានសម្រេចអនុវត្តតាមគំរូយុត្តិធម៌តាមរយៈការផ្សះផ្សាដោយដាក់ទោសខ្មែរក្រហមទាំងអស់ (ទទួលស្គាល់ឧក្រិដ្ឋកម្ម) និងសម្រេចអភ័យទោសជនដៃដល់ដែលជាកម្មាភិបាលថ្នាក់កណ្ដាលនិងថ្នាក់ទាប ។ នៅក្នុងរបាយការណ៍ដែលបានបោះពុម្ពផ្សាយ សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទទួលស្គាល់ទោសកំហុសរបស់ខ្មែរក្រហមដែលបានសម្លាប់ប្រជាជនកម្ពុជា៣លាននាក់ នៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ សម្ដេចក៏បានប្រកាសថា «ឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមធ្វើឡើងមិនត្រឹមតែប្រឆាំងប្រជាជនកម្ពុជាប៉ុណ្ណោះទេ ប៉ុន្តែវាប្រឆាំងនឹងមនុស្សជាតិ» ហើយលោកបានសន្យាថានឹង «បង្កើតវប្បធម៌ដែលអាចការពារមិនឲ្យឧក្រិដ្ឋកម្មបែបនេះកើតមានម្ដងទៀត» ។ ការទទួលស្គាល់និងការដាក់ទោសរបបខ្មែរក្រហមរបស់សម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន មានសារសំខាន់ក្នុងការទទួលស្គាល់ទុក្ខវេទនា ការឈឺចាប់ និងការបាត់បង់គ្រួសាររបស់ជនរងគ្រោះ និងធានាចំពោះមុខប្រជាជនកម្ពុជាថា «នឹងមិនឲ្យកើតឡើងម្ដងទៀត» ។ សមាជិកជាច្រើនរបស់រដ្ឋាភិបាលកម្ពុជារួមទាំងសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ខ្លួនឯងផ្ទាល់ក៏ជាសមាជិកខ្មែរក្រហមដែរ (ដោយជ្រើសរើសឬដោយបង្ខំ) ។ អាស្រ័យហេតុនេះវាមានសារសំខាន់ដែលថាអ្នកទាំងនេះឈប់មានភាពស្មោះត្រង់ចំពោះរបបខ្មែរក្រហម ហើយមិនត្រឹមតែផ្ដន្ទាទោសសកម្មភាពនោះថាជាអំពើឧក្រិដ្ឋកម្មប៉ុណ្ណោះ តែថែមទាំងផ្ដន្ទាទោសវាថាជាអំពើអសីលធម៌តាមរយៈសេចក្ដីថ្លែងការណ៍ ដូចជាសេចក្ដីថ្លែងការណ៍មួយដែលធ្វើឡើងដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ។



ប្រាសាទព្រះវិហារ

ផ្នែកទីពីរនៃគំរូយុត្តិធម៌តាមរយៈការផ្សះផ្សាដែលធ្វើឡើងដោយរដ្ឋាភិបាលកម្ពុជាគឺការអភ័យទោសឲ្យជនដៃដល់ដែលជាកម្មាភិបាលថ្នាក់កណ្ដាល និងថ្នាក់ទាប ។ អត្ថបទបោះពុម្ពផ្សាយរបស់អង្គជំនុំជម្រះបានអះអាងថា «រដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានសម្រេចថាអង្គជំនុំជម្រះគួរតែកំណត់នូវមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរ» ។ ដោយធ្វើការអត់ទោសដល់ជនដៃដល់ថ្នាក់ទាបនិងថ្នាក់កណ្ដាល និងផ្ដោតទៅលើការកាត់ទោសមេដឹកនាំជាន់ខ្ពស់ រដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិបានចៀសវាងការលំបាកក្នុងការបែងចែកអ្នកណាជាជនរងគ្រោះ អ្នកណាជាជនដៃដល់ ខណៈពេលដែល «ជនដៃដល់» ជាច្រើននាក់ក៏ជាជនរងគ្រោះដែរ ។ ខ្ញុំក៏មានការលំបាកក្នុងការសម្គាល់ជនរងគ្រោះនិងជនដៃដល់នៅក្នុងបទសម្ភាសន៍ជាមួយអតីតអ្នកយាមមន្ទីរស-២១ គៀវ ពៅ ដែរ ។ គៀវ ពៅ បានរៀបរាប់ថា នៅពេលដែលគាត់មានអាយុ១២ឆ្នាំ ខ្មែរក្រហមបានយកគាត់ទៅធ្វើជាកូនទាហានមុនពេលបញ្ជូនគាត់ទៅមន្ទីរសន្តិសុខស-២១ នៅអាយុ១៥ឆ្នាំ ។ វីនីស៊ីអាណូ បាននិយាយថា «ក្មេងៗកម្ពុជាត្រូវបានបណ្ដុះបណ្ដាលឲ្យអនុវត្តតាមបញ្ជារបស់ខ្មែរក្រហម ទោះជាបញ្ជានោះសាហាវឬឃោរឃៅយ៉ាងណាក៏ដោយ» ។ ប្រជាជនដែលខ្ញុំបានសម្ភាសន៍មួយចំនួនយល់ថា វាមិនចាំបាច់មានការកាត់ទោសតាមផ្លូវច្បាប់ និងការ

ដាក់ទោស «ជនដៃដល់» ដែលរស់នៅក្នុងសហគមន៍ជាមួយគ្នាគាត់ទេ ។ ប្រជាជនដែលខ្ញុំបានសម្ភាសន៍ម្នាក់ដែលជាអ្នកជិតខាងរបស់ ហ៊ឹម ហ៊ុយ (អ្នកដឹកនាំអនុវត្តការងារនៅមន្ទីរស-២១) បាននិយាយថា គាត់គិតថា ហ៊ឹម ហ៊ុយ មិនគួរត្រូវបានកាត់ទោសទេ ពីព្រោះគាត់ធ្វើតាមតែបញ្ជាប៉ុណ្ណោះ ។ ការអត់ឱនទោសអាចស្តារឡើងវិញនូវសន្តិភាពនៅក្នុងសហគមន៍ ។ វាមិនត្រឹមតែជាយន្តការសម្រាប់បង្រួបបង្រួម និងថែរក្សាគ្រួសារឡើងវិញប៉ុណ្ណោះទេ (ដោយមិនដាក់ទោសជនដៃដល់) ប៉ុន្តែវាក៏ជាយន្តការសម្រាប់ ៖

- លុបបំបាត់ការថប់បារម្ភរបស់ប្រជាជននៅក្នុងសហគមន៍ និងភាពភ័យខ្លាចដែលបង្កឡើងដោយការកាត់ទោសនិងការផ្តន្ទាទោស
- ការពារមិនឲ្យមានការខឹងសម្បានឹងគ្នាដែលបង្កឡើងដោយការខ្វែងគំនិតគ្នាទៅលើការពិត និងករណីរបស់បុគ្គលម្នាក់ៗ (ទំនាស់សក្ខីកម្ម និងការចងចាំ)
- មិនជំរុញឲ្យមានការសងសឹកដែលមិនអាចផ្តល់ «យុត្តិធម៌» និងមិនមែនជាការអប់រំតាមព្រះពុទ្ធសាសនា
- បណ្តុះឲ្យមានការចែករំលែកនិងការយល់ចិត្តជនដៃដល់ជាច្រើនដែលទទួលភាពអយុត្តិធម៌ ការឈឺចាប់ និងការបាត់បង់ដូចគ្នា
- ជំរុញឲ្យមានការគិតទៅមុខ
- កែសម្រួលទំនាក់ទំនងដែលបានបែកបាក់
- ហើយនៅទីបញ្ចប់ ជំរុញឲ្យមានការត្រឡប់មកភាពដើម

អ្នករិះគន់ការអភ័យទោសបានអះអាងថា វាគឺជាកិច្ចខំប្រឹងប្រែងដែលបានរៀបចំទុកមុនរបស់មន្ត្រីរដ្ឋាភិបាលបច្ចុប្បន្នដើម្បីបញ្ចៀសនូវការផ្តន្ទាទោស និងការកាត់ទោសតាមផ្លូវច្បាប់ចំពោះតួនាទីផ្ទាល់របស់គេនៅក្នុងរបបខ្មែរក្រហម ។ អ្នករិះគន់នេះក៏បានអះអាងថា ការអភ័យទោសកាន់តែជំរុញ «វប្បធម៌នៃនិទ្ទណ្ឌភាព» ។ គ្រេក អេតឆេសុន បានពន្យល់ថា «ឫសគល់នៃបញ្ហានិទ្ទណ្ឌភាពអាចធ្វើប្រជាជនចាប់ផ្តើមសួរខ្លួនឯងថា ៖ ឧក្រិដ្ឋកម្មដែលខ្ញុំបានប្រព្រឹត្តគឺតិចជាងអ្នកដែលបានប្រព្រឹត្តនៅក្នុងរបបខ្មែរក្រហមទៅទៀត ។ ចុះហេតុអ្វីបានជាខ្ញុំមិនអាចធ្វើអ្វីដែលខ្ញុំចង់? អ្នកទាំងនេះសម្អាងទៅលើស្ថានភាពបែបនេះ» ។ អេតឆេសុន បានលើកឡើងនូវការព្រួយបារម្ភយ៉ាងខ្លាំង ។ ទោះបីជាយ៉ាងនេះក៏ដោយ លទ្ធភាពនៃការអភ័យទោសដែលបង្កឲ្យមានការផ្សះផ្សាបុគ្គលនិងសហគមន៍គឺខ្ពស់ជាងលទ្ធភាពដែលថាការទទួលខុសត្រូវទាំងស្រុងនឹងកែប្រែ «វប្បធម៌នៃនិទ្ទណ្ឌភាព» ដែលបានចាក់ឫសយ៉ាងជ្រៅនៅក្នុងកម្ពុជា ។ ជាងនេះទៅទៀត ការដាក់ឲ្យប្រជាជនកម្ពុជាទាំងអស់ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មនៅក្នុងរបបខ្មែរក្រហមឲ្យទទួលខុសត្រូវគឺមិនអាចធ្វើទៅរួចដោយសារតែពេលវេលា និងធនធាន ។ ការដាក់ឲ្យអ្នកទទួលខុសត្រូវខ្ពស់បំផុត (មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម) ទទួលខុសត្រូវតាមរយៈការកាត់ទោសកំពុងតែដំណើរការ ហើយវាអាចប្រឆាំងនឹង «វប្បធម៌នៃនិទ្ទណ្ឌភាព» ។ ក្នុងន័យផ្សេងអាចមានការទទួលខុសត្រូវនិងការអភ័យទោសតាមរយៈការប្រើប្រាស់គំរូយុត្តិធម៌តាមរយៈការផ្សះផ្សានិងការកាត់ទោសនៅពេលជាមួយគ្នា ។

## សំណើរគោលការណ៍សម្រាប់អនុវត្ត ៖ គំរូយុត្តិធម៌តាមរយៈការផ្សះផ្សានិងការកាត់ទោស

អង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាអាចបោះជំហានដើម្បីអភិវឌ្ឍការប្រើប្រាស់គំរូយុត្តិធម៌តាមរយៈការផ្សះផ្សានិងការកាត់ទោស ។ កម្មវិធីសង្គមដែលបានរៀបចំឡើងយ៉ាងល្អអាចអភិវឌ្ឍនិងជំរុញលទ្ធភាពនៃគំរូនីមួយៗដើម្បីសម្រេចបាននូវការផ្សះផ្សាសម្រាប់ប្រជាជនកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរួមចំណែកក្នុងការអភិវឌ្ឍកម្មវិធីសង្គមផ្សេងៗដែលផ្តល់ជាជំនួយដល់ដំណើរការផ្សះផ្សា ។ កម្មវិធីសង្គមរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាខ្លះមានជាប់ពាក់ព័ន្ធនឹងកិច្ចខំប្រឹងប្រែងថែរក្សា និងបកប្រែឯកសារខ្មែរក្រហម ចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅតាមសាលារៀននៅកម្ពុជា ចងក្រងសក្ខីកម្មរបស់អ្នកនៅរស់ ផ្តល់ភ័ស្តុតាងអំពីអំពើសាហាវឃោរឃៅដែលប្រព្រឹត្តឡើងនៅរបបខ្មែរក្រហមទៅឲ្យអង្គជំនុំជម្រះ និងសាងសង់មជ្ឈមណ្ឌលស្រាវជ្រាវអចិន្ត្រៃយ៍មួយ បណ្ណាល័យ សារមន្ទីរ និងបូជនីយដ្ឋានមួយដើម្បីឧទ្ទិសដល់ជនរងគ្រោះក្នុងរបបខ្មែរក្រហម ។ ទោះបីជាយ៉ាងណាក៏ដោយ កម្ពុជាត្រូវការកិច្ចខំប្រឹងប្រែងច្រើនជាងមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីសម្រេចការផ្សះផ្សាដ៏ជោគជ័យ ។ សហគមន៍អន្តរជាតិ និងរដ្ឋាភិបាលកម្ពុជាគួរតែសហការជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា (និងអង្គការផ្សេងទៀត) ដើម្បី

អភិវឌ្ឍន៍ ផ្តល់ថវិកា ប្រតិបត្តិ និងពង្រីកកម្មវិធីសង្គមផ្សេងៗ ។

កម្មវិធីសង្គមផ្សេងៗដែលជំរុញឲ្យមានគំរូយុត្តិធម៌តាមរយៈការផ្សះផ្សាគួរតែគាត់តែងឡើងដើម្បី ៖

◆ បង្កើនការចូលរួមរបស់ជនរងគ្រោះឲ្យកាន់តែច្រើននៅក្នុងដំណើរការសវនាការដោយផ្តល់ជាមធ្យោបាយធ្វើដំណើរដល់ប្រជាជនដើម្បីចូលរួមសវនាការ និងជួយជនរងគ្រោះឲ្យដាក់ពាក្យបណ្តឹងដើម្បីធ្វើជាកស្តុតាងអង្គជំនុំជម្រះប្រឆាំងនឹងខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីសង្គមមួយគឺគម្រោងជួយជនរងគ្រោះដាក់ពាក្យបណ្តឹងទៅតុលាការ ។ គម្រោងនេះគួរតែទទួលបានថវិកាច្រើនជាងនេះនិងពង្រីកដើម្បីចុះទៅជួបជនរងគ្រោះច្រើនជាងមុន ។

◆ បង្កើនការចូលរួមដោយផ្ទាល់របស់ជនរងគ្រោះនៅក្នុងដំណើរការរបស់អង្គជំនុំជម្រះដោយធ្វើការអប់រំប្រជាពលរដ្ឋអំពីវិធានច្បាប់និងផ្តល់ព័ត៌មានដល់ប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសប្រជាជនដែលនៅតំបន់ដាច់ស្រយាល ។ នេះអាចធ្វើឡើងតាមរយៈក្រដាសផ្សព្វផ្សាយ ការផ្សព្វផ្សាយតាមវិទ្យុ មេដឹកនាំសហគមន៍ ទូរទស្សន៍ និងនៅតាមសាលា ។

◆ ផ្សព្វផ្សាយនិងសង្កត់ធ្ងន់ទៅលើការសុំទោសតាមរយៈសារព័ត៌មានដ៏ទូលំទូលាយ ។ ជាឧទាហរណ៍ ឌុច ប្រធានមន្ទីរស-២១ បានទទួលខុសត្រូវនិងធ្វើការសុំទោសនៅក្នុងតុលាការចំពោះតួនាទីរបស់គាត់នៅក្នុងរបបខ្មែរក្រហម ។ ការផ្តល់ដំណឹងដល់ប្រជាជនចំពោះការទទួលកំហុស និងការសុំទោសរបស់ ឌុច អាចជួយដល់ការផ្សះផ្សាបុគ្គលនិងសហគមន៍ ។

◆ ផ្សព្វផ្សាយ និងសង្កត់ធ្ងន់ទៅលើសេចក្តីសម្រេចតាមរយៈសារព័ត៌មានដ៏ទូលំទូលាយ ។ សេចក្តីសម្រេចនេះនឹងបញ្ចប់ការពន្យារពេលដ៏យូរក្នុងការទទួលបានយុត្តិធម៌តាមផ្លូវច្បាប់ និងផ្តល់ការអស់ចិត្តដល់ប្រជាជន ។

◆ ផ្តល់សំណង ។ មេដឹកនាំខ្មែរក្រហមដែលត្រូវបានអង្គជំនុំជម្រះរកឃើញថាមានទោសដែលមានប្រាក់និងទ្រព្យសម្បត្តិគួរតែតម្រូវឲ្យបោះបង់ទ្រព្យសម្បត្តិទាំងនោះ ។ ហើយទ្រព្យសម្បត្តិទាំងនេះគួរតែយកមកប្រើក្នុងកិច្ចខំប្រឹងប្រែងដើម្បីរំឭកនូវការចងចាំ កម្មវិធីសុខភាពសង្គម សម្រាប់ជនរងគ្រោះ ការអប់រំអំពីរបបខ្មែរក្រហមជាដើម ។

កម្មវិធីសង្គមដែលជំរុញឲ្យមានគំរូយុត្តិធម៌តាមរយៈការផ្សះផ្សាគួរតែបង្កើតឡើងដើម្បី ៖

◆ ផ្សព្វផ្សាយពីការទទួលស្គាល់ឧក្រិដ្ឋកម្មដែលធ្វើទៅលើប្រជាជនរបស់រដ្ឋាភិបាល (តាមរយៈក្រដាសផ្សព្វផ្សាយ ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ មេដឹកនាំក្នុងស្រុក និងនៅសាលាដើម្បីផ្តល់ដំណឹងដល់ប្រជាជនកម្ពុជា) ។

◆ អប់រំប្រជាជនកម្ពុជាអំពីរបបខ្មែរក្រហមដោយបង្កើតឲ្យមានកម្មវិធីសិក្សានៅតាមសាលារៀន ដោយផ្តល់សៀវភៅសិក្សា និងបណ្តុះបណ្តាលគ្រូអំពីរបៀបបង្រៀនប្រវត្តិសាស្ត្រកម្ពុជានៅក្នុងរបបនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតជាកម្មវិធីសង្គមមួយ ប៉ុន្តែវាគួរតែយកមកពង្រីកនិងផ្តល់ថវិកាឲ្យច្រើនជាងនេះ ។

◆ បង្កើតកម្មវិធីព្យាបាលដែលផ្អែកទៅលើការអប់រំតាមព្រះពុទ្ធសាសនា ។ ៩៥ភាគរយនៃប្រជាជនកម្ពុជាគឺជាពុទ្ធសាសនិកជន ។ ការអប់រំតាមបែបព្រះពុទ្ធសាសនាអាចជួយដល់ពុទ្ធសាសនិកដោះស្រាយនិងជម្នះទៅលើកំហឹង និងការឈឺចាប់ ក៏ដូចជាជំរុញឲ្យមានការផ្សះផ្សា ។

មិនមានគំរូយុត្តិធម៌ណាមួយមានប្រសិទ្ធភាពក្នុងការផ្សះផ្សាប្រជាជនកម្ពុជាទាំងអស់នោះទេ ។ ៧០ភាគរយនៃប្រជាជនកម្ពុជាមានអាយុក្រោម២៥ឆ្នាំ ហើយមិនបានឆ្លងកាត់របបខ្មែរក្រហម ។ អាស្រ័យហេតុនេះ ក្មេងៗជំនាន់ក្រោយត្រូវទទួលបានការផ្សះផ្សាដោយមធ្យោបាយផ្សេងពីមនុស្សវ័យចំណាស់ដែលជួបប្រទះនឹងរបបនេះមុន ។ វាមានសារសំខាន់ថាដំណើរការផ្សះផ្សាជាដំណើរការដែលមានធាតុផ្សំសំខាន់ៗជាច្រើន និងជាប់ពាក់ព័ន្ធការមិនត្រឹមតែការចងចាំពីអតីតកាលប៉ុណ្ណោះ តែថែមទាំងមានឥទ្ធិពលជាវិជ្ជមានដល់អនាគតទៀតផង ។ ការបង្កើតវិធានច្បាប់នៅក្នុងកម្ពុជាតាមរយៈអង្គជំនុំជម្រះនិងការធានាថាវានឹងមិនកើតឡើងម្តងទៀតតាមរយៈការអប់រំនិងកម្មវិធីសង្គម ប្រហែលមិនមែនជា «យុត្តិធម៌» សម្រាប់អំពើប្រល័យពូជសាសន៍ទេ ប៉ុន្តែវាអាចជាការផ្សះផ្សាអតីតកាលដែលពោរពេញទៅដោយការធ្វើទារុណកម្ម ហើយវាអាចជាក្តីសង្ឃឹមសម្រាប់អនាគតដ៏សន្តិភាព ។ **សាវ៉ាន់ណាស ឌីសរ៉ែន**

# សម្លឹងមើលទៅអនាគតកាល យុត្តិធម៌ និង ការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា

ខណៈពេលដែលយន្តហោះចុះមកដល់ទឹកដីប្រទេសកម្ពុជា ប្រហែលជារយៈពេលមួយខែមុន ខ្ញុំបានរៀបចំតាមដានពីផលប៉ះពាល់នៃការបំផ្លាញដែលអំពើប្រល័យពូជសាសន៍បានធ្វើមកលើប្រទេសនេះ ។ ការសិក្សារៀនសូត្រអស់រយៈពេលពីរសប្តាហ៍ គឺចាំបាច់ណាស់សម្រាប់ការមកដល់របស់ខ្ញុំដែលធ្វើឲ្យខ្ញុំរំពឹងទុកកាន់តែអាក្រក់ ។ ដោយបានត្រៀមខ្លួនដើរចូលមកក្នុងប្រទេសកម្ពុជាប្រហែលនៅឆ្នាំ១៩៧៩ ខ្ញុំបានស្រមៃឃើញប្រទេសកម្ពុជាដែលខ្ញុំធ្លាប់បានឃើញនៅក្នុងរូបភាពគឺជាទីក្រុងមួយដែលត្រូវបំផ្លាញទទេស្អាត ការបង្ហាញទឹកមុខអស់សង្ឃឹមរបស់អ្នកស្រុក ខ្លួនប្រាណដេកនៅតាមដងផ្លូវនិងសម្បកគ្រាប់បែកពង្រាយនៅតាមទីជនបទ ។

វាជាការភ្ញាក់ផ្អើលសម្រាប់ខ្ញុំ ទីក្រុងភ្នំពេញនៅពេលនេះអ៊ូអរជាទីក្រុងដ៏ទូលំទូលាយពេញដែលផ្ទុកទៅដោយ មនុស្ស និងទោចក្រយានយន្ត ។ មនុស្សនៅលើទោចក្រយានយន្តភាគច្រើនរីករាយជាមួយក្រុមគ្រួសារនិងមនុស្សដែលខ្លួនស្រឡាញ់នៅពេលល្ងាច ។ ទោះបីជាភាពក្រីក្រមាននៅគ្រប់ទីកន្លែងទាំងអស់ក៏ដោយក៏ ទីក្រុងនេះហាក់ដូចជាអាចជម្នះរាល់ឧបសគ្គនេះជាមួយនឹងសកម្មភាពដ៏ទូលំទូលាយរបស់អ្នកស្រុក និងប្រកបដោយស្នាមញញឹមនៅលើមុខរបស់គេ ។ ខ្ញុំដឹងខ្លួនឯងថាខ្ញុំមិនអាចរស់នៅក្នុងប្រទេសដែលរុំព័ទ្ធទៅដោយប្រពៃណីដែលគួរឲ្យភ័យខ្លាចនិងមានសង្គ្រាមបានតទៅទៀតទេ វាច្បាស់ថាប្រទេសកម្ពុជានិងចំនួនប្រជាជនដ៏ក្មេងខ្ចីនេះ បានត្រៀមខ្លួនរួចជាស្រេចដើម្បីជ្រើសរើសសន្ទឹកក្រដាសទម្លាយអតីតកាល ។

ទោះបីជាប្រទេសកម្ពុជាធ្លាប់ឆ្លងកាត់ផ្លូវដ៏វែងឆ្ងាយទៅមុខជាមួយនឹងបញ្ហាជាច្រើនដែលរារាំងដល់ការអភិវឌ្ឍ និងកម្លាំងរបស់ប្រជាជនក៏ដោយ ក៏បញ្ហាសំខាន់បំផុតដែលប្រទេសកម្ពុជាកំពុងប្រឈមមុខគឺតើត្រូវបន្តភ្ជាប់រឿងយុត្តិធម៌ និងការផ្សះផ្សាជាតិទៅក្នុងសង្គមក្រោយរបបប្រល័យពូជសាសន៍ដោយវិធីណា ។ សាមសិបឆ្នាំក្រោយបន្ទាប់ពីបំបាត់សង្គមកម្ពុជាទំនើបបានទាំងស្រុងនិងការស្លាប់មនុស្សអស់មួយភាគបួននៃចំនួនប្រជាជនសរុប ប្រទេសកម្ពុជាត្រូវតែធ្វើឲ្យមានតុល្យភាពរវាងការប្រឈមមុខនឹងអតីតកាលនិងសម្លឹងមើលអនាគតទាំងមានក្តីសង្ឃឹម ។ បន្ទាប់ពីបាននិយាយជាមួយអ្នកនៅរស់រានមានជីវិតចំនួនបីបួននាក់ពីរបបប្រល័យពូជសាសន៍ ប៉ុល ពត វាបានបង្ហាញឲ្យឃើញកាន់តែច្បាស់ថាដើម្បីឆ្ពោះទៅមុខបាន ប្រទេសនេះត្រូវតែជ្រើសរើសយកគំរូយុត្តិធម៌អន្តរកាលពីរគឺ យុត្តិធម៌ដែលស្តាបនាឡើងវិញ និងយុត្តិធម៌ដែលមានកម្មពៀរ ។

យោងទៅតាមមជ្ឈមណ្ឌលអន្តរជាតិសម្រាប់យុត្តិធម៌អន្តរកាល យុត្តិធម៌អន្តរកាល «គឺជាចម្លើយមួយដើម្បីផ្សព្វផ្សាយការរំលោភបំពានលើសិទ្ធិមនុស្ស» ។ មជ្ឈមណ្ឌលនេះបានលើកយកយុត្តិសាស្ត្រសំខាន់ៗចំនួនបីបួនដែលអាចជួយនៅក្នុងដំណើរការអន្តរកាលនេះនិងដែលអាចជ្រើសរើសយកនិងដាក់ទៅលើករណីមួយៗ ។ ទាំងនេះរួមមាន ការកាត់ទោសព្រហ្មទណ្ឌ ការខិតខំប្រឹងប្រែងរំឭកគណៈកម្មការសច្ចៈធម៌ កម្មវិធីសំណងនិងកែទម្រង់ប្រពន្ធ័សុវត្ថិភាព ។

ចំណែកការកាត់ទោសព្រហ្មទណ្ឌ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានយុត្តាធិការដាក់មន្ត្រីថ្នាក់ខ្ពស់ៗបំផុត របស់ខ្មែរក្រហមដើម្បីកាត់ទោស ។ វាបានចំណាយរយៈពេលសាមសិបឆ្នាំនិងជួបឧបសគ្គជាច្រើនដែលមិនអាចរៀបរាប់បានក្នុងការធ្វើឲ្យមានដំណើរការកាត់ទោសព្រហ្មទណ្ឌនៅក្នុងប្រទេសកម្ពុជា ថ្វីបើមានការពន្យារក៏ដោយ វាហាក់ដូចជាថាមានការជួយគាំទ្រ យ៉ាងទូលំទូលាយពីសំណាក់សាធារណជនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ យោងតាម គ្រេក អេតឆេសសុន នៅក្នុងសៀវភៅ «ក្រោយពីវាលពិឃាត» ការស្ទាបស្ទង់មតិសាធារណជនបានបង្ហាញថា «ចំនួនច្រើនបំផុតនៃការឆ្លើយតបពី ៧០ ទៅ

៧៥ភាគរយជួយដល់សាលាក្តីសម្រាប់មេដឹកនាំក្រៅប្រទេស» ។

រយៈពេលដែលខ្ញុំរស់នៅក្នុងប្រទេសកម្ពុជា សមាជិកក្រុមរបស់ខ្ញុំនិងខ្ញុំមានសំណាងខ្លាំងណាស់ដែល បានសម្ភាសនជាមួយអ្នកនៅរស់រានមានជីវិតនិងជនដែលនៅក្នុងរបបខ្មែរក្រហម ។ ដំណើរការសម្ភាសរបស់យើងបានបង្ហាញថា អ្នកទាំងអស់គ្នាដែលយើងបានសម្ភាសជាក្រុមជាជនរងគ្រោះ ឬជនដែលយល់ស្របឲ្យមានការកាត់ទោសព្រហ្មទណ្ឌដោយជឿជាក់ថាគេនឹងអាចជួយផ្តល់នូវភាពយុត្តិធម៌បាន ។ បន្ទាប់ពីបានពិនិត្យមើលទៅលើបទសម្ភាសន៍របស់ក្រុមដទៃ វាក៏បានបង្ហាញផងដែរថាប្រជាជនជាច្រើនបានសម្តែងការព្រួយបារម្ភអំពីភាពជោគជ័យរបស់សាលាក្តីក៏ដូចជាថាតើដំណើរការកាត់ក្តីនឹងចំណាយរយៈប៉ុន្មាន ។ ទោះបីជា មានចម្លើយប្រឬកប្រឬលគ្នាចំពោះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាយ៉ាងណាក៏ដោយ ក៏មនុស្សមួយចំនួនធំដែលបានផ្តល់បទសម្ភាសន៍គិតថាតុលាការនេះអាចនាំក្តីសង្ឃឹមដល់ប្រជាជនផងដែរ ។ វាក៏ជាគោលបំណងរបស់តុលាការដើម្បីផ្តល់ទម្រង់យុត្តិធម៌ខុសៗគ្នាដល់ប្រជាជនកម្ពុជាដែលស្ថិតនៅខាងក្រោយព្រំដែននៃយុត្តិធម៌ដែលមានកម្មពៀរ ។ ចូរក្រឡេកមកមើលទម្រង់ខុសៗគ្នានៃគម្រោងយុត្តិធម៌អន្តរកាលខាងលើ ការកាត់ទោសព្រហ្មទណ្ឌ គណៈកម្មការសច្ចៈធម៌និងសំណង ។ រយៈពេលដែលតុលាការមិនបានបំពេញតួនាទីជាផ្លូវការដោយសារតែរដ្ឋជួយដល់គណៈកម្មការសច្ចៈធម៌ ឬកម្មវិធីសំណងផ្នែកហិរញ្ញវត្ថុ ដំណើរការកាត់ក្តីនេះក៏នឹងអនុញ្ញាតឲ្យធាតុផ្សំនីមួយៗកើតឡើងនៅក្នុងការដាក់ជាសាធារណៈ ។

រយៈពេលដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងកាត់ទោសរឿងព្រហ្មទណ្ឌ វាក៏មានបំណងបម្រើជាគណៈកម្មការសច្ចៈធម៌និងផ្តល់ជាសំណងដើម្បីសុំទោសនិងបកស្រាយដោយចុងចោទសម្រាប់អ្នកដែលទទួលឥទ្ធិពលដោយអំពើប្រល័យពូជសាសន៍នៅពេលកំពុងទស្សនាដំណើរការកាត់ក្តី បានបង្ហាញឲ្យឃើញថាក្រៅពីបង្កើតពិរុទ្ធភាពរបស់ ឌុច តុលាការនេះក៏បានខិតខំប្រឹងប្រែងប្រាប់ទៅកាន់សាធារណជនអំពីអ្វីដែលបានកើតឡើងពិតប្រាកដនៅក្រោយរបបខ្មែរក្រហមពី(ខែមករា ឆ្នាំ១៩៧៥ ដល់ ខែមករា ឆ្នាំ១៩៧៩) ។ អតីតចុងភៅឃុំម្នាក់ឈ្មោះ ណៅ អុន បាននិយាយនៅក្នុងកំឡុងពេលធ្វើបទសម្ភាសន៍ថាគាត់ជឿជាក់យុត្តិធម៌គឺជាការជឿជាក់និងភាពស្មោះត្រង់ ។

តុលាការនេះក៏បានផ្តល់ជាសំណងផងដែរ ។ អត្ថបទមួយនៅក្នុងសេចក្តីផ្តើមខ្លីបានបកស្រាយថា «ចៅក្រមនឹងសម្រេចឲ្យអ្នកដែលចូលរួមនិងសំណងផ្នែកសីលធម៌ដូចជា ដីកាមួយដើម្បីប្រកាសពីការកាត់ទោសទៅតាមព័ត៌មានដែលអាចទទួលយកបានឬក៏ប្រពន្ធ័ផ្សព្វផ្សាយផ្សេងទៀត ទៅលើការចំណាយរបស់អ្នកដែលត្រូវផ្តន្ទាទោស ឬក៏ដីកាដើម្បីផ្តល់ប្រាក់ដល់សកម្មភាពមួយចំនួនទៀតដែលមិនរកប្រាក់ចំណូល ឬក៏សេវាកម្មផ្សេងទៀតដែលមានគោលបំណងសម្រាប់ផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះ ។

ខណៈពេលដែលតុលាការនឹងមិនផ្តល់ជាសំណងផ្នែកថវិកាដល់បុគ្គលម្នាក់ៗសម្រាប់មនុស្សម្នាក់ៗដែលទទួលរងដោយអំពើប្រល័យពូជសាសន៍ អ្នកទាំងនោះខទ្ទិសជូនទៅដល់អង្គការដែលបានផ្តល់ប្រាក់ជំនួយដែលអាចបន្តដំណើរនៃការផ្សះផ្សាជាតិបានទៅមុខទៀតដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការក្រៅរាជរដ្ឋាភិបាលផ្សេងទៀត ។ តុលាការនេះក៏សង្ឃឹមផងដែលថានឹងផ្តល់ជាសំណងនៅក្នុងទម្រង់សុំទោសជាលក្ខណៈផ្លូវការពីចុងចោទនិងបកស្រាយសម្រាប់អ្វីដែលគាត់បានធ្វើខុស ។ ខណៈពេលដែលយើងកំពុងចូលរួមសវនាការ ឌុច គាត់បាននិយាយជាច្រើនដងថាគាត់សោកស្តាយប៉ុណ្ណាចំពោះអ្វីដែលគាត់បានធ្វើកន្លងមក ។ ខណៈពេលដែលមានការពេញចិត្តពីសំណាក់អ្នកដែលនៅរស់រានមានជីវិតក៏មានមនុស្សម្នាក់ឈ្មោះ គួង សួ ដែលជឿជាក់ថា «សនាការនេះហាក់ដូចជាផ្តល់ឲ្យមនុស្សដូចជា ឌុច រួចផុតពីកំហុសដោយអនុញ្ញាតឲ្យគេស្តីបន្ទោសពីភាពខ្លាំងក្លានៃឧក្រិដ្ឋកម្មរបស់គេ» ។ សេចក្តីអស់សង្ឃឹមជាមួយដំណើរការសវនាការក៏បានបង្ហាញពីភាពស្មុគស្មាញសំខាន់ៗពីរគឺអំពើពុករលួយនិងរយៈពេលនៃដំណើរការក្តី ។ នៅក្នុងលិខិតខ្លីៗដែលចែកចាយទៅដល់អ្នកដែលមកចូលរួមទាំងអស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អតីតអគ្គលេខានៃអង្គការសហប្រជាជាតិ កូហ្វី អាណាន់ បានសរសេរជាសារបញ្ជាក់ពីការស្ថិតនៅរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា «ជាសញ្ញាថាការមិនដាក់ទោសគឺជាប្រពៃណីមួយដ៏គួរឲ្យខ្លាចតាមពិត អាចជំនួសដោយប្រពៃណីនៃការទទួលខុសត្រូវ» ប៉ុន្តែវា

ហាក់ដូចជាភ្លើងសញ្ញានេះទទួលការចោទប្រកាន់ក្នុងរឿងអំពើពុករលួយខ្លះៗ ជាសំណាងអាក្រក់អំពើពុករលួយនៅខាងផ្នែករដ្ឋបាលបានជះឥទ្ធិពលដល់ដំណើរការសវនាការតាមផ្លូវច្បាប់ និងធ្វើឲ្យប្រជាជនជាច្រើនបាត់បង់ជំនឿចិត្តក្នុងការស្វែងរកយុត្តិធម៌ ។ អាងស្រ្តីមួយរូបដែលនៅរស់ពីរបបខ្មែរក្រហមនៅខេត្តស្វាយរៀង ភូមិភាគបូព៌ាបានបង្ហាញពីសេចក្តីអស់សង្ឃឹមរបស់គាត់ចំពោះតុលាការ ។ គាត់បាននិយាយថា «ខ្ញុំជឿជាក់ថាយុត្តិធម៌នឹងអាចទទួលបាន ប៉ុន្តែខ្ញុំមានចម្ងល់អំពីសវនាការនេះពីព្រោះគេបានចំណាយពេលយូរមកហើយដោយគ្មានបានលទ្ធផលមួយច្បាស់លាស់សោះ ហើយចុងចោទនៅតែព្យាយាមរិះរកវិធីដើម្បីឲ្យបានសេរីភាព ខ្ញុំបានសម្លឹងមើលនៅពីក្រោយភ័ស្តុតាងនៃអ្វីដែលអ្នកទាំងនោះបានធ្វើ» ។

សមាជិករបស់ខ្ញុំម្នាក់ទៀតបានសម្ភាសអតីតទាហានខ្មែរក្រហមមួយរូបដែលធ្លាប់ជាប់គុកអស់រយៈពេលបីខែនៅក្នុងគុកជីឡូញ ។ គាត់ឈ្មោះ សា ញឹម ហើយគាត់បានមកមើលសវនាការរបស់ ឌុច ដែរ ។ គាត់បានបង្ហាញពីក្តីអស់សង្ឃឹមចំពោះតុលាការនៅថ្ងៃដែលគាត់បានមកចូលរួមមើលដោយផ្ទាល់ ហើយបកស្រាយថា «ថ្ងៃនេះមិនមានអ្វីគ្រប់គ្រាន់សម្រាប់និយាយក្នុងអំឡុងពេលសវនាការទេ និងនៅមានភាពលម្អិតជាច្រើនទៀតដែលមិនបាននិយាយនិងមិនបានពុ» ។ ដំណើរការច្បាប់ហាក់ដូចជាច្របូកច្របល់ចំពោះប្រជាជនកម្ពុជាជាច្រើន ។ បញ្ហាផ្នែកបកប្រែឯកសារ និងសំណុំរឿងផ្នែកច្បាប់ដែលជាប់ទាក់ទងដទៃទៀតក៏កំពុងបង្អាក់ដំណើរការក្តីនេះផងដែរ ដោយសារតែសមាសភាពចៅក្រមអន្តរជាតិដែលទាមទារឲ្យដំណើរការក្តីនេះធ្វើឲ្យជាបីភាសាខុសគ្នាគឺ ខ្មែរ អង់គ្លេស និងបារាំង ។ នៅពេលដែលគេបានដឹងថា សវនាការនេះនឹងចំណាយរយៈពេលយូរ ប្រជាជនកម្ពុជាជាច្រើនដែលឃើញថាសវនាការនេះចំណាយអស់រយៈពេលសាមសិបឆ្នាំសម្រាប់ចាប់ផ្តើមដំណើរការក្តីនេះចង់ឲ្យសវនាការនេះប្រព្រឹត្តទៅលឿនៗ ហេតុដូច្នេះហើយបានជាមិនចង់ឲ្យតុលាការចំណាយពេលឥតប្រយោជន៍ច្រើនជាងនេះទៀតទេ ។ ខ្មែរក្រហមដែលនៅរស់និងអតីតព្រះសង្ឃឈ្មោះ គួង សួ បានបង្ហាញអំពីការសោយចិត្តនេះដោយបកស្រាយថា គាត់ចង់ឲ្យសវនាការនេះបង្កើនល្បឿនចំពោះសវនាការដែលបានពន្យារពេលរួចហើយពីព្រោះទោះបីជាមានសំណាងក៏ដោយ គឺគ្មានអត្ថន័យអ្វីទាំងអស់សម្រាប់ជនរងគ្រោះដែលបានស្លាប់ជារៀងរាល់ថ្ងៃពីព្រោះអ្នកទាំងអស់នោះចាស់ហើយចង់ឃើញសាលារៀននិងទីវត្តអារាមសាងសង់រួច ។

ថ្វីបើតុលាការនេះមានរយៈពេលខ្លីយ៉ាងណាក៏ដោយវាបានទទួលជោគជ័យនៅក្នុងការផ្សព្វផ្សាយការផ្សះផ្សាជាតិ ។ តាមរយៈអ្នកដែលនៅរស់មួយរូបដែលយើងបានសម្ភាសន៍ នង ចាន់ផល មានការជឿជាក់មួយដែលថាសវនាការនេះនឹងផ្តល់អត្ថន័យមួយសម្រាប់អ្នកទាំងអស់គ្នាដែលទទួលរងគ្រោះដោយសាររបបខ្មែរក្រហម ។ នៅក្នុងកិច្ចសម្ភាសន៍របស់គាត់អ្នកនៅរស់ពីគុកទួលស្លែងរូបនេះបាននិយាយថា «សវនាការផ្តល់ឲ្យព្រលឹងអ្នកនៅរស់ដើម្បីរស់ហើយអ្នកទាំងនោះអាចចាប់ផ្តើមជីវិតសាជាថ្មីបាន» ។ គាត់ក៏បាននិយាយទៀតថា គាត់បានព្យាយាមគេចវេះពីអ្នកកាសែតទាំងអស់រហូតដល់ពេលគាត់បានឮអំពីសវនាការរបស់ ឌុច ហើយបន្ទាប់មកក៏សម្រេចចិត្តនិយាយទៅកាន់អ្នកកាសែតទាំងនោះពីព្រោះគាត់ចង់ផ្តល់ព័ត៌មានដើម្បីធ្វើឲ្យប្រាកដថា គាត់ត្រូវជាប់គុកដែរ ។

សវនាការនេះក៏ជាប់ទាក់ទងនឹងគំនិតនៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌផងដែរ ។ នៅពេលដែលខ្ញុំបានសួរ នង ចាន់ផល គាត់មានអារម្មណ៍ថា ខ្មែរក្រហមត្រូវទទួលខុសត្រូវចំពោះការបាត់បង់សមាជិកគ្រួសាររបស់គាត់ ។ គាត់ក៏បាននិយាយទៀតថាគាត់ជឿជាក់ថា អ្នកទាំងអស់នោះដែលត្រូវគេចាត់ទុកថាជាអ្នកដឹកនាំជាន់ខ្ពស់ដូចជា ប៉ុល ពត គួរតែត្រូវនាំយកមកកាត់ទោសដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ។ មនុស្សជាច្រើនដែលបានសម្ភាសន៍មានការជឿជាក់ដូច្នេះដូចគ្នា ហើយតាមពិតទៅប្រជាជនមួយចំនួនចង់ឲ្យកាត់ទោសមនុស្សផ្សេងទៀតក្រៅពីអ្នកដឹកនាំទាំងប្រាំរូបនេះដែលពេលវេលាបានកំណត់ទុករួចហើយសម្រាប់បើកសវនាការ ។ នៅរយៈពេលសម្ភាសន៍អតីតទាហានខ្មែរក្រហម សុខ ផាត បាននិយាយថា «គាត់យល់ស្របមួយរយភាគរយដែលមនុស្សទាំងប្រាំរូបនេះត្រូវគេយកមកកាត់ទោស គឺគ្រប់គ្រាន់ហើយក្នុងការស្វែងរកយុត្តិធម៌» ។ គាត់បាននិយាយថាវាមានសារសំខាន់ខ្លាំងណាស់ក្នុងការកាត់ទោសមនុស្សទាំងប្រាំរូបនេះ ជនដៃដល់ថ្នាក់ទាបដែលជាញឹកញាប់ត្រូវបង្ខិតបង្ខំឲ្យធ្វើសកម្មភាពឧក្រិដ្ឋកម្ម គឺមាន

សារប្រយោជន៍ខ្លាំងណាស់សម្រាប់ផ្តល់ព័ត៌មានដើម្បីយកមន្ត្រីជាន់ខ្ពស់ខ្មែរក្រហមមកកាត់ទោស ។ ម្យ៉ាងវិញទៀតអ្នកដែលនៅរស់ឈ្មោះ អ៊ឹង បានបង្ហាញថាគាត់ចង់ឲ្យមានការកាត់ទោសជនដៃដល់បន្ថែមទៀត ។ គាត់បាននិយាយថាគាត់មិនយល់ស្របទេដែលថាការពន្យារពេលសវនាការអាចធ្វើឲ្យជ្រួលច្របល់នៅក្នុងប្រទេសកម្ពុជានិងបដិសេធថា ជនផ្សេងគំនិតរបស់អ្នកដឹកនាំជាន់ខ្ពស់គួរតែយកមកកាត់ទោសដែរ ។ គាត់បានបន្ថែមទៀតថា គ្មាននរណាម្នាក់នៅក្នុងភូមិរបស់គាត់គួរតែត្រូវកាត់ទោសទេ ដោយកត់សម្គាល់ឃើញថា គាត់ត្រូវដោះស្រាយជាមួយអ្នករាល់គ្នានៅក្នុងភូមិរបស់គាត់បន្ទាប់ពីទទួលបានសិទ្ធិសេរីភាពប្រសិនបើអ្នកទាំងនោះទទួលខុសត្រូវ ។

សរុបទៅវាហាក់ដូចជាមានខុសៗគ្នាទាក់ទងទៅនឹងថា តើនរណាជាអ្នកទទួលខុសត្រូវហើយខណៈពេលដែលមនុស្សភាគច្រើននឹងស្វែងរកសន្តិភាពតាមរយៈការកាត់ទោសមន្ត្រីជាន់ខ្ពស់ ហើយអ្នកខ្លះទៀតចង់ឃើញជនដៃដល់ថ្នាក់ទាបត្រូវនាំយកមកកាត់ទោសដែរ ។ នៅខណៈពេលដែលយុត្តិធម៌ដែលមានកម្ពុជាត្រូវបានកំណត់ចំពោះការកាត់ទោសមន្ត្រីជាន់ខ្ពស់ខ្មែរក្រហម វានៅតែជាជំហានសំខាន់មួយឆ្ពោះទៅរកការទទួលខុសត្រូវដ៏ពិតប្រាកដមួយតាមរយៈវិធានច្បាប់ ។ វាហាក់ដូចជាពិបាកក្នុងការបញ្ជាក់ឲ្យឃើញច្បាស់ថាតើនរណាជាអ្នកទទួលខុសត្រូវបទឧក្រិដ្ឋចំពោះសកម្មភាពដែលបានធ្វើនៅចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។ យោងទៅតាមប្រពៃណីដ៏លើសលប់នៃការភ័យខ្លាចដែលព័ទ្ធជុំវិញទិដ្ឋភាពនីមួយៗនៃជីវិតក្រោមរបបខ្មែរក្រហមវាពិបាកក្នុងការបែងចែកជនដៃដល់ពីជនរងគ្រោះណាស់ ។ នៅក្នុងសារណារបស់គាត់នៅក្នុងសៀវភៅវាលពិឃាត ហាំង ង៉ំ បានរៀបរាប់ពីការឃុំឃាំងដែលរីករាលដាលនិងអំពើភេរវកម្មដែលមានស្ទើរតែរៀងរាល់ថ្ងៃនៅក្រោមរបបខ្មែរក្រហម ។ «ភាពខ្លាំងក្លាបំផុតរបស់ខ្មែរក្រហមគឺការឃោសនា» ។ អ្នកអស់នោះបានដឹងថាការកុហកតូចមួយអាចនឹងចាប់បានហើយការកុហកធំមួយគឺកាន់តែងាយស្រួលចេញឲ្យឆ្ងាយ ។ ប្រព័ន្ធរបស់គេគឺខុសពីអ្វីដែលយើងបានដឹងពីមុនមកហើយដែលយើងទទួលយកវាដោយមិនដឹងថាត្រូវតទល់ជាមួយនឹងវាដោយរបៀបណាផង ។ ទោះបីជាយើងត្រូវបានអនុញ្ញាតឲ្យនិយាយចេញមកខាងក្រៅជាសាធារណៈក៏ដោយ ក៏យើងមិនអាចនិយាយដែរហើយបើយើងធ្វើ អ្នកទាំងនោះនឹងចង់រីតនិងជាន់ពីលើយើងឲ្យឆ្ងាយ យើងគ្មានសមត្ថភាពគ្រប់គ្រាន់ក្នុងការព្យាយាមប្រើពាក្យសម្តីរបស់យើងទៅប្រឆាំងជាមួយនឹងអ្នកទាំងនោះទេ ។ វាគ្មានអ្វីអាចជួយបានឡើយ» ។

ប្រព័ន្ធនៃការកំណត់សំគាល់សត្រូវនៅក្នុងរយៈពេលនោះគឺជាប្រពៃណីមួយគួរឲ្យខ្លាច ។ យោងទៅតាមឯកសារមន្ត្រីខ្មែរក្រហម D០១៧៩១ «សត្រូវគឺជាអ្នកដែលមិនមែនជាអ្នកបដិវត្តន៍ហើយប្រឆាំងនឹងបដិវត្តន៍» ។ និយមន័យដ៏ទូលាយសម្រាប់កត់សំគាល់សត្រូវដែលមិនទាន់បានឃើញឲ្យមានគំនិតថា នរណាដែលធ្វេសប្រហែសមិនថាអ្នកទាំងនោះជាប្រជាជនថ្មី ឬក៏កម្មាភិបាលខ្មែរក្រហមសុទ្ធតែអាចចាត់ទុកថាជាសត្រូវទាំងអស់ ។ ដូច្នេះក្នុងអំឡុងពេលរកយុត្តិធម៌ដែលមានកម្ពុជា ត្រូវតែយកចំណុចនេះការស្វែងរកយុត្តិធម៌ដើម្បីស្តាបនាគួរតែត្រូវបានយកចិត្តទុកដាក់បំផុតយោងទៅតាមឥទ្ធិពលដែលអំពើប្រល័យពូជសាសន៍ដែលមានមកលើសង្គមកម្ពុជាទាំងមូល ។

ការខិតខំរំព្ញកគឺបានទទួលជោគជ័យយ៉ាងសម្បើមនៅក្នុងប្រទេសកម្ពុជារហូតដល់ពេលបច្ចុប្បន្ន ។ ទៅមើលជើងឯកនិងអតីតគុកស-២១នៅទួលស្លែង បានអនុញ្ញាតឲ្យខ្ញុំពិនិត្យមើលការខិតខំទាំងនេះដើម្បីការពារគំនរខ្មោចដែលបង្ហាញពីជីវិតរាប់ពាន់នាក់និងចំនួនបន្ទប់ពិតប្រាកដដែលទារុណកម្មរបស់ជនរងគ្រោះបានកើតឡើង ។ មានសារមន្ទីរជាច្រើននៅទីតាំងនីមួយៗជាមួយនឹងព័ត៌មានអំពីរបបខ្មែរក្រហមនិងឥទ្ធិពលដ៏គួរឲ្យខ្លាចនៃពលកម្មដ៏ធ្ងន់ធ្ងរការអត់បាយនិងការកាប់សម្លាប់ដែលបានធ្វើមកលើប្រទេសកម្ពុជា ។ អង្គការក្រៅរាជរដ្ឋាភិបាលជាច្រើនដូចជា មជ្ឈមណ្ឌលឯកសារកម្ពុជាជាដើមបានធ្វើសកម្មភាពយ៉ាងសកម្មនៅក្នុងការផ្តល់ឯកសារនិងលាតត្រដាងការពិតអំពីអ្វីដែលបានកើតឡើងនៅអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាអប់រំដល់សាធារណជននិងយុវជនអំពីអតីតកាលដើម្បីការពារមិនឲ្យរបបនេះកើតឡើងសាជាថ្មីម្តងទៀតនៅថ្ងៃអនាគត ។ មានការយកចិត្តទុកដាក់យ៉ាងធំសម្បើមមួយទៅលើការអប់រំអំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជានាពេលថ្មីៗនេះនិងសង្ឃឹមថានិន្នាការនេះនឹងបន្តនិងអនុញ្ញាតឲ្យប្រជា

ជនកម្ពុជាជំនាន់ក្រោយរៀនអំពីអតីតកាលនិងក្រឡេកមកមើលអនាគតដ៏ភ្លឺត្រចះត្រចង់ ។ កម្មវិធីដែលខ្ញុំបានរកឃើញជាពិសេសការអប់រំដែលមានចំណងជើងថា «ទម្លាយភាពស្ងៀមស្ងាត់» ដែលជាល្ខោនមួយដែលនិពន្ធដោយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានិងសម្តែងនៅក្នុងភូមិ ។ គោលបំណងរបស់វាគឺលើកទឹកចិត្តប្រជាជនឲ្យនិយាយអំពីបទពិសោធន៍របស់ខ្លួននៅក្នុងរបបខ្មែរក្រហមនិងជួយសម្រួលដល់ការផ្តល់គំនិតនៅក្នុងសាច់រឿងទៅដល់គ្រួសារនិងអ្នកភូមិដើម្បីជួយដល់ដំណើរការនៃការផ្សះផ្សាជាតិ ។ ខ្ញុំយល់ឃើញថាការសម្តែងនេះពិតមានប្រសិទ្ធភាពខ្លាំងណាស់ក្នុងការផ្សព្វផ្សាយការផ្សះផ្សាជាតិនិងជួយសម្រុះសម្រួលនៅក្នុងប្រទេសកម្ពុជាដូចដែលអ្នកទស្សនាទាំងអស់អាចមានឱកាសដើម្បីផ្តល់ការចងចាំពីអតីតកាលដ៏ឈឺចាប់របស់គេ ។ វាជាការជឿជាក់របស់ខ្ញុំដែលប្រទេសកម្ពុជានឹងបន្តទៅរកទិសដៅត្រឹមត្រូវឆ្ពោះទៅកាន់អនាគតដ៏រុងរឿង ។ នៅខណៈពេលដែលមានទិដ្ឋភាពជាច្រើនដែលការពារប្រទេសកម្ពុជាទៅរកការអភិវឌ្ឍន៍ ខ្ញុំបានឃើញថាប្រជាជននៅក្នុងប្រទេសហាក់ដូចជាសប្បាយរីករាយដោយបានរស់នៅនៅក្នុប្រទេសមួយដែលមានសន្តិភាព ។ អ្នកទាំងនោះរីករាយនឹងរស់នៅក្នុងផ្ទះជាមួយនឹងគ្រួសាររបស់គេ ថែទាំសត្វពាហនៈនិងវាលស្រែ សន្ទនាជាមួយនឹងអ្នកជិតខាងនិងបង្ហាញអំពីការស្រឡាញ់ទៅកាន់អ្នកដែលខ្លួនស្រឡាញ់ ។ ធម្មតានៅក្នុងជីវិតរបស់គេគឺមានអត្ថន័យខ្លាំងណាស់ពីព្រោះប្រជាជនកម្ពុជាជាច្រើនដឹងថាអ្វីជាការសំខាន់ដែលត្រូវដកហូតហើយអ្នកដទៃទៀតគិតថាមិនសំខាន់ទៅវិញ ។

បន្ទាប់ពីអស់រយៈពេលពាក់កណ្តាលទសវត្សរ៍នៃរបបប្រល័យពូជសាសន៍និងពីរទសវត្សរ៍ជាងនៃសង្គ្រាមប្រទេសកម្ពុជានៅទីបញ្ចប់បានទទួលសន្តិភាព ។ មូលដ្ឋានគ្រឹះនៃសង្គមកម្ពុជាត្រូវបានធ្វើឲ្យរញ្ជួយទៅដល់ចំណុចកណ្តាល ហើយស្ទើរតែលុបបំបាត់ចោលទាំងស្រុងដោយការពិសោធន៍សង្គមដែលគ្មានមេត្តារបស់ប៉ុល ពត និងថ្នាក់ដឹកនាំខ្មែរក្រហម ។

ក្រោយពីការក្រឡាប់ចាក់ យ៉ាងខ្លាំងនៃទិដ្ឋភាពជីវិតទំនើបចាប់តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ វាជារឿងធម្មតាប៉ុណ្ណោះដែលថាវាចំណាយរយៈពេលយូរសម្រាប់ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសដើម្បីសាងសង់វាសាជាថ្មីម្តងទៀតនិងសម្រាប់ប្រជាជនកម្ពុជាដើម្បីលុបបំបាត់របួសពីអតីតកាល ។

ខ្ញុំជឿជាក់ថា នង ចាន់ផល បានបង្ហាញអំពីមនោសញ្ចេតនារបស់ប្រជាជនកម្ពុជាជាច្រើននៅពេលដែលគាត់និយាយថា ពេលវេលាគឺជាចម្លើយដ៏ពិតប្រាកដមួយដើម្បីទទួលបាននូវការផ្សះផ្សាជាតិ ។ នៅពេលនិយាយដោយស្មោះត្រង់គាត់បាននិយាយដោយសំឡេងតិចៗថា ការចងចាំរបស់កម្មាភិបាលខ្មែរក្រហមដែលបានវាយ និងទាត់ម្តាយរបស់ខ្ញុំ គឺជាអ្វីដែលខ្ញុំពិបាកនឹងអាចបំភ្លេចបាន ។ ការចងចាំគឺមិនអាចលុបបានហើយគេត្រូវការការពារដើម្បីថតទុកនិងឯកសារថាតើមានអ្វីកើតឡើងក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាអតីតកាលផ្ទុកទៅដោយឈុតឆាកដ៏គួរឲ្យរន្ធត់នៃការកាប់សម្លាប់ ការភ័យខ្លាច និងការអស់សង្ឃឹមក៏ដោយ ក៏ជំនាន់ថ្មីមួយបានចាប់ផ្តើមឡើងដើម្បីធ្វើឲ្យជាសះនូវរបួសទាំងនេះតាមរយៈការអប់រំនិងការស្វែងរកការពិតមួយដ៏ច្បាស់លាស់ ។ វាគឺជាអ្វីដែលខ្ញុំសង្ឃឹមយ៉ាងជ្រៅថា សន្តិភាពនឹងកើតមានជារៀងរហូតនៅក្នុងប្រទេសកម្ពុជា ។

**គៀល ស្រួប**

# ដំណឹងស្វែងរកគ្រួសារ

ខ្ញុំបាទឈ្មោះ ស៊ុន ភី មានអាយុ៤៣ឆ្នាំ រស់នៅភូមិតាគង់ ឃុំណាតាវ ស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ មានឪពុកឈ្មោះ ស៊ុន ហួ និង ម្តាយឈ្មោះ ធី ។ ខ្ញុំសូមប្រកាសស្វែងរកបងប្អូន៦នាក់ដែលបានបាត់ខ្លួននៅឆ្នាំ១៩៧៦ ៖ ១) បងប្រុស ស៊ុន ហួង ២) បងស្រី ស៊ុន រិន ៣) បងប្រុស ស៊ុន ពន្លក ៤) បងស្រី ស៊ុន នឿន ៥) ប្អូនប្រុស ស៊ុន ថៃ ៦) ប្អូនស្រី ស៊ុន ថុល ។ នៅឆ្នាំ១៩៧៦ រយៈពេលពីរទៅបីថ្ងៃក្រោយថ្ងៃដែលខ្មែរក្រហមចាប់ខ្លួនឪពុករបស់ខ្ញុំយកទៅ ខ្មែរក្រហមបានជម្លៀសគ្រួសាររបស់ខ្ញុំទៅកាន់ព្រៃស ។ ចាប់តាំងពីថ្ងៃនោះមក ខ្ញុំក៏បាត់ដំណឹងពីគាត់រហូត ដោយមិនដឹងថានៅរស់ឬក៏ស្លាប់ទេ ។

ប្រសិនបើបងប្អូនណាបានឃើញ ឬបានស្គាល់ សូមទាក់ទងមកអាសយដ្ឋានខាងលើ ឬតាមរយៈលេខទូរស័ព្ទ ០១២ ២៩០ ៨៨១ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ។ **សូមអរគុណ!**

# កសាងឱ្យបានយូរអង្វែង៖ ការផ្សះផ្សាសម្រាប់ប្រជាជនខ្មែរកម្ពុជាក្រោម

ខេត្តពោធិ៍សាត់ជាខេត្តមួយដែលមានសភាពស្ងប់ស្ងាត់ និងសម្បូរដោយដើមឈើ និងវាលស្រែខៀវស្រងាត់ ។ យ៉ាងណាមិញទោះបីជាមានសភាពស្ងប់ស្ងាត់ក៏ដោយ ក៏នៅខេត្តពោធិ៍សាត់មានប្រជាជនប្រមាណ២០០០នាក់ ដែលភាគច្រើនជាខ្មែរកម្ពុជាក្រោមត្រូវបានសម្លាប់នៅវាលដើមត្នោតយ៉ាងអាណោចអាធ័មក្នុងរបបខ្មែរក្រហម ។ សាមសិបឆ្នាំក្រោយមក កាលពីថ្ងៃទី២ សីហា ឆ្នាំ២០០៩ ប្រជាជនក្នុងសហគមន៍ប្រមាណជា៤០០នាក់បានជួបជុំគ្នានៅក្បែរវាលដើមត្នោតនេះដើម្បីចូលរួមក្នុងគម្រោងឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ប្រជាជនដែលចូលរួមបានចែករំលែកបទពិសោធន៍របស់ខ្លួនក្នុងរបបខ្មែរក្រហមសិក្សាស្វែងយល់ពីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងបានពិភាក្សាពីការកសាងបូជនីយដ្ឋានអចិន្ត្រៃយ៍មួយសម្រាប់ជនរងគ្រោះ និងដើម្បីអប់រំក្មេងជំនាន់ក្រោយ ។

បូជនីយដ្ឋានដំបូងគេត្រូវបានកសាងឡើងដោយប្រជាជននៅក្នុងសហគមន៍ភ្លាមៗក្រោយពីរបបខ្មែរក្រហមដួលរលំទៅ ។ ប៉ុន្តែ ប៉ុន្មានឆ្នាំក្រោយមកសំណង់ជាឈើនេះបានពុកផុយហើយធាតុរបស់ជនរងគ្រោះត្រូវបានយកទៅកប់សាជាថ្មីនៅក្រោមដើមពោធិ៍ជាបណ្ដោះអាសន្ន ។ ឥឡូវនេះមជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្ដល់ជំនួយដល់សហគមន៍ដើម្បីសាងសង់បូជនីយដ្ឋានថ្មីមួយ ។ ដើម្បីធានាថាបូជនីយដ្ឋានអាចឋិតថេរបានយូរអង្វែង គម្រោងសាងសង់នឹងត្រូវគូរប្លង់ដោយសិស្សស្ថាបត្យកម្មរបស់សកលវិទ្យាល័យកូឡុមបៀ សហរដ្ឋអាមេរិក ។ ការសាងសង់អគារបូជនីយដ្ឋាននេះនឹងត្រូវប្រមូលថវិកាពីប្រជាជននៅក្នុងសហគមន៍ដៃគូរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយគម្រោងប្លង់ចុងក្រោយបង្អស់នឹងត្រូវសម្រេចជាសមូហភាពដោយប្រជាជនក្នុងតំបន់ ។ បន្ថែមលើនេះបូជនីយដ្ឋាននេះនឹងភ្ជាប់ជាមួយនឹងសៀវភៅមួយដែលមានឈ្មោះជនរងគ្រោះនិងបណ្ណាល័យមួយសម្រាប់អប់រំនិងថែរក្សាជាឯកសារ ។

### ប្រវត្តិសង្ខេបនៃប្រជាជនខ្មែរកម្ពុជាក្រោម

ប្រជាជនខ្មែរកម្ពុជាក្រោមជាជនជាតិភាគតិចមកពីតំបន់ទន្លេមេគង្គក្រោមនៅវៀតណាម ។ ដោយមានការប្រឈមមុខនឹងគំនាបនយោបាយ និងការរើសអើងពូជសាសន៍ ប្រជាជនខ្មែរកម្ពុជាក្រោមជាច្រើនបាននាំគ្នាភៀសខ្លួនមកទៅខេត្តពោធិ៍សាត់ដើម្បីសេរីភាពនិងការប្រកបការងារកសិកម្ម ។ ក្នុងអំឡុងរបបខ្មែរក្រហម ប្រជាជនជាច្រើនត្រូវបាននាំទៅតំបន់បូព៌ានៃប្រទេសកម្ពុជា ដើម្បីសម្លាប់ រួមមានប្រជាជនខ្មែរកម្ពុជាក្រោម ចាម-មូស្លីម និងជនជាតិភាគតិចដទៃទៀត ។ ខ្មែរក្រហមបានចាត់ទុកប្រជាជនខ្មែរកម្ពុជា



បូជនីយដ្ឋាននៅខេត្តពោធិ៍សាត់

ក្រោមថាជាពួក «ក្បាលយួនខ្លួនខ្មែរ» ដូច្នេះហើយបានជាប្រជាជនភាគច្រើនដែលត្រូវបានសម្លាប់នៅខេត្តពោធិ៍សាត់គឺជាប្រជាជនខ្មែរកម្ពុជាក្រោម ។

## និយាយការពិតចេញពីដួងចិត្ត

ប្រជាជនក្នុងសហគមន៍បានជួបជុំគ្នាមិនមែនត្រឹមតែមានការពិភាក្សាពីរឿងសាងសង់បូជនីយដ្ឋានថ្មីប៉ុណ្ណោះទេ ថែមទាំងព្យាយាមផ្សះផ្សារបួសអតីតកាលរបស់គេទៅវិញទៅមកទៀតផង ។ ប្រធានភូមិទាំងអស់ បានជំរុញឲ្យប្រជាជនទាំងអស់ដែលចូលរួមឲ្យ «និយាយការពិតចេញពីដួងចិត្ត» តាមរយៈការចែករំលែករឿងរ៉ាវ មតិយោបល់សម្រាប់ដំណើរការទៅមុខទៀត ។ ទោះបីជាមជ្ឈមណ្ឌលឯកសារកម្ពុជាបានរៀបចំព្រឹត្តិការណ៍នេះដើម្បីចែកសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហមក៏ដោយ ក៏ការប្រជុំជួបជុំនេះបានយកចិត្តទុកដាក់លើកិច្ចសន្ទនាផ្សះផ្សាជាមួយនឹងប្រជាជនក្នុងសហគមន៍ដែរ ។

លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជា បានបើកការពិភាក្សានេះដោយការនិយាយរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់ដែលខ្មែរក្រហមបានបំផ្លិចបំផ្លាញគ្រួសារគាត់ ។ បងស្រីរបស់លោក ឆាំង យុ បងប្រុសថ្លៃ និងកូនពីរនាក់របស់បងស្រីគាត់បានស្លាប់នៅខេត្តពោធិ៍សាត់ក្នុងរបបខ្មែរក្រហម ។ បងប្រុសថ្លៃរបស់លោក ឆាំង យុ ត្រូវបានខ្មែរក្រហមវាយដំយ៉ាងសាហាវឃោរឃៅខណៈពេលដែលបងប្រុសថ្លៃគាត់ត្រូវបានខ្មែរក្រហមចាប់បានពេលដែលគាត់លួចយកត្រសក់មួយនៅផ្ទះដែលកម្មាភិបាលខ្មែរក្រហមបានបោះបង់ចោល ។ ដោយមានសភាពទ្រុឌទ្រោម និងមិនអាចអត់ឃ្លានបាន បងប្រុសថ្លៃគាត់បានស្លាប់ប៉ុន្មានថ្ងៃក្រោយមកដោយសារតែរបួសនិងការអត់ឃ្លាន ។ រីឯបងស្រីរបស់លោក ឆាំង យុ វិញបានធ្លាក់ខ្លួនឈឺបន្ទាប់ពីមរណភាពរបស់ប្ដីគាត់ ហើយមិនអាចបំបៅដោះកូនប្រុសដែលទើបនឹងកើតរបស់គាត់បានឡើយ ។ ទោះបីជាបងស្រីរបស់លោក ឆាំង យុ បានសូមអង្វរឲ្យស្ត្រីដែលអាចបំបៅដោះកូនដទៃទៀត ឲ្យជួយបំបៅដោះកូនប្រុសរបស់គាត់ក៏ដោយក៏មិនបានសម្រេចដែរ មិនបានយូរប៉ុន្មានកូនប្រុសគាត់ក៏បានស្លាប់ទៅ ។ ក្រោយមកទៀត បងស្រីរបស់លោក ឆាំង យុ ត្រូវបានខ្មែរក្រហមសម្លាប់ដោយសារតែចោទប្រកាន់ថា គាត់បានលួចអង្ករ ហើយបានវះពោះបងស្រីគាត់យ៉ាងអាណោចអាធ័មបំផុត ។ ក្រោយពីការស្លាប់របស់បងស្រីរបស់ លោក ឆាំង យុ ក្មួយស្រីរបស់គាត់ឈ្មោះ ថេរីន បានដុះដុំសាច់នៅលើខ្នងផ្នែកខាងក្រោម ដែលមិនអាចព្យាបាលបាន ទោះបីជាលោកយាយរបស់នាងបានព្យាយាមអស់ពីសមត្ថភាពក៏ដោយ ដោយសារតែដុំសាច់នេះ ថេរីន ក៏ត្រូវ



លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាចែកទស្សនាវដ្ដីដល់សិស្ស និងអ្នកភូមិ

ស្លាប់ ។ ចំណែកឯប្អូនស្រីរបស់ ថេរីន ឈ្មោះថា ធារី ជាក្មួយស្រីដែលនៅរស់រានមានជីវិតធ្លាប់បានរៀបរាប់ប្រាប់លោក ឆាំង យុ ពីការចងចាំរបស់នាងដែលបានស្តាប់ឮសំឡេងស្រែកថ្ងូរពោរពេញដោយការឈឺចាប់របស់បងស្រីនាង រហូតដល់ថ្ងៃដែលបងស្រីនាងឈប់ស្រែកយំ ។ ការចងចាំចុងក្រោយរបស់ ធារី ពីបងស្រីនាងគឺការឃើញសាកសពបងស្រីនាងអណ្តែតពីលើគ្រែក្នុងរដូវទឹកជំនន់ ។

ប្រជាជនដែលចូលរួមមានភាពស្ងៀមស្ងាត់ ក្រោយពីបានឮលោក ឆាំង យុ រៀបរាប់ពីបទពិសោធន៍គ្រួសារគាត់ ។ ក្នុងសង្គមដែលជនរស់រានមានជីវិតលាក់លៀម មិនព្រមរ៉ាយរាប់ពីភាពតានតឹង ផ្លូវចិត្តដែលខ្លួនធ្លាប់បានឆ្លងកាត់នោះ លោក ឆាំង យុ បានក្លាយជាឧទាហរណ៍មួយដែលបង្ហាញថាការផ្សះផ្សារទាមទារឲ្យប្រជាជនចែករំលែកនូវរឿងរ៉ាវរបស់ខ្លួនដើម្បីឲ្យអ្នកដទៃទៀតបានយល់ដឹងពីប្រវត្តិសាស្ត្រនិងពីឥទ្ធិពលនៃរបបខ្មែរក្រហម ។

## ចូលរួមនិងប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

លោកប្រធានឃុំទាំងប្រាំរូបបាននិយាយទៅកាន់ប្រជាជនដែលចូលរួមដោយភាពស្មោះត្រង់ និងសេចក្តីគោរពស្រឡាញ់ ។ ប្រធានឃុំទាំងអស់បាននិយាយពីការគាំទ្ររបស់គាត់លើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងបានជំរុញលើកទឹកចិត្តឲ្យជនរស់រានមានជីវិតពីរបបខ្មែរក្រហមទាំងអស់ចូលរួមចែករំលែកនូវរឿងរ៉ាវរបស់ខ្លួន ។ លោកមេស្រុកបានសួរថា ហេតុអ្វីបានជាមិនសូវមានសិស្សសាលាចូលរួមច្រើនហើយសួរដេញដោលឲ្យជនរស់រានមានជីវិតនិយាយជាមួយកូននិងចៅរបស់គេពីរបបខ្មែរក្រហមដើម្បីចៀសវាងអំពើសាហាវឃោរឃៅនេះនៅថ្ងៃអនាគត ។ ជាមួយគ្នានេះប្រធានឃុំម្នាក់ទៀតដែលបាននាំប្រជាជនប្រមាណ១២០នាក់ពីតំបន់របស់គាត់ក៏បានសង្កត់ធ្ងន់ថា ការប្រាស្រ័យទាក់ទងគ្នាគឺពិតជាមានសារសំខាន់សម្រាប់ជនរងគ្រោះនិងកម្មាភិបាលខ្មែរក្រហមដើម្បីឲ្យគេទាំងអស់គ្នាអាចរស់នៅជួបជុំគ្នា ។ គាត់បាននិយាយថាជនរងគ្រោះទាំងអស់ត្រូវតែចែករំលែកបទពិសោធន៍ឲ្យទូលាយ ហើយកុំមានភាពភ័យខ្លាចថាមានការសម្លាប់តទៅទៀត ។ ចំណែកលោកប្រធានឃុំទីបី ក៏បានជំរុញលើកទឹកចិត្តឲ្យប្រជាជន «ចូលរួមនិងប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិ» ។ដោយបានធ្វើការសង្កត់ធ្ងន់លើការគាំទ្ររបស់គាត់លើអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានិងជំនួយសហប្រតិបត្តិការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា លោកប្រធានឃុំរូបនេះ ក៏បាននិយាយថា តុលាការកាត់ទោសនេះនឹងជួយរកយុត្តិធម៌ក្នុងទម្រង់ជានិមិត្តរូបក្នុងការជួសជុលសំណងខូចខាត និងសំណងជំងឺចិត្តដល់កម្ពុជាផងដែរ ។

## មិនគ្រប់ទាំង១០០ភាគរយទេ ប៉ុន្តែគ្រប់គ្រាន់ហើយ

ការប្រជុំនេះក៏បានអប់រំនិងសំណូមពរឲ្យមានសំណួរទាក់ទងនឹងតុលាការកាត់ទោសខ្មែរក្រហមនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប្រជាជនទាំងប្រាំពីររូប ដែលធ្លាប់បានតាមដានពីដំណើរការកាត់ទោស ឌុច ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែករំលែកបទពិសោធន៍អំពីដំណើរទស្សនកិច្ចទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ក្រោយមក ខណៈពេលដែលត្រូវបានសួរថាតើពួកគាត់គាំទ្រតុលាការនេះដែរឬទេ ប្រជាជនភាគច្រើនបានលើកដៃគាំទ្រទាំងអបអរសាទរ ។ ក្រោយពីការប្រជុំខ្ញុំក៏មានឱកាសនិយាយជាមួយនឹងជនរងគ្រោះមួយចំនួន ។ ជនរងគ្រោះទាំងអស់បាននិយាយដោយបញ្ចេញពីអារម្មណ៍ ទាំងកំហឹងនិងភាពឈឺចាប់របស់ខ្លួន ។ គួរឲ្យភ្ញាក់ផ្អើល គ្មាននរណាម្នាក់មានបំណងធ្វើការសងសឹកទេ ជាងនេះទៅទៀត មានតែតុលាការប៉ុណ្ណោះដែលនាំមកនូវការព្យាបាល និងការបញ្ចប់របួសផ្លូវចិត្ត ។ ហ៊ឹម ស៊ីនួន អាយុ១៦ឆ្នាំ ខណៈពេលដែលនាងត្រូវបានបញ្ជាឲ្យចូលក្នុងកងកុមារ នៅក្នុងអំឡុងរបបខ្មែរក្រហម នាងបានបាត់បង់សាច់ញាតិចំនួន២៥នាក់ដែលខ្មែរក្រហមបានចោទប្រកាន់ថាជាខ្មែរកម្ពុជាក្រោម ។ នៅពេលដែលនាងត្រូវសួរថាតើតុលាការកាត់ទោសខ្មែរក្រហមបានជួយធ្វើឲ្យនាងធូរស្បើយទេ ស៊ីនួន បានរៀបរាប់ប្រាប់ថាភាពធូរស្បើយរបស់នាងមិនបានគ្រប់«១០០ភាគរយទេ ប៉ុន្តែគ្រប់គ្រាន់» ។ ជនរស់រានមានជីវិតម្នាក់ទៀតឈ្មោះ សៅ សុផាត ត្រូវបានបង្ខំឲ្យលើកទំនប់ ក្រោយពីកើតកូនបានមួយខែ ។ នាងបានបាត់បង់កូនស្រីនិងឪពុកម្តាយរបស់នាង នៅក្នុងរបបខ្មែរក្រហម ។ ទោះបីជាមានការឈឺចាប់ប៉ុណ្ណាក៏ដោយ សៅ សុផាត បាននិយាយថា នាងមិនចង់សងសឹកអ្វីទេ ហើយបានបង្ហាញការគាំទ្ររបស់នាងទៅលើតុលាការកាត់ទោសខ្មែរក្រហមថា «ជាយានមួយដែលស្វែងរកយុត្តិធម៌ដ៏ពិតប្រាកដ» ។ ជាមួយគ្នានេះ នាងក៏បានកោតសរសើរចំពោះជនដែលដល់

ដែលមិនធ្វើជាមនុស្សសាហាវព្រៃផ្សៃដូចកាលពីមុនតទៅទៀត ។ ដោយឡែកប្រជាជនចាម-មូស្លីម ដែលធ្លាប់ជាគោលដៅរបស់ខ្មែរក្រហមដោយសារតែប្រជាជនចាម-មូស្លីមមានសាសនាជាតិពន្ធុនិងវប្បធម៌ខុសគេ បានរស់នៅប្រកបដោយសេចក្តីសុខក្នុងរបបថ្មីដែរ ។ កែវ មឿ ជាជនជាតិចាម-មូស្លីមបានរៀបរាប់ពីរបៀបដែលកូនទាំងប្រាំនាក់របស់គាត់បានស្លាប់នៅក្នុងរបបខ្មែរក្រហមដែរ ។ កែវ មឿ បាននិយាយថាវាពិតជាលំបាកណាស់ក្នុងការរៀបរាប់ពីទុក្ខវេទនានិងភាពអយុត្តិធម៌ដែលគាត់ទទួលរង ប៉ុន្តែគាត់ក៏បានបង្ហាញពីការយោគយល់ដល់មេដឹកនាំខ្មែរក្រហម ដែលកំពុងត្រូវតុលាការធ្វើការកាត់ទោសក្នុងវ័យដ៏ចាស់នេះ ។ កែវ មឿ បានបន្ថែមទៀតថា ជំនួសឲ្យការសងសឹក «ការស្វែងរកការពិត និងការខិតខំអប់រំក្មេងជំនាន់ក្រោយទើបជាការប្រសើរ ។ វាគ្រប់គ្រាន់ហើយសម្រាប់ការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងនោះ និងការទទួលបាននូវដំណោះស្រាយមួយសម្រាប់សហគមន៍របស់គេ ហេតុដូច្នេះ យើងទាំងអស់គ្នាមិនចាំបាច់ចងកំហឹង ឬគិតអំពីរបបខ្មែរក្រហមនេះតទៅទៀតឡើយ» ។

**ប្ញជនីយដ្ឋានដ៏គង់វង្សយូរអង្វែង**

ទោះបីជាការប្រជុំបានចំណាយពេលតែពីរបីម៉ោងក៏ដោយ ក៏សមាគមនេះបានបង្ហាញ ពីដំណាក់កាលបន្តសម្រាប់ការផ្សះផ្សាប្រជាជនខ្មែរកម្ពុជាក្រោមផងដែរ ។ ប្រជាជនខ្មែរកម្ពុជាក្រោមជ្រើសរើសមិនយកចិត្តទុកដាក់ទៅលើកំហឹង ឬការសងសឹកទេ ប៉ុន្តែគេបានព្យាយាមស្វែងរកនូវដំណោះស្រាយមួយដើម្បីទទួលបានយុត្តិធម៌ មិនថាតាមរយៈការចូលរួមក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬចូលរួមក្នុងគម្រោងមួយដើម្បីគោរពចំពោះការបាត់បង់ជីវិតមនុស្សស្លូតត្រង់ ឬជំរុញឲ្យមានបរិយាកាសដែលបើកចំហមួយសម្រាប់ការបញ្ចេញយោបល់ឡើយ ។ សាមសិបឆ្នាំក្រោយពីការស្លាប់របស់សមាជិកគ្រួសារនិងញាតិមិត្ត ប្រជាជនខ្មែរកម្ពុជាក្រោមបានបង្ហាញថា ពួកគេមិនត្រឹមតែសាងសង់ប្ញជនីយដ្ឋានប៉ុណ្ណោះទេ ពួកគេក៏កំពុងតែស្ថាបនានូវសហគមន៍ដ៏រឹងមាំមួយថែមទៀត ។ **អេឡេន សៅ**

# ឌុច មិនមានការស្មោះត្រង់

ខ្ញុំបាទសូមសរសេរឆ្លើយតបទៅនឹងអត្ថបទរបស់ដុកទ័រ ដេប ឡឺវីន ស្តីអំពី «ឌុច ភាពឥតមនោសញ្ចេតនា និងការបន្ថែមន័យក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា» នាថ្ងៃទី១២ ខែសីហា ឆ្នាំ២០០៩នេះ ។ ខ្ញុំសូមផ្តល់តម្លៃខ្ពស់និងកោតសរសើរយ៉ាងខ្លាំងចំពោះការវិភាគដ៏ស៊ីជម្រៅ និងហ្មត់ចត់របស់លោកបណ្ឌិត ដេប ឡឺវីន ដែលជាអ្នកជំនាញចិត្តសាស្ត្រខាងព្យាបាលនិងដោះស្រាយរបួសផ្លូវចិត្តទៅលើកសក្ខីកម្មរបស់ ឌុច ព្រមទាំងបញ្ហាសីលធម៌ទាក់ទងនឹងសកម្មភាពរបស់ ឌុច និងការវិភាគទៅលើអំពើសាហាវឃោរឃៅដែលកើតក្រោយរបបខ្មែរក្រហម ។ ប៉ុន្តែតើការវិភាគនេះមានន័យអ្វីទៅចំពោះសង្គមខ្មែរបច្ចុប្បន្ន? វាមានអត្ថន័យតិចតួចណាស់ចំពោះប្រជាជនខ្មែរយើង ។ អ្វីដែលយើងទាមទារគឺយុត្តិធម៌ និងការទទួលកំហុសស្មោះអស់ពីចិត្តជាងនេះពីអ្នកគ្រប់គ្រងគុកដែលមានឈ្មោះអាស្រូវបំផុតក្នុងប្រវត្តិសាស្ត្រកម្ពុជា ដោយមានមនុស្សរាប់ពាន់នាក់ត្រូវបានធ្វើទារុណកម្មបង្អត់អាហារនិងសម្លាប់ដូចជាការកម្សាន្តយ៉ាងព្រៃផ្សៃនៅទីនោះ ។ សព្វថ្ងៃ បើយើងទៅទស្សនាគុកទួលស្លែង យើងនឹងស្វែងយល់ពីការពិតដ៏មិនគួរឲ្យជឿតាមរយៈរូបថត បន្ទប់ឃុំឃាំង ឧបករណ៍ធ្វើទារុណកម្ម ចំនួននៃរណ្តៅកប់ខ្មោចនៅជើងឯកដែលអ្នកទោសគុកទួលស្លែងត្រូវនាំយកទៅសម្លាប់ សំណេររបស់អ្នកទោសដែលត្រូវបង្ខំឲ្យសារភាព និងរូបថតរបស់ម្តាយនិងកូនក្មេងជាច្រើន ។ ម្យ៉ាងវិញទៀត បើយើងក្រឡេកមកមើលលិខិតបញ្ជាឲ្យយកទៅសួរចម្លើយនិងសម្លាប់ ដែល ឌុច សរសេរផ្ទាល់ដៃ រូបថតកម្មាភិបាលបម្រើការក្នុងមន្ទីរស-២១ក្នុងពេលប្រជុំ ពេលហូបបាយរួមគ្នា ពេលហ៊ឹកហាត់ និងទឹកមុខដ៏មោះមុត និងពោរពេញ

ដោយមោទកភាពចំពោះអ្វីដែលគេកំពុងធ្វើ យើងអាចសន្និដ្ឋានបានតែរឿងពីរប៉ុណ្ណោះ គឺ ឌុច ត្រូវតែទទួលទណ្ឌកម្មចំពោះអ្វីដែលបានកើតឡើងនៅក្នុងមន្ទីរស-២១ ហើយគាត់គប្បីបង្ហាញនូវការសោកស្តាយនិងវិប្បដិសារីជ្រាលជ្រៅជាងនេះ ។

ការទទួលកំហុសរបស់ ឌុច ពិតជាគួរឲ្យសង្ស័យ ។ ក្នុងផ្នត់គំនិតខ្មែរយើង អ្នកដែលមានវិប្បដិសារី គប្បីមានទឹកមុខក្រៀមក្រោះ ហើយនិយាយដោយទម្លាក់សំឡេងទៅកាន់អ្នកដទៃ ។ គាត់មិនគួរបែរជាមានទឹកមុខពោរពេញដោយជំនឿចិត្ត លើកដាក់សំឡេង និងបង្ហាញកាយវិការនៅពេលនិយាយក្នុងតុលាការទេ ថ្វីបើគាត់ត្រូវបានអនុញ្ញាតឲ្យនិយាយក៏ពិតមែន ។ លើសពីនេះ ពេលដែលមាត់គាត់និយាយពីវិប្បដិសារី ទឹកមុខគាត់នៅតែមានអំនួតទៅលើការស្នេហាជាតិ ការគោរពតាមបញ្ជាថ្នាក់លើ និងការបម្រើបដិវត្តន៍អស់ពីកម្លាំងកាយចិត្ត (ថ្វីត្បិតតែគាត់អះអាងថា គាត់មិនបំពេញកិច្ចការនេះដើម្បីបដិវត្តន៍ តែដើម្បីការពារអាយុជីវិតខ្លួនឯងនិងក្រុមគ្រួសារគាត់ក៏ដោយ) នេះជាភក្តីភាពចំពោះថ្នាក់លើដែលជាទិន្នាការរវាងម្ចាស់ និងអ្នកបម្រើក្នុងប្រពៃណីខ្មែរ ។ ឌុច ថែមទាំងបង្ហាញនូវកំហឹងចំពោះមនុស្សម្នានិងសង្គម ហាក់បីដូចជាកំហឹងដែលអាចឲ្យគាត់ដាក់បន្ទាប់ទៅលើការធ្វើទារុណកម្ម និងសម្លាប់ជនរងគ្រោះយ៉ាងច្រើនបែបនេះ ។ ទាំងនេះគឺមិនមែនជាអត្តចរិតដែលអ្នកទទួលកំហុសម្នាក់គួរមាននោះទេ ។

ប្រសិនបើអ្នកដទៃមានឱកាសទៅគ្រប់គ្រងមន្ទីរស-២១ វិញ តើវានឹងយ៉ាងណាទៅវិញ? នេះមិនពិបាកឆ្លើយតបទេ មិនមានអ្នកណាចាំបាច់ដាក់ខ្លួនឯងនៅក្នុងស្ថានភាពទុគ្រោះនៃការរស់និងស្លាប់ដើម្បីឆ្លើយនឹងសំណួរនេះ និងមិនចាំបាច់ដាក់ខ្លួនរបស់គាត់នៅក្នុងស្ថានភាពរបស់ ឌុច ដើម្បីឆ្លើយនឹងសំណួរនេះដងទេ ។ ខ្មែរក្រហមមិនដែលស្នើឲ្យនរណាម្នាក់ដឹកនាំបែបនេះឡើយ ។ អង្គការមិនដែលចាត់តាំងឲ្យអ្នកណាម្នាក់ទៅគ្រប់គ្រងកន្លែងបែបនោះងាយៗទេ តែគេប្រហែលជាជ្រើសរើសអ្នកដែលមាន «ចរិតលក្ខណៈ» ដែលអាចបំបាត់មនោសញ្ចេតនារបស់ខ្លួន (មានតែមនុស្សបែបនេះទេដែលអាចបំពេញភារកិច្ចនៅកន្លែងដ៏គួរឲ្យតក់ស្លុតនោះរាប់ឆ្នាំ) ដើម្បីធ្វើទារុណកម្ម ធ្វើទុក្ខបុកម្នេញ និងយកទៅសម្លាប់ ។ អង្គការត្រូវការមនុស្សខស្សរាហ៍ ហ្មត់ចត់និងចេះគិតគូរ ។ លើសពីនេះ អង្គការចង់បានអ្នកដែលអាចទុកចិត្តបាន ស្មោះត្រង់ និងបម្រើបដិវត្តន៍អស់ពីកម្លាំងកាយចិត្ត ។ យើងអាចសន្និដ្ឋានថា ចំពោះអ្នកដែលមិនស័ក្តសមនឹងមុខតំណែងនេះ ប្រាកដជាត្រូវដកចេញ ឬសម្លាប់ចោលដោយសារកំហុសណាមួយជាមិនខាន ។

ខ្សែភាពយន្ត «អ្នកអានជាឧទាហរណ៍មួយដ៏គួរឲ្យចាប់អារម្មណ៍ បើប្រៀបធៀបនឹងករណី ឌុច ។ ហាននណាញ ស្កុមីដ ត្រូវបានឃុំឃាំងអស់រយៈពេលជាច្រើនឆ្នាំ ហើយនៅថ្ងៃដែលគាត់ត្រូវបានដោះលែង នាងបានសម្លាប់ខ្លួនឯង ។ ក្រោយពេលទស្សនាខ្សែភាពយន្តនេះ យើងមានអារម្មណ៍ថាគាត់សមនឹងទទួលការអភ័យទោស ព្រោះក្រោយពីបណ្តាលឲ្យស្ត្រីជនជាតិជ្វីហ្វដល់ទៅ៣០០នាក់បាត់បង់ជីវិតគាត់ដឹងថាមានតែការជាប់ពន្ធនាគារនិងមរណភាពរបស់គាត់ទេ ដែលប្រហែលជាអាចលុបលាងទោសកំហុសរបស់គាត់ចំពោះស្ត្រីជនជាតិជ្វីហ្វទាំងនោះបាន ។ វិប្បដិសារីរបស់គាត់មានភាពស្មោះត្រង់បំផុត ។ **អេង កុកថាយ**



មេធាវីការពារក្តី កា សាវុធ

# ស្ថានភាពផ្លូវចិត្តរបស់ ឌុច

នៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០០៩ នៅពេលដែលលោកសាស្ត្រាចារ្យ ដេវីដ ឆេនល័រ ផ្តល់សក្ខីកម្មនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា គាត់ត្រូវបានអញ្ជើញឲ្យនិយាយអំពីអត្តចរិតរបស់ជនជាប់ចោទ កាំង ហ្គេចអ៊ាវ ហៅ ឌុច ដែលជាអតីតប្រធានគុកនៅមន្ទីរស-២១ ដែលជាមជ្ឈមណ្ឌលសម្រាប់ធ្វើទារុណកម្មនិងសម្លាប់មនុស្សក្នុងរបបខ្មែរក្រហម ។ លោកសាស្ត្រាចារ្យ ដេវីដ ឆេនល័រ បានពិពណ៌នាថា ឌុច «ពេញចិត្ត» នឹងការងាររបស់គាត់ ។

ខ្ញុំបានប្រើប្រាស់ចំណេះដឹងរបស់ខ្ញុំក្នុងនាមជាអ្នកជំនាញខាងជំងឺផ្លូវចិត្តនិងអ្នកព្យាបាល ។ ខ្ញុំបានស្តាប់និងមើលយ៉ាងល្អិតល្អន់និងគ្រប់ជ្រុងជ្រោយ នៅពេល ឌុច ផ្តល់កំណត់សម្គាល់ចុងក្រោយ ។ នៅពេលនោះ ខ្ញុំបានព្យាយាមស្តាប់ស្ត្រីជនជាតិអាមេរិកម្នាក់ដែលអង្គុយនៅក្រោយខ្ញុំ ដោយនិយាយថា គាត់មានអារម្មណ៍ «គួរឲ្យខ្ពើម» ដែលឃើញ ឌុច ខ្វះការភ្ញាក់រឭក ។ នៅថ្ងៃបន្ទាប់ខ្ញុំខិតខំស្វែងយល់ពីខ្លឹមសារអ៊ីម៉ែលមួយដែលបញ្ជូនបន្តមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលក្នុងនោះសាស្ត្រាចារ្យម្នាក់បានពណ៌នា ឌុច ថាជា «បិសាច» ។

ខ្ញុំសរសេរមកនេះដើម្បីលើកឡើងពីបញ្ហាបីដែលចេញពីការសង្កេតលើ ឌុច និងសាក្សីគ្រប់រូបក្នុងអំឡុងថ្ងៃទី៦, ៧ ខែសីហា ឆ្នាំ២០០៩ ។

ចំពោះបញ្ហាដំបូង គឺមានចម្ងល់ជាបន្តបន្ទាប់ទាក់ទងទៅនឹងភាពដែលអាចជឿជាក់បាននៃសក្ខីកម្មរបស់សាក្សីនិងចុងចោទ ។ ទាក់ទងនឹងបញ្ហានេះ ខ្ញុំយល់ឃើញថា ពាក្យ «ភាពអាចជឿទុកចិត្តបាន» គឺមានតម្លៃស្មើទៅនឹងពាក្យដែលត្រូវបានប្រើប្រាស់នៅក្នុងការស្រាវជ្រាវតាមបែបគុណភាព ហើយគួបផ្សំជាមួយនឹងវិធីសាស្ត្រសម្រាប់វាស់វែងអំពីតួនាទីដែលបរិបទនេះដើរតួក្នុងការចងចាំនិងការរំឭកឡើងវិញ ។ ឧទាហរណ៍ថា ប្រសិនបើនរណាម្នាក់ស្ថិតនៅក្នុងស្ថានភាពមួយដែលបង្កឲ្យមានភាពរំជួលចិត្តខ្លាំងនោះគាត់នឹងអាចមានអាកប្បកិរិយាចម្លែកដែលយើងអាចកត់សម្គាល់ឃើញបាន ។ បញ្ហាទាក់ទងទៅនឹងភាពដែលអាចជឿជាក់បាននេះ ត្រូវបានលើកឡើងនៅក្នុងអំឡុងពេលនៃសក្ខីកម្មរបស់បណ្ឌិត ដេវីដ ឆេនល័រ ។

បើនិយាយឲ្យងាយយល់ គឺមានមនុស្សពីរប្រភេទដែលក្នុងនោះក៏មាន ឌុច ម្នាក់ដែរ ។ ម្ខាងគឺមានសាក្សីដែលស្ថិតនៅក្នុងក្រុមអាយុមួយដែលងាយនឹងប៉ះពាល់ដល់អារម្មណ៍ នៅពេលដែលគាត់ត្រូវបានយកចេញពីតថភាពពិត ការអនុវត្តការការពារសតិអារម្មណ៍តាមបែបប្រពៃណី ហើយនិងគ្រួសារដែលពោរពេញទៅដោយសេចក្តីសុខនិងសុវត្ថិភាព ។

ភ័ស្តុតាងនៃរបួសផ្លូវចិត្តដ៏ខ្លាំងក្លារបស់គាត់គឺត្រូវបានបង្កប់នៅក្នុងការពិតដែលថាពួកគាត់ពុំបានស្វែងយល់ពីការពិតឲ្យបានច្បាស់លាស់នោះទេ ។ ឆ្លងកាត់ការស្រាវជ្រាវអស់រយៈពេល ១០ឆ្នាំរបស់ខ្ញុំទាក់ទងនឹងឹកការរៀបអាពាហ៍ពិពាហ៍ និងការសម្រាលកូនក្នុងរបបខ្មែរក្រហម ក៏ដូចជាការធ្លាក់ចុះនៃពិធីបុណ្យប្រពៃណីរបស់កម្ពុជាប្រជាធិបតេយ្យ ខ្ញុំត្រូវតែបង្កើតវិធីសាស្ត្រដែលគួរឲ្យទុកចិត្តនិងមានគុណភាពមួយដើម្បីអាចតាមដានពីរឿងរ៉ាវអ្នកដែលនៅរស់ទាំងនោះ ជាជាងបោះបង់ពួកគាត់ចោលដោយសារតែយល់ឃើញថាមិនគួរឲ្យទុកចិត្ត ។

ម៉្យាងវិញទៀត គឺមានមនុស្សមួយក្រុមទៀត ដូចជា ឌុច ដែលមានសមត្ថភាពខ្ពស់ក្នុងការរំឭកឡើងវិញអំពីព័ត៌មានយ៉ាងពិស្តារនិងត្រឹមត្រូវដែលធ្វើឲ្យគាត់មើលទៅដូចជាមិនមែននិយាយការពិត (ដូចជាក្លែងបន្លំ) នៅក្នុងក្រសែភ្នែកទស្សនិកជន ។ ប៉ុន្តែដំណើរការនេះក៏ជាភ័ស្តុតាងមួយដែរ ។ ការកម្រើកដៃជើង សំឡេង និងសមត្ថភាពដែលគាត់អាចអង្គុយរាប់ម៉ោងដោយមិននិយាយស្តីអ្វីទាំងអស់ នោះគឺជាសមត្ថភាពដែលសេសសល់ ដែលប្រហែលជាបានមកពីបទពិសោធន៍នៃបដិវត្តន៍ជ្រុលនិយម ។

ដូចជាឧទាហរណ៍ដែលទាក់ទងមួយ ខ្ញុំមើលកុនរបស់ លោក ប៉ាន់ រិទ្ធី ជាច្រើនលើកច្រើនសាអំពីការសម្តែងឡើងវិញរបស់អ្នកសួរចម្លើយនៅក្នុងមន្ទីរស-២១ ។ ចំពោះអ្នកអង្កេតជាទូទៅ

សកម្មភាពនិងកាយវិការដែលបន្ទិតបន្ទំបែបនោះសម្តែងពីភាពអមនុស្សធម៌ ចិត្តឃោរឃៅ ។ ប៉ុន្តែខ្ញុំយល់ឃើញថា វាសាមញ្ញណាស់ ។

បើវិភាគតាមទស្សនៈនៃការសិក្សាអំពីរបួសផ្លូវចិត្ត កាយវិការដែលហាក់ដូចបានគ្រងទុកជាមុនហើយដដែលៗនេះអាចបង្ហាញនូវភាពខុសប្រក្រតីបណ្តាលមកពីរបួសផ្លូវចិត្ត ដែលអាចចាត់ចូលក្នុងអារម្មណ៍មួយដែលមិនព្រមធ្វើតាម ពេលដែលផ្លូវកាយនិងផ្លូវចិត្តរបស់មនុស្សមិនអាចស្ថិតក្នុងកន្លែង និងពេលវេលាតែមួយបានទៀត (ដូចក្នុងករណីសាក្សី) ឬពេលដែលផ្លូវកាយនិងផ្លូវចិត្តរបស់មនុស្សស្ថិតក្នុងកន្លែងនិងពេលវេលាមួយយូរពេក (ដូចក្នុងករណីអតីតយោធានៅក្នុងភាពយន្តរបស់លោក រិទ្ធី) ។

ជាសរុប ខ្ញុំសូមលើកឡើងនូវសំណួរខ្លះៗសម្រាប់ធ្វើការពិចារណា៖ តើយើងនឹងបាត់បង់ខ្លឹមសារអ្វីខ្លះនៅពេលដែលយើងបន្ថែមន័យ ឬក៏លើកជាសំណួរឡើង?

ឧទាហរណ៍ដូចជាសំណួរដែលចោទសួរថាតើ ឌុច មានវិប្បដិសារីដែរឬទេ? ការពិតទៅវិប្បដិសារីគឺជាស្ថានភាពផ្លូវចិត្តមួយមិនមែនជាចរិតលក្ខណៈនោះទេ ។ ដូច្នេះ ពេលខ្លះគាត់ប្រហែលជាគាត់មានវិប្បដិសារី ហើយពេលពេលខ្លះទៀតគាត់ប្រហែលជាមិនមានវិប្បដិសារីទេ ។ នេះគឺជាភាពខុសគ្នារវាងស្ថានភាពផ្លូវចិត្តនិងចរិតលក្ខណៈ ។

អ្វីដែលខ្ញុំបានឃើញតាមរយៈក្រសែភ្នែករបស់ខ្ញុំដែលក្នុងនាមខ្ញុំជាអ្នកជំនាញខាងរបួសផ្លូវចិត្តម្នាក់ គឺ ឌុច នៅតែតាំងខ្លួនជាអ្នកបដិវត្តន៍ម្នាក់ ហើយគាត់មានសមត្ថភាពពិសេសក្នុងការបិទបាំងមនោសញ្ចេតនា ។ ឆ្លងតាមការសង្កេតថាតើ ឌុច បិទបាំងមនោសញ្ចេតនាខ្លួនដោយរបៀបណានិងនៅពេលណា យើងអាចស្វែងយល់កាន់តែច្បាស់ពីបាតុភូត «បំផ្លាញជ្រុលនិយម»នេះ ។ តាមរយៈការស្រាវជ្រាវ ខ្ញុំបានសិក្សាអំពីដំណើរការនៃការធ្វើឲ្យដូចទៅនឹងលទ្ធិជ្រុលនិយម ។

ខ្ញុំបានសិក្សាអំពីអ្វីដែលបានកើតឡើងនៅពេលដែលការប្រណិប័តន៍និងការគោរពសាសនាប្រពៃណីខ្មែរត្រូវបានលុបបំបាត់ទាំងស្រុង ហើយត្រូវបានជំនួសដោយការប្រណិប័តន៍ផ្សេងទៀត ហើយថាតើភាពភ័យខ្លាចត្រូវបានគ្រប់គ្រងដោយរបៀបណានៅក្នុងករណីនេះ (ជាមួយនឹងកំណត់សម្គាល់ឃើញថាការអង្គុយនៅស្ងៀមមិនកម្រើកគឺជាសកម្មភាពនៅស្ងៀមដែលធ្វើឡើងម្តងហើយម្តងទៀត) ។ ខ្ញុំមិនបានសង្កេតមើល ឌុច ដោយមានការរំពឹងទុកឬវាយតម្លៃគាត់ក្នុងផ្លូវណាមួយឡើយ តែខ្ញុំគ្រាន់តែសង្កេតប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ ខ្ញុំនៅតែមានភាពឆ្ងល់ចំពោះសមត្ថភាពមិនធម្មតារបស់ ឌុច ក្នុងការ «ប្រកាន់គោលជំហរខ្លួន» ដោយមិន «ចុះចាញ់» ។

ខ្ញុំបានដើរចេញពីអង្គជំនុំជម្រះដោយគិតអំពីមូលហេតុថាតើការប្រែក្លាយខ្លួនជាអ្នកប្រកាន់សាសនាគ្រិស្តក្នុងពេលថ្មីៗនេះរបស់ ឌុច មានបង្កប់នូវអត្ថន័យផ្សេងទៀតដែរឬទេ (ទោះបីជាអ្នកខ្លះគិតថានោះគឺជាការបង្ហាញពីវិប្បដិសារីក៏ដោយ) ។ ប្រាកដជាមានមូលហេតុអ្វីមួយបង្កប់ក្នុងចិត្តរបស់ ឌុច (ដែលធ្វើឲ្យគាត់បានបោះបង់ជាថ្មីម្តងទៀត) ដោយលះបង់ជំនឿរបស់គាត់ ហើយបែរទៅទទួលយក «សាសនាផ្សេង» នេះគឺពិតជាចម្លែកខ្លាំងណាស់ ។ តើយើងនឹងដឹងអំពីអ្វីថែមទៀតប្រសិនបើកំណត់សម្គាល់ «ដំណើរការ» នៃសេរីភាពក្នុងការជ្រើសរើសសាសនាបែបនេះបានឲ្យទម្ងន់ទៅលើការផ្តោតទៅលើ «ទស្សនៈ» ដូចដែលភស្តុតាងកំពុងតែត្រូវបានប្រមូលផ្តុំ?

**ផេច ឡឺវីន**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង ៧-៧:៣០ ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ថ្ងៃមុនខ្ញុំបានឃើញបិសាច

ថ្ងៃមុនខ្ញុំបានឃើញបិសាចត្រឹមតែមួយថ្ងៃគឺនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៩ ដែលខ្ញុំបានចូលរួមតាមដានដំណើរការសវនាការ កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរស-២១ ដែលជាកន្លែងធ្វើទារុណកម្មនិងសម្លាប់ដ៏សាហាវរបស់ខ្មែរក្រហម ។ ក្រោមការគ្រប់គ្រងអំណាចរបស់ ប៉ុល ពត នៅរវាងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩មានមនុស្សប្រមាណ១៦.០០០នាក់ត្រូវបានបញ្ជូនមកមន្ទីរស-២១សព្វថ្ងៃជាសារមន្ទីរ(ប្រល័យពូជសាសន៍ទួលស្លែង) និងមានមនុស្សប្រមាណ១៧នាក់ប៉ុណ្ណោះដែលនៅរស់ជីវិត ។ នៅថ្ងៃដែលខ្ញុំបានចូលរួមសវនាការ ហ៊ឹម ហ៊ុយ អតីតឆ្មាំគុក និងត្រូវបានស្គាល់ថាជាឃាតករដែរនោះបានចូលខ្លួនមកធ្វើជាសាក្សី ។ តុលាការបានសួរគាត់ថាតើមាននរណាម្នាក់ដែលបានរួចចេញពីមន្ទីរស-២១ទេ ឬក៏អ្នកទាំងនោះមិនដែលមានវាសនាចេញមកវិញទេ ។ ហ៊ឹម ហ៊ុយ បានឆ្លើយថាគ្មាននរណាម្នាក់មានវាសនាចេញមកវិញទេអ្នកទាំងនោះត្រូវគេបញ្ជូនចូលហើយបន្ទាប់មកគឺ«ចប់» ។ អ្នកភូមិចំនួន៣៥០នាក់មកពីខេត្តកំពង់ធំដែលមានវត្តមាននៅថ្ងៃនោះបានខ្សឹបគ្នាទៅវិញទៅមក ពេញសាលសវនាការ ។ អ្នកស្រុកមុខតែនឹងមានការភ្ញាក់ផ្អើលចំពោះការសម្រាលពាក្យរបស់ ហ៊ឹម ហ៊ុយ ។ អ្នកជាប់ឃុំនៅគុកទួលស្លែងមិនមែនគ្រាន់តែចប់ទេអ្នកជាប់ឃុំត្រូវបានសម្លាប់ឬក៏ក្នុងភាសារបស់ខ្មែរក្រហមថា អ្នកទោសត្រូវបាន«កម្ទេច» ។

តាំងពីដើមមកខ្ញុំគឺជាអ្នកគាំទ្រគំនិតក្នុងការបង្កើតតុលាការខ្មែរក្រហមស្របជាមួយនឹងគំនិតមជ្ឈមណ្ឌលឯកសារដែរក្នុងការស្វែងរកការពិតបើកកកាយនូវរឿងរ៉ាវពិត និងអ្វីដែលកើតមានឡើងហើយវាជាវិធីប្រសើរបំផុតក្នុងការទប់ស្កាត់អំពើហិង្សាឃោរឃៅកុំឲ្យកើតមានម្តងទៀត ។ ក៏ប៉ុន្តែចេញពីការអង្កេតមួយថ្ងៃនោះ ខ្ញុំសារភាពថា ខ្ញុំទៅទីនោះបានត្រឹមតែសម្លឹងមើល ឌុច ដែលនាំមកវិញនូវភាពរន្ធត់និងសោកសៅចំពោះដំណើរការនេះប៉ុណ្ណោះ ។ ខ្ញុំពិតជាបានត្រឹមតែគិតថាសវនាការ ឌុច នឹងគ្មានតម្លៃអ្វីនោះទេ ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដទៃទៀតរួមមាន នួន ជា បងធំទីពីរ បន្ទាប់ពី (ប៉ុល ពត) អៀង សារី ខៀវ សំផន និង អៀង ធីរិទ្ធ ទាំងអស់គ្នាមុខតែនិយាយថារឿងរ៉ាវទាំងអស់ដែលបានកើតឡើងមិនមែនបណ្តាលមកពីគាត់ទេ ប៉ុន្តែគំនិតទាំងអស់គឺចេញមកពី ប៉ុល ពត, សុន សេន និងអ្នកផ្សេងៗទៀតដែលបានស្លាប់បាត់ទៅហើយ និងមិនអាចមកការពារខ្លួនបាន ។ នេះក៏ព្រោះតែមានតែ ឌុច ម្នាក់ ដែលបានសម្រេចចិត្តសារភាពពីកំហុសរបស់គាត់និងព្រមរៀបរាប់ប្រាប់រឿងរ៉ាវទាំងអស់ដែលបានកើតឡើងកាលពី៣០ឆ្នាំមុន ។ ឌុច បានចូលជាគ្រិស្តសាសនិកនៅពេលគាត់ស្នាក់នៅជំរុំជនភៀសខ្លួនតាមព្រំដែនថៃ ។ នៅពេលអ្នកកាសែត នីក ឌុនលុប ចំណាំគាត់បាន ឌុច បាននិយាយថា«ទាំងអស់នេះគឺជាបំណងមកពីព្រះជាម្ចាស់ដែលបណ្តាលឲ្យអ្នកមកដល់ទីនេះ ។ ឥឡូវនេះអនាគតរបស់ខ្ញុំស្ថិតនៅក្នុងដៃព្រះជាម្ចាស់ហើយ» ។ ឌុច បាននិយាយជាសាធារណៈថាគាត់មានការសោកស្តាយខ្លាំងណាស់ហើយគាត់សូមទោស ។ ពេលដែលតុលាការនាំគាត់ទៅដើរឯកកន្លែងសម្លាប់អ្នកទោសដែលដឹកមកពីទួលស្លែងនិងជាផ្នែកមួយនៃដំណើរការស៊ើបអង្កេតសម្រាប់អង្គសវនាការជំនុំជម្រះ ឌុច បានយំ ។ ព្យួរច្នេះខ្ញុំគិតថាតុលាការនេះពិតជាមានតម្លៃ យ៉ាងហោចណាស់ ក៏មានមនុស្សម្នាក់បានបង្ហាញនូវការសោកស្តាយចំពោះការសម្លាប់នៅសម័យនោះដែរ ។ ការចូលជាគ្រិស្តសាសនិកពិតជាត្រូវនឹងទង្វើនេះណាស់ ។ នៅក្នុងក្នុងព្រះពុទ្ធសាសនាគ្មានទស្សនវិជ្ជាណាមួយចង្អុលបង្ហាញឲ្យយើងធ្វើការលើកលែងទោសទេ ។ បើអ្នកធ្វើអំពើល្អអ្នកនឹងទទួលផលល្អ ប្រសិនបើ អ្នកប្រព្រឹត្តអំពើអាក្រក់អ្នកនឹងទទួលបានផលអាក្រក់ពីទង្វើរបស់អ្នក ។ គ្មានព្រះជាម្ចាស់ណាអាចមកលើកលែងទោសឲ្យអ្នកបានទេ ។ មានតែចូលជាគ្រិស្តសាសនិកទេទើប ឌុច អាចធ្វើរឿងអ្វីមួយដែលគាត់មិនអាចធ្វើបានឲ្យក្លាយទៅជាការព្យាយាមបង្ហាញក្នុងផ្លូវត្រឹមត្រូវវិញ ។ ដូចគ្នានេះ ឌុច កំពុងតែធ្វើបែបនេះនៅក្នុងតុលាការ ។ អង្គជំនុំជម្រះស្ថិតនៅក្រោយកញ្ចក់ ហេតុនេះ

អ្នកអង្កេតអាចមើលទៅក្នុងនោះជារៀងរាល់ថ្ងៃដូចមើលអ្នកសម្តែងសិល្បៈនៅលើឆាកឬនៅលើផ្ទាំងសំពត់សដូច្នេះដែរ ។ អ្នកទស្សនាអាចស្តាប់ដំណើរការនេះជាភាសាខ្មែរតាមរយៈប្រដាប់បំពងសំឡេង និងភាសាបារាំង ឬ អង់គ្លេស តាមរយៈឧបករណ៍សម្រាប់ស្តាប់សំឡេងជាប់ទៅនឹងត្រចៀកដែលអាចផ្តល់ជូននូវការបកប្រែដែលស្ទើរតែស្របគ្នា ។ ឌុច ជាជនជាប់ចោទបានអង្គុយនៅផ្នែកខាងស្តាំ ។ ស្បែកគាត់មានពណ៌លឿងព្រឿងៗ ប៉ុន្តែមើលទៅគាត់នៅតែរឹងមាំហើយប្រុងខ្លួនជាប់ជានិច្ច ។ មើលទៅ ឌុច ដូចជាមើលដំណើរការនោះដោយគ្មានបញ្ចេញនូវអារម្មណ៍អ្វីទាំងអស់ ទ្រោបមកខាងមុខហើយសម្លឹងមើលទៅសាក្សីយ៉ាងច្បាស់លាស់បំផុត ។ ឌុចអង្រួនជើងអង្អែលជាយតុដែលជាកាយវិការមួយ ប្រាប់យើងថាគាត់ប្រហែលជាច្រួលច្រាលក្នុងចិត្តជាងអ្វីដែលគាត់បង្ហាញមកខាងក្រៅ ។ ពេលខ្លះទៀត គាត់ក្រឡេកមើលជាមួយភ្នែកដែលមានពន្លឺមកកាន់អ្នកចូលរួមទោះត្រឹមតែមួយប៉ប្រិចភ្នែកក៏ដោយ ។ លោកវ៉ាន ណាត ដែលជាអ្នកគូររូបដ៏ល្បីល្បាញនិងជាជនរងគ្រោះនៅមន្ទីរស-២១បានប្រាប់ខ្ញុំថា «អ្នកដឹងទេ ឌុច គឺជាអ្នកចេះដឹងម្នាក់ ហើយគាត់មានពេលប៉ុន្មានឆ្នាំនេះ (ចាប់ពីឆ្នាំ១៩៩៩ ពេលគេរកគាត់ឃើញហើយចាប់គាត់ដាក់គុករហូតដល់ពេលដែលសវនាការចាប់ផ្តើមកាលពីឆ្នាំមុន) ដើម្បីត្រៀមខ្លួនឆ្លើយតបទៅនឹងគ្រប់សំណួរ និងគ្រប់ភ័ស្តុតាងទាំងអស់ ។ គាត់មានចម្លើយសព្វគ្រប់អស់ទៅហើយ ។ ឌុច កំពុងតែស្ថិតនៅចំកណ្តាលនៃការសម្តែងមួយហើយប្រការខ្លះ គាត់ពេញចិត្តនឹងការសម្តែងនេះហើយគាត់សម្រេចចិត្តដើរតួនៅក្នុងនោះដែរ ។ អ៊ីចឹងតើមានបញ្ហាអ្វី? ហេតុអ្វីបានជាខ្ញុំយល់ថាវាគួរឲ្យរំខានយ៉ាងនេះ? កំហុសរបស់ ឌុច គឺជាក់ស្តែងណាស់ ។ គាត់បានសារភាពថាគាត់ជាប្រធានមន្ទីរស-២១ ។ គាត់និយាយថា «ខ្ញុំគឺជាជនឧក្រិដ្ឋកំពូលទទួលខុសត្រូវចំពោះអំពើទាំងអស់ដែលបានប្រព្រឹត្តនៅមន្ទីរស-២១» ។ ហត្ថលេខា និងស្នាមមេដៃរបស់គាត់ស្ថិតនៅគ្រប់ឯកសារទាំងអស់ ។ ខ្ញុំធ្វើការនៅផ្នែកឯកសារនៅទួលស្លែង រយៈពេល៦ខែនៅឆ្នាំ១៩៩០ ដោយធ្វើការចុះលេខនិងថតចម្លងឯកសារនៅក្នុងមីក្រូហ្វីល ។ ខ្ញុំបានឃើញចំណាររបស់គាត់នៅគែមទំព័រនៃសន្លឹកនីមួយៗមានដូចជា «សួរគាត់ពីរឿងនេះ» «វាកុហកនៅត្រង់នេះ» ហើយដែលសាហាវជាងគេនោះគឺ «យកពួកវាទៅកម្ទេចទាំងអស់» នៅលើបញ្ជីឈ្មោះអ្នកទោស ។ គាត់សារភាពថា គាត់បានទទួលការណែនាំតិចតួចក្នុងការរៀបចំនិងដំណើរការមន្ទីរស-២១ ។ គាត់ជាអ្នកសម្រេចចិត្តទៅលើរបៀបនៃការធ្វើ ទារុណកម្ម និងការសម្លាប់ ទោះជាគាត់និយាយថាគាត់ដឹងថាកាលនោះរឿងរ៉ាវដែលបានមកពីការធ្វើទារុណកម្មសុទ្ធតែមិនពិតទាំងអស់ ។ អ្នកទាំងនោះត្រូវគេវាយនឹងដំបង ឆក់ខ្សែភ្លើង ជ្រមុជទឹក បង្អត់អាហារ និង បំបាក់ រហូតដល់អ្នកនោះសារភាពនូវរឿងរ៉ាវដែលមិនត្រឹមត្រូវថាខ្លួនជាភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ ឬក៏មានបំណងចង់ផ្តួលរំលំបដិវត្តន៍ ។ ទាល់តែដល់ពេលអ្នកជាប់ទោសនោះសារភាពទើបខ្មែរក្រហមយកទៅសម្លាប់ ។ យើងមានសៀវភៅដែលសិក្សាយ៉ាងល្អិតល្អន់របស់ដេវីដ ឆេនល័រ និងកុនដ៏គួរឲ្យរន្ធត់និងមានឥទ្ធិពលរបស់ រិទ្ធី ប៉ាន់ ដែលមានចំណងជើងដូចគ្នា «មន្ទីរស-២១» ដើម្បីនាំយើងទៅកាន់កន្លែងនោះ ។

ចំណែកឯ នៅតុលាការវិញនៅពេលដែលសាក្សីម្នាក់ៗឡើងធ្វើសក្ខីកម្ម ឌុច និងមេធាវីការពារក្តីរបស់គាត់មានឱកាសសួរសំណួរទៅកាន់សាក្សីហើយគាត់យកសក្ខីកម្មម្តងមួយបន្ទាត់មកសួរ ។ អ្វីដែលបានកើតឡើងនោះគឺដំនៀលដៀលដាក់ទៅលើសាក្សីនីមួយៗត្រូវបានបាត់បង់ ។ រយៈពេល៣០ឆ្នាំក្រោយមក ការចងចាំបានរលត់ទៅម្តងបន្តិចៗ ។ តើ ឌុច បានបញ្ជាឲ្យមានការកម្ទេចបុរស នារី និងកុមារចំនួន១៦.០០០នាក់ ឬក៏១២.០០០នាក់ទេ? តើ ឌុច បានទៅកន្លែងសម្លាប់នៅជើងឯកចំនួនម្តងឬពីរដងឬច្រើនដង? តើ ឌុច មានដែលសម្លាប់នរណាម្នាក់ដោយផ្ទាល់ដៃឬទេ ឬក៏គ្រាន់តែបញ្ជាឲ្យកូនចៅរបស់គាត់ធ្វើ ហើយគាត់គ្រាន់តែជាអ្នកមើលថាកិច្ចការនោះសម្រេចឬអត់? ខ្ញុំបានទទួលទានបាយថ្ងៃត្រង់ជាមួយមេធាវីជនជាតិបារាំងជាស្ត្រីម្នាក់ដែលបានអង្កេតមើលតុលាការ ដោយធ្វើការប្រៀបធៀបជាមួយនឹងដំណើរការនៅប្រទេសរវ៉ាន់ដា និងប្រទេសអាហ្វ្រិកខាងត្បូង ។ គាត់និយាថា ឌុច បានសហការយ៉ាងល្អគាត់បានជួយដល់ដំណើរការនេះហើយគាត់ក៏បានបង្ហាញវិប្បដិសារីចំពោះទង្វើរបស់គាត់ ។ មេធាវីនោះគិតថាគាត់មុខតែនឹងបានទទួលការបន្ធូរបន្ថយទោស ។ មិនមែនជាបុគ្គលដ៏អាក្រក់ម្នាក់នោះទេ នោះជារបៀបនិយាយរបស់គាត់មិន

មែនជាអ្វីដែលគាត់បាននិយាយដោយផ្ទាល់ទេ ។ ខ្ញុំទៅជាស្រឡាំងកាំង ។ បន្ទាប់មកទៀត គឺបញ្ហាជាមួយនឹងការបកប្រែភាសា ។ ការបកប្រែនៅក្នុងឧបករណ៍ស្តាប់សំឡេងនៅត្រចៀកនិងការបកប្រែជាភាសាខ្មែរគឺមិនដូចគ្នាទេ ។ ខ្ញុំបានមើលសវនាការនេះរាប់ខែតាមរយៈគេហទំព័រដ៏អស្ចារ្យមួយ នោះគឺcambodiatribunal.org ដែលបាននាំយើងទៅទាន់នឹងដំណើរការសវនាការជារៀងរាល់ថ្ងៃ ដោយមានទាំងការបកប្រែផង និងគេហទំព័រដែលមានព័ត៌មានសង្ខេប ។ ចំណែកឯនៅក្នុងបន្ទប់សវនាការខ្ញុំឃើញពីភាពខុសគ្នា ។ នៅពេល ហ៊ឹម ហ៊ុយ និយាយអ្នកដែលបានជាប់នៅមន្ទីរស-២១ គាត់ហៅអ្នកទាំងនោះថាអ្នកទោស ឬអ្នកកាត់ទោស ដែលមានន័យត្រង់ថាអ្នកដែលរកឃើញថាមានទោស ។ បើសិនជាបកប្រែជាភាសាអង់គ្លេសវិញ ពាក្យនេះមានន័យថា «ជនជាប់ឃុំ» ។ អត្ថន័យពាក្យទាំងពីរគឺមិនដូចគ្នាទេ ។ ពាក្យដំបូងបង្កប់នូវអត្ថន័យដែលថាមនុស្សដែលបានជាប់ឃុំនិងសម្លាប់នៅមន្ទីរស-២១សុទ្ធតែមានទោសពីកំហុសអ្វីមួយ ចំណែកឯពាក្យខាងក្រោយមានន័យផ្ទុយពីនេះ ។ ពេលដែលអ្នកទោសត្រូវគេធ្វើទារុណកម្មនៅមន្ទីរស-២១អ្នកនោះត្រូវគេសួរថា តើយើងបានធ្វើអ្វីដែលក្បត់នឹងបដិវត្តន៍អង្គការ (ជាក្រុមឬបក្សមួយ) មិនដែលធ្វើខុសទេដូច្នេះមានតែអ្នកឯងជាអ្នកប្រព្រឹត្តខុសអ្វីមួយតើកំហុសនោះជាអ្វីទៅ? ភាសារបស់អតីតអ្នកជាប់គុកនិងអ្នកសម្លាប់នៅតែបង្កប់នូវសំនៀងបែបនេះនៅឡើយ ទោះជាវាបានរលុបខ្លះដោយសារការបកប្រែក៏ដោយ ។ ពេល ឌុច ហៅឈ្មោះសាក្សីគាត់អាចមានឱកាសនឹងនិយាយដោយកំហឹងទៅកាន់សាក្សីទាំងនោះឬក៏បន្ទោកអ្នកទាំងនោះហើយវាយប្រហារដោយប្រើប្រាស់ភាសាដូចជា ភ្ជាប់ពាក្យបុព្វបទ «អា» ទៅនឹងឈ្មោះមនុស្ស ។ ក្នុងនោះគ្មានការបកប្រែដោយផ្ទាល់ជាភាសាអង់គ្លេសទេ ប៉ុន្តែបញ្ញវន្តជាច្រើនប្រើ «ពាក្យថាអាក្រក់ដូជាតិគ្មានសីលធម៌» ថា «អាពត» ។ នៅពេល ឌុច សម្គុត គាត់ចង្អុលម្រាមដៃគាត់ទៅក្នុងខ្យល់ហើយដំឡើងសំឡេងរបស់គាត់ ។ នេះមិនមែនជាបុរសម្នាក់ដែលមានការភ្ញាក់ខ្លួន សុំអភ័យទោសចំពោះបទឧក្រិដ្ឋនោះទេ ។ នេះជាបុរសម្នាក់កាលពីទសវត្សរ៍ ១៩៧០ជាគ្រូគណិតវិជ្ជាដែលបានប្រើប្រាស់ទ្រឹស្តីទុច្ចរិត ដើម្បីរំលើងដង្កូវដែលបានជ្រៀតចូលក្នុងបដិវត្តតាំងចិត្តថានឹងកម្ទេចឲ្យបាន ។ ពាក្យនេះអាចបកប្រែទៅជាភាសាអង់គ្លេសជាពាក្យគួរសម «លោកនេះ និង នោះ» ។ យើងបានបាត់បង់នូវការជឿជាក់ថា ឌុច នៅតែធ្វើចំពោះអ្នកនៅក្រោមបង្គាប់គាត់និងអតីតអ្នកទោសរបស់គាត់ ។ ស្ត្រីម្នាក់ដែលជាកសិករមកពីខេត្តកំពង់ធំមានចំណាប់អារម្មណ៍ដូចអ្វីដែលខ្ញុំគិតថាមានភាពរំខានខ្លាំង ។ នៅពេលសវនាការសម្រាកដើម្បីទទួលទានអាហារថ្ងៃត្រង់ ខ្ញុំបានទៅតាមស្ត្រីពីរនាក់ដែលបានធ្វើដំណើរផ្លូវឆ្ងាយមកមើលសវនាការរយៈពេលមួយថ្ងៃ ។ ស្ត្រីម្នាក់បានបែរទៅស្ត្រីម្នាក់ទៀតហើយនិយាយថា «អត់បេះខ្មាស» ។ តាមលក្ខណៈរបស់ខ្មែរ ប្រសិនបើគាត់ពិតជា



រណ្តៅសាកសពនៅវាលពិឃាតបឹងជើងឯក

ស្តាយក្រោយមែន គាត់គួរតែមើលទៅក្រោមគេចមិនមើលភ្នែកអ្នកដទៃនិងបង្ហាញតាមរយៈកាយវិការថាគាត់ពិតជាមានការសោកស្តាយចំពោះទង្វើកន្លងមក ។ គាត់ក៏គួរតែបង្ហាញដែរថាគាត់ខ្មាសអៀននូវអ្វីដែលគាត់បានធ្វើ ។ ផ្ទុយទៅវិញ គាត់បែរជាបង្ហាញនូវអាកប្បកិរិយាបែបកាចប្រឆាំងនិងវាយប្រហារទៅលើសាក្សីដែលធ្វើសក្ខីកម្មប្រឆាំងនឹងគាត់ ។ នៅពេលសវនាការបានសម្រាកអ្នកទស្សនាបានខិតទៅមុខមិនខិតទៅដល់កញ្ចក់ទេ ប៉ុន្តែទៅកៅអីជួរទីពីរដើម្បីសម្លឹងមើលទៅ ឌុច ដូចជាសត្វមួយនៅក្នុងទ្រុង ។ នៅពេលខ្ញុំជិះឡានត្រឡប់ទៅភ្នំពេញ ជាមួយបុគ្គលិកមជ្ឈមណ្ឌលឯក

សារកម្ពុជាមួយក្រុម ខ្ញុំបានសួរទៅនារីម្នាក់អាយុប្រហែល២០ ឆ្នាំថា តើគាត់គិតយ៉ាងណាចំពោះដំណើរការសវនាការថ្ងៃនេះ ។ នារីម្នាក់នោះនិយាយថា គាត់មានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ខ្ញុំសួរគាត់ថាគាត់ភ្ញាក់ផ្អើលនឹងរឿងអ្វី ។ គាត់ឆ្លើយថា គាត់រន្ធត់យ៉ាងខ្លាំងដែលកុមារ៦០នាក់ត្រូវខ្មែរក្រហមសម្លាប់(កម្ទេច) ដោយបោកក្បាលទៅនឹងដើមឈើ ។ និយាយមិនបានប៉ុន្មានផង គាត់ក៏ហូរទឹកភ្នែករួចក៏បែរមុខទៅបង្អួចឡានវិញ ដើម្បីសម្រួលអារម្មណ៍ ។ សក្ខីកម្មនៅថ្ងៃនោះមិនបានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលទេ ។ ខ្ញុំបានអានរឿងរ៉ាវនេះរួចអស់ហើយ ។ ដំណើរការសម្លាប់មនុស្សរបៀបចងមុខ



ដាក់ឈ្មោះនិងបញ្ជូនទៅលើឡាន របៀបខ្មែរក្រហមវាយក្បាលផ្នែកខាងក្រោយនិងរុញមនុស្សបញ្ចូលរណ្ដៅសុទ្ធតែ ហ៊ឹម ហ៊ុយ បានប្រាប់រួចអស់ហើយមួយចំណុចម្ដងៗ ទុកតែចំណុចដែលគាត់មានតួនាទីជាអ្នកសម្លាប់ប៉ុណ្ណោះ ។

នៅក្នុងសៀវភៅរបស់គាត់ស្ដីអំពីជីវិតនៅមន្ទីរស-២១ វ៉ាន់ ណាត បានរៀបរាប់ពីការតតាំងទល់មុខគ្នារវាងគាត់នឹង ហ៊ឹម ហ៊ុយ នៅឆ្នាំ១៩៩៦ ។ ហ៊ឹម ហ៊ុយ សារភាពថាគាត់បានសម្លាប់មនុស្សប្រមាណតែ៤-៥នាក់ប៉ុណ្ណោះនិងបញ្ជាក់ថាគាត់មានតួនាទីត្រឹមតែជាអ្នកយាមប៉ុណ្ណោះ មិនមែនជាពេជ្ឈឃាតទេ ។ វ៉ាន់ ណាត បានចោទប្រកាន់គាត់ថា បំផ្លើសការពិតដោយបន្ថែមថា បើទោះជាចំនួនមនុស្ស២០០០នាក់ដែលគាត់បានសារភាពពីលើកមុនថាគាត់សម្លាប់ក៏មិនទាន់គ្រប់គ្រាន់ដែរ ។ បន្ទាប់មក វ៉ាន់ ណាត បានសួរគាត់អំពីអំពើដ៏រន្ធត់ដែលបានគូរនៅក្នុងគំនូរតើរូបភាពទាំងអស់នេះពិតឬយ៉ាងណា? ហ៊ឹម ហ៊ុយ បានឆ្លើយថារូបភាពទាំងអស់នោះមិនមានលក្ខណៈពន្លើសទេនៅមានទិដ្ឋភាពសាហាវឃោរឃៅជាងនេះទៅទៀត ។ ក្រោយមក វ៉ាន់ ណាត បានសួរ ហ៊ឹម ហ៊ុយ បន្ថែមទៀតអំពីទិដ្ឋភាពដែលទារកត្រូវគេឆក់យកពីដៃម្ដាយគាត់ចង់ដឹងថាតើទារកទាំងអស់នោះត្រូវគេយកទៅណា? ហ៊ឹម ហ៊ុយ ឆ្លើយថា យើងយកទារកទាំងអស់នោះទៅសម្លាប់ ។ វ៉ាន់ ណាត ឆ្លើយតបវិញថា «តើអ្នកសម្លាប់ទារកតូចៗទាំងអស់ឬ? ឱ ព្រះជាម្ចាស់អើយ» ។ បុរសម្នាក់ដែលធ្លាប់ជាសាក្សី ចំពោះអំពើសាហាវឃោរឃៅនៅសម័យខ្មែរក្រហមអស់រយៈពេល១៥ ឆ្នាំមកហើយ ក៏នៅតែរន្ធត់ចំពោះការសម្លាប់ទារកតូចៗដ៏កាចសាហាវដូចគ្នាទៅនឹងនារីម្នាក់ដែលធ្វើការនៅមជ្ឈមណ្ឌលឯកសារដែលខ្ញុំបានសួរនៅលើឡាននោះដែរ ។ វាស្ទើរតែមិនអាចទ្រាំបាន ។ វ៉ាន់ ណាត តែងតែគិតថាយ៉ាងណាក៏ដោយ ក៏ខ្មែរក្រហមទុកជីវិតឲ្យទារកតូចៗទាំងនោះដែរ ។

ខ្ញុំយល់ថាប្រតិកម្មខ្ញុំចំពោះសវនាការនេះមានលក្ខណៈខ្មែរច្រើនជាងអាមេរិក ។ យើងមកពីលោកខាងលិចច្រើនតែចូលចិត្តរូបភាពជនជាប់ចោទដែលមានលក្ខណៈតស៊ូ គ្រវីដៃ និង ដាក់ទោសទៅលើសាក្សី ។ យើងចូលចិត្ត ភើរី ម៉េសិន ច្បាប់ និង របៀបរៀបរយ ។ យើងសង្ឃឹមថានោះជាពេលវេលាដែលការសម្ដែងមួយត្រូវចាប់ផ្ដើម ។ ផ្ទុយទៅវិញ ចំពោះលក្ខណៈរបស់ខ្មែរ ឌុច គួរតែបង្ហាញថាគាត់មានវិប្បដិសារីដោយបង្ហាញនូវការគោរពរបស់គាត់ចំពោះអតីតជនរងគ្រោះមិនមែនអាកប្បកិរិយាបែបកាចសាហាវទេ ។ គាត់គួរតែបន្ទន់ឥរិយាបថគាត់ចំពោះជនរងគ្រោះទាំងកាយវិការនិងពាក្យសម្ដី ។ ប៉ុន្តែគាត់នៅតែគិតថាគាត់ល្អជាងជនរងគ្រោះ ។ គាត់គ្មានការស្ដាយក្រោយពិតប្រាកដទេ ។ ប៉ុន្មានឆ្នាំកន្លងមកនេះ គាត់នៅតែអាចវាយប្រហារចំពោះជនរងគ្រោះ ។ ហេតុនេះ ទើបគាត់ជាបុរសម្នាក់ដ៏សាហាវ ។

**ជូឌី លេដជឺវូដ**

# ទណ្ឌកម្មដួងចិត្ត

*នៅចុងឆ្នាំ១៩៧០ ខ្ញុំរស់នៅក្នុងភូមិទម្លាប់ ស្រុកគិរីវង្ស ខេត្តតាកែវ ។ ខ្ញុំអាយុ១៨ឆ្នាំ បានចូលរៀននៅថ្នាក់ទី៨ នៃអនុវិទ្យាល័យគិរីវង្ស ដោយមានលោក សុន សាមុន្ទ ជាសាស្ត្រាចារ្យនិងលោក គឹម គីន ជានាយកសាលា ។ ចំណែក ឪពុករបស់ខ្ញុំឈ្មោះ ស៊ុំ សំណាពុ ក៏ជាគ្រូបង្រៀននិងជាអគ្គានុរក្សនៃអនុវិទ្យាល័យទន្លាប់ (បង្កើតថ្មី) ដែលមានចម្ងាយ១៨គីឡូម៉ែត្រពីទីរួមស្រុកគិរីវង្ស និង លោក សុខ អាន ជានាយកសាលាដែរ ។*

*ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧០ ស្រុកគិរីវង្សស្ទើរតែទាំងមូលបានធ្លាក់ក្រោមការគ្រប់គ្រងរបស់កងទ័ពវៀតកុង(កងទ័ពរណសិរ្សវៀតកុង) និងខ្មែរកម្មុយនីស្ត (ខ្មែរក្រហម) ដែលភាគច្រើនទើបតែបញ្ចប់ការហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រទ័ពនៅទីក្រុង*



*សារ៉ុង ថតនៅពេលចូលទស្សនាការកាត់ទោស ឌុច ឆ្នាំ២០០៩*

*ហាណូយ ។ ខណៈពេលនោះ រដ្ឋាភិបាល លន់ នល់ បានប្រកាសជាសាធារណៈថា កងទ័ពរណសិរ្សវៀតកុងបានឈ្លានពានអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ។ បន្ទាប់ពីចេញសេចក្តីប្រកាសនេះមិនយូរប៉ុន្មានសង្គ្រាមក៏ចាប់ផ្តើមឆាបឆេះឡើង ។*

*សិស្សសាលានិងគ្រូបង្រៀនក្នុងស្រុកគិរីវង្សភាគច្រើនបានចូលរួមបម្រើចលនាទ័ពរំដោះរបស់ (ខ្មែរកុម្មុយនីស្ត) (ខ្មែរក្រហម) ក្រោមការឃោសនាថា ជួយច្បាំងរំដោះទឹកដីពីចក្រពត្តិអាមេរិកនិងរដ្ឋាភិបាល លោក លន់ នល់ ដើម្បីថ្វាយអំណាចជូនសម្តេច នរោត្តម សីហនុ វិញ ។ បន្ទាប់ពីបានឮការឃោសនានេះភ្លាមហើយម្យ៉ាងទៀត ដោយសារចង់កាន់កាំភ្លើងផងទើបធ្វើឲ្យខ្ញុំចង់ស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ ប៉ុន្តែត្រូវបានឪពុករបស់ខ្ញុំបដិសេធនិងស្តីបន្ទោសខ្លាំងៗ ។ ទោះបីជាមានការ ហាមឃាត់យ៉ាងណាក៏ដោយ ក៏ខ្ញុំបានឆ្លៀតពេលទៅលួចមើលកងទ័ពវៀតកុងនិងកងទ័ពខ្មែរកម្មុយនីស្តជាអ្នកបកប្រែភាសាវៀតណាមធ្វើការបង្ហឹកក្បួនយុទ្ធសាស្ត្រទ័ពដល់ក្មេងៗនៅវាលស្រែ និងបានទៅមើលការចល័តកងទ័ព និងការដើរក្បួនព្យុហយាត្រានៃកងទ័ពចិន-កូរ៉េខាងជើងក្នុងសាលាបឋមសិក្សាទន្លាប់ទៀតផង ។ ជាញឹកញាប់ក្រោយពេលសម្រាកពីធ្វើការងារផ្ទះ ខ្ញុំក៏បានទៅមើលកងទ័ពរំដោះ (កងទ័ពខ្មែរក្រហម) ដឹកជញ្ជូនអ្នករបួសតាមរថយន្តឈ្នួលរបស់ឈ្មោះ អៀក សេងឌី ហៅ សែ ពីសមរភូមិទីរួមខេត្តតាកែវ និងទៅមើលកងទ័ពរំដោះនិងកងទ័ពវៀតកុងដើរប្រមូលទ្រព្យសម្បត្តិតាមក្រសួង-មន្ទីររបស់រដ្ឋការ លន់ នល់ ឈ្នួញធំៗនៅតាមផ្សារនិងផ្ទះរបស់មន្ត្រីក្នុងស្រុកគិរីវង្សដែលបានភៀសខ្លួនទៅទីក្រុងភ្នំពេញ ។ មួយរយៈក្រោយមក កងទ័ពរំដោះខ្មែរកម្មុយនីស្ត និងកងទ័ពវៀតណាមបានចាប់ផ្តើមវាយប្រយុទ្ធយ៉ាងសាហាវឃោរឃៅ តទល់ជាមួយកងទ័ពខ្មែរសេរី «កន្សែងស» ដឹកនាំដោយលោក សឺង ង៉ុកថាញ់ (ខាងរដ្ឋាភិបាល លន់ នល់) ដោយតាំងមូលដ្ឋានទ័ពនៅភ្នំដិនដែលមានចម្ងាយប្រមាណ៧គីឡូម៉ែត្រពីទន្លាប់ជាប់ព្រំដែនយួនខាង*

ត្បូង ។ ការវាយប្រយុទ្ធបានអូសបន្លាយរហូតដល់ចុងខែវិច្ឆិកា ឆ្នាំ១៩៧០ នៅពេលនោះដោយសារបារម្ភពីសុវត្ថិភាពផ្ទាល់ខ្លួន ឪពុកខ្ញុំនិងបងប្រុសឈ្មោះ សុំ ប៊ុនណាល់ ខ្ញុំ និងអ្នកជិតខាងពីរនាក់ទៀតបានលួចរត់ភៀសខ្លួនពីផ្ទះស្ថិត (ក្នុងតំបន់ខ្មែរក្រហមកាន់កាប់) តាមទោចក្រយាន្តអស់រយៈពេលប្រាំមួយថ្ងៃ ដោយត្រូវឆ្លងកាត់សមរ ភូមិគ្រាំខ្នារ អង្គតាសោម ថ្នល់បែកគូស និងស្ពានស្ទឹងស្លាគូ ទើបបានមកដល់ទីក្រុងភ្នំពេញ ។

នៅភ្នំពេញឪពុកខ្ញុំបានស្ម័គ្រចិត្តចូលបម្រើក្នុងកងទ័ព លន់ នល់ ក្នុងឋានន្តរស័ក្តជាអនុសេនីយ៍ឯក ចំណែកខ្ញុំក៏បានចុះឈ្មោះចូលរៀននៅវិទ្យាល័យក្បាលថ្នល់ដែរ ។ ទោះបីយ៉ាងណាក៏ដោយ ក៏សង្គ្រាមកាចសាហាវរវាងកងទ័ពលោក លន់ នល់ និងកងទ័ពខ្មែរក្រហមក្រោមជំនួយឧបត្ថម្ភពីកងទ័ពវៀតកុង និងចិនប៉េកាំងនៅតែបន្តមិនដាច់ ។ ខ្មែរក្រហមបានបាញ់ផ្លោងគ្រាប់ចូលក្នុងទីក្រុងភ្នំពេញជាញឹកញាប់ដែលបណ្តាលឲ្យប្រជាជនស៊ីវិល ស្លូតត្រង់ស្លាប់យ៉ាងច្រើន ។

បន្ទាប់ពីថ្ងៃបុណ្យចូលឆ្នាំថ្មីបានបញ្ចប់ នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ស្នូរគ្រាប់កាំភ្លើងគ្រប់ធុនបានលាន់ៗដូចភ្នំភ្លើងផ្ទុះ ។ ខ្ញុំមានអាយុ១៩ឆ្នាំ និងជាអតីតយុវសិស្សថ្នាក់បញ្ចប់ផ្នែកវិទ្យាសាស្ត្រពិសោធន៍នៃវិទ្យាល័យ១៨មីនា ឬវិទ្យាល័យ កែវ សង់គីម (បច្ចុប្បន្នវិទ្យាល័យយុគន្ធរ) និងមួយគ្រួសារទៀតដែលមានសមាជិក១៥នាក់ត្រូវបានកងយោធាក្មេងៗរបស់ខ្មែរក្រហមដែលស្លៀកសម្លៀកបំពាក់ខ្មៅស្រែកគំរាមខ្លាំងឲ្យចាកចេញពីទីក្រុងភ្នំពេញជាបន្ទាន់ ។ ហ្វូងមនុស្សរាប់ម៉ឺននាក់បាននាំគ្នាដើរចេញពីផ្ទះ ក្រោមកម្តៅថ្ងៃក្តៅហួតហែង ដោយមានការតាមឃ្លាំមើលពីក្រុមយោធាប្រដាប់ដោយគ្រាប់បែកចងព្យួរជុំវិញចង្កេះនិងកាំភ្លើងគ្រប់ដៃឈរយាមនៅអមសងខាងផ្លូវ ហើយបញ្ចេញទឹកមុខយ៉ាងកាចសាហាវដាក់អ្នកជម្លៀស ដែលមើលទៅគួរឲ្យភ័យខ្លាច ។ នៅពេលធ្វើដំណើរកងយោធាទាំងនេះបានរុញច្រានភ្ជង់កាំភ្លើង និងធ្វើការបាញ់រះយ៉ាងសាហាវពីលើក្បាលមនុស្សដែលធ្វើឲ្យរាំងស្ទះផ្លូវធ្វើដំណើររកទៅណាមិនរួច ។

នៅវេលាម៉ោង២រសៀល ពេលខ្ញុំកំពុងធ្វើដំណើរយឺតៗនៅលើមហាវិថីប្រជាធិបតេយ្យ (មហាវិថីព្រះមុនីវង្ស) លាយឡំជាមួយអារម្មណ៍សោកស្តាយម្តងម្កាល ខ្ញុំបានក្រឡេកភ្នែកសម្លឹងមើលហ្វូងមនុស្សរាប់ម៉ឺននាក់ដើម្បីរកមើលបងប្អូននិងមិត្តភក្តិដែលបានស្គាល់ពីមុនមក ។ គ្រួសារខ្ញុំបានធ្វើដំណើរក្នុងទិសដៅឆ្ពោះទៅក្បាលថ្នល់ ប៉ុន្តែរយៈពេលបីម៉ោងក្រោយគ្រួសារខ្ញុំទើបតែដើរដល់ផ្លូវបំបែករោងកុនបូកគោប៉ុណ្ណោះ ។ នៅក្រោមកម្តៅថ្ងៃខែចែត្រដែលក្តៅស្ទើរខ្លោចស្បែកនៅតាមដងផ្លូវមានភាពកកស្ទះណែននៅខណៈនោះ សំឡេងថ្ងូររបស់មនុស្សចាស់ជរា ជនពិការដែលត្រូវបានបងប្អូនបោះបង់ចោលតាមផ្លូវ សម្លេងស្រែករកបងប្អូន កូនៗ ឪពុក-ម្តាយ និងសំឡេងក្មេងៗយំបានលាន់ឮទ្រហឹងអឺងកង ដែលមានសភាពគួរឲ្យអាណោចអាធ័មជាទីបំផុត ។ ចំណែកប្អូនស្រីរបស់ខ្ញុំ ក៏ចាប់ផ្តើមយំទាបាយដោយការស្រេកឃ្លានយ៉ាងខ្លាំង ។ ខ្ញុំបានស្រក់ទឹកភ្នែកដោយមិនដឹងខ្លួនដោយសារនឹកអាណិតប្អូនតូចៗ ។

គ្រួសារខ្ញុំត្រូវចំណាយពេលមួយថ្ងៃមួយយប់ ទើបមកដល់ផ្លូវបំបែកក្បាលថ្នល់រួចបន្តដំណើរទៅទីក្រុងតាខ្មៅ ដែលនៅអមសងខាងផ្លូវមានពោរពេញទៅដោយសពមនុស្សស្លាប់ ។ មកដល់ប៉ុស្តិ៍ឆែកឆេរមួយកន្លែង ខ្ញុំឃើញខ្មែរក្រហមកំពុងបណ្តើរមនុស្សជាច្រើនដោយចងស្លាបសេកទៅក្រោយដែលភាគច្រើនសុទ្ធតែជាទាហាន លន់ នល់ បញ្ចូលក្នុងឡានទ្រុងមួយ ។ ពេលនោះសំឡេងស្រែកគំរាមកំហែងលាយឡំ ជាមួយសំឡេងយំសោកអាឡោះអាល័យរបស់គ្រួសារដែលត្រូវបានចាប់ខ្លួនទាំងនោះចាប់ផ្តើមឮកងរំពងម្តងទៀត ។ នៅពេលដែលខ្ញុំកំពុងឈរសម្លឹងមើលទៅហេតុការណ៍នោះស្រាប់តែមានកងយោធាខ្មែរក្រហមក្មេងៗចំនួន២នាក់-៣នាក់ដើរសំដៅមករកខ្ញុំ រួចភ្ជង់កាំភ្លើងព្រមទាំងស្រែកសម្លុតថា មិត្តឯងជាទាហានអា លន់ ណល់ មែនទេ? ខ្ញុំខំប្រឹងញញឹម រួចឆ្លើយតបដោយសម្លេងញ័រថាៈ «ទេខ្ញុំជាកូនសិស្ស» ។ ខណៈនោះ ទាហានម្នាក់អាយុប្រហែល១៣ឆ្នាំបានស្ទុះមកចាប់កន្ត្រាក់នាឡិកាចេញពីដៃរបស់ខ្ញុំ ចំណែកទាហានម្នាក់ទៀតបានទាញយកកាបូបរបស់ខ្ញុំទៅឆែកឆេរ រួចយកសៀវភៅប្រលោមលោកដែលខ្ញុំបានសរសេរនឹងបោះពុម្ពថ្មីៗចំនួន២៣ក្បាលនិងសម្ភារៈសិក្សាមួយចំនួនគ្រវែងចោលទៅលើដី ។ ឃើញដូច្នេះខ្ញុំប្រុងស្ទុះទៅតតាំងនិងដណ្តើមយកនាឡិកាម៉ាកទីតូនី(ឪពុករបស់ខ្ញុំបាន

វិញឲ្យពេលខ្ញុំប្រឡងជាប់ឌីប្លូមនៅឆ្នាំ១៩៧១) មកវិញស្រាប់តែម្តាយខ្ញុំចាប់ឃាត់ខ្ញុំជាប់ ។

នៅចុងខែខសភាឆ្នាំ១៩៧៥ នៅលើផ្លូវធ្វើដំណើររយៈពេលជិតមួយខែដោយមិនដឹងទិសដៅច្បាស់លាស់ គ្រួសារខ្ញុំបានទៅដល់ភូមិភ្លៀត ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ដែលពីមុនមកខ្ញុំមិនដែលស្គាល់អ្នកភូមិក្នុងស្រុកនេះទេ ។ ដំបូងនៅក្នុងភូមិមិនទាន់មានការតឹងតែងប៉ុន្មានទេ ប៉ុន្តែរយៈពេល៣-៤ខែក្រោយមកគ្រួសារខ្ញុំដែលជាអ្នកភ្នំពេញឬ «អ្នក១៧មេសា» ត្រូវធ្វើការលះបង់ទ្រព្យសម្បត្តិ និងរបស់របរប្រើប្រាស់ទាំងអស់ជូនអង្គការលើ ។

នៅថ្ងៃមួយខ្ញុំបានជួបតា ម៉ង់ ដូលីន ជាសិល្បករកំប្លែងដ៏ល្បីល្បាញម្នាក់ ។ ខ្ញុំបានដងទឹកឲ្យគាត់ផឹក ជាមួយសំឡេងអរគុណញាប់មាត់តបមកវិញដែលធ្វើឲ្យខ្ញុំសប្បាយចិត្តយ៉ាងខ្លាំង ព្រោះវាជាលើកដំបូងដែលខ្ញុំបានឃើញគាត់ផ្ទាល់ភ្នែក ព្រោះខ្ញុំបានឃើញគាត់ត្រឹមតែតាមរយៈខ្សែភាពយន្តប៉ុណ្ណោះ ។ តា ម៉ង់ ដូលីន បានរៀបរាប់ប្រាប់ខ្ញុំថា គាត់បែកកូនប្រុសគាត់ម្នាក់ធ្វើជាកងនាវាចរណ៍ (ម៉ា រីន) ប្រចាំនៅទីក្រុងកំពង់សោម ហើយពេលនេះគាត់ចង់ត្រឡប់មករស់នៅជាមួយបងប្អូនខាងប្រពន្ធរបស់គាត់ដែលមានស្រុកកំណើតនៅឯស្រុកកោះធំ ។ រហូតដល់ខែសីហាឆ្នាំ១៩៧៥ ស្រាប់តែមានកងយោធានៅតំបន់៣៣ ខេត្តតាកែវមួយក្រុមបានតាមរកចាប់គ្រួសារ តា ម៉ង់ ដូលីន មានសមាជិកទាំងអស់១០នាក់ ដែលទើបធ្វើដំណើរមកដល់ ភូមិសំរោង ឃុំក្រាំយ៉ូវ ស្រុកស្អាង ខេត្តកណ្តាល ហើយចោទថា គ្រួសាររបស់គាត់ជាខ្មាំងនិង «ដើរហើរសេរីពុំស្តាប់បញ្ជារបស់អង្គការ» ។ ទោះបីជាមានការធានាពីប្រធានភូមិសំរោងយ៉ាងណាក៏ដោយ ក៏កងយោធាក្មេងៗទាំងនោះពុំព្រមដោះលែងដែរ បន្ទាប់មកបានចាប់ តា ម៉ង់ ដូលីន ចងស្លាបសេកទៅក្រោយ ព្រមទាំងទាត់ធាក់យ៉ាងដំណំ រួចបណ្តើរចេញទៅជាមួយគ្រួសារបាត់ ។

នៅចុងខែធ្នូឆ្នាំ១៩៧៥ ខ្ញុំនិងគ្រួសារព្រមទាំងប្រជាជនផ្សេងទៀតដែលរស់នៅក្នុងភូមិសំរោង ត្រូវបានអង្គការចាប់បង្ខំនិងចាប់បញ្ជូនទៅខេត្តបាត់ដំបងតាមកប៉ាល់ ។ គ្រួសារខ្ញុំ ត្រូវធ្វើដំណើរពីស្រុកស្អាងកាត់ទីក្រុងភ្នំពេញខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ទើបឈប់រង់ចាំរយៈពេលបីយប់៣ថ្ងៃដើម្បីជិះរទេះភ្លើងបន្តទៅខេត្តបាត់ដំបង ។ រថភ្លើងបានបោះពួយយ៉ាងលឿនដោយមានផ្ទុកមនុស្សរាប់ពាន់នាក់ ខ្លះជិះនៅលើដំបូល ខ្លះឈរតោងចម្រឹងដែកក្នុងទូរថភ្លើងជាមួយអីវ៉ាន់សំពីងសំពោងនិងមនុស្សអង្គុយប្រជ្រៀតគ្នាពេញណែន ។ រថភ្លើងបានមកឈប់នៅស្ថានីយមោងឫស្សីដើម្បីដាក់មនុស្សចុះពាក់កណ្តាល ហើយម្នាក់ៗនាំគ្នាត្រេកអរយ៉ាងខ្លាំងដោយគិតថាស្រុកនេះសម្បូរស្រូវអង្ករណាស់ដូច្នេះពួកគេលែងអត់អាហារទៀតហើយ ។ នៅខណៈនោះស្រាប់តែប្រជាជនទាំងអស់នាំគ្នាផ្អើលប្រុងចុះពីរថភ្លើង ប៉ុន្តែត្រូវកងយោធាក្មេងៗហាមឃាត់និងស្រែកគំរាមភ្លាម ។ រថភ្លើងចាប់បន្តដំណើរទៅមុខអ្នកជិះទាំងអស់មានទឹកមុខស្រពោន ដោយសារអស់កម្លាំងយ៉ាងខ្លាំង ម្យ៉ាងទៀតដោយសារអត់ងងុយពេលរង់ចាំរទេះភ្លើងនៅខេត្តពោធិ៍សាត់ ។ នៅតាមចន្លោះបង្អួចនៃទូររថភ្លើងខ្ញុំបានឃើញប្រជាជនទិនងើបៗក្នុងកាយវិការកំពុងដកស្ទូងយ៉ាងស្ងៀមស្ងាត់ ហើយនៅក្បែរពួកគេមានយោធាបួនប្រាំនាក់កាន់កាំភ្លើងគ្រប់ដៃកំពុងជជែកគ្នា និងជក់បារីតាមភ្លឺស្រែខៀវស្រងាត់ ។ ជាងមួយម៉ោងក្រោយមករថភ្លើងបានមកដល់ស្ថានីយបាក់បែកមួយគឺស្ថានីយគោកត្រុំ ។ គ្រួសារខ្ញុំ និងគ្រួសាររបស់អ្នកជម្លៀសផ្សេងទៀតដែលនៅសេសសល់ក្នុងទូរថភ្លើងប្រហែល៣០០០-៤០០០នាក់ ត្រូវបានកងយោធាបញ្ជាឲ្យចុះនៅមុខស្ថានីយ៍នេះទាំងអស់ ។ ខ្ញុំចាប់ផ្តើមពិបាកចិត្តយ៉ាងខ្លាំង អ្នកជម្លៀសទាំងអស់បាននាំគ្នាជញ្ជូនអីវ៉ាន់កំប៉ិកកំប៉ុករួមមាន ចាន ឆ្នាំង សម្លៀកបំពាក់ ស្បៀងបន្តិចបន្តួចចេញពីរថភ្លើងយ៉ាងប្រញាប់ប្រញាល់ ។ ប្រជាជននាំគ្នាដើរជាក្រុមៗ ខ្លះឆ្លងកាត់អូរទៅប្រាំងម្ខាងទៀត ខ្លះទៀតដើរសំដៅចូលក្នុងភូមិរៀងៗខ្លួនតាមការបញ្ជារបស់មេកងដែលនៅឈររង់ចាំចាំទទួលជាស្រេច ។

គ្រួសារខ្ញុំ (ពុំមានលោកឪពុកមកជាមួយទេ ព្រោះនៅថ្ងៃ១៧មេសា ឆ្នាំ១៩៧៥គាត់ស្នាក់នៅបន្ទាយក្នុងខេត្តកំពង់ស្ពឺ) ត្រូវអង្គការបញ្ជូនឲ្យទៅរស់នៅក្នុង ភូមិសាយថ្មី ឃុំប៉ែន ស្រុកគាស់ក្រឡ ខេត្តបាត់ដំបង ដែលមានចម្ងាយប្រមាណ៣-៤គីឡូម៉ែត្រពីស្ថានីយរថភ្លើង ។ ភូមិសាយថ្មីនេះ ស្ថិតនៅក្បែរភូមិចាស់មួយដែលមានមនុស្សមករស់នៅមុនគ្រួសារខ្ញុំទៅទៀត ។ ភូមិទាំងពីរនេះគឺជាវាលដាច់កន្ទុយភ្នែកដែលសម្បូរទៅដោយព្រៃស្បូវ និង

ឈើព្រៃដូចជា ដើមកកោះ ពពាលខែ ត្បែង និងដើមថ្នឹងបន្តិចបន្តួចប៉ុណ្ណោះ ។ មកដល់ក្នុងភូមិភ្លាមអង្គការបានបែងចែកជាបីក្រុមដោយក្នុងមួយក្រុមមាន១០គ្រួសារ ។ នៅភូមិសាយថ្មីនេះអង្គការអនុញ្ញាតឲ្យអ្នកជម្លៀសរស់នៅបីក្រុម(៣០គ្រួសារ) ហើយគ្រួសារខ្ញុំស្ថិតនៅក្នុងក្រុមទីមួយដែលគ្រប់គ្រងដោយមេកងម្នាក់ឈ្មោះ កេត ។ បន្ទាប់ពីបែងចែកកងរួចមក ខ្ញុំ បងប្រុសខ្ញុំ និងបងថ្លៃខ្ញុំចាប់ផ្តើមរកឈើដើម្បីសាងសង់ផ្ទះ ប៉ុន្តែដោយសារភូមិនេះមិនសូវសម្បូរឈើ យើងបានប្រូតស្បូវយកមកប្រក់ធ្វើដំបូល និងកាប់កូនឈើតូចមកក្រាលធ្វើជារនាបរួចយកបាវអង្ករចាស់ទ្រាប់ជំនួសកន្ទេល និងយកខោអាវមកធ្វើជាខ្នើយ ។

បន្ទាប់ពីគ្រួសារខ្ញុំស្នាក់នៅក្នុងភូមិនេះបានរយៈពេល៣-៤ខែ ជីវភាពរស់នៅចាប់ផ្តើមប្រែប្រួលជាបន្តបន្ទាប់ ព្រោះភ្លៀងចាប់ផ្តើមធ្លាក់មកយ៉ាងខ្លាំង ហើយទឹកអូរក៏ចាប់ផ្តើមជោរជន់ព័ទ្ធជុំវិញភូមិ ។ ចំណែកស្បៀងអាហារបម្រុងរបស់ប្រជាជនជម្លៀសទាំងអស់គឺចាប់ផ្តើមអស់ជាបណ្តើរៗ ហើយអាហារប្រចាំថ្ងៃបានមកដោយសារការដោះដូររបស់របរដែលនៅសេសសល់បន្តិចបន្តួចជាមួយនឹងអ្នកមូលដ្ឋានប៉ុណ្ណោះ ។ ជីវភាពប្រជាជនទាំងអស់ចាប់ផ្តើមលំបាកវេទនាយ៉ាងខ្លាំង និងពុំសូវមានទំនាក់ទំនងជាមួយគ្នាទេ ព្រោះទឹកជន់ឡើងកាន់តែខ្លាំង ម្យ៉ាងទៀតស្បូវភ្លាំងដុះយ៉ាងក្រាស់ដែលពិបាកក្នុងការធ្វើដំណើរទៅមក ។ អ្នកជម្លៀសទាំងអស់បានជួបមុខគ្នាតែនៅពេលប្រជុំប៉ុណ្ណោះ គឺ៥ថ្ងៃត្រូវប្រជុំតូចម្តង និងកន្លះខែត្រូវប្រជុំធំម្តងនៅផ្ទះមេកង កេត ដែលស្ថិតនៅលើដីទួលមួយកន្លែង ។ ប្រជុំតូចគឺជាការប្រជុំបើកស្បៀង ចំណែកប្រជុំធំគឺដើម្បីរៀនសូត្រពីគោលការណ៍នយោបាយរបស់អង្គការដឹកនាំប្តែនការផ្សេងៗឲ្យប្រជាជនធ្វើ ។ ប៉ុន្តែដោយសារពេលនោះប្រជាជនភាគច្រើនកើតជំងឺរាកមួល គ្រុញចាញ់ ដំបៅហើមរលួយដោយសារមុតស្បូវនិងមែកឈើ ដូច្នេះមានសមាជិកមកចូលរួមប្រមាណតែជិត៥០ប៉ុណ្ណោះ ធ្វើឲ្យមេកង កេត ខឹងយ៉ាងខ្លាំង ។ នៅថ្ងៃប្រជុំនោះមេកង កេត បានដាក់បញ្ជាឲ្យមេក្រុមប្រមូលមនុស្សទៅធ្វើពលកម្មនិងចាត់ចែងកម្លាំងដើម្បីទៅបើកអង្ករឃ្លាំងស្តុកស្បៀងស្ថិតនៅស្ថានីយរថភ្លើងភ្នំធិបតីដែលមានចម្ងាយប្រមាណ២០គីឡូម៉ែត្រពីភូមិសាយថ្មី ។ បន្ទាប់ពីប្រជុំចប់ ខ្ញុំត្រូវចេញទៅធ្វើស្រែក្នុងភូមិមួយកន្លែងដែលមានចម្ងាយប្រមាណ៥គីឡូម៉ែត្រពីផ្ទះ ។ ដោយសារអង្គការពុំមានគោនិងនង្គ័លសម្រាប់ឲ្យភ្ជួរស្រែ ដូច្នេះខ្ញុំត្រូវប្រើចបជំនួសដើម្បីកាប់ដីដាំស្រូវនៅក្រោមភ្លៀងធ្លាក់រៀងរាល់ថ្ងៃធ្វើឲ្យខ្ញុំរងានិងអស់កម្លាំងយ៉ាងខ្លាំង ។ ទោះបីខ្ញុំធ្វើការធ្ងន់យ៉ាងណាក៏ដោយ ក៏របបអាហារដែលអង្គការចែកឲ្យហូបនៅតែពុំឆ្អែតដដែល ឃើញដូច្នេះម្តាយខ្ញុំតែងតែលួចលាក់ដាំបបរទុកឲ្យខ្ញុំជានិច្ច ។ បន្ទាប់ពីហូបរួចម្តងៗខ្ញុំតែងតែសម្ងំមើលទៅពាងអង្កររួមដែលមានចំនួន១២កំប៉ុងសម្រាប់រយៈពេល៥ថ្ងៃជាមួយមនុស្ស១៥នាក់ ។ ប៉ុន្តែដោយសារការស្រេកឃ្លានខ្លាំងពេក ពេលខ្លះខ្ញុំបានសូមអង្ករម្តាយរបស់ខ្ញុំដើម្បីសុំយកអង្ករចំនួនពីរស្លាបព្រាបាយមកលីងហូបបន្ថែមទៀត ។

មួយរយៈក្រោយមកប្អូនរបស់ខ្ញុំ ស៊ុំ សូវី ហៅ ស្រីពៅ អាយុ១៥ឆ្នាំ ស៊ុំ សុម៉ាលី ហៅ ស្រីទូច អាយុ៩ឆ្នាំ, ស៊ុំ យ៉ារ៉ាន់ ហៅ ស្រីអូន អាយុ៧ឆ្នាំ, ប្អូនប្រុស សុំ សុភ័ក្ក ហៅ ប៉ុយ អាយុ១១ឆ្នាំ បានធ្លាក់ខ្លួនឈឺគ្រុនក្តៅនិងរាកមួលជាបន្តបន្ទាប់ធ្វើឲ្យគ្រួសារខ្ញុំមានការព្រួយបារម្ភយ៉ាងខ្លាំង ។ ម្តាយខ្ញុំនិងបងស្រីខ្ញុំបានខិតខំដើររកថ្នាំពេទ្យគ្រប់ទីកន្លែងក្នុងភូមិដោយធ្វើការដោះដូររបរមានតម្លៃខ្លះៗដែលនៅសេសសល់ជាប់នឹងខ្លួន ប៉ុន្តែថ្នាំទាំងអស់នោះពុំមានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺរបស់ប្អូនៗខ្ញុំឲ្យជាសះស្បើយបានឡើយ ។ ពីមួយថ្ងៃទៅមួយថ្ងៃសភាពជំងឺកាន់តែធ្ងន់ធ្ងរទៅៗរហូតបណ្តាលឲ្យប្អូនស្រីពៅនិងស្រីអូន ស្លាប់ជាបន្តបន្ទាប់គ្នាដែលធ្វើឲ្យម្តាយខ្ញុំយំសោកនិងមានទុក្ខព្រួយជាទម្ងន់ ។ ចំណែកឯស្រីទូច វិញ កំពុងមានជំងឺគ្រុនក្តៅដេកលើគ្រែ ហើយប្អូនប្រុសប៉ុយ ក៏មានជំងឺដំបៅយ៉ាងធំនៅត្រង់ជើង(ភ្នែកគោរ) ដោយសារតែមុតស្បូវភ្លាំងនៅពេលកំពុងដើររើសផ្លែកកោះហូប ។

នៅថ្ងៃបន្ទាប់មេកង កេត បានប្រកាសជ្រើសរើសកម្លាំង៦នាក់ឲ្យទៅបើកអង្ករនៅភ្នំធិបតី បន្ទាប់ពីឮដំណឹងនេះភ្លាម នាយស្លឹក អ្នកក្រុងភ្នំពេញ ចឹក សេង ចៅកែស៊ីក្លូនៅផ្សារដើមថ្កូវ បង វណ្ណា នាយកសាលានាយទាហានសម័យ លន់ ណល់ បង ដុន សាស្ត្រាចារ្យភូមិវិទ្យានិងប្រវត្តិវិទ្យា, យីង សាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រខ្មែរនិងខ្ញុំដែលពុំសូវមានកម្លាំងផងបានស្ម័គ្រចិត្តភ្លាមព្រោះសង្ឃឹមថាយ៉ាងហោចណាស់ ពេលត្រឡប់មកវិញក៏លួចលាក់

បានអង្ករខ្លះសម្រាប់ដាំបាយហូបដែរ ។ នៅមុនពេលចេញដំណើរ ខ្ញុំបានឆៀតចូលផ្ទះដើម្បីមើលប្អូនប្រុស ប៉ុយ និងប្អូនស្រី ទូច ដែលមិនទាន់បានជាសះស្បើយ ។ ប្អូនទាំងពីរមានរូបរាងស្គមស្គាំង និងស្លេកស្លាំងដោយសារពុំមានអាហារហូបគ្រប់គ្រាន់ ហើយខ្ញុំក៏ស្ទាបក្បាលវាតិចៗដោយបានសន្យាថា «ពេលត្រឡប់មកពីបើកអង្ករវិញមុខនឹងលួចអង្ករខ្លះយកមកដាំបាយឲ្យប្អូនៗទាំងអស់គ្នាហូបបានម្តង» ។ បន្ទាប់ពីបានឮពាក្យនេះភ្លាមប្អូន ប៉ុយ និងស្រីទូច បានខំប្រឹងសើចទាំងស្នាមជ្រីវជ្រួញលើផ្ទៃមុខនិងសេចក្តីស្រេកឃ្លានយ៉ាងខ្លាំង ។

ព្រឹកឡើងខ្ញុំបានភ្ញាក់តាំងពីម៉ោង៥ភ្លឺដើម្បីរៀបចំចេញដំណើរដោយទទួលបានរបបអង្ករពីរកំប៉ុងពីមេកង កេត ចែកឲ្យសម្រាប់ទុកដាំបាយហូបនៅតាមផ្លូវ ។ នៅក្នុងក្រុមទៅយកអង្ករខ្ញុំបានស្គាល់ចិនម្នាក់ ឈ្មោះ ចឹក សេង គាត់បាននិយាយរឿងរ៉ាវពីប្រវត្តិរបស់ឪពុកគាត់ដែលបានរត់ចេញពីប្រទេសចិននៅជំនាន់បដិវត្តន៍របស់ ម៉ៅ សេទុង ។ យូរៗម្តងខ្ញុំបានកេះរួចខ្សឹបប្រាប់គាត់កំពុងឲ្យនិយាយឮៗពេកព្រោះពេលនោះខ្ញុំបានឃើញឈ្លបមួយកងកំពុងដើរចេញពីរទេះភ្លើងនៅក្បែរនេះដោយមានចងស្ពាយសេកអ្នកទោសបួននាក់បណ្តើរផង ។ អ្នកទោសទាំងនោះមានរូបរាងស្គមស្គាំងហើយ ពេលខ្លះកងឈ្លបបានកំរាមកំហែងនិងធ្វើទារុណកម្មថែមទៀតផង ។ ឃើញសភាពការណ៍ដូច្នេះ ចឹង សេង ក៏បាត់មាត់ឈឹងរហូតទាល់តែកងឈ្លបដើរទៅផុតទើបគាត់ងាកមកខ្សឹបប្រាប់ខ្ញុំថាអ្នកទោសទាំងអស់នោះសុទ្ធតែជាអតីតទាហាន លន់ នល់ ហើយត្រូវបញ្ជូនទៅមន្ទីរកសាងកោះឬមន្ទីរកសាងភូមិហប់ ។

មួយសន្ទុះក្រោយ ខ្ញុំដើរមកដល់ផ្លូវរថភ្លើងដែលមានមនុស្សឈររង់ចាំគ្នាកកកុញដោយម្នាក់ៗកាន់ស្បោងមួយជាប់នឹងដៃក្នុងគោលដៅឆ្ពោះទៅភ្នំតាដ្ត «ភ្នំធិបតី» ដើម្បីបើកអង្ករតាមការចាត់តាំងរបស់ប្រធានកងហើយអ្នកទាំងនោះភាគច្រើនជាប្រជាជន១៧មេសា ដែលមានរូបរាងស្គមស្គាំង ស្លេកស្លាំង និងមានសម្លៀកបំពាក់រហែកគ្រប់កន្លែង ។ ទោះបីជាយើងធ្លាប់បានស្គាល់និងជួបមុខគ្នាក៏ដោយ ក៏យើងមិនសូវហ៊ាននិយាយរកគ្នាដែរព្រោះមានមេក្រុម មេកង មេឈ្លប និងកម្មាភិបាលមូលដ្ឋាន ដើរនាំមុខនៅក្បែរនោះ ។ ខ្ញុំបានដើរលើកំណល់ឈើផ្លូវរទេះភ្លើងដោយគ្មានស្បែកជើងពាក់នៅក្រោមកម្តៅព្រះអាទិត្យដែលចាំងពន្លឺស្ទើរឆេះ ។ នៅតាមផ្លូវធ្វើដំណើរដែលមានទឹកជំនន់ពេញប្រៀបក្នុងវាលស្រែដ៏ធំល្វឹងល្វើយ ជើងរបស់ខ្ញុំចាប់ផ្តើមឈឺចុកចាប់យ៉ាងខ្លាំងហើយដោយមិនអាចបន្តដំណើរទៅមុខទៀតបានខ្ញុំក៏អង្គុយសម្រាកបន្តិចដើម្បីរង់ចាំ ចឹក សេង ដើរមកដល់ ។ នៅក្នុងកងមកយកអង្កររបស់ភូមិសាយថ្មីមិនមាន មេក្រុម មេកង មេឈ្លប ឬមូលដ្ឋានតាមមកត្រួតត្រាទេ ដូច្នេះនៅពេលយើងមកជុំគ្នាអាចឈប់សម្រាកនិងហូបបបរដែលយកមកពីផ្ទះបាន ។ ប៉ុន្តែដោយសារហូបមិនឆ្អែតយើងក៏ដើររកអុសនិងដុំថ្មកល់ធ្វើជាជើងក្រាន រួចយកអង្ករដែលមេកងចែកឲ្យខ្លះមកដាំបាយហូបបន្ថែម ។

បន្ទាប់ពីហូបបាយរួចយើងក៏បានបន្តដំណើរទៅមុខទៀតដោយមាន បង ផុន ជាអ្នកនាំផ្លូវព្រោះគាត់ជាមនុស្សរួសរាយស្លូតបូតនិងចេះប្រុងប្រយ័ត្នក្នុងការនិយាយស្តី ។ រីឯ ចឹក សេង នៅតែនិយាយពាក្យព្រោកប្រាជ្ញតាមផ្លូវហូរហែអំពីបដិវត្តន៍កុម្មុយនិស្តរបស់ ម៉ៅ សេទុង នៅស្រុកចិនដោយសំឡេងខ្លាំងៗ ។ ឮដូច្នេះបង ផុន បានកេះខ្ញុំឲ្យប្រញាប់ប្រាប់ទៅ ចឹក សេង កុំឲ្យនិយាយឮៗខ្លាំងពេកព្រោះខ្លាចអង្គការចាប់កំហុស ។

នៅពេលខ្ញុំដើរមកដល់ឃ្លាំងស្ថានីយរថភ្លើងផ្តៅនៅវេលាម៉ោងប្រហែល៤ល្ងាចមានបងប្អូនខ្លះបានស្ពាយអង្ករត្រឡប់ទៅភូមិវិញហើយ ។ ខណៈនោះ បង ផុន បានប្រញាប់យកក្រដាសបញ្ជីឈ្មោះដែលខទ្មុសនាមដោយមេកង កេត ទៅឲ្យមេឃ្លាំងម្នាក់ឬហៅថា(មេពាណិជ្ជ) ដែលកាន់កាប់ឃ្លាំងស្បៀងដ៏ធំមួយដែលពោរពេញដោយបាវអង្ករនិងក្រូចពោធិ៍សាត់ ។ ចំណែកអ្នកយាមឃ្លាំងសុទ្ធតែជាក្មេងៗអាយុប្រហែល១២-១៣ឆ្នាំ ហើយនៅក្នុងដៃម្នាក់ៗមានកាន់រំពាត់អង្គុយលើបាវអង្ករចាំវាយវាត់អ្នកណាដែលលួចបន្លំយកអង្ករឬផ្លែក្រូច ។ នៅទីនោះ ខ្ញុំបានឃើញបុរសម្នាក់ត្រូវអ្នកយាមឃ្លាំងវាយនឹងរំពាត់ចេញឈាមពេញខ្នងដោយសារតែគាត់បានលួចយកផ្លែក្រូចមកហូប បន្ទាប់មកយោធាម្នាក់ដែលឈរនៅក្បែរនោះបានយកជើងមកខ្ទាស់បុរសនោះឲ្យដួលរួចក៏ចាប់ចងស្ពាយសេកបណ្តើរចេញទៅបាត់ ។ ការធ្វើទារុណកម្មនេះបានធ្វើឲ្យខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំង ខ្ញុំមិនហ៊ានសម្លឹងមើលយោធានោះទេ ហើយក៏មិននឹកស្មានថាអ្នកយាមក្មេងៗទាំងនោះកាចសាហាវឃោរ

យោដូច្នេះដែរ ។

នៅពេលខ្ញុំឈរទ្រឹងនៅមួយកន្លែង ស្រាប់តែ ចឹង សេង កេះស្មារួចខ្សឹបប្រាប់ខ្ញុំតិចៗថាអាទី «តាមភាសាចិនគឺប្អូនមកនេះ!» ដែលធ្វើឲ្យខ្ញុំភ្ញាក់ក្រញាងខ្លួនហើយគាត់ក៏ញញឹមញញែមរួចអូសដៃខ្ញុំទៅក្បែរឃ្លាំងអង្ករ បន្ទាប់មកគាត់ក៏ចង្អុលទៅភក់ក្បែរនោះដែលមានផ្លែក្រូចជាំស្របកចំនួន៣ផ្លែ ។ ចឹក សេង បានចុះក្នុងភក់រើសយកក្រូចរួចហុចមកឲ្យខ្ញុំ ហើយគាត់ប្រាប់ថាក្រូចនេះគេបោះចោលឬធ្លាក់ចេញពីឃ្លាំងទេ ។ បន្ទាប់ពីស្តាប់ការពន្យល់របស់គាត់ ខ្ញុំក៏យកក្រូចទាំងនោះមកជូតភក់ចេញ រួចក៏វេចនឹងក្រម៉ាដើម្បីទុកផ្ញើម្តាយនិងប្អូនរបស់ខ្ញុំដែលឈឺនៅផ្ទះ ។

ខ្ញុំឈររង់ចាំរហូតដល់ម៉ោងប្រមាណប្រាំកន្លះ ទើប បង ផុន ស្រែកហៅប្រញាប់ប្រញាល់ឲ្យជួយរំលែកយកអង្ករជញ្ជូនទៅភូមិវិញព្រោះមេឃជិតយប់ទៅហើយ ។ ភូមិសាយថ្មីរបស់ខ្ញុំទទួលបានអង្ករចំនួន៥បាវនិងអំបិលមួយចំនួន ប៉ុន្តែដោយសារយើងមានមនុស្សតែ៦នាក់ ម្យ៉ាងមិនមានមធ្យោបាយដឹកជញ្ជូនទៀតមេពាណិជ្ជក៏បានដកយកអង្ករពីរបាវវិញ នៅសល់តែអង្ករចំនួន៣បាវប្រហែល១០០គីឡូក្រាមប៉ុណ្ណោះសម្រាប់ចែកឲ្យប្រជាជនជាង៣០០នាក់ ។ ដោយឃើញចំនួនអង្ករតិចយ៉ាងនេះយើងមានការព្រួយក្នុងចិត្តជាខ្លាំងចំពោះការខ្វះខាតរបស់អ្នកភូមិ ។

ដោយមេឃកាន់តែងងឹតទៅហើយ បង ផុន ក៏ចាប់ផ្តើមរំលែកអង្ករចាក់ដាក់ម្នាក់កន្លះបាវនិងអំបិលមួយកញ្ចប់ធំរៀងខ្លួន ។ ទោះបីអង្ករធ្ងន់យ៉ាងណាក៏ដោយ ក៏ខ្ញុំត្រូវតែជញ្ជូនទៅឲ្យម្តាយបងប្អូននិងអ្នកភូមិដែលអត់អាហារដែរ ។ ចំណែក ចឹក សេង ធ្វើមុខជូរលើកអង្ករបណ្តើរអ៊ូបណ្តើរធ្វើឲ្យខ្ញុំនឹកអាណិតគាត់យ៉ាងខ្លាំង ។ មេឃយប់ងងឹតណាស់ទៅហើយ អាកាសធាតុក៏ចាប់ផ្តើមត្រជាក់យើងបម្រុងចេញដំណើរ ស្រាប់តែមានភ្លៀងធ្លាក់មួយមេយ៉ាងធំ ។ ខ្ញុំប្រវេប្រវាយកកៅស៊ូភ្លៀងមួយបន្ទះមកគ្របអង្ករដើម្បីការពារកុំឲ្យទទឹក រួចក៏រត់ទៅជ្រកក្បែរសំយាបឃ្លាំងដែលមានមនុស្សជាច្រើនកំពុងឈរនៅទីនោះដែរ ។ ដោយសារឃើញមានមនុស្សកកកុញជារឿយៗកុមារយាមឃ្លាំង តែងតែស្រែកដេញកុំឲ្យឈរនៅក្បែរឃ្លាំងរបស់ពួកគេ ។

ភ្លៀងនៅតែបន្តធ្លាក់យ៉ាងយូរ រហូតធ្វើឲ្យខ្ញុំទទឹកខោអាវជោក ។ បន្តិចក្រោយមកភ្លៀងចាប់ផ្តើមរាំង ប៉ុន្តែខ្យល់នៅតែបោកបក់មកយ៉ាងខ្លាំងបណ្តាលឲ្យខ្ញុំរងាស្ទើរតែនិយាយមិនចេញ ។ ម៉ោងប្រមាណ១០យប់ទៅហើយ ខ្ញុំគ្មានសម្លៀកបំពាក់ស្ងួតសម្រាប់ផ្លាស់ប្តូរទេពេលនោះ បង ផុន ក៏បានប្រាប់ខ្ញុំ និង ចឹក សេង ថាបើមិនអាចដើរទៅបាន ព្រឹកស្អែកឡើងចាំទៅជួបគ្នានៅមន្ទីរសេដ្ឋកិច្ចភូមិ ចំណែកគាត់ទាំង៤នាក់ចេញដំណើរទៅមុន ។ យើងទាំងពីរនាក់បានឱបដៃជាប់បាវអង្ករក្បែរឃ្លាំងរហូតដល់ព្រុសសំឡេងមាន់រងាវនិងសំឡេងម៉ាស៊ីនរទេះភ្លើងកំពុងរោទ៍ ទើបភ្ញាក់រួចប្រញាប់ប្រញាល់រៀបចំចេញដំណើរ ។ ចឹក សេង បានបើកគ្របកាម៉ែលបាយមានដៃយួររបស់អាមេរិកាំង យកបាយមកហូបជាមួយអំបិលដែលដាក់នៅក្នុងថ្នក់ចង្កេះខោដោយមិនខ្វាយខ្វល់អ្វីទាំងអស់ ។

ម៉ោង១១ថ្ងៃត្រង់យើងដើរបានប្រហែលមួយភាគបួននៃប្រវែងចម្ងាយផ្លូវមកភូមិប៉ុណ្ណោះ ហើយខ្ញុំក៏មិនបានចាំផ្លូវច្បាស់លាស់ដែរ ។ នៅលើផ្លូវរទេះភ្លើងខ្ញុំឃើញមនុស្សជាច្រើន ដែលនៅលើស្មាមានលីបាវអង្ករយ៉ាងធ្ងន់ម្នាក់មួយបាវៗដើរសំដៅទៅភូមិរបស់គេរៀងៗខ្លួន ចំណែកអ្នកភូមិខ្លះបានឈប់សម្រាកដើម្បីយកសម្លៀកបំពាក់ដែលទទឹកពីយប់ទៅហាលនិង ខ្លះទៀតបានឈប់ដាំបាយហូប ។ ដើរដល់វាលស្រឡះមួយ ចឹង សេង ក៏បានស្រែកហៅខ្ញុំឲ្យឈប់សិនព្រោះជើងរបស់គាត់ហើមធំ ។ ប៉ុន្តែដោយគ្មានដើមឈើនិងម្លប់ឈើសម្រាប់ឈប់ជ្រកខ្ញុំក៏ប្រាប់គាត់ឲ្យខំប្រឹងដើរទៅមុខទៀត ប៉ុន្តែដើរដល់ទីទួលមួយកន្លែងគាត់ក៏ដួលព្រួសទៅលើបាវអង្ករទាំងហេវហត់អស់កម្លាំង ។ សម្រាកបន្តិចគាត់ក៏យកកាម៉ែលបាយចេញដើម្បីយកបាយហូបស្រាប់តែព្រួសចេញមកវិញភ្លាមដោយសារតែបាយជូម ។ ឃើញដូច្នេះ ខ្ញុំក៏ប្រាប់ ចឹក សេង ថាពេលយើងទៅដល់ភូមិជំរំថ្កូវវិញ ចាំដាំបាយឲ្យពេញឆ្នាំងហូបតែម្តង ប៉ុន្តែដោយ ចឹក សេង ឈឺជើងខ្លាំងមិនអាចបន្តដំណើរទៅមុខទៀតបាន ទើបប្រញាប់ប្រញាល់ដើររកអុស ។ នៅពេលនោះខ្ញុំស្រាប់តែឮដូចជាសំឡេងរថភ្លើងបន្លឺឡើងទើបរត់ទៅទាញបាវអង្ករចេញឲ្យផុតពីផ្លូវដែក ប៉ុន្តែមកដល់ឃើញតែរថភ្លើងក្បាលខ្លី(ឡូរី) ដែលដឹកពួកកម្មករចិនប្រាំនាក់ក្នុងសម្លៀកបំពាក់អាវអៀមពណ៌ខៀវដើម្បីជួសជុលផ្លូវដែលខូចខាត ។ កម្មករ

ចិនទាំងនេះបានជិះឡូរីជាច្រើនត្រឡប់ដើម្បីត្រួតពិនិត្យមើលផ្លូវរថភ្លើងក្នុងទឹកមុខញញឹមរីករាយហាក់ដូចជាអ្នកទេសចរណ៍មកដើរកម្សាន្តលេងសប្បាយដោយពុំរវល់មើលទៅអ្នកជំងឺនិងអ្នកអត់អាហារឡើយ ។ ពេលនោះស្រាប់តែ ចឹក សេង ដើរអួសជើងយ៉ាងលឿនសំដៅទៅជួបកម្មករចិននោះ ឃើញដូច្នេះយោធាម្នាក់ដែលឈរយាមក្បែរចិននោះបានស្ទុះមកបម្រុងចាប់គាត់ ប៉ុន្តែបានឈប់នៅទ្រឹងមួយកន្លែងដោយឃើញ ចឹក សេង អាចនិយាយភាសាចិនបាន ។ ចឹក សេង បានរៀបរាប់ពីទុក្ខលំបាកនិងការខ្វះខាតអាហារប្រាប់ទៅចិនទាំងនោះបន្ទាប់មកចិនម្នាក់ដែលមានរាងធាត់កន្ទុល(ប្រហែលជាមេគេ) ភ្នែកធំៗបញ្ចេញទឹកមុខកាចសាហាវរបស់គេជាមួយនឹងសំឡេងស្រែកគំហកខ្លាំងដាក់ ចឹក សេង រួចគ្រវែងមួបនំប៉័ងនិងផ្លែក្រូចដែលនៅសេសសល់លើឡូរីទាំងអស់ចូលទៅក្នុងទឹកស្រែក្បែរនេះអស់ហើយបញ្ជារឲ្យអ្នកបើកបរបន្តដំណើរទៅមុខទៀត ។ ចឹក សេង បានត្រឹមអង្គុយយំស្រក់ទឹកភ្នែកហើយរៀបរាប់ថាគាត់ឃ្លានបាយខ្លាំងពេកហើយដោយសារ ឃើញកម្មករទាំងនោះមានដើមកំណើតជាជនជាតិចិនដូចគាត់ដែរទើបគាត់ស្ទុះទៅនិយាយជាមួយ ។ គាត់ក៏បានសុំនំប៉័ងដែលនៅសល់ប៉ុន្តែមេរបស់វាមិនឲ្យព្រមទាំងជៀលថាចិនដែលមករស់នៅក្នុងស្រុកខ្មែរនេះសុទ្ធតែជាចិនក្បត់ជាតិ ក្បត់បដិវត្តន៍ គួរតែសមមុខដូច្នេះហើយ ។

រហូតដល់ពេលថ្ងៃត្រង់ទើបខ្ញុំអាចដើររកអុសមកដាំបាយហូបដើម្បីឆាប់បន្តដំណើរទៅទៀតបានព្រោះនៅតាមផ្លូវអូរចូលភូមិនៅមានទឹកជំជន់នៅឡើយ ។ ម្យ៉ាងទៀតនៅពេលមេឃងងឹតមើលមិនឃើញផ្លូវទេ ។ មិនយូរប៉ុន្មាន ខ្ញុំបានមកដល់ផ្លូវចូលភូមិហើយត្រូវដើរឆ្លងកាត់ទឹកអូរកំពុងហូរជម្រៅត្រឹមចង្កេះ ។ នៅពេលនោះខ្ញុំអស់បារម្ភដោយឃើញ បង ផុន និងនាយ ស្លឹក បានឈរចាំយើងនៅឯច្រាំងអូរម្ខាងទៀតជាស្រេច ។ ដោយអស់កម្លាំងខ្លាំងពេកពេលមកដល់មាត់ច្រាំងខ្ញុំក៏ដួលព្រូសទៅលើដី ឃើញដូច្នេះ បង ផុន ក៏ជួយរំលែកយកអង្ករពី ចឹក សេង ចំណែក នាយ ស្លឹកក៏ជួយរំលែកយកអង្ករពីខ្ញុំពាក់កណ្ដាលដែរ ។ ខ្ញុំត្រូវដើរប្រមាណមួយគីឡូម៉ែត្រទៀត ទើបទៅដល់កន្លែងសេដ្ឋកិច្ចភូមិ ។ នៅតាមផ្លូវធ្វើដំណើរខ្ញុំឃើញ នាយស្លឹក លួចលូកកាយយកអង្ករដាក់ពេញហោប៉ៅអាវ-ខោដោយគ្មានខ្លាចក្រែងឡើយ រួចដើរយ៉ាងលឿនឲ្យទាន់ បង ផុន ។ ពេលនោះ ចឹក សេង ក៏បានខ្សឹបប្រាប់ខ្ញុំឲ្យយកក្រូច៣ផ្លែនិងអង្ករមួយកូនថង់តូចដែលមានលាយធូលីដីផងនោះទៅលាក់នៅក្នុងគុម្ពស្បូវសិន ។ ថ្ងៃរសៀលបន្តិច ខ្ញុំ និង ចឹក សេង បានដើរមកដល់រោងសេដ្ឋកិច្ចភូមិ ស្រាប់តែឃើញបងប្អូនអ្នកជម្លៀសមកជុំគ្នាសម្លឹងមកខ្ញុំនិង ចឹក សេង គ្រប់ៗគ្នាដើម្បីរង់ចាំបើកអង្ករជាស្រេច ។ ស្រាប់តែពេលនោះខ្ញុំក្រឡេកទៅម្ខាងក៏ឃើញមនុស្សម្នាក់កំពុងដេកស្តូកស្តឹងក្នុងថ្កុកឈាមក្បែររោង ។ ខណៈនោះសំឡេងមេកង កេត បានស្រែកខ្លាំងហៅខ្ញុំទាំងពីរនាក់ឲ្យយកអង្ករទៅចាក់ក្នុងបាវថ្មីមួយទៀត រួចបញ្ជាឲ្យមេក្រុមរួមនឹងបងថ្លៃខ្ញុំដែលឈរនៅក្បែរនោះមកឆែកយើងទាំងពីរនាក់ ។ ខ្ញុំភ័យយ៉ាងខ្លាំងហើយបងថ្លៃបានខ្សឹបសួរខ្ញុំថា ប្អូនមានលួចលាក់អង្ករទេ? ព្រោះមុននេះបន្តិចមេកង កេត បានវាយ នាយ ស្លឹក នឹងត្បូងចបស្លាប់បាត់ទៅហើយ ដោយចោទថាលួចអង្ករ ។ ខ្ញុំភិតភ័យយ៉ាងខ្លាំងរួចគ្រវីក្បាលដោយនិយាយមិនចេញ ។ ក្រោយមកដោយឆែកពុំឃើញអង្ករមេកង កេត នោះក៏អនុញ្ញាតឲ្យយើងទាំងពីរទៅសម្រាកនៅផ្ទះ ។ ដោយសារអង្ករមិនបានគ្រប់ចំនួនទើបធ្វើឲ្យមេកង កេត ខឹងយ៉ាងខ្លាំង រួចដើរប្រមូលអង្ករទាំងអស់មកដាក់រួមទោះបីអង្កររើសបានពីណាក៏ដោយ ។

ចឹក សេង បានលាខ្ញុំទៅផ្ទះ ចំណែកខ្ញុំក៏រត់ទៅយ៉ាងលឿនទៅយកអង្ករនិងក្រូចមកផ្ទះ ។ «ខ្ញុំបានស្រែកហៅម្ដាយខ្ញុំដែលមានសម្បុរខ្មៅស្រអែមនិងរាងកាយស្គមស្គាំងតិចៗ» ហើយគាត់ងើបមុខឡើងសម្លឹងមកខ្ញុំទាំងទឹកមុខស្លេកស្លាំងនិងទុក្ខព្រួយ ។ បន្ទាប់មកខ្ញុំក៏បានសួរគាត់ថាប្អូនប៉ុយនិងប្អូនស្រីទូចដូចម្ដេចហើយម៉ែ? គាត់បានឆ្លើយប្រាប់ខ្ញុំថាប្អូនទាំងពីរនាក់ស្លាប់បាត់ហើយ ។ ខ្ញុំសួរបញ្ជាក់គាត់ម្ដងទៀតដោយបើកភ្នែកធំៗដោយដៃកាន់ថ្នក់ក្រមាស្ទុះទៅក្នុងខ្ទមស្រាប់តែឃើញនៅលើសាកសពរបស់ប្អូនមានស្រមោចខ្មៅរោមដុំដិតនៅលើមាត់ភ្នែកនិងច្រមុះ ។ ម្ដាយរបស់ខ្ញុំបានរៀបរាប់ថាមុនពួកវាស្លាប់វាស្រែករកឈ្មោះខ្ញុំដើម្បីយកអង្ករដាំបាយឲ្យវាហូប ។ ខ្ញុំមិនបានយកអាហារឲ្យប្អូនទាំងពីរហូបទេ គឺបានត្រឹមតែមកសែងសាកសពប្អូនទាំងពីរនាក់យកទៅកប់នៅលើដីបូកមួយក្បែរផ្ទះប៉ុណ្ណោះ ។

**ហេង ថាល់សាវុធ**

# លិខិតថ្លែងអំណរគុណ

*លោកនាយកជាទីគោរព!*

*ខ្ញុំបាទឈ្មោះ ចាន់ ម៉ាឌី ។ ខ្ញុំមានកិត្តិយសនិងសូមថ្លែងអំណរគុណយ៉ាងក្រៃលែង ដែលខ្ញុំបានសរសេរសំបុត្រមកលោកនៅពេលនេះ ។ ខ្ញុំបានមកមជ្ឈមណ្ឌលឯកសារកម្ពុជាដ៏ល្បីល្បាញនិងមានប្រយោជន៍របស់លោកនៅឆ្នាំមុននៅថ្ងៃទី៣១ ខែកក្កដា មុនពេលដែលខ្ញុំធ្វើមាតុភូមិនិវត្តន៍ ។ ខ្ញុំជាជនជាតិខ្មែរ មានសញ្ជាតិបារាំង សព្វថ្ងៃរស់នៅជាយក្រុងទីក្រុងប៉ារីស ។*

*គោលបំណងដែលខ្ញុំបានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺដើម្បីសំណូមពរឲ្យលោក ឬមិត្តរួមការងារជួយចុះផ្សាយឯកសារមួយនៅលើគេហទំព័រទស្សនាវដ្ដី ពីព្រោះវាមានអត្ថន័យពិសេសសម្រាប់ជីវិតរបស់ខ្ញុំ «សំបុត្រនៃពាក្យបណ្ដាំចុងក្រោយរបស់ឪពុកខ្ញុំទៅកាន់ម្ដាយខ្ញុំ» មុនពេលគាត់ត្រូវទ័ពខ្មែរក្រហមចាប់យកទៅធ្វើទារុណកម្មនិងសម្លាប់ ។*

*សោកនាដកម្មនៃគ្រួសារខ្ញុំនេះកើតឡើងក្នុងយប់ថ្ងៃទី៧ ខែវិច្ឆិកា ឆ្នាំ១៩៧៧ ក្នុងសហករណ៍តាលាស់ ឃុំមោងឫស្សី ស្ថិតក្នុងខេត្តពោធិ៍សាត់ ។*

*ក្នុងឱកាសដែលខ្ញុំបានមកកាន់មជ្ឈមណ្ឌលឯកសារ លោកស្រី ស៊ីវ សាវីណា បានណែនាំខ្ញុំឲ្យជួបជាមួយក្រុមជំនួយការតុលាការខ្មែរក្រហមដែលអាចជួយបញ្ជូនឯកសាររបស់ខ្ញុំទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ពេលនេះ ខ្ញុំមានអារម្មណ៍សប្បាយរីករាយជាខ្លាំង ព្រោះនេះគឺជាបំណងធំមួយរបស់ខ្ញុំផងដែរ ។*

*ដូច្នេះ ខ្ញុំបានចំណាយពេលមួយព្រឹកដើម្បីរំឭកអំពីរឿងរបស់ខ្ញុំឡើងវិញឲ្យបានល្អិតល្អន់ ហើយប្រាប់ទៅដល់សមាជិកក្រុមគម្រោងនោះ ។ ខ្ញុំសូមយកឱកាសនេះដើម្បីថ្លែងអំណរគុណដល់គាត់យ៉ាងជ្រាលជ្រៅផងដែរ ចំពោះការជួយសម្រេចបំណងប្រាថ្នារបស់ខ្ញុំ ។ តាំងពីខ្ញុំធ្វើមាតុភូមិនិវត្តន៍មក ខ្ញុំមិនដែលភ្លេចពីរឿងរបស់ខ្ញុំនោះទេ ទោះបីជាពេលនេះខ្ញុំទើបតែមានទំនេរសរសេរសំបុត្រនេះមកកាន់លោកក៏ដោយ ។ ពេលខ្លះ ខ្ញុំក៏បានមើលនៅលើគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ប៉ុន្ដែ ខ្ញុំហាក់ដូចជាមិនទាន់បានឃើញរូបថតក្នុងឯកសារខ្ញុំនៅក្នុងកម្រងរូបថតតុលាការខ្មែរក្រហមនៅឡើយ ។ ហេតុដូចនេះ ហើយខ្ញុំសូមផ្ញើរូបថតទាំងនេះមកលោកម្ដងទៀតដោយភ្ជាប់ជាមួយនឹងសំបុត្រនេះ ។ ខ្ញុំរង់ចាំទទួលការឆ្លើយតបពីលោកដោយភាពរីករាយ ។ ខ្ញុំសូមថ្លែងអំណរគុណដល់លោករួមទាំងក្រុមការងាររបស់លោកយ៉ាងជ្រាលជ្រៅ និងសូមឲ្យមានសំណាងល្អ ។* **ចាន់ ម៉ាឌី**





## ប្លង់អគារនៃបូជនីយដ្ឋានជើងឯក
### ដោយ ដេវីដ សាឡាហ្សា នៃស្ទូឌីយ៉ូ *MDA*
### នៃទីក្រុងញូវយ៉ក








ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវេ ស៊ុយអែត និងសហរដ្ឋអាមេរិក

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**

ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 117, September 2009 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.